
ប៉ាកកាទេព
កែវចន្ទ័បូណ៌
សិល្ប៍វិធីនិពន្ធដោយ
ប្រើវិញ្ញាណ១០
CHANBOKEO.COM

# ប៉ាកកាទេព

# សិល្បវិធីនិពន្ធ

# ដោយប្រើវិញ្ញាណ១០

==============================

និពន្ធរៀបរៀង និង រចនាក្រប

អ្នកស្រី កែវ ចន្ទបូរណ៍

www.chanbokeo.com

chanbo@camboda.com

==============================

សហការីអក្សរសាស្ត្រ

សាស្ត្រាចារ្យ ម៉ៀច សុខារី

==============================

សហការីស្មារតីខ្មែរ

លោក នភ ហង្សផលា

www.smaradeykhmer.org

nphalla@hotmail.com

==============================

សូមទាក់ទងជាវ

016-318-023

012-774-751

==============================

=========================================

# សូមឧទ្ទិសស្នាដៃនេះប្រគេននិងជូនចំពោះ

=========================================

- លោក មេងស្ងួងសុវណ្ណធី ជាស្វាមី និង កុមារី សុវណ្ណធីធម្មិកាបារមីបុណ្យជាបុត្រី
- លោកឪពុក ប៊ុនថង អ្នកម្ដាយ កែវយឿង និងប្អូនៗព្រមទាំងក្រុមគ្រួសារ
- លោកឪពុកក្មេក មេងស្ងួង និងអ្នកម្ដាយក្មេក កូវសារ៉ាន់ ព្រមទាំងកូនចៅ
- ព្រះគ្រូ សេងប៊ុនសង ព្រះគ្រូចៅអធិការ ម៉ឹងសាង ព្រះគ្រូ គិមសុវត្ថិ
- សាស្ត្រាចារ្យនិងអ្នកនិពន្ធខ្មែរទាំងឡាយ



អ្នកស្រី កែវ ចន្ទ័បូរណ៌



សាស្ត្រាចារ្យ មៀច សុខារី



នភ ហង្ស ផលា

# ស្នាដៃទាំងឡាយរបស់អ្នកនិពន្ធកែវចន្ទ័បូរណ៍

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្មឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង បើសិននៅមានថ្ងៃស្អែក
១២- រឿង លំអងផ្កាស្នេហ៍
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង ស្អែកចាកផុតទៅ
១៦- រឿង តន្ត្រីបេះដូង
១៧- រឿង មួយខែក្បែរមច្ចុរាជ
១៨- រឿង ខ្ញើយវាសនា
១៩- រឿង ត្រៃមិត្ររតននារី
២០- រឿង សីវបុរេកាល
២១- រឿង បទុមបឹងបិសាច
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីសួនសុបិន
២៦- រឿង បេះដូងសុក្រិត
២៧- រឿង មេឃង៏សក្តិសិទ្ធិ
២៨- រឿង ផ្ការីកក្រៅសួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង រាត្រីសន្យា
៣៣- រឿង បើអាចបង្វិលផែនដី
៣៤- រឿង ផ្ការាជបឹងរាំង
៣៥- រឿង ថ្ងៃបើដើងមេឃនៅឆ្ងាយ
៣៦- រឿង មេឃរងា
៣៧- សិល្បវិធីនិពន្ធដោយប្រើវិញ្ញាណ១០
៣៨- រឿង ទិវាដួងចិត្ត
៣៩- ឧទ្យានកំណាព្យភាគ១
៤០- ឧទ្យានកំណាព្យភាគ២
៤១- ឧទ្យានកំណាព្យភាគ៣
៤២- ឧទ្យានកំណាព្យភាគ៤
៤៣- ឧទ្យានកំណាព្យភាគ៥
៤៦- ឧទ្យានកំណាព្យភាគ៦

=========================================

# វាចាអ្នកនិពន្ធ

=========================================

សៀវភៅប៉ាកកាទេព បាននាំមកនូវការសិក្សាយ៉ាងថ្មីស្រឡាងមួយជាលើកដំបូងបង្អស់នៅប្រទេសកម្ពុជា ជូនប្រិយមិត្តអ្នកនិពន្ធទាំងឡាយដែលចង់បណ្តុះជំនាញខាងការនិពន្ធអត្ថបទអក្សរសិល្ប៍ខ្មែរ អោយបានភ្លឺពណ្ណរាយ ។ នោះគឺការសិក្សាអំពីវិញ្ញាណ១០ និងអំពីប្រសិទ្ធិភាពនៃការប្រើវិញ្ញាណទាំង១០ ក្នុងការនិពន្ធសំណេរអក្សរសិល្ប៍ អោយមានតម្លៃថ្កុំថ្កើងវិសេសវិសាល ។

គោលបំណងពិតរបស់អ្នកនិពន្ធ ក្នុងការសរសេរក្បួនប៉ាកកាទេព ជូនមិត្តអ្នកអានសិក្សារៀនសូត្រនេះ មិនមែនស្ថិតនៅត្រឹមគោលការណ៍លើកតម្កើង និងថែរក្សាភាសាអក្សរសាស្ត្រខ្មែរដើមកំណើត អោយគង់វង្សឋិតថេរតែម្យ៉ាងប៉ុណ្ណោះទេ ។ ដើម្បីឲ្យងាយស្រួលយល់ យើងសូមប្រៀបធៀបអក្សរសាស្ត្រខ្មែរទៅនឹងឫស្សីមួយគុម្ព ។ ការដែលយើងបង្រៀនសិស្សឲ្យស្គាល់ដើមឫស្សី គល់ឫស្សី ទំពាំង មែក ស្លឹក និងរបៀបដាំដុះថែទាំដើមឫស្សីអោយបែកសាយគុម្ពល្អ នោះក៏មិនខុសអ្វីអំពីការបង្រៀនសិស្ស អោយស្គាល់តួអក្សរ ឫសគល់ មែកធាង និង ការរៀនតាក់តែងនិពន្ធឃ្លាប្រយោគ តាមក្បួនខ្នាតអក្សរសាស្ត្រខ្មែរ យ៉ាងត្រឹមត្រូវ ទាំងនោះឡើយ ។

ប៉ុន្តែ គោលបំណងខ្ពង់ខ្ពស់វិសេសបំផុតនៃសៀវភៅប៉ាកកាទេពនេះ គឺជាការបណ្តុះទេពកោសល្យរបស់មនុស្ស អោយមានគំហើញវែងឆ្ងាយលើសពីការរៀនដាំដុះ និងថែរក្សាគុម្ពឫស្សីនោះទៅទៀត រាប់រយដង ។ មានន័យថា សៀវភៅប៉ាកកាទេពគឺជាមូលដ្ឋានណែនាំនូវសិល្បវិធីប្រសិទ្ធពិសេសៗ សំរាប់អ្នកនិពន្ធទាំងឡាយរៀនបណ្តុះគំនិត សតិប្រាជ្ញា និងទេព្យកោសល្យរបស់ខ្លួនអោយបានភ្លឺថ្លាពណ្ណរាយ ក្នុងការរចនាច្រៀកខាត់អក្សរសាស្ត្រខ្មែរ អោយក្លាយទៅជាអត្ថបទអក្សរសិល្បិ៍ប្លែកៗ ហើយមាន

ប្រយោជន៍យ៉ាងវិសេសវិសាល ចំពោះសង្គមជាតិ ទាំងនៅបច្ចុប្បន្ន និង នៅអនាគត មិនខុសអំពីការសិក្សានូវរបៀបរចនាកែច្នៃច្រៀកកាត់ខាត់ ពត់ដើម មែក និង ស្លឹកឫស្សី អោយក្លាយជាវត្ថុដែលមានប្រយោជន៍ សំរាប់សង្គម ដូចជាការយកស្លឹកឫស្សីទៅខ្ទប់នំចាំង យកមែកស្រាស់របង យកបំពង់ដុតក្រឡាន យកទំពាំងទៅធ្វើអាហារ យកដើម ទៅសង់ផ្ទះ ធ្វើរបស់របរប្រើប្រាស់ដូចជា កន្ទេល ក្រែ តុទូ ទ្រូ លប ឈ្នាង កញ្ជើ ចង្អេរ អង្រុត អង្រឹង វែក សម្ល ចង្កើសចាប់ អាហារ តម្បុតត្បុតត្រី ដងសន្ទូច ដងដោយ ដងទង់ បំពង់ទឹកត្នោត និង របស់របរអ្វីៗ ទៀតជាច្រើន ។ល ។

សរុបមក ការដែលយើងស្គាល់របៀបដាំដុះថែទាំឫស្សីតែម្យ៉ាង ពិត ជាមិនគ្រប់គ្រាន់ទេ កាលបើយើងគ្មានគំនិត គ្មានមធ្យោបាយ គ្មានសិល្ប៍ វិធីរចនាឫស្សី អោយក្លាយទៅជាវត្ថុដែលមានសារប្រយោជន៍យ៉ាងច្រើន រាប់មិនអស់ចំពោះសង្គមមនុស្ស ។ ដូច្នេះហើយទើបសៀវភៅប៉ាកកាទេព ចូលខ្លួនមកលាតត្រដាងនូវសិល្បវិធីប្រសិទ្ធិ ដើម្បីណែនាំមនុស្សទូទៅ អោយមានគំនិតរចនាបថ មានគំហើញភ្លឺស្វាង ចេះសង្កេត ចេះពិចារណា ចេះបង្កើតមធ្យោបាយផលិតអក្សរសាស្ត្រខ្មែរ ឲ្យក្លាយទៅជាអក្សរសិល្ប៍ ដ៏មានប្រយោជន៍មហិមា ចំពោះសង្គមជាតិ វាស់មិនបានឡើយ ។

សូមជូនពរដល់ប្រិយមិត្តអ្នកនិពន្ធទាំងឡាយ អោយបានប្រកបតែសតិ ប្រាជ្ញឧត្តុងឧត្តម និងភ្លឺស្វាង ក្នុងការនិពន្ធសំណេរបំរើជាតិយើង យ៉ាង ប្រពៃថ្កុំថ្កើង មិនអោយចាញ់សមត្ថភាពរបស់អ្នកប្រាជ្ញខ្មែរទាំងឡាយ នានា កាលពីជំនាន់បុរាណឡើយ ! ! !

=======================================

អ្នកស្រី កែវ ចន្ទ័បូរណ៍

ខែកក្កដា ២០០៧

=======================================

========================================

# ថ្ងៃណាទើបភ្លឺ ?

========================================

ភ្លេងខ្មែរវង់ធំបែរហៅភ្លេងសៀម
សម្លខ្មែរត្រៀមបែរហៅម្ហូរយួន
រាំវង់ខ្មែរល្បីបែរហៅឡាំថូន
រាំវង់ញាក់ខ្លួនបែរហៅឡាំលាវ ។
ខោជេរសង្ហាហៅខោបារាំង
ចូលវត្តយើងគាំងបាលីជាផ្លូវ
ភាសាបរទេសស្តាប់យល់អីទៅ
អាវច្រើនហោប៉ៅបែរហៅអាវចិន ។
ផ្លាកនៅមុខហាងខ្មែរអានមិនដាច់
អង់គ្លេសវាតខ្មៅចគ្មានអ្នកធុញទ្រាន់
ឈុតអាវតាមផ្សារអ្នកលក់អួតលាន់
ឈុតសឿងសោភ័ណម៉ូដស្រុកកូរេ ។
ខ្មែរណាស្បែកសហៅកូនជប៉ុន
ខ្មែរណាខ្មៅក្រិនហៅកូនសំរែ
ផ្លែឈើណាល្អផ្លែស្រុកផង់គេ
ខ្មែរឯងនៅស្រែល្វិតល្វង់លង់ជ្រាំ ។
ទម្លាប់ខ្មែរខុសប្រមាថតែខ្លួន
ពូជពង្សតាដូនភ្លេចស្ងួនថែទាំ
លើកយសបរទេសជាន់ខ្លួនលិចកម្ម
ឱខ្មែរស្រងាំ...ថ្ងៃណាទើបភ្លឺ ?

=========================================

# បាលីនិងខ្មែរ

=========================================

ស្មេរខ្លះនិពន្ធស្នេហ៍បាលី
គិតថាប្រពៃល្អខ្ពង់ខ្ពស់
ប្រើពាក្យខ្មែរងាយលាយចម្រុះ
គិតថាស្រកយសអស់តម្លៃ ។
ភ្លេចគិតហើយឬថាភាសា
បាលីសាស្ត្រាខ្មែរបានខ្ចី
ពីស្រុកគេផ្សេងយូរមកអី
បើប្រើបាលីយើងត្រូវប្រែ ។
ហេតុម្តេចទម្លាប់ដំទើតជើង
បរទេសលើកឡើងខ្ពស់ម្ល៉េះទេ
រួចជាន់បង្អាប់ភាពជាខ្មែរ
ភាសាស្រុកស្រែពុកម៉ែប្រៀន ?
ភាសាខ្មែររាយងាយស្រួលស្តាប់
អ្នកស្រុកអានគាប់មិនយ៉ាករៀន
មិនបាច់រត់ស្វែងបណ្ឌិតស្មៀន
ជួយបកស្រាយប្រៀនពន្យល់ន័យ ។
ភាសាតាដូនផ្ញើកូនចៅ
ម្តេចជាន់លិចទៅទាបស្មើដី
ពាក្យខ្មែររាយតួសមប្រពៃ
ស្តាប់យល់អស់ន័យម្តេចថាអន់ ?

=======================================

# ត្រីស្អិតត្រីស្អុយ

=======================================

ឃើញត្រីស្អិតៗចង្វារៀល
កុំអាលតិះដៀលថាខ្ពើមអី
បុកចៀនប្រហិតផ្អាប់ទឹកត្រី
ឆ្ងាញ់លើសចំណីពាសពេញផ្សារ ។
ឃើញត្រីស្អិតៗស្អុយពេញត្រក
កុំអាលគិតខកស្រកចិន្តា
ស្អុយធ្វើប្រហុកដាំអាហារ
រសឆ្ងាញ់ពិសាមានតម្លៃ ។
ឃើញមនុស្សរយរាយកុំអាលថា
គួរគន់កិច្ចការសព្វវិស័យ
ក្រែងមានកោសល្យផលិតថ្លៃ
មិនខុសតម្លៃត្រីស្អុយអន់ ។
ឃើញក្មេងក្រីក្រកុំប្រមាថ
សង្វាតវិភាគគិតស្អិតល្អន់
ក្រែងមានប្រាជ្ញាឆ្លាតគួរគន់
ឆ្លុះមន្តអច្ឆរិយៈវិទ្យាសាស្ត្រ ។
ច្នេះឃើញអ្វីអន់កុំអាលសើច
ក្រែងពេលក្រោយខើចដួលជើងបះ
ជួនកាលខ្ទឹមក្លែបប្រយោជន៍ល្អះ
លាក់ឱជារសក្នុងសំបកអន់ ។

=====================================

# មុនប្រៀនគេ...

=====================================

បើសិនស្គាល់ក្បួនច្បាប់តម្រា
គប្បីសិក្សាអោយយល់ន័យ
ហើយប្រតិបត្តិដោយប្រពៃ
កុំសូត្រទទឹស្តីត្រឹមតែមាត់ ។
បើសិនបានចូលពោលសន្ទនា
ស្វែងពាក្យរមនាកុំអោយភ្លាត់
ខេមរភាសាល្អមរកត
ជ្រើសស្តីអោយស្ទាត់ពាក្យមង្គល ។
បើគិតថាខ្លួនជាអ្នកប្រាជ្ញ
កុំខ្លាចបង្ហាញភាពនិមល
ថ្លៃថ្នូរគំនិតទាំងកាយកល
ពុំនាំល្អក់ខ្វល់ដល់ញាតិណា ។
បើបានតាំងខ្លួនជាគម្រូ
គប្បីផ្តាច់ប្តូរកាន់កិរិយា
អោយសិស្សតម្រាប់តាមអាត្មា
ដោយសីលតម្រាមិនរំលង ។
ចាស់ៗចំណាំផ្តែផ្តាំប្រាប់
ពុតគ្រូខូចច្បាប់នាំសៅហ្មង
សិស្សមើលគម្រូមុនដើរឆ្លង
ច្នេះប្រៀនខ្លួនផងមុនប្រៀនគេ ។

======================================

# ឆ្លាក់

======================================

នាមល្បីជាខ្មែរពូកែឆ្លាក់
រូបក្បាច់ចម្លាក់ឆ្លាក់ប្រាសាទ
ឆ្លាក់ថ្មឆ្លាក់ឈើធ្វើសង្ហាត
ក្លាយក្បាច់ស្រស់ស្អាតល្អគ្មានពីរ ។
ជាតិផ្សេងរែងស្ញើចស្នាដៃខ្មែរ
ឆ្លងយុគហូរហែយ៉ាងរមណីយ៍
ថ្វីដៃល្បីល្បាញគ្រប់ទិសទី
គេឯងសំភីប្រាថ្នាយល់ ។
ថៃដន្យយើងប៉ិនឆ្លាក់របស់
ព្រងើយឆ្លាក់មនុស្សអោយនិមល
ពិភពលោកចរខ្ពស់មង្គល
ជាតិយើងបែរវិលថយសីលធម៌ ។
ឆ្លាក់ថ្មវិចិត្រពិតមិនស្មើ
ឆ្លាក់មនុស្សប្រសើរដើរផ្លូវល្អ
ឆ្លាក់ថ្មនៅស្ងៀមមិនអាចចរ
សាងអំពើល្អជូនដល់ជាតិ ។
បើសិនឆ្លាក់មនុស្សបានប្រពៃ
នោះទើបស្នាដៃពិតវរនាថ
មនុស្សឆ្លាក់មនុស្សល្អថែមព្រោងព្រាត
ចរនាំស្រុកជាតិរីកចំរើន ។

==========================================

# ដើមអំពិល

==========================================

ដឹងថាគេបោចពេលខ្លួនលាស់ត្រួយ
ចេញក្តិបមួយរយផ្លែទំមួយពាន់
អ្នកភូមិឡើងបេះធ្វើអាហារលាន់
អំពិលមិនទាន់លាស់ត្រួយថែមទៀត ។
ជាដើមអំពិលមិនខ្ជិលផ្លែផ្កា
ទាំងប្រាំងវស្សាបំរើផៅញាតិ
ស្លឹកខ្ចីបួតស្ល ស្លឹកចាស់បុកទៀត
ធ្វើថ្នាំអស់ស្មៀតថ្នមអ្នកកូនខ្ចី ។
បោចណាស់លាស់ណាស់អំពិលដីស្រែ
បំរើហូរហែជាតិខ្មែរប្រុសស្រី
មិនខុសអ្នកប្រាជ្ញបំរើតិចអី
លាស់ចំណេះថ្មីចែកចាយមិនភ្លាត់ ។
បេះណាស់លាស់ណាស់អ្នកប្រាជ្ញបញ្ចេញ
គ្មានថ្ងៃទោម្ទេញទ្រោមដើមប្រាកដ
សិស្សតាមបេះបោចគំនិតមរកត
ចែកមួយមិនភ្លាត់លាស់ទៀតរយពាន់ ។
គំនិតអ្នកប្រាជ្ញមិនខុសអំពិល
រាល់ថ្ងៃមិនខ្ជិលបញ្ចេញសម្ពន្ធ័
លាស់គំនិតថ្មីចែកចាយរួសរាន់
ជាតិខ្មែរលែងភន្ត័ត្បិតពលរដ្ឋប្រាជ្ញ ។

=====================================៦

# បើព្រះមានតែមួយអង្គ

=====================================

ពេលជួបអាសន្នមានទុក្ខព្រួយ
គ្រប់គ្នាបោះពួយថ្វាយចេកដូង
អុជធូបបន់ស្រន់បួងសង្រួង
ឲ្យញហៅព្រះអង្គយាងមកប្រោស ។
បើព្រះមានតែមួយព្រះអង្គ
តើលោកត្រូវផ្ទង់យាងសណ្ដោស
មួយណាមុនទៅអោយរួចទោស
ផុតអាសន្នគ្រោះរស់សុខសាន្ត ?
មនុស្សមានទុក្ខគ្រប់នគរ
លង់សោកលង់មោហ៍ច្រើនបរិមាណ
ពឹងតែព្រះម្យ៉ាងច្បាស់ខកខាន
ព្រះតែមួយប្រាណប្រោសម្ដេចទាន់ ។
ច្នេះទើបព្រះអង្គមានដីកា
ជនគ្រប់អាត្មារៀនរួសរាន់
ខ្លួនទីពឹងខ្លួនកុំអោយភន្ត័
ព្រះយាងមិនទាន់ក៏មិនស្លុត ។
តម្រាអាត្មាយោងខ្លួនឯង
ជាក់ស្ដែងប្រយោជន៍ល្អមរកង
មានទុក្ខដោះស្រាយដោយម៉ឺងចត់
ជួបសុខប្រាកដមិនចាំព្រះជួយ ។

=======================================

# ឥទ្ធិពលទឹកខ្មៅ

=======================================

ទឹកខ្មៅដៅដាំផ្សាំតម្រា
ស្រក់លើសត្រាចារចំណោះ
អ្នកអានក្រេបច្រើនកើនតម្រិះ
ប្រាជ្ញាវិសេសយ៉ាងថ្លាថ្លៃ ។
ទឹកខ្មៅដែលល្អចរនាំមនុស្ស
ដើរចៀសផ្លូវខុសផុតចង្រៃ
ទឹកខ្មៅឧបទ្រមពនាំអប្រិយ
ដល់ជនប្រុសស្រីក្នុងសង្គម ។
ទឹកខ្មៅមានសីលអាចប្ដូរផ្លាស់
មនុស្សពីល្ងិតផ្ដាសមកសមរម្យ
ចាកភាពអន្ធពាលយល់សុខុម
ជីវិតឧត្តមត្បិតទឹកខ្មៅ ។
បំណាច់នឹងចាយពេលសរសេរ
គួរណាស់អស់ស្នេរចារតម្រូវ
នាំមិត្តអ្នកអានត្រិះយកផ្លូវ
ដែលនាំមកនូវសុខមង្គល ។

========================================

# ប៉ាកកាទេព

## សិល្បវិធីនិពន្ធដោយប្រើវិញ្ញាណ១០

========================================

## មាតិការឿង


| | |
|---|---|
| អារម្ភកថា | ទំព័រ ១៥ |
| អំពីវិធីសាស្ត្រនិពន្ធ | ទំព័រ ១៦ |
| ជំពូកទី១ អក្ខរាវិរុទ្ធ | ទំព័រ ១៧ |
| ជំពូកទី២ វេយ្យាករណ៍ | ទំព័រ ៣៧ |
| ជំពូកទី៣ ទំរង់និងបែបបទនិពន្ធ | ទំព័រ ៤៨ |
| ជំពូកទី៤ អត្ថសញ្ញាណសៀវភៅ | ទំព័រ ៧១ |
| ជំពូកទី៥ សច្ចភាពនិងអត្ថរស | ទំព័រ ៨១ |
| ជំពូកទី៦ ការជ្រើសរើសប្រធានបទ | ទំព័រ ៩០ |
| ជំពូកទី៧ រូបវិញ្ញាណទាំង៥ | ទំព័រ ១០៩ |
| ជំពូកទី៨ អរូបវិញ្ញាណទាំង៥ | ទំព័រ ១១៧ |
| ជំពូកទី៩ ប្រភេទអ្នកនិពន្ធ | ទំព័រ១៣៦ |
| ជំពូកទី១០ ការប្រើវិញ្ញាណ១០ | ទំព័រ១៤៧ |
| ជំពូកទី១១ មោទនភាពរបស់អ្នកនិពន្ធ | ទំព័រ១៦០ |
| ជំពូកទី១២ កម្លាំងចិត្តនិងជំនួយផ្សេងៗ | ទំព័រ១៦៦ |


========================================

==========================================

# អារម្ភកថា

==========================================

អ្នកនិពន្ធពិតប្រាកដ គឺជាសិក្ខាជន ដែលស្វះស្វែងរៀនសូត្រនូវគំនិតនិងវិជ្ជាផ្សេងៗ សំរាប់បណ្តុះសំណេរល្អៗជាសិល្បៈកំសាន្តផង ជាការណែនាំផ្លូវដល់អ្នកអាន អោយបានស្គាល់អ្វីទៀត ទាំងឡាយដែលអ្នកនិពន្ធបំភ្លឺពន្យល់ប្រាប់ផង ។ បើសិនអ្នកនិពន្ធមានសតិប្រាជ្ញាភ្លឺស្វាង សំណេររបស់គេក៏ក្លាយជាមាគ៌ាភ្លឺស្វាង សម្រាប់អ្នកអានធ្វើដំណើរ ដោយសុវត្ថិភាព និងជោគជ័យគាប់ប្រសើរ ។ បើអ្នកនិពន្ធជាបុគ្គលដែលមានប្រាជ្ញាស្មារតីនិងគំនិតអាប់អួរ នោះសំណេររបស់គេក៏ប្រែក្លាយទៅជាមាគ៌ាដ៏សែនងងឹត ដែលអាចនាំអ្នកអាន អោយធ្លាក់ចេញពីផ្លូវ ដែលប្រពៃហើយមានសុវត្ថិភាព ។

ដូច្នេះ តើអ្នកនិពន្ធគួរធ្វើយ៉ាងណា ដើម្បីរក្សាមាគ៌ាដែលយើងត្រួសត្រាយតាមរយៈសំណេរនិពន្ធ អោយស្ថិតនៅក្នុងបន្ទាត់ដ៏ប្រពៃសម្រាប់អ្នកអានធ្វើដំណើរ ? សៀវភៅប៉ាកកាទេព ក្បាលទី១ នេះបានត្រូវនិពន្ធឡើង ជាទៀនបំភ្លឺសតិប្រាជ្ញាដល់អ្នកនិពន្ធជំនាន់ថ្មីក្នុងការកសាងស្នាដៃនិពន្ធរបស់គេ អោយមានប្រសិទ្ធិភាពនិងមានការកោតគោរពពីប្រជាពលរដ្ឋទូទៅ យូរអង្វែង នៅក្នុងសង្គមជាតិដែលកំពុងអភិវឌ្ឍន៍ឆ្ពោះទៅរកសន្តិភាព និងអធិបតេយ្យភាពយ៉ាងរុងរឿងត្រចះត្រចង់ ។

សូមមិត្តអ្នកនិពន្ធទាំងអស់ បានជួបនូវជោគជ័យគ្រប់ប្រការក្នុងការបម្រើជាតិខ្មែរ តាមរយៈសំណេរនិពន្ធដ៏ពណ្ណរាយភ្លឺស្វាង ។

==========================================

=======================================

# អំពីវិធីសាស្ត្រនិពន្ធ

=======================================

វិធីនិពន្ធដែលមានប្រសិទ្ធភាពទាំងឡាយ តែងតែពឹងផ្អែកទៅលើកត្តាដែលជាឫសគល់សំខាន់ៗជាច្រើនយ៉ាង ដូចជា :

១. អក្ខរាវិរុទ្ធ
២. វេយ្យាករណ៍
៣. ទំរង់និពន្ធ
៤. អត្តសញ្ញាណរបស់សៀវភៅ
៥. អត្ថរស និង សច្ចភាពរបស់សំណេរ
៦. ការជ្រើសរើសប្រធានបទ
៧. សិល្បវិធីនិពន្ធ ដោយប្រើវិញ្ញាណទាំង១០
   (រូបវិញ្ញាណ និង អរូបវិញ្ញាណ)
៨. មោទនភាពរបស់អ្នកនិពន្ធ
៩. សម្រង់មតិ
១០. កម្លាំងចិត្ត
១១. គណកម្មការពិនិត្យ
១២. ការផ្សព្វផ្សាយស្នាដៃ
១៣. ថវិកាសំរាប់ឧបត្ថម្ភការបោះពុម្ពផ្សាយ

=======================================

========================================

# ជំពូកទី១

# អក្ខរាវិរុទ្ធ

========================================

<u>ក. អំពីការវិវត្តន៍ផ្លាស់ប្តូររបស់អក្ខរាវិរុទ្ធខ្មែរ</u> ៖

នៅរវាង៥០ឆ្នាំកន្លងមកនេះប្រទេសខ្មែរបានឆ្លងកាត់យុគសម័យវឹកវរដោយសង្គ្រាមនិងការប្រែប្រួលផ្នែកនយោបាយក្រឡាប់ផ្កាប់ផ្ងារបណ្តាលអោយការវិវត្តន៏ផ្នែកអក្សរសាស្ត្រដើរទៅមុខផងបែរទៅក្រោយផងរហូតដល់ស្មេរជាច្រើនវិលវល់វង្វេងមិនដឹងថា តើគួរគេយកលំនាំអក្ខរាវិរុទ្ធតាមក្បួនបែបណាមួយជាគ្រិះជាក់លាក់ពិតប្រាកដ ។ កាលពីសម័យសង្គមរាស្ត្រនិយម ក្រោមការដឹកនាំរបស់សម្តេចប្រមុខរដ្ឋនរោត្តមសីហនុ សង្គមខ្មែរទទួលយកលំនាំអក្ខរាវិរុទ្ធ ដោយយកវចនានុក្រមរបស់សម្តេចសង្ឃរាជជួនណាតជាបង្អែកសសរ ។

លុះសង្គមខ្មែរឈានចូលដល់សម័យសាធារណរដ្ឋ ក្រោមការដឹកនាំរបស់ឧត្តមសេនីយ៏លន់នល់ ចន្លោះពីឆ្នាំ១៩៧០ ទៅ១៩៧៥ អក្ខរាវិរុទ្ធខ្មែរ បានត្រូវផ្លាស់ប្តូរនិងកែសម្រួលសាជាថ្មី ដោយក្រុមគណកម្មការខេមរយានកម្ម ដែលបានប្រែសម្រួល និងសម្រាយពាក្យខ្មែរជាច្រើន ពីភាសាបាលីសំស្រ្កឹតមកជាពាក្យខ្មែរសាមញ្ញក្នុងគោលបំណងកាត់បន្ថយពាក្យដែលមានព្យាង្គតម្រួតផងនិងដើម្បីបន្ថយនូវភាពវិសាមញ្ញ ក្នុងការសរសេរអក្សរខ្មែរផង ។

នៅរវាងយុគសម័យ ១៩៧៥ ដល់ ១៩៧៨ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យរបស់ពួកខ្មែរក្រហម បញ្ញវ័ន្តខ្មែរច្រើនសែននាក់បានត្រូវអង្គការខ្មែរក្រហមធ្វើឃាដយ៉ាងសាហាវព្រៃផ្សៃ ។ រីឯ

បញ្ញវ័ន្តដែលរត់រួចរស់រានមានជីវិតវិញ ក៏មានចំនួនស្តួចស្តើងស្ទើររកចំនួនរាប់មិនចង់ឃើញឡើយ ។

នៅឆ្នាំ១៩៧៩ ពេលខ្មែរក្រហមខ្ចាត់ខ្ចាយទៅ ដោយកម្លាំងទ័ពវៀតណាមចូលមកក្នុងកម្ពុជា បញ្ញវ័នខ្លះបានរត់ឆ្លងព្រំដែនទៅរស់ជ្រកកោននៅប្រទេសទីបី ហើយក៏លាក់ខ្លួនពួនអាត្មាគេចពីពិភពចលាចលនៅប្រទេសខ្មែររហូតរៀងទៅ ដោយគ្មានបំណងវិលមកមាតុប្រទេសវិញ ។ រីឯបញ្ញវ័ន្តខ្លះទៀត បានបែរទៅរស់នៅជាមនុស្សធម្មតាៗក្នុងទឹកដីរបស់ខ្លួន រួចក៏លែងមានទឹកចិត្តខ្វល់ខ្វាយអំពល់ពីការវិវត្តន៍របស់ប្រទេសជាតិតទៅទៀត ព្រោះគេនឿយណាយចំពោះទារុណកម្មខ្លោចផ្សា ដែលខ្លួនបានទទួលកាលពីសម័យខ្មែរក្រហម ។ ចំពោះក្រុមបញ្ញវ័ន្តដែលនៅសល់ចុងក្រោយ ក៏មានចំនួនកាន់តែស្តួចស្តើងណាស់ទៅហើយ ។ ពួកគេបានសំរេចចិត្តវិលវិញពលីកាយសាជាថ្មីក្នុងការបំរើជាតិខាងផ្នែកអក្សរសាស្ត្រខ្មែរតាមដែលខ្លួនចងចាំ ត្បិតសំណៅសិក្សាទាំងឡាយ តាំងពីកំរិតបឋមសិក្សារហូតឧត្តមសិក្សាបានត្រូវរបបខ្មែរក្រហមបំផ្លាញចោលអស់រលីងគ្មានសល់ ។ ម្ល៉ោះហើយ សំណេរទាំងឡាយដែលគេបានសរសេរចងក្រងសាជាថ្មីនោះ ក៏ក្លាយជាសំណេរដែលមិនមានគ្រឹះមូលដ្ឋានអក្ខរាវិរុទ្ធជាក់លាក់ មិនដឹងថាក្បួនអក្ខរាវិរុទ្ធបែបណាមួយមានលក្ខណៈត្រឹមត្រូវតាមក្បួនច្បាប់ពិតប្រាកដ ជាពិសេស រវាងពាក្យដែលមានព្យាង្គរាយ និងពាក្យដែលមានព្យាង្គតម្រួត ។

ចាប់តាំងពីឆ្នាំ១៩៩៣មក ក្រោមការដឹកនាំរបស់រដ្ឋាភិបាលថ្មី ប្រទេសខ្មែរយើងក៏ចាប់មានអភិវឌ្ឍន៍ កាន់តែខ្ពង់ខ្ពស់ថ្កុំថ្កើងឡើងមកវិញ ។ ខេមរជនទាំងឡាយមានឱកាសបានចូលសិក្សាបន្ថែម មានឱកាសស្រាវជ្រាវ ហើយបានស្រាវជ្រាវ រកឃើញសំណៅចាស់ៗខ្លះៗមកវិញជាច្រើន ហើយក៏ចែកចាយគ្នារៀនសូត្រជា

បន្តៗ ។ បច្ចុប្បន្ននេះ ទាំងខ្មែរនៅក្នុងប្រទេស ទាំងខ្មែរនៅក្រៅប្រទេស ភាគច្រើននៅគាំទ្រនិងរក្សាសំណេរ ដែលយកអក្ខរាវិរុទ្ធក្នុងវចនានុក្រមខ្មែររបស់សម្តេចសង្ឃជួនណាតជាមូលដ្ឋាន ព្រោះថា ខ្មែរជំនាន់មុននិងខ្មែរជំនាន់ក្រោយនៅអាចប្រស្រ័យគ្នា ស្តាប់គ្នាបាន មិនវង្វេងភាសាសរសេររបស់ខ្លួនច្រើនពេកទេ ។ ដោយឡែក ការសរសេរអត្ថបទថ្មីចាប់តាំងពីឆ្នាំពីរពាន់កន្លងមក ភាសាខ្មែរកាន់តែមានភាពច្របូកច្របល់ថែមឡើងកាន់តែច្រើន ដោយសារមានការពង្រាយវប្បធម៌និងភាសាបរទេស ពាសពេញប្រទេសខ្មែរ ជាពិសេសគឺភាសាអង់គ្លេស ភាសាកូរេ ភាសាថៃ ភាសាចិនជាដើម ជាហេតុធ្វើអោយអក្ខរាវិរុទ្ធរបស់ភាសាខ្មែរកាន់តែមានភាពរាយមាយ គ្មានគោលជាក់លាក់ថា តើខ្មែរគួរសរសេរបែបណាទើបត្រឹមត្រូវឡើយ ។

<u>ខ. អំពីការប្រកបពាក្យតាមខេមរយានកម្ម-ពង្រាយព្យាង្គ</u> ៖

តាមធម្មតា ចំពោះអ្នកដែលប្រើកុំព្យូទ័រវាយអក្សរ ការសរសេព្យាង្គរាយជាការងាយស្រួលបំផុតព្រោះគេអាចវាយបានច្រើនហើយរហ័សទាន់ចិត្ត ។ ប៉ុន្តែ ចំពោះព្យាង្គតម្រួតមានដៃមានជើងច្រើន ការវាយពុម្ពអក្សរច្រើនមានការសាំញ៉ាំ ហើយក៏ពន្យឺតពេលវេលានៃការសរសេរអត្ថបទទៅតាមនោះដែរ ។ ចែងន្យការសរសេរព្យាងរាយខ្លះតាមលក្ខណៈខេមរយានកម្មថ្មី អាចធ្វើអោយអ្នកអានទាំងឡាយអានហើយភន្តច្រឡំអត្ថន័យរបស់ពាក្យនិងរបស់ប្រយោគទាំងមូល ។

<u>ឧទាហរណ៍</u> ៖

ឆាងសំលក់ធំ = ឆាង-សម្លក់-ធំ

ឆាងសំលក់ធំ = ឆាងសំ-លក់-ធំ

ឃ្លាពីរខាងលើអាចមានន័យផ្សេងគ្នាយ៉ាងស្រឡះ បើសិនអ្នក អានញែកសម្លេងអានដកឃ្លាខុសកន្លែង លើព្យាង្គរាយ ។ ប៉ុន្តែមានព្យាង្គតម្រួតខ្លះ ក៏នាំការពិបាកដល់ស្មេរយើងដែរ ព្រោះអាចបណ្តាលអោយអ្នកអានឃើញអត្ថបទ ប្រកបទៅដោយភាពសាំញ៉ាំមិនទូលាយងាយស្រួលអាន ស្រួលយល់ ជាពិសេស បើសិនអ្នកអានមានកំរិតសិក្សាស្តួចស្តើង ។មិត្តអ្នកអានខ្លះយល់ថាយើងបានខ្ចីពាក្យបាលីសំស្ក្រឹតមកធ្វើជាពាក្យខ្មែរច្រើនពេក ដូច្នេះហើយទើបយើងសម្បូណ៌ពាក្យដែលសរសេរជាព្យាង្គតម្រួត ច្រើនជាងពាក្យដែលសរសេរជាព្យាង្គរាយ ។ មតិអ្នកអានសម័យថ្មីតែងតែទាមទារការប្រែសម្រួលពាក្យខ្មែរបាលី មកជាខ្មែរសម្រាយ ដើម្បីអោយងាយស្រួលអានផង ងាយស្រួលសរសេរផង ហើយងាយស្រួលនឹងយល់អត្ថន័យរបស់អត្ថបទ ដោយមិនពិបាកដើររកជំនួយបកប្រែ ។

ដូច្នេះ ចំពោះអ្នកនិពន្ធដែលប្រើអក្ខរាវិរុទ្ធចម្រុះ លាយឡំទាំងភាសាខ្មែរជំនាន់សង្គមរាស្ត្រនិយមផង ជំនាន់សម័យខេមរយានកម្មផង គប្បីប្រឹងប្រែងព្យាយាមអោយអស់ពីសមត្ថភាពដើម្បីសរសេរសម្រួលនិងសម្រាយពាក្យពេចន៍អោយបានល្អប្រសើរបំផុត កុំឲ្យបាត់បង់នូវអត្ថរសរបស់សាច់រឿងរបស់ខ្លួនផង និងដើម្បីនាំអ្នកអានអោយឆាប់យល់អត្ថន័យរបស់អត្ថបទនោះអោយបានច្បាស់លាស់ផង ។

<u>គ. អំពីការប្រើសំនួនពាក្យ</u> ៖

នៅក្នុងការនិពន្ធនិមួយៗ ស្មេរត្រូវតែប្រុងប្រយត្ន័បំផុត នូវការប្រើសំនួនពាក្យ អោយមានកំរិត និងអត្ថន័យប្រដំប្រសងគ្នា ពីពាក្យមួយទៅពាក្យមួយ ពីឃ្លាមួយទៅឃ្លាមួយ ពីប្រយោគមួយទៅប្រយោគមួយ ពីល្បះមួយទៅល្បះមួយទៀត ។

<u>ឧទាហរណ៍ទី១</u> ៖

សូមមាតាបិតាជួយប្រដៅប្រដៅកូនផងកុំអោយវាព្រហើនពេក !
ប្រយោគខាងលើនេះ មានសំនួនប្រើ ចំនួនបីកំរិត :
១- កំរិតឧត្តម ៖ អ្នកនិពន្ធប្រើពាក្យ មាតាបិតា ជាពាក្យកំរិតវប្បធម៌ឧត្តម ។
២- កំរិតមធ្យម៖ អ្នកនិពន្ធបានទម្លាក់កំរិតសំនួនពាក្យមកនៅត្រឹមកំរិតវប្បធម៌មធ្យម ដោយយកពាក្យថា កូន មកប្រើជំនួសពាក្យ បុត្រ ដែលស្ថិតក្នុងកំរិតឧត្តមដូចគ្នានឹងពាក្យ មាតាបិតា ។
៣- កំរិតទាប ៖ អ្នកនិពន្ធប្រើពាក្យថា វា ដែលជាពាក្យកំរិតទាបនៅក្នុងឃ្លាតែមួយជាមួយពាក្យកំរិតឧត្តម (មាតាបិតា) និង ពាក្យកំរិតមធ្យម (កូន) ។

<u>ឧទាហរណ៍ទី ២</u> ៖

សម្តេចនាយក គាត់មានប្រសាសន៍ទៅកាន់ប្រជាជនខ្មែរ...
នៅក្នុងឃ្លាខាងលើនេះ យើងឃើញមានការប្រើពាក្យលាយឡំដល់ទៅបីកម្រិតលាយគ្នាដែរ គឺពាក្យ "សម្តេច " ដែលជាពាក្យកម្រិតឧត្តម បន្ទាប់មកមានពាក្យថា "គាត់ " ដែលជាពាក្យកម្រិតទាប និងពាក្យថា"ប្រសាសន៍" ដែលជាពាក្យកម្រិតមធ្យម ។

ឧទាហរណ៍ខាងលើ បានបញ្ជាក់អោយឃើញនូវការសរសេរសំនួនពាក្យលាយឡំ កំរិតខ្ពស់ទាប ច្របល់គ្នា ដូចឡើងទួលហើយធ្លាក់រណ្តៅ ដើបឡើងរួចកញ្ឆក់ចុះវិញ ធ្វើអោយអ្នកអាន វង្វេងកំរិតវប្បធម៌របស់ប្រយោគនិមួយៗ ។ នោះមិនខុសពីគេឃើញផ្លែឈើទុំល្អស្រស់ស្អាតស្រាប់តែឃើញមានដង្កូវចោះដូច្នោះឯង គឺអ្នកអានពិបាកទទួលយកណាស់ ត្បិតសំណេរប្តូរកំរិតវប្បធម៌ឡើងចុះខ្លាំងពន់ពេក ។

<u>ឃ. ការប្រើគ្រាមភាសា</u> ៖

និយមន័យ : គ្រាមភាសាគឺជាភាសានិយាយប្រស្រ័យជាទម្លាប់រាល់ថ្ងៃរបស់អ្នកស្រុក ដែលអាចមានអត្ថន័យផ្លាស់ប្តូរទៅតាមទីកន្លែងខណ្ឌខេត្តដែលអ្នកស្រុករស់នៅ ឧទាហរណ៍ ៖

=====================================

| នៅភ្នំពេញ | នៅបាត់ដំបង |
|---|---|
| សាច់ក្រកគោ | ត្វាគោ |
| សំពត់ជីបជាក់កៅស៊ូ | សំពត់កំប្រោង |
| ម៉ាគំនរគរជី | ម៉ាកំប៉េះកំពាញ |
| ម៉ាក់ | អ្នក (អ្នកម្តាយ) |
| បុកទឹកគ្រឿង | បុកអំព្រឹក |

======================================

អ្នកនិពន្ធគប្បីចៀសវាងការប្រើគ្រាមភាសាច្រើនពេក ដើម្បីកុំអោយអ្នកអានវង្វេងអត្ថន័យ ស្តាប់មិនយល់ ។ បើសិនជា អ្នកនិពន្ធចង់ប្រើ សូមពន្យល់ពាក្យឬឃ្លាប្រយោគផង បើមិនដូច្នេះទេ អ្នកអានដែលមកពីមណ្ឌលភូមិសាស្ត្រ ខុសពីអ្នកនិពន្ធ ច្បាស់ជាវង្វេងអត្ថន័យក្នុងប្រយោគរបស់អ្នកនិពន្ធខ្លះមិនខាន ។ បើសិនជាអាចធ្វើទៅបាន អ្នកនិពន្ធគួរប្រើភាសាអក្សរសាស្ត្រកណ្តាល ដែលអ្នកអានអាចយល់បានគ្រប់គ្នាដោយមិនចាំបាច់គិតថាគេមកពីខេត្រណា ឬតំបន់ណានៃប្រទេសខ្មែរឡើយ ។

ង. ការប្រើអក្ខរាវិរុទ្ធតាមសង្គមអ្នកអាន ៖

អ្នកនិពន្ធនិមួយៗគប្បីត្រៀមជាមុន ថា តើយើងមានបំណងសរសេរ ដើម្បីសង្គមអ្នកអានមួយណា មានកំរិតវិជ្ជាបែបណា កំរិតវប្បធម៌ជំពូកណា វ័យណា ចំណង់ចំណូលបែបណា... ដើម្បីអោយគេបានទទួលឥទ្ធិពលស្នាដៃរបស់យើងពេញទំហឹង ។ កាលបើយើងជ្រើសសង្គមអ្នកអានរួចហើយ ទើបយើងសរសេរនិពន្ធដោយ

ប្រើកំរិតភាសានិងអត្ថន័យអោយសមស្របទៅតាមវ័យ តាមកំរិតវិជ្ជារបស់អ្នកអានទាំងឡាយនោះ ។

ង១. វ័យអ្នកអាន ៖

ការសរសេរដែលមានប្រសិទ្ធិភាពបំផុត គឺ ការសរសេរអោយសមស្របនឹងវ័យរបស់សង្គមអ្នកអាន ។ បើសិនយើងសរសេរសំរាប់អ្នកអានដែលជាកុមារ យើងត្រូវចៀសវាងអក្ខរាវិរុទ្ធដែលបង្កសាច់រឿងខុសកំរិតវ័យនិងការចេះដឹងរបស់ក្មេង ។ បើយើងនិពន្ធសំរាប់យុវជនយុវតី យើងត្រូវពិនិត្យថា តើការប្រើសំនួនអក្ខរាវិរុទ្ធរបស់យើងទាំងនោះ នាំគុណសម្បត្តិនិងផលវិបាកអ្វីខ្លះដល់ពួកគេ ដែលជាអ្នកអាន ហើយតើយើងត្រូវសរសេរពាក្យពេចន៏បែបណាវិញ ដើម្បីរក្សាអត្ថរសរបស់សាច់រឿងឲ្យមានខ្លឹមសារជានិច្ច ចំពោះអ្នកអាននៅក្នុងវ័យនោះ ។ ប្រសិនអ្នកអានជាមនុស្សចាស់វិញ យើងក៏គប្បីជ្រើសរើសពាក្យពេចន៏អក្ខរាវិរុទ្ធដែលសមស្របនឹងវ័យរបស់អ្នកអានទាំងឡាយនោះផងដែរ ដើម្បីកុំអោយអ្នកអានមានអារម្មណ៍ ថា អ្នកនិពន្ធប្រើពាក្យគ្រោតគ្រាតមិនគប្បីចំពោះអ្នកអាន ។

ង២. កំរិតវិជ្ជារបស់អ្នកអាន ៖

នៅប្រទេសខ្មែរយើងសព្វថ្ងៃ បន្ទាប់ពីសម័យខ្មែរក្រហមមកថ្វីបើយើងមានឱកាស មានសាលា មានគ្រូបង្រៀនវិញហើយក្តី ក៏ចំនួនប្រជាពលរដ្ឋដែលមានវិជ្ជាខ្ពស់ដល់កំរិតសិក្សាមធ្យមនៅតែមានចំនួនស្តួចស្តើងដដែល ក្នុងឱកាសដែលខ្មែរមួយចំនួនតូចបានលូតលាស់ដល់ឧត្តមសិក្សា ហើយបានទទួលការសិក្សាបញ្ចប់ជាបណ្ឌិតខ្លះៗហើយក៏ដោយ ។ មធ្យមភាគនៃការចេះដឹងរបស់ប្រជាពលរដ្ឋទូទៅក្នុងប្រទេសស្ថិតនៅក្នុងកំរិតទាបនៅឡើយ វៀរលែងតែនៅក្នុងទីក្រុងធំៗដូចជាភ្នំពេញ សៀមរាប កំពង់ចាម និងនៅ

បាត់ដំបងជាដើម ដែលហាក់ដូចជាសំបូរបញ្ញវ័ន្តជាងមុន ជាពិសេសគឺ ពន្លកទំពាំងថ្មីៗក្រោយសម័យ អ៊ុនតាក់១៩៩៣ គឺចំនួនបញ្ញវ័ន្តបានកើនយ៉ាងច្រើនដូចផ្សិត ។ ប៉ុន្តែ នៅតាមខេត្រនិងជនបទខ្លះៗ អ្នកមិនបានចូលរៀនសូត្រអ្វីនោះ ក៏នៅតែមានចំនួនខ្ពស់ដដែល មិនទាន់ផ្លាស់ប្តូរប៉ុន្មានដែរទេ ។

យោងទៅតាមកម្រិតសិក្សានៃពលរដ្ឋទូទៅ ក្នុងប្រទេសខ្មែរ ការនិពន្ធចងក្រង ដែលអាចមានប្រសិទ្ធិភាពបំផុត ចំពោះអ្នកអាននានា គឺសំណេរដែលប្រើអក្ខរាវិរុទ្ធកំរិតមធ្យម ។ ថ្វីបើយ៉ាងនោះក៏ដោយ ក៏អ្នកនិពន្ធអាចនៅមានឱកាសបញ្ចូលគំនិតខ្ពង់ខ្ពស់ ទៅក្នុងសំណេរ ដោយមិនបាច់ប្រើសំនួនពាក្យឬអក្ខរាវិរុទ្ធកំរិតខ្ពង់ខ្ពស់ពេកទេ ។ ដរាបណាយើងនៅរក្សាកំរិតសំណេរអោយនៅស្មើខ្ទង់កំរិតថ្នាក់ទី៨ នោះសំណេររបស់យើងអាចទាញចំនួនអ្នកអានបានច្រើនជាងគេបំផុត ព្រោះថា អ្នកដែលមានកំរិតទាបជាងថ្នាក់ទី៨ កាលបើបានចាប់សៀវភៅយកមកអានហើយ ក៏អាចមានលទ្ធភាពនិងសមត្ថភាពយល់នូវសេចក្តីនៅក្នុងអត្ថបទនោះ ។ រីឯអ្នកដែលមានកំរិតវិជ្ជាខ្ពស់ជាងថ្នាក់ទី៨ក៏អាចអានបាន ដោយមិនអាក់អន់ស្រពាន់ចិត្ត ត្បិតសំណេររបស់យើងនោះមានលាក់តម្លៃគុណសម្បត្តិផ្នែកវប្បធម៌យ៉ាងខ្ពង់ខ្ពស់គួរអោយគេចាប់អារម្មណ៍ ។ ដូច្នេះ នៅក្នុងការប្រើអក្ខរាវិរុទ្ធ កំរិតកណ្តាល អ្នកអានទាំងកំរិតក្រោម និងកំរិតលើ អាចទទួលយកបានទាំងសងខាង រួមទាំងអ្នកកំរិតកណ្តាលផងដែរ ដោយមិនមានការទើសទាល់ក្នុងចិត្ត ។

<u>ង៣. កំរិតវប្បធម៌របស់សំណេរ</u> ៖

អ្នកនិពន្ធខ្លះសរសេរអត្ថបទ ទៅតាមចំណង់ចំណូលចិត្តរបស់ខ្លួនផ្ទាល់ ដោយមិនគិតអំពីសង្គមអ្នកអានទេ គឺគេគ្រាន់តែចង់បញ្ចេញមតិរបស់គេ មកលើក្រដាសសៀវភៅ ឲ្យធូរស្រាលភាព

ណែនណាន់តានតឹងក្នុងទ្រូងរបស់គេតែប៉ុណ្ណោះ ។ ខ្លះទៀតចង់សរសេរចងក្រងអ្វីៗ គឺដើម្បីអោយអ្នកអានបានទទួលឥទ្ធិពលពីសំណេររបស់គេទាំងឡាយនោះ ។ ពេលនោះហើយ ដែលអ្នកនិពន្ធត្រូវតែជ្រើសរើសកំរិតវប្បធម៌របស់សង្គមអ្នកអាន ថាតើអ្នកនិពន្ធចង់បានសង្គមអ្នកអានកំរិតវប្បធម៌បែបណា ដើម្បីអោយមកអានសៀវភៅរបស់គេ ។ ដូច្នេះ គេត្រូវប្រឹងប្រែងព្យាយាមសរសេរដោយប្រើអក្ខរាវិរុទ្ធដែលតម្រូវទៅតាមកំរិតវប្បធម៌និងសមត្ថភាពរបស់សង្គមអ្នកអាន ដោយការផ្តួចសន្ទេហវិធី អោយអ្នកអានមានចំណង់ចំណូលខាងអានថែមផង បង្កើនភាពរំភើបចំពោះអត្ថរសរបស់សាច់រឿងផង ហើយអោយអ្នកអានមានចិត្តសោមនស្ស មានមោទនភាពក្នុងការចែកចាយសំណេរនោះ ទៅញាតិមិត្តរបស់គេអោយអានកាន់តែច្រើនថែមផង ។

ចំពោះអ្នកនិពន្ធខ្លះៗដែលសរសេរដើម្បីកម្រៃ គេមិនសូវគិតពីតម្លៃវប្បធម៌ប៉ុន្មានទេ ។ គេច្រើនគិតយ៉ាងណាឲ្យតែបានប្រាក់ចំណូលច្រើនមកវិញពីការសរសេរនោះអោយបានច្រើនបំផុត ទោះបីជាខ្លួនគេត្រូវដើរក្នុងផ្លូវកំរិតវប្បធម៌ទាបបន្តិចក៏ដោយ គឺគេធ្វើយ៉ាងណា ចាប់យកសង្គមអ្នកអានមួយរង្វង់នោះ អោយបានច្រើនបំផុត តាមដែលគេអាចធ្វើទៅបាន ថ្វីបើស្នាដៃនោះមានតម្លៃសំរាប់តែពេលបច្ចុប្បន្ននេះក៏ដោយ ។ នោះគឺជាការសរសេរ តម្រូវតាមចំណង់របស់សង្គមមួយវង់ តែមិនមែនតម្រូវតាមចំនួនអ្នកអានជាទូទៅឡើយ ។ ការសរសេររបៀបនោះ មិនសូវមានតម្លៃចេរស្ថិតស្ថេរយូរលង់ប៉ុន្មានទេ ច្រើនតែសាបរលាបទៅតាមកាលវេលាព្រោះសង្គមខ្មែរទូទៅមិនសូវជ្រោមជ្រែងគាំទ្រ លើកទឹកចិត្ត ឬជួយថែរក្សាប៉ុន្មានឡើយ ។

<u>ច. សារៈប្រយោជន៍របស់អក្ខរាវិរុទ្ធ</u> ៖

អ្នកនិពន្ធចាំបាច់ត្រូវតែស្គាល់អក្ខរាវិរុទ្ធ អោយបានជ្រៅជ្រះ បំផុត តាមដែលអាចធ្វើទៅបាន ។ ការដែលយើងស្គាល់អក្ខរាវិរុទ្ធ ច្រើននោះ អាចអោយយើងទទួលនូវផលប្រយោជន៍ជាច្រើនយ៉ាង ដូចជា ៖

- អាចសរសេរបានឃ្លាប្រយោគប្លែកៗពិរោះៗ ដោយចៀសវាង នូវការសរសេរស្ទួនពាក្យច្រំដែលៗ ច្រើនដង មិនអោយអ្នកអាន ទ្រាន់អារម្មណ៍ឬទ្រាន់គំនិតនៅពេលគេអានសំណេររបស់យើង ។
- បង្កើនអត្ថរសសំណេរអោយកាន់តែមានខ្លឹមសារជាងមុន ។
- បង្កើនផ្នែកវប្បធម៌និងកិរិតអក្សរសាស្ត្រអោយកាន់តែខ្ពង់ខ្ពស់
- បង្កើនចេតនារម្មណ៍របស់អ្នកអាន អោយកាន់តែត្រេកត្រអាល ជាមួយនឹងការអានសំណេរទាំងឡាយ ។

<u>ឧទាហរណ៍</u> ៖

នារី ធីតា តរុណី កល្យាណី មាណវី ស្រស់ស្រី ធិតា នាង

មាណព បុរស យុវជន នរៈ នាយ អ្នកកម្លោះ

មានន័យថា គេអាចយកពាក្យណាមួយ មកប្រើជំនួសគ្នាក៏បាន ដើម្បីកុំឲ្យឃ្លាប្រយោគឬល្បះនិមួយៗមានពាក្យច្រំដែលៗ ចៀស វាងមិនអោយអ្នកអានធុញទ្រាន់ ប៉ុន្តែនៅរក្សាអត្ថរសនិងអត្ថន័យ របស់សាច់រឿងអោយនៅដដែល មិនផ្លាស់ប្តូរ ។

រួមសេចក្តីមក ការប្រើអក្ខរាវិរុទ្ធសមស្ទួនដើម្បីរំលេចអត្ថន័យ និងអត្ថរសរបស់សំណេរមានសារៈសំខាន់ណាស់ ចំពោះអត្ថបទ និមួយៗ ។ បើយើងប្រើពាក្យខ្ពស់ ប៉ុន្តែក្នុងកិរិតវប្បធម៌ទាប ឬក៏ ប្រើពាក្យទាបៗគ្រោតគ្រាត ក្នុងវណ្ណៈខ្ពស់នោះ ពិតជាមិនអាចទៅ រួចឡើយ ព្រោះសំណេររបស់យើងនោះនឹងបង្ហាញនូវភាពខ្មោះ បីដូចជាផ្លែឈើទុំល្អស្អាតត្រូវដង្កូវចោះស៊ីអញ្ចឹង មិនខុសគ្នា ឡើយ ។ ដូច្នេះ ដើម្បីនឹងអាចក្លាយខ្លួនជាអ្នកនិពន្ធដ៏ប្រសើរបាន

គឺយើងត្រូវប្រយត្ន័នូវពាក្យពេចន៍របស់យើង រក្សាយ៉ាងណាអោយស្ថិតនៅជាកណ្តាល មិនខ្ពស់ជ្រុលពេក មិនទាបជ្រុលពេក មិនកខ្វក់ពេក មិនពណ្ណរាយ មកពីឋានសួគ៌ពេក ។ ពេលនោះយើងនឹង អាចទាក់ទាញអ្នកអាន ទាំងគ្រប់កំរិត ខាងខ្ពស់ ខាងទាប និង ខាងកណ្តាល អោយមកអាន សំណេររបស់យើង ហើយគេអាចយល់អត្ថន័យរបស់សំណេរដោយគ្មានការទើសទាល់ក្នុងអារម្មណ៍របស់គេឡើយ ដូចព្រះពុទ្ធដីការសម្តែងថា ផ្លូវ កណ្តាលគឺជាផ្លូវដែលមានដំណើរជោគជ័យជាងគេបំផុតក្នុងជីវិត ។

<u>ឆ. អំពីការប្រើភាសាឯកទេស</u> ៖

យើងបានដឹងស្រាប់ហើយថា ភាសាខ្មែរដែលយើងប្រើប្រាស់រាល់ថ្ងៃ ទាំងភាសានិយាយប្រស្រ័យទាក់ទងគ្នាប្រចាំថ្ងៃ ទាំងភាសាដែលយើងប្រើប្រាស់ជាផ្លូវការ ជាលាយលក្សណ៍ក្នុងក្រសួង មានលាយឡំទៅដោយភាសាខ្មែរកំណើតផង និងភាសាដែលខ្មែរយើងបានខ្ចីពីបរទេសមកផង ។ ភាសាបរទេសដែលមានឥទ្ធិពលជាងគេបង្អស់នៅក្នុងប្រទេសខ្មែរទាំងមូល តាំងពីវណ្ណៈក្សត្រ រហូតទៅដល់វណ្ណៈពលរដ្ឋសាមញ្ញ គឺភាសាបាលីនិងសំស្រ្កឹតនោះតែម្តង ។ ភាសាបាលីនឹងសំស្រ្កឹត បានលាតអនុភាពដណ្តប់ប្រទេសខ្មែរតាមរយៈពុទ្ធសាសនា ដែលមហាក្សត្រខ្មែរជំនាន់មហានគរ បានត្រងទទួលយកមកផ្សព្វផ្សាយក្នុងអាណាចក្រដោយទឹកចិត្តស្វាមីភក្តិ ឡិតព្រះអង្គមានជំនឿថា ពុទ្ធសាសនានឹងនាំមកនូវសុខសន្តិភាព និងវឌ្ឍនភាពក្សេមក្សាន្ត ដល់ជាតិខ្មែរ សង្គមខ្មែរ ជានិរន្តន៍ ។ កាលដើមឡើយ គេច្រើនឃើញការប្រើប្រាស់ភាសានេះ តែនៅក្នុងវណ្ណៈក្សត្រនិងវណ្ណៈមន្ត្រីដែលមានងារខ្ពង់ខ្ពស់នៅក្នុងរាជការ ។ លុះចំណេរក្រោយមកទៀត ភាសានេះក៏បានផ្សព្វផ្សាយចេញទៅដល់ប្រជាពលរដ្ឋខ្មែរទូទៅ តាមរយៈការផ្សព្វផ្សាយពុទ្ធសាសនា

តាមវត្តអារាម ដោយមានការបង្រៀនភាសាខ្មែរ និងភាសាបាលីសំស្ក្រឹតដល់ភិក្ខុនេន ឬសិស្សនានាដែលមានបំណងចង់សិក្សារៀនសូត្រអក្សរសាស្ត្រ ។ ដោយហេតុថា ភាសាបាលីនិងសំស្ក្រឹតជាភាសាបរទេស ដែលខ្មែរសាមញ្ញមិនអាចយល់នឹងនូវអត្ថន័យបាន ទើបក្រសួងធម្មការជំនាន់នោះ បានធ្វើការបកប្រែអត្ថបទនៅក្នុងគម្ពីរពុទ្ធសាសនា មកជាភាសាខ្មែរសម្រាយសាមញ្ញ ដើម្បីអោយពលរដ្ឋខ្មែរទូទៅអាចមានសមត្ថភាពរៀនបាន ហើយយល់ច្បាស់នូវអត្ថន័យនៃទ្រឹស្តីពុទ្ធសាសនាផង និងអត្ថន័យនៃភាសាបាលីសំស្ក្រឹត ដែលគេបានសិក្សានោះផង ។

នៅកំឡុងពេលក្រោយៗមកទៀត ប្រទេសខ្មែរបានឆ្លងកាត់សម័យកាលមួយ ដែលមានបរទេសចូលត្រួតត្រា ឬក៏ចេញចូលធ្វើអាជីវកម្ម ភាសារបស់បរទេសបានជះឥទ្ធិពលមកលើសង្គមខ្មែរជាទូទៅ ជាបន្ថែមទៀត ដូចជាភាសាបារាំង ភាសាសៀម ភាសាចិន ភាសាអង់គ្លេសជាដើម ។ ដោយសារមូលហេតុនោះ ភាសាដែលខ្មែរនិយមប្រើប្រស្រ័យទាក់ទងគ្នាប្រចាំថ្ងៃ ជាភាសាឆ្លើយឆ្លងធម្មតា ច្រើនលាយឡំចម្រុះទៅដោយភាសាបរទេសទាំងឡាយនោះ ។ ជួនកាល យើងគ្មានពាក្យខ្មែរសម្រាយសាមញ្ញ បកប្រែភាសាអង់គ្លេស ភាសាបារាំងទាំងនោះបាន ក៏នាំគ្នាបកទៅជាភាសាបាលីសំស្ក្រិតទាំងដុំៗ ដែលជាហេតុធ្វើអោយខ្មែរពិបាកយល់ន័យងដែល ជួនកាលក៏មានចំនួនព្យាង្គច្រើន វែងៗ ពិបាកនិយាយពិបាកចងចាំ ម្ល៉ោះហើយខ្មែរទូទៅក៏នាំគ្នាទម្លាប់ប្រើ ភាសាកាត់ៗខ្លីៗសម្រាប់អោយឆាប់យល់វិញ ថ្វីបើមិនមែនជា ភាសាដែលរដ្ឋាភិបាល បានទទួលស្គាល់ជាផ្លូវការក៏ដោយ ។ ឧទាហរណ៍ ដូចជាពាក្យបារាំងមួយម៉ាត់ដែលសរសេរថា "gare" បកប្រែមកជាភាសាបាលីសំស្ក្រិត ថា "ស្ថានីយអយស្ម័យយាន " ។ ឯភាសា

ខ្មែរសម្រាយវិញប្រែថា " ចំណតរទេះភ្លើង " ប៉ុន្តែ ការប្រើប្រាស់ ជាសាមញ្ញទូទៅ គេបែរនិយមនាំគ្នាហៅថា " រ៉ា " យ៉ាងពេញប្រជាប្រិយជាពាក្យខ្លីមួយម៉ាត់ ស្រួលហៅ ស្រួលចាំ ជាជាងឈ្មោះជាពាក្យបាលីសំស្រ្កឹតវែងអន្លាយ ពិបាកហៅ ពិបាកយល់ ។

<u>ឧទារណ៍ផ្សេងៗទៀត ៖</u>

| <u>ភាសាបារាំង-អង់គ្លេស</u> | <u>ភាសាបាលី-ខ្មែរ</u> | <u>ភាសារាយ</u> |
|---|---|---|
| motocycle | ទោចក្រយានយន្ត | ម៉ូតូ |
| cyclo | ត្រីចក្រយាន | ស៊ីក្លូ |
| technology | បច្ចេកវិជ្ជា | តិចណូ |
| bicycle | ទោចក្រយាន | កង់ |
| origine | ប្រភព (ដើមកំណើត) | ឈិន |
| bureau | ការិយាល័យ | ប៊ុរ៉ូ |
| remorque | ទោចក្រយានសណ្តោង | ឡាម៉ក |
| brouillon | ក្រដាសព្រៀង | ប្រយ៉ុង |

---

នេះគ្រាន់តែជាឧទាហរណ៍ខ្លះៗ ជូនអ្នកនិពន្ធទាំងឡាយគិត ត្រិះរិះអ្វីជាភាសាបរទេសពិត អ្វីជាភាសាខ្មែរឆ្លងវប្បធម៌ ហើយភាសាណាមួយសមរម្យសំរាប់អ្នកនិពន្ធគប្បីជ្រើសយកមកប្រើ ។

ចំពោះភាសាបាលីសំស្រ្កិតវិញ ថ្វីបើបានវាតទីពេញសង្គមខ្មែរអស់ជាច្រើនសតវត្សមកហើយក៏ដោយ ក៏ភាសានេះនៅតែរក្សាសភាពខ្លួនជាភាសាបរទេស ចំពោះខ្មែរដដែល ត្បិតខ្មែរទូទៅនៅតែមិនស្គាល់អត្ថន័យជ្រៅជ្រះរបស់ភាសានេះ នៅពេលគេយកមកប្រើ ។ នៅបច្ចុប្បន្ននេះ គេប្រើភាសាបាលីសំស្រ្កិត ជាភាសាឯកទេស នៅក្នុងផ្នែកសាសនា ផ្នែកសិក្សាធិការ និងសាលាអក្សរសាស្រ្តជាន់ខ្ពស់ មិនខុសឡើយពីភាសាឯកទេសដទៃទៀត នៅក្នុង

គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា សរីរវិទ្យា ធរណីវិទ្យា ឬក៏ខាងបច្ចេកវិជ្ជាជាដើម ។ ដោយសារខ្មែរយើងមិនអាចមានលទ្ធភាពបកប្រែសម្រួលភាសាបរទេសទាំងនោះ មកជាភាសាខ្មែរសម្រាយបាន ទើបយើងនាំគ្នារក្សាទុកសុពលភាពដើម ពេលសម្រួលភាសាទាំងនោះជាភាសាខ្មែរ ដោយគ្រាន់តែសរសេរប្រកបតួអក្សរអោយសមតាមសូរសម្លេងអានរបស់ពាក្យនិមួយៗ ទាំងនោះជំនួសវិញ ដូចជាពាក្យថា ម៉ាស ញូតុន អុកស៊ីសែន អ៊ីដ្រូសែន គីប កំព្យូទ័រ អុបទិក អេក្យូទ័រ គីឡូក្រាម គីឡូម៉ែត្រ លីត្រ ឌីវីឌី ស៊ីឌី អឹមភីទ្រី ជាដើម ។ល ។ ដូចគ្នានេះដែរ ខ្មែរយើងយកអក្សរខ្មែរមកប្រកបតាមសម្លេងរបស់ភាសាបាលី-សំស្ក្រិត ដែលមានប្រភពដើមមកពីប្រទេសឥណ្ឌាសិរីលង្កា ។

ដោយសារខ្មែរនិយមប្រើភាសាបាលីសំស្ក្រឹត នៅក្នុងសង្គមថ្នាក់លើនៃប្រទេសកម្ពុជា ប្រជាពលរដ្ឋទូទៅក៏បាក់ផ្នត់គំនិត នាំគ្នាគិតថា ភាសាបាលី គឺជាភាសារបស់អ្នកមានវណ្ណៈខ្ពង់ខ្ពស់ ដែលមានអំណាចចេស្តា ហើយមានគេគោរពទទួលគ្រប់ទីកន្លែង ។ រហូតមកដល់ឥឡូវនេះ យើងនៅតែឃើញសង្គមខ្មែរចូលចិត្តជំរុញលើកតម្កើងអោយមានការប្រើភាសាបាលីសំស្ក្រិត នៅគ្រប់ស្រទាប់វណ្ណៈទាំងអស់ ជាជាងការប្រើភាសាខ្មែរដែលជាភាសាដើមកំណើតរបស់ខ្លួនឯង សុទ្ធសាធទៅវិញ ។

រួមសេចក្តីមក តើការប្រើភាសាបាលីសំស្ក្រិតមានប្រយោជន៍ ឬគុណសម្បត្តិអ្វីខ្លះចំពោះអ្នកនិពន្ធដែលប្រាថ្នាសរសេរអត្ថបទអក្សរសិល្ប៍ទុកជាស្នាដៃដ៏មានសារប្រយោជន៍ចំពោះសង្គមខ្មែរទូទៅ ?

យើងបានពន្យល់រួចមកហើយថា ប្រជាពលរដ្ឋទូទៅនៅក្នុងប្រទេសខ្មែរ មិនមែនសុទ្ធតែជាបញ្ញវន្តគ្រប់គ្នាទេ ហើយក៏មិនមែន

ជារាជវង្ស ឬជាអ្នកបួសរៀនគ្រប់គ្នាដែរ ដូច្នោះហើយ ការនិពន្ធដោយប្រើភាសាបាលីសំស្ក្រិតធំៗពេក អាចបណ្តាលអោយអ្នកអានសាមញ្ញទូទៅស្តាប់មិនយល់ន័យ ត្បិតអ្នកអានភាគច្រើន មិនងាយមានលទ្ធភាពនឹងបើកវចនានុក្រមបកប្រែភាសា នៅរៀងរាល់ពេលដែលគេមានចម្ងល់នោះទេ ។ យើងទាំងអស់គ្នាគប្បីគិតទៅមើលថាតើគ្រួសារខ្មែរនៅក្នុងប្រទេសប៉ុន្មានភាគរយ ដែលមានវចនានុក្រមនៅក្នុងផ្ទះសំរាប់ជាជំនួយផ្នែកអក្សរសាស្ត្រ ? តើវត្តអារាមនិមួយៗនៅក្នុងប្រទេសខ្មែរ មានតម្កល់វចនានុក្រមគ្រប់វត្តឬទេ ? ចំពោះសិស្សទាំងឡាយដែលមករៀនសាលារាល់ថ្ងៃ តើពួកគេទាំងនោះមានវចនានុក្រមខ្មែរកាន់គ្រប់គ្នាជាកម្មសិទ្ធិដែរឬទេ ? បើចម្លើយឆ្លើយថា ភាគរយនៃចំនួនមនុស្សដែលមានវចនានុក្រមជាកម្មសិទ្ធិមានចំនួនតិចតួចស្តួចស្តើងនោះទេ តើហេតុអ្វីយើងប្រឹងបង្កើនការសរសេររបស់យើង ក្នុងភាសាបាលីសំស្ក្រិតដោយបង្កប់ទៅដោយអត្ថន័យជ្រៅៗនោះធ្វើអ្វី កាលបើអ្នកអានទាំងឡាយមានការលំបាកក្នុងការបកប្រែអត្ថន័យរបស់ពាក្យទាំងឡាយនោះ ?

ដូចនេះ ការប្រឹងសរសេរអត្ថបទដោយប្រើពាក្យបាលីសំស្ក្រិតខ្ពស់ពេក អាចធ្វើអោយអ្នកអានពិបាកយល់ច្បាស់នូវអត្ថន័យ និងអត្ថរសពិតរបស់សំណេរ ដែលអ្នកនិពន្ធចង់ផ្តល់ ចំពោះអ្នកអានគ្រប់ៗគ្នា ។ ឯអ្នកនិពន្ធខ្លះទៀតដែលប្រើភាសាបាលីច្រើននៅក្នុងអត្ថបទ ជួនកាលក៏ខិតខំបញ្ចូលការពន្យល់ពាក្យ នៅតាមជើងទំព័រសៀវភៅ ប៉ុន្តែការសរសេរបៀបនេះ អាចធ្វើអោយអ្នកអានបែកអារម្មណ៍ពីដំណើររឿង ឬដំណើរសេចក្តីនៃអត្ថបទ ប្រៀបដូចជាការជិះរថយន្តធ្វើដំណើរចេញពីភ្នំពេញទៅសៀមរាប ដែលអាល័យតែនាំគ្នាឈប់តាមផ្លូវរតាក់រតុប ត្រង់នេះមួយភ្លែតត្រង់នោះមួយភ្លែតអស់ជាច្រើនដំណាក់ ទំរាំនឹងដល់ទីចំណតចុងក្រោយនោះឡើយ ។

ប្រការមួយទៀត ក្នុងខណៈដែលប្រទេសជាតិយើងកំពុងមាន ការរីកចំរើនទៅមុខ បច្ចាជនជំនាន់ក្រោយក៏បានទទួលការសិក្សា ប្លែកៗ ជាការសិក្សាចំណេះវិជ្ជាដទៃផ្សេងៗទៀត ជួនកាលជាវិជ្ជា ឯកទេសជាន់ខ្ពស់ ខាងវិទ្យាសាស្ត្រ ខាងវិស្វកម្ម ខាងវេជ្ជសាស្ត្រ ចិត្តសាស្ត្រ ឬ មុខវិជ្ជាឯកទេសសំខាន់ៗ ដែលតម្រូវអោយសិស្ស រៀនភាសាឯកទេសយ៉ាងសំបូរបែប ។ ដូច្នេះ សិស្សទាំងអស់នោះ មិនមែនសុទ្ធតែជាសិស្ស ដែលមានការហ្វឹកហ្វឺនស៊ីជម្រៅ ខាង បាលីសំស្ក្រិតជាភាសាឯកទេសដែរ ។ ម្ល៉ោះហើយ មធ្យមភាគនៃ ការចេះដឹងរបស់ខ្មែរ ក្នុងភាសាបាលីសំស្ក្រឹត ក៏ត្រូវថមថយចំនួន មកវិញ ដោយសារការរីកចំរើនខាងភាសាឯកទេសដទៃទៀតដែល កាន់តែមានចំនួនច្រើនឡើងៗនៅក្នុងប្រទេសយើង ។ យោងទៅ តាមប្រការខាងលើនេះ តើយើងអាចគិតបានទេថា ការសរសេរ និពន្ធដោយប្រើពាក្យបាលីសំស្ក្រឹតច្រើនពេក នៅក្នុងសំណេរ នឹង មានប្រសិទ្ធិភាពទៅលើអ្នកអាន បានដល់កម្រិតណាដែរ ?

ម្យ៉ាងទៀត តម្លៃពិតរបស់អក្សរសិល្ប៍ មិនមែនលាក់នៅក្នុង ពាក្យបាលីសំស្ក្រិតធំៗ ដែលយើងខ្ចីគេយកមកប្រើនោះទេ ។ ការ ប្រើភាសាខ្ពស់ៗ តែខ្វះគំនិត ខ្វះសតិប្រាជ្ញ ខ្វះខ្លឹមអត្ថរសសំរាប់ ណែនាំអ្នកអាននោះ ពិតជាមិនអាចនាំសំណេររបស់យើង អោយ មានប្រសិទ្ធិភាព មានឧត្តមភាព នៅក្នុងសង្គមខ្មែរបានដែរ ។ ការ ខំប្រឹងទាញយកពាក្យបាលីធំៗ មកប្រើនៅក្នុងសំណេរ ដែលមាន អត្ថរសងាយៗ សាមញ្ញៗ មិនខុសអ្វីពីការប្រឹងដាំពេជ្រអោយសត្វ ក្របីពាក់ជាអលង្ការ លំអរូបនោះឡើយ ។ ពាក្យចាស់លោកសំដែង ថា "កាត់មួកតម្រូវក្បាល កាត់ខាអាវតម្រូវមាឌអ្នកពាក់ " គឺមាន ន័យសំរាប់អោយយើងរៀនគិត អោយបានសព្វជ្រុងជ្រោយថា តើ

យើងគួរសរសេរអត្ថបទបែបណា កម្រិតណា ទើបអាចតម្រូវទៅតាមសមត្ថភាព និងសេចក្តីត្រូវការរបស់អ្នកអាន ជាទូទៅ ?

សូមអ្នកនិពន្ធចងចាំផងដែរថាការដែលយើងសរសេរសម្រួលសំណេររបស់យើងជាភាសាខ្មែរសម្រាយពេញលក្ខណៈ ដើម្បីអោយអ្នកអានងាយយល់អត្ថន័យរបស់សំណេរ មិនមែនមានន័យថាអ្នកនិពន្ធកំពុងបង្អាប់បង្អោនអក្សរសាស្ត្រខ្មែរ ឲ្យស្រកស្រុតឧត្តមភាពនោះឡើយ ។ ការពិត ការសរសេរអត្ថបទដោយពាក្យខ្មែររាយ ប៉ុន្តែមានអត្ថន័យខ្ពស់ មានលាក់ចំណេះចេះដឹងខ្ពស់ មានសីលធម៌វប្បធម៌ខ្ពស់ ដែលខ្មែរភាគច្រើនក្នុងប្រទេសជាទូទៅ អាចយល់ជំរៅអត្ថរសនិងខ្លឹមសាររបស់អត្ថបទនោះបានយ៉ាងងាយ ដោយមិនបាច់ពឹងវចនានុក្រម ពឹងព្រះសង្ឃ ឬគ្រូអាចារ្យអោយមកជួយបកប្រែបន្ថែមទៀតនោះ គឺយើងអាចចាត់ទុកសំណេរនោះថាជាស្នាដៃប្រណីតមួយរបស់អ្នកនិពន្ធ ដែលខំថែរក្សាភាសាខ្មែរកំណើតដើម អោយមានអត្ថន័យ មានសុពលភាព មិនចាញ់ភាសាឯកទេសដែលយើងបានខ្ចីពីបរទេស យកមកប្រើទាំងនោះឡើយ ។ នោះហើយគឺជាស្នាដៃដ៏មានប្រសិទ្ធភាពយ៉ាងបរិបូណ៌ សំរាប់ណែនាំអ្នកអាន អោយស្វែងយល់នូវការចេះដឹងដែលមានសារប្រយោជន៍ចំពោះជីវិតរស់នៅ ដោយគ្មានភាសាឯកទេសជាឧបសគ្គឡើយ ។

ឧទាហរណ៍ ៖

នៅពេលអ្នកនិពន្ធម្នាក់មានគំនិតប្រាថ្នាចង់សរសេរ អំពីដំណើងនានា ដើម្បីណែនាំពួកទេសចរដែលមកលេងសៀមរាប អោយស្គាល់ភូមិសាស្ត្រតំបន់អង្គរ ស្គាល់អាសយដ្ឋាននិងទូរស័ព្ទ សំរាប់ទាក់ទងរកឡានឈ្នួល រកផ្ទះសំណាក់ឬសណ្ឋាគារ រកភោជនីយដ្ឋាន រកមន្ទីរព្យាបាល រកផ្សារ ។ល ។ គេមិនចាំបាច់ដាក់ចំណងជើងសៀវភៅនោះ ដោយប្រើពាក្យបាលីសំស្ក្រិតយ៉ាងធំៗ ដូចជាពាក្យ

ថា "មគ្គុទេសក៍ទេសចរណ៍ " នោះឡើយ ត្បិតចំណងជើងនោះ ជាចំណងជើងភាសាបរទេស ព្រោះអ្នកអានទូទៅត្រូវស្វែងរក វចនានុក្រមមកប្រែពីបាលីសំស្រ្កឹត ទៅភាសាជាតិរបស់ខ្មែរដើម កំណើត មួយជាន់ទៀត ដើម្បីអាចស្តាប់យល់ន័យបាន ។ ម្យ៉ាង ទៀត ការប្រើភាសាខ្ពស់នៅក្នុងសៀវភៅសាមញ្ញធម្មតាមួយក្បាល ក៏មិនអាចជួយលើកតម្កើងតម្លៃសៀវភៅនោះ អោយខ្ពង់ខ្ពស់ទៅ ណា ថែមទៀតដែរ ក្រៅពីការណែនាំផ្តល់ពត៌មានបន្តិចបន្តួច អំពី ទិសតំបន់សំរាប់ដើរកំសាន្ត រកកន្លែងស្នាក់នៅ រកកន្លែងបរិភោគ និងសម្រាប់រកមន្ទីរពេទ្យ តែប៉ុណ្ណោះ ។ ចំពោះសំណៅខាងលើ អ្នកនិពន្ធអាចប្រើចំណងជើងថា សៀវភៅណែនាំអ្នកដំណើរ (Traveler's Guide) នោះ គឺមានន័យគ្រប់គ្រាន់សំរាប់ខ្មែរទូទៅ អានយល់យ៉ាងងាយ ដោយមិនពិបាកពឹងវចនានុក្រម មកជួយប្រែ បន្ថែមឡើយ ។

ចំពោះ អ្នកនិពន្ធដែលមានឯកទេសខាងធម្មការ ពុទ្ធសាសនា ខាងអក្សរសាស្រ្តជាដើម ក៏អាចនៅរក្សាការប្រើភាសាបាលីសំស្រ្កឹត ជាភាសាឯកទេស សំរាប់ការប្រើប្រាស់ក្នុងក្រសួង សំរាប់ការ សរសេរសំណេរស្រាវជ្រាវ ឬការចងក្រងសំណៅផ្សេងៗ ដោយ មិនមានទើសទាល់អ្វីដែរ ត្បិតភាសាបាលីនេះបានដោតជាប់ទៅនឹង ជីវិតរបស់ខ្មែរ ផ្នែកសាសនាយ៉ាងមុតជ្រៅ ជាភាសាឯកទេស រួច ស្រេចទៅហើយ ។

នៅមានមួយចំណុចទៀតដែលអ្នកនិពន្ធខ្មែរទូទៅ គប្បីប្រយ័ត្ន ក្នុងការសរសេរ គឺការប្រើពាក្យរាយឆ្លងវប្បធម៌ ដូចនៅក្នុង តារាងឧទាហរណ៍ពន្យល់នៅប៉ុន្មានទំព័រមុននេះ ត្បិតការប្រើគ្រាម ភាសា នៅក្នុងការសរសេរ អាចធ្វើឲ្យអ្នកអានខ្លះដែលមានជីវិត រស់នៅខុសកន្លែងគ្នាពីអ្នកនិពន្ធ មានការលំបាកនឹងយល់ន័យរបស់

ពាក្យទាំងនោះ ។ បើសិនជាអាចធ្វើបាន អ្នកនិពន្ធគប្បីប្រើគ្រាម ភាសាអោយបានតិចបំផុត ព្រោះភាសាទាំងនោះមិនមែនជាភាសា ពិតប្រាកដរបស់ខ្មែរឡើយ គឺគ្រាន់តែជាភាសាកម្ចាយ ឬភាសាកម្ចី មកពីភាសារបស់ជាតិគេដទៃនានា តែប៉ុណ្ណោះ ។ ដូច្នេះយើងមិន គួរសម្រុតតម្លៃអក្សរសិល្ប៍របស់យើង ដោយសារការប្រើភាសា កម្ចាយ ឥតឬសឥតគល់ ទាំងនោះច្រើនពេកឡើយ ។

ជ. យោបល់ ៖

រួមសេចក្ដីមក អ្នកនិពន្ធខ្មែរទាំងអស់ដែលបានប្រឹងព្យាយាម សរសេរអត្ថបទ ជាភាសាខ្មែរសម្រាយដើមកំណើត ងាយអាន ងាយយល់ គឺជាពលរដ្ឋគម្រូយ៉ាងប្រសើរ ដែលបានរក្សាស្មារតីជា ខ្មែរ មនសិការជាខ្មែរ ដោយការប្រឹងថែរក្សាភាសារបស់ខ្លួនតាម រយៈសំណេរទាំងឡាយ ហើយក៏បានបំរើជាតិយ៉ាងពេញលក្ខណៈ មិនខុសពីបុគ្គលដែលមាននាទីដឹកនាំជាតិ ឬ យុទ្ធជនការពារជាតិ ទាំងឡាយនោះដែរ ។ មានន័យថា អ្នកនិពន្ធទាំងអស់នោះកំពុង តែបំរើជាតិយើង ការពារជាតិយើងមិនអោយរលាយទៅវិញ ដោយ ការថែរក្សានិងលើកដំកើងភាសាខ្មែរ អក្សរសាស្ត្រខ្មែរ អោយមាន សុពលភាព មានប្រសិទ្ធភាព និងមានឥទ្ធិពលលើសលប់នៅក្នុង ប្រទេស មិនអោយចាញ់ច្រាបភាសាបរទេសនានា ដែលខ្មែរយើង បានខ្ចី យកមកប្រើប្រាស់ពាសពេញមាតុភូមិនោះឡើយ ។

================================

**ភាសារលត់ ជាតិរលាយ**

**ភាសាពណ្ណរាយ ជាតិថ្កុំថ្កើង**

ភាសិតបុរាណ

=================================

=============================================

# ជំពូកទី២
# វេយ្យាករណ៍

=============================================

ក. និយមន័យ ៖

វេយ្យាករណ៍មានន័យថា ជាការណែនាំគោលសាស្ត្រ ឬមូលដ្ឋានភាសា ដើម្បីអត្ថាធិប្បាយពន្យល់សេចក្តីរបស់សាច់រឿងអោយបានត្រឹមត្រូវជាក់លាក់ មិនឲ្យច្របូកច្របល់គំនិតនិងការពន្យល់នានា ។

ខ. សារៈប្រយោជន៍របស់វេយ្យាករណ៍ ៖

ការដែលអ្នកនិពន្ធត្រូវរៀនស្គាល់ក៏រិតវេយ្យាករណ៍ច្បាស់លាស់ នោះនឹងធ្វើអោយសំណេររបស់អ្នកនិពន្ធមានអត្ថន័យនិងអត្ថរស
ពេញលក្ខណៈ ជាពិសេស គឺការសរសេរមានប្រធាន កិរិយាស័ព្ទនិងឃ្លោងឃ្លា មានដើមមានខ្លួន និងដៃជើងគ្រប់គ្រាន់សព្វអត្ថន័យជាពិសេសទៅទៀត គឺការរៀនដកឃ្លា ខ័ណ្ឌ និងចុះបន្ទាត់ ។ អ្នកនិពន្ធខ្មែរយើងខ្លះ ទម្លាប់សរសេរឃ្លាវែងៗ មិនដកឃ្លាសោះជួនមិនមានប្រធានឃ្លា ហើយភ្លេចមិនព្រមចុះបន្ទាត់អោយត្រូវនឹងដំណើរសាច់រឿងរបស់សំណេរ ។ ពោលគឺស្នេរចេះតែសរសេរបន្តៗតាមតែដំណើររហូតទៅ ដោយមិនអោយអ្នកអានដកដង្ហើម ដើម្បីស្រង់ការពន្យល់របស់អ្នកនិពន្ធឡើយ ។ ជួនកាល ប្រយោគខ្លះជាសាច់រឿងដែលត្រូវចុះបន្ទាត់ ធ្វើជាល្បះពីរផ្សេងគ្នា តែអ្នកនិពន្ធបែរជាចេះតែសរសេរបន្តរហូតដោយគ្មានខ័ណ្ឌ និងចុះបន្ទាត់សោះរហូតដល់ក្លាយជាល្បះមួយដ៏វែង ដែលមានអត្ថន័យរវាក់រវិនច្រើនសាច់រឿងជំពាក់គ្នាយ៉ាងរសាំងដូចសម្លកំពឹស ។ ជួនកាល ស្នេរខ្លះ

សរសេរឃ្លាពីរបីជាប់រដឹក រហូតដល់ទៅជាងដប់បន្ទាត់ឯណោះ ទើបនឹកឃើញដាក់ខណ្ឌមួយ ដើម្បីញែកឃ្លា ។

បើនិយាយអោយជាក់ស្តែងទៅ ការដែលយើងសរសេរឃ្លាប្រយោគវែងៗ មិនព្រមដកឃ្លា ឬដកឃ្លាខុសកន្លែង មិនមានប្រធានកិរិយា មិនមានខ័ណ្ឌ ឬចុះបន្ទាត់នោះ មិនមែនមានន័យថាយើងពូកែខាងសរសេរនោះទេ បើសិនជាការសរសេរនោះមិនមានប្រើវេយ្យាករណ៍អោយបានត្រឹមត្រូវ ។ មានន័យថា សំណេរបែបនោះ ជាភស្តុតាងបញ្ជាក់ថា សំណេររបស់យើងបង្កប់នូវភាពខ្ជីខ្ជានិងស្នាដៃទន់ខ្សោយរបស់អ្នកនិពន្ធ ខាងផ្នែកវេយ្យាករណ៍ នោះតែម្តង ។

ចំណែកឯស្នាដៃសំណេរដែលប្រសើរ ហើយមានប្រសិទ្ធភាពបំផុតនោះ គឺការសរសេរឃ្លាខ្លីល្មមៗ ច្បាស់លាស់ សមសាច់រឿងហើយមានការដកឃ្លាសំរាប់អោយអ្នកអានដកដង្ហើម ដើម្បីទទួលគំនិតពីអ្នកនិពន្ធតាមសម្រួល ដោយមិនបាច់អានត្របាញ់ជើង រកឃ្លាចប់មិនឃើញនោះឡើយ ។ ឯសញ្ញាខណ្ឌវិញមានសារៈសំខាន់ណាស់ ក្នុងការបញ្ចប់សេចក្តីរបស់ឃ្លាមួយ មុននឹងឈានទៅរកការបង្កើតឃ្លាថ្មីមួយទៀត ។ បើសិនសាច់រឿង ឬប្រធានបទផ្លាស់ប្តូរការសរសេរចុះបន្ទាត់ជាការប្រសើរបំផុត សំរាប់ចាប់ផ្តើមល្បះថ្មីដែលមានន័យឬសាច់រឿងដាច់ស្រឡះអំពីល្បះចាស់មុននោះ ។

បន្ថែមពីលើហ្នឹងទៀត អ្នកនិពន្ធត្រូវរៀនសង្កេតថា តើឃ្លារបស់ខ្លួននិមួយៗនោះ មានទំរង់ពេញលក្ខណៈដែរឬទេ ជាពិសេសគឺប្រធានរបស់ឃ្លានិងកិរិយាស័ព្ទ ដាច់ខាតត្រូវតែមានជានិច្ចក្នុងឃ្លានិមួយៗ ប្រៀបដូចជាមនុស្សដែលមានក្បាលនិងដងខ្លួនបែកពីគ្នាមិនបានដូច្នោះដែរ ។

*<u>ឧទាហរណ៍ទីមួយ</u> ៖ សូមសង្កេតការភ្លេចដកឃ្លា និងភ្លេចដាក់សញ្ញាខ័ណ្ឌបញ្ចប់ឃ្លា ។*

ពេលនោះពូបូរបានឃើញមីងណៃញញឹមឡើងយ៉ាងស្រស់បំព្រង ជាលើកដំបូងបំផុតតាំងពីគាត់បានស្គាល់មីងណៃ ថ្ងៃណាមកពូបូរមិនដែលឃើញគាត់ញញឹមស្រស់អញ្ចឹងម្តងណាឡើយការពិតមីងណៃមានវ័យ៤៥ឆ្នាំទៅហើយតែមីងនៅមាន លាក់គំនូចសោភ័ណធម្មជាតិមួយយ៉ាងត្រកាលក្រៃលែងបើនរណាបាននៅ ក្បែរមីងណៃមិនលែងអីគេនឹងបានទទួលនូវភាពកក់ក្តៅក្នុង ចិត្តខ្លះមិនខានឡើយត្បិតគាត់ជាមនុស្សមាន សទ្ធាមានទឹកចិត្តល្អមានសប្បុរទាប្រកបដោយការប្រឹងព្យាយាមជួយខ្លួន ដោយសតិបញ្ញាស្មារតីនិងកម្លាំងតស៊ូមិនរាថយចំពោះជីវិត ។

*ពេលនេះ បើយើងជាអ្នកអានវិញ តើយើងមានអារម្មណ៍យ៉ាងណាដែរ កាលបើល្បះទាំងមូលនេះ គ្មានខណ្ឌ័ ឬដកឃ្លាជាការញែកគំនិតអោយយើងបានយល់សាច់រឿងច្បាស់លាស់ ? តើយើងអាចយល់សាច់រឿងដោយមិនមានអារម្មណ៍សាំញ៉ាំក្នុងចិត្តទេ ? តើយើងត្រូវធ្វើយ៉ាងណាវិញ ដើម្បីកែប្រែអោយប្រយោគងាយអាន ងាយយល់ បើសិនជាយើងជាអ្នកនិពន្ធអត្ថបទនោះ ?*

*<u>ឧទាហរណ៍ទីពីរ</u> ៖ សូមសង្កេតមើលការដកឃ្លា និងការដាក់ខណ្ឌ័ ខុសកន្លែង ។*

ពេលនោះពូបូរបាន ឃើញមីងណៃញញឹម ឡើងយ៉ាងស្រស់បំព្រងជាលើកដំបូងបំផុត ។ តាំងពីគាត់បានស្គាល់មីងណៃថ្ងៃ ណា មក ពូបូរមិនដែលឃើញគាត់ញញឹមស្រស់ អញ្ចឹងម្តងណាឡើយ ។ ការពិតមីងណៃមានវ័យ៤៥ឆ្នាំទៅហើយតែមីងយើងនៅមានលាក់គំនូចសោភ័ណធម្មជាតិមួយយ៉ាងត្រកាលក្រៃលែង ។ បើនរណាបាននៅក្បែរមីងណៃ មិនលែងអីគេនឹងបាន ទទួលនូវភាពកក់ក្តៅក្នុងចិត្តខ្លះមិនខានឡើយ ។ ត្បិតគាត់ជាមនុស្សមានសទ្ធាមាន ទឹកចិត្ត ល្អ

មានសម្បទាប្រកបដោយការប្រឹងព្យាយាម ជួយខ្លួនដោយសតិបញ្ញាស្មារតីនិងកម្លាំង តស៊ូមិនរាថយចំពោះជីវិត ។

*តើអត្ថន័យរបស់ល្បះមួយនេះ ផ្លាស់ប្តូរយ៉ាងណាដែរ កាលបើអ្នកនិពន្ធដកឃ្លា ឬដាក់សញ្ញាខ័ណ្ឌនៅកណ្តាលឃ្លាបែបនេះ ? នៅឃ្លាទីបី ដែលចាប់ផ្តើមដោយពាក្យថា "ត្បិតគាត់ជា..." បើយើងអានឃ្លានោះតែម្នាក់ឯង តើឃ្លាមានន័យគ្រប់គ្រាន់ទេ ? បើមិនគ្រប់គ្រាន់ទេ តើគេសរសេរឃ្លានេះ ដើម្បីពន្យល់ឃ្លាណាមួយទៀត ? បើសិនយើងជាអ្នកនិពន្ធម្នាក់នោះ តើយើងនឹងកែសម្រួលឃ្លាយ៉ាងណាវិញដែរ ? ហេតុអ្វី ?*

*<u>ឧទាហរណ៍ទីបី</u> ៖ សូមសង្កេតការដកឃ្លានិងការដាក់ខ័ណ្ឌ ដើម្បីញែកឃ្លានិងគំនិតរបស់អ្នកនិពន្ធខាងក្រោមនេះ ។*

ពេលនោះ ពូបូរបានឃើញមីងណៃញញឹមឡើង យ៉ាងស្រស់ បំព្រងជាលើកដំបូងបំផុត ។ តាំងពីគាត់បានស្គាល់មីងណៃថ្ងៃណា មក ពូបូរមិនដែលឃើញគាត់ញញឹមស្រស់អញ្ចឹងម្តងណាឡើយ ។ ការពិត មីងណៃមានវ័យ៤៥ឆ្នាំទៅហើយ តែមីងនៅមានលាក់គំនួចសោភ័ណធម្មជាតិមួយយ៉ាងត្រកាលក្រៃលែង ។ បើនរណាបាននៅក្បែរមីងណៃ មិនលែងអីគេនឹងបានទទួលនូវភាពកក់ក្តៅក្នុងចិត្តខ្លះមិនខានឡើយ ត្បិតគាត់ជាមនុស្សមានសទ្ធា មានទឹកចិត្តល្អ មានសម្បទាប្រកបដោយការប្រឹងព្យាយាមជួយខ្លួន ដោយ សតិបញ្ញាស្មារតីនិងកម្លាំងតស៊ូមិនរាថយចំពោះជីវិត ។

*បន្ទាប់ពីបានយើងអានឧទាហរណ៍ទាំងបីខាងលើ តើយើងគិតថាសំណេរមួយណាមានអត្ថរសជាងគេ ? ហេតុអ្វីទៅ ? ក្នុងល្បះទាំងបី តើមួយណាមានវេយ្យាករណ៍ត្រឹមត្រូវជាងគេ ? ចម្លើយគឺល្បះទីបី ជាប្រយោគដែលមានការប្រើវេយ្យាករណ៍ត្រឹមត្រូវ ដោយការដកឃ្លានិងការដាក់សញ្ញាខ័ណ្ឌត្រូវកន្លែង ដោយរក្សាប្រយោគ*

ឲ្យមានន័យពេញលេញផង ដោយទុកឱកាសអោយអ្នកអានញែក គំនិត ញែកសាច់រឿងរបស់សំណេរយ៉ាងមានរបៀបផង ។

<u>ឧទាហរណ៍ទីបួន</u> ៖ សូមសង្កេតមើលកំហុសនៃការមិនចុះ បន្ទាត់ ឬចុះបន្ទាត់ខុសកន្លែង ។

ឆាយសៅថៃវទូកធ្វើដំណើរចេញទៅ ទុកអោយប្អូនស្រីឆៅឈរ មើលពីក្រោយទាំងដួងចិត្តសោកសៅឥតឧបមា ។

យូរៗម្តង ឆរៈលួចងាកក្រោយសម្លឹងប្អូនស្រី សំដៃងឆូវភាព អាលោះអាល័យក្នុងអារម្មណ៍ ហាក់បីមិឆចង់ឃ្លាតបត្តិចណាសោះ ឡើយ ។

៧ថ្ងៃក្រោយមក ឆាងស្ងួឆជាប្អូឆបាទទូលដំណឹងថា សៅ បាឆត្រូវរាជការចាប់ខ្លួឆឆៅឯរាជធាឆី ។

ឆរីស្រក់ទឹកភ្នែកប្រោក ឆឹកអណោចក្នុងចិត្ត អាណិតដល់បង ប្រុសដែលកំពុងជាប់ឃុំ មិឆដឹងថា ឆាយត្រូវទទួលរងទណ្ឌកម្ម អ្វីខ្លះ...

ឆៅឯពន្ធឆាគារវិញ សៅអង្គុយត្របោមជង្គង់ ឆឹកស្តាយ ដល់អតិតកាលដែលខ្លួឆបាឆប្រព្រឹត្តខុសព្រោះតែជឿសំដីទ្រុស្តមិត្ត ។

នៅទីនេះ អ្នកនិពន្ធចុះបន្ទាត់ខុសកាលវេលានៃសាច់រឿង ធ្វើ អោយអ្នកអាន អានហើយវង្វេងវេលា និងមូលហេតុ ។

<u>ឧទាហរណ៍ទី៥</u> ៖ សូមសង្កេតមើលការចុះបន្ទាត់ អោយត្រូវ តាមស្ថានការណ៍ ពេលវេលា និងសាច់រឿង ។

ឆាយសៅថៃវទូកធ្វើដំណើរចេញទៅ ទុកអោយប្អូនស្រីឆៅឈរ មើលពីក្រោយទាំងដួងចិត្តសោកសៅឥតឧបមា ។ យូរៗម្តង ឆរៈ លួចងាកក្រោយសម្លឹងប្អូនស្រី សំដៃងឆូវភាពអាលោះអាល័យ ក្នុង អារម្មណ៍ ហាក់បីមិឆចង់ឃ្លាតបត្តិចណាសោះឡើយ ។

៧ថ្ងៃក្រោយមក ឆាងស្ងួឆជាប្អូឆបាឆទទួលដំណឹងថា សៅបាឆ ត្រូវរាជការចាប់ខ្លួឆឆៅឯរាជធាឆី ។ ឆរីស្រក់ទឹកភ្នែកប្រោក ឆឹក អណោចក្នុងចិត្ត អាណិតដល់បងប្រុសដែលកំពុងជាប់ឃុំ មិឆដឹង ថា ឆាយត្រូវទទួលរងទណ្ឌកម្មអ្វីខ្លះ...

នៅឯពន្ធនាគារវិញ សៅអង្គុយត្របោមជង្គង់ នឹកស្តាយដល់ អតីតកាល ដែលខ្លួនបានប្រព្រឹត្តខុស ព្រោះតែលង់សំដីបោកប្រាស របស់ទុស្តមិត្ត ។

*នៅក្នុងឧទាហរណ៍ខាងលើនេះ អ្នកអានពិតជាបានសាច់រឿង យ៉ាងស្រឡះចិត្ត ព្រោះឃ្លោងឃ្លានិងល្បះនិមួយៗបានញែកដាច់ សាច់រឿងនិងកាលវេលាជាក់ច្បាស់ មិនជំពាក់ជំពាន់ ។*

*ត្រិះរិះ* ៖

*ចំពោះឧទាហរណ៍បែបខាងលើ តើអ្នកនិពន្ធមួយណា ប្រើ កំរិតវេយ្យាករណ៍ត្រឹមត្រូវជាងគេ ? ហេតុអ្វី ? បើរូបអ្នក ជាអ្នក និពន្ធវិញ តើអ្នកគួរកែសម្រួលប្រយោគខាងលើនេះ បែបណា វិញ ? ហេតុអ្វី ? តើការសរសេរដោយខ្វះក្បួនខ្នាត វេយ្យាករណ៍ បែបនោះ ធ្វើអោយអត្ថន័យនិងអត្ថរសរបស់សំណេរ ផ្លាស់ប្តូរយ៉ាង ណាដែរ ?*

*គ. វេយ្យាករណ៍ឆ្លងវប្បធម៌* ៖

*ចំណុចខ្សោយមួយទៀត ដែលយើងតែងតែសង្កេតឃើញជា ញឹកញាប់បំផុតនៅក្នុងសំណេររបស់អ្នកនិពន្ធខ្មែរយើងខ្លះនោះ គឺ ការសរសេរចម្លងបែបបទ(ស្ទីល)ពីវប្បធម៌បរទេស អ៊ឺរ៉ុបនិយម ឬអាមេរិកនិយម ដូចជាភាសាបារាំង ឬ អង់គ្លេស ជាដើម ដែល ជាហេតុធ្វើអោយអ្នកអានខ្មែរ ដែលមិនស្គាល់វប្បធម៌បរទេស វង្វេងនឹងគំនិតរបស់អត្ថបទទាំងឡាយនោះ ។*

*ឧទាហរណ៍ទី១* ៖ *ប្រយោគតាមលក្ខណៈឆ្លងវប្បធម៌ បារាំង ឬ អង់គ្លេស*

ក្រឡេកមើលទៅសង្គមខ្មែរសព្វថ្ងៃ ភាពច្របូកច្របល់ផ្នែក នយោបាយ ផ្នែកសង្គមធម៌ និងផ្នែកសីលធម៌ត្រូវបានមើលឃើញ យ៉ាងច្បាស់ក្រឡែត ។

*នៅក្នុងប្រយោគខាងលើ យើងសូមសួរថា តើនរណាជាអ្នក ក្រឡេកមើលសង្គមខ្មែរ ហើយផ្នែកសីលធម៌ត្រូវបានឃើញដោយ*

នរណាដែរ ? ក្នុងប្រយោគនោះ អ្នកនិពន្ធមិនមានសរសេរប្រាប់អោយយើងបានដឹងឡើយ ។

<u>ឧទាហរណ៍ទី២</u> ៖ ប្រយោគបែបលក្ខណៈវេយ្យាករណ៍ និងវប្បធម៌របស់ខ្មែរ

បើសិនជាយើងក្រឡេកមើលទៅសង្គមខ្មែរសព្វថ្ងៃ យើងនឹងប្រទះឃើញនូវភាពច្របូកច្របល់ផ្នែកនយោបាយ ផ្នែកសង្គមធម៌ និងផ្នែកសីលធម៌ យ៉ាងច្បាស់ក្រឡែត...

នៅក្នុងប្រយោគខាងលើនេះ អ្នកនិពន្ធមានបញ្ជាក់អំពីអ្នកដែលក្រឡេកមើលនិងអ្នកដែលឃើញ មានន័យថាឃ្លារបស់គេមានប្រធានរបស់ឃ្លា ត្រឹមត្រូវតាមក្បួនខ្នាតវេយ្យាករណ៍ខ្មែរពិត ។

<u>ឃ. ការប្រើខណ្ឌ័សញ្ញា ( ។) បុច្ឆនសញ្ញា ( ?) ឧទាន សញ្ញា (!) និងបរិយោសានត្ត ( ។ល៕) </u>៖

តាមធម្មតា ឃ្លាប្រយោគនិមួយៗ ត្រូវបញ្ចប់ដោយសញ្ញាខ័ណ្ឌ ( ។) ជានិច្ច ។ ប៉ុន្តែ ចំពោះឃ្លាប្រយោគដែលបញ្ជាក់ពីភាពភ្ញាក់ផ្អើល រន្ធត់តក់ស្លុត លាន់មាត់ ពាក្យស្រែកបញ្ជា ពាក្យស្រែកឆ្លើយតប នោះគេច្រើនបញ្ចប់ឃ្លាដោយឧទានសញ្ញា (!) ។ ចំពោះប្រយោគដែលជាសំណួរឬជាចម្លល់វិញ គេបញ្ចប់ដោយបុច្ឆនសញ្ញា ( ?) ។ ពេលនោះ ស្មេរត្រូវចងចាំថា កាលបើខ្លួនបញ្ចប់ឃ្លាដោយបុច្ឆនសញ្ញា ( ?) ឬក៏ឧទានសញ្ញា (!) ហើយ គេមិនចាំបាច់ប្រើសញ្ញាខណ្ឌ័ ( ។) សំរាប់បញ្ចប់ឃ្លា បន្ថែមពីលើ មួយជាន់ទៀតទេ ។

<u>ឧទាហរណ៍</u> ៖

១. យីអើសម្លាញ់ !យើងមិនដែលជួបគ្នាសោះ ជាងបីឆ្នាំហើយ ! ។
២. យីអើសម្លាញ់ ! យើងមិនដែលជួបគ្នាសោះ ជាងបីឆ្នាំហើយ !
៣. នែ៎ ! បើឯងខ្ជិលធ្វើការយ៉ាងនេះ តើបានអ្វីចិញ្ចឹមពោះ ? ។

៤. នែ៎ ! បើឯងខ្ជិលធ្វើការយ៉ាងនេះ តើបានអ្វីចិញ្ចឹមពោះ ?

<u>*សូមចំណាំ*</u> ៖

*បុច្ឆនសញ្ញា( ?) និងឧទានសញ្ញា( !)អាច បញ្ចប់ឃ្លាដូចជាសញ្ញាខណ្ឌដែរ ។ យើងមិនចាំបាច់ដាក់សញ្ញាខណ្ឌ បន្ថែមពីលើទៀត ដើម្បីបញ្ចប់ឃ្លាឡើយ ។*

*រីឯបរិយោសានសព្ទ ( ។៚) វិញ គេប្រើសំរាប់ទីអវសាននៃសាច់រឿង តែម្យ៉ាងប៉ុណ្ណោះ ។*

<u>*ង. ការចងក្រងឃ្លា ប្រយោគ ល្បះ និង វគ្គឬជំពូក*</u> ៖

<u>*ង១. ឃ្លាពេញលក្ខណ:*</u> ៖

*ឃ្លាជាការប្រមូលផ្តុំរបស់ពាក្យ ដែលមានរួមទាំង ប្រធាន* (sujet) *កិរិយាសព្ទ* (verbe) *និង កម្ម* (complément) *ដើម្បីអោយកើតជាអត្ថន័យ មានក្បាល ដងខ្លួន អវយវ: គ្រប់លក្ខណ: ពោលគឺ ឃ្លានោះមានន័យគ្រប់គ្រាន់ ។*

<u>*ឧទាហរណ៍*</u> ៖

ឆាយសៅមិនបានទៅធ្វើការទេ ។

*ប្រយោគនេះមានន័យនិងលក្ខណ:ឃ្លាគ្រប់គ្រាន់ ។*

<u>*ង២. កំណាត់ឃ្លា*</u> ៖

*នេះគឺជាប្រយោគដែលផ្អែកលើឃ្លាមួយទៀត អោយមកជួយបំពេញអត្ថន័យឃ្លាអោយបានគ្រប់គ្រាន់ ។*

<u>*ឧទាហរណ៍*</u> ៖

ត្បិតមានជំងឺជាងបីខែហើយ ។

*កំណាត់ឃ្លាខាងលើនេះ មិនមានន័យគ្រប់គ្រាន់ទេ ព្រោះបាត់ឃ្លាបង្អែក ។ ទាល់តែយើងដាក់ឃ្លាបង្អែកបន្ថែម ទើបកំណាត់ឃ្លាមួយនេះមានន័យគ្រប់គ្រាន់ បើមិនដូច្នោះទេ អ្នកអានពិតជាមិនដឹងថា តើនរណាមានជំងឺបីខែហើយនោះឡើយ ។*

<u>ឧទាហរណ៍</u> ៖

ឆាយសៅមិនបានទៅធ្វើការទេ ត្បិតមានជំងឺជាងបីខែហើយ ។

*ពេលនេះ យើងអាចយល់បានហើយថា តើមួយណាជា កំណាត់ឃ្លា ហើយមួយណាជាឃ្លាបង្អែក ។ សូមកត់សំគាល់ថា ឃ្លាបង្អែកជាឃ្លាដែលមានលក្ខណៈឯករាជ្យ អាចបង្ហាញអត្ថន័យគ្រប់គ្រាន់ដោយមិនបាច់ពឹងផ្អែកកំណាត់ឃ្លា អោយមកជួយពន្យល់ឡើយ ។*

<u>*ង៣. ប្រយោគ*</u> ៖

*នោះគឺជាការចងក្រងឃ្លាវែងៗ ដែលមានយកកំណាត់ឃ្លាជាច្រើនមករួមបញ្ចូលឃ្លា អោយមានអត្ថន័យនិងអត្ថរសថែមទៀត ។*

<u>ឧទាហរណ៍</u> ៖

បើនរណាបាននៅក្បែរមីងណៃ មិនលែងអីគេនឹងបានទទួលនូវភាពកក់ក្ដៅក្នុងចិត្តខ្លះមិនខានឡើយ ត្បិតគាត់ជាមនុស្សមាន សទ្ធាមានទឹកចិត្តល្អ មានសម្បទាប្រកបដោយការប្រឹងព្យាយាម ជួយខ្លួនឯងដោយសតិបញ្ញាស្មារតី និងកម្លាំងតស៊ូមិនរាថយ ចំពោះជីវិត ។

<u>*ង៤. ល្បះ ឬល្បះខ័ណ្ឌ*</u> ៖

*ការរួមផ្សំរបស់ឃ្លានិងប្រយោគជាច្រើន ដែលបរិយាយពីស្ថានការណ៍រួមគ្នា ពេលវេលារួមគ្នា ឬ សាច់រឿងតែមួយ ។*

<u>ឧទាហរណ៍</u> ៖

មីងណៃក៏ដឹកដៃចៅស្រីដើរមកដល់មុំវត្តបាឡាត់ ដើម្បីដើរសួររកមិត្តភក្ដិដែលធ្លាប់ស្គាល់គ្នា ស្រាប់តែមានគេប្រាប់ថា ក្រុមគ្រួសារ នោះត្រូវអង្គការខ្មែរក្រហមប្រមូលយកទាំងពូជ តាំងពីឆ្នាំ១៩៧៥ នោះម្ល៉េះ ។ មីងយើងក៏រសេះរសោះដៃជើងមួយរំពេច កាលបើបាន ឮដូច្នោះ ។ លុះឈរវេរាមួយស្របក់មិនដឹងទៅណាទៀត មីងក៏សំរេចចិត្តដើរចូលទៅក្នុងវត្តបាឡាត់ដើម្បីរកកន្លែងសំណាក់ ។ ចៃដន្យ នៅទី នោះមិនទាន់មានព្រះសង្ឃគ្រងផ្នួសនៅឡើយទេ មានតែអ្នកដំណើរជាច្រើននាក់រត់ចូលទីនោះរកជំរូលជ្រកប៉ុណ្ណោះ ។ ដោយ

សារមីងណៃមកដល់ក្រោយគេ គាត់ក៏រកកន្លែងជ្រកមិនបាន ទើបគាត់នាំចៅស្រីទៅចូលជ្រកនៅសំយាបកុដិចាស់មួយ ។ មីងកំសត់របស់យើងបានដើររើសធាងដូងងាប់ពីរបីធាង ដើម្បីយកមកបាំងជាជីបូលបណ្តោះអាសន្ន ។

មួយស្របក់ក្រោយមក គាត់ក៏ដណ្តាំបបរបញ្ចុកចៅស្រី ។ មីងណៃធ្វើបណ្តើរ លួចសម្រក់ទឹកភ្នែកបណ្តើរ នឹកអាណិតខ្លួនដែលត្រូវមករងកំសត់វេទនាយ៉ាងត្រមង់ត្រមោចពីរនាក់ចៅស្រី ។

កំពុងតែនាំចៅ បរិភោគ ស្រាប់តែមានភ្លៀងមកយ៉ាងខ្លាំងហាក់ដូចជាភ្លៀងមេ កក់ ផ្កាស្វាយដ៏ធំមួយ ។ រន្ទះផ្នែងឆ្វាត់ហោះកាត់ស្បែមេឃ បង្កជាផ្គរលាន់ យ៉ាងគ្រាំគ្រេងគ្គររន្ធត់ ហាក់ដូចជាកំពុងសម្លុតស្មារតីមីងណៃនិង ចៅស្រីអោយរឹងរិតតែតក់ស្លុតកាន់តែខ្លាំងឡើងៗ ។

*បីល្បះខាងលើនេះ បង្ហាញនូវស្ថានការណ៍ដែលបញ្ជាក់សាច់រឿងខុសៗគ្នា ។ ល្បះទីមួយនិយាយអំពីដំណើរតាមរកមិត្តភក្តិ ។ ឯល្បះទីពីរ បង្ហាញនូវទីកន្លែងដែលមីងណៃជ្រក ។ ចំណែកល្បះទីបីបរិយាយអំពីស្ថានភាពនិងអារម្មណ៍របស់តួអង្គ ។ ដូច្នេះស្មេរត្រូវចេះបណ្តាច់ល្បះរបស់ខ្លួន យោងទៅតាមស្ថានការណ៍ សាច់រឿង និងអារម្មណ៍របស់តួអង្គ អោយដាច់ពីគ្នា ។ ការសរសេរមានរបៀប តាមលក្ខណ:វេយ្យាករណ៍ត្រឹមត្រូវ នឹងធ្វើអោយអ្នកអានឆាប់យល់ ហើយក៏មានត្រេកចង់អានដោយមិនធុញទ្រាន់ មិនខុសពីការរៀបផ្ទះអោយរៀបរយ ដែលទាក់ទាញចិត្តមនុស្សអោយចង់ស្នាក់នៅមិនជិនណាយដូច្នោះឯង ។*

*<u>ង៥. វគ្គឬជំពូក</u> ៖*

*វគ្គឬជំពូកជាការចងក្រងចំនួនល្បះជាច្រើន ដែលបរិយាយពីសាច់រឿងតែមួយរួមគ្នា ។ វគ្គនិមួយៗអាចមានប្រវែងវែងពីមួយ*

ទំព័រទៅច្រើនទំព័រ តែមិនអាចអោយអោយវែងអន្លាយខ្លាំង ពេក ព្រោះអាចធ្វើអ្នកអានវង្វេងនឹងដម្រៅគតិរបស់សាច់រឿង ។

ដើម្បី កត់ចំណាំនូវគតិ ឆន្ទៈ ឬអត្ថន័យរបស់សាច់រឿងនៃ ជំពូកនិមួយៗ អ្នកនិពន្ធភាគច្រើន និយមដាក់ចំណងជើងអោយ ជំពូកនោះទៀត ជាចំណងជើងតូចៗខ្លី ងាយអោយអ្នកអានឆាប់ យល់ ឬក៏អាចបង្កចម្ងល់ អោយអ្នកអានកាន់តែចង់ដឹងសាច់រឿង ហើយចង់អានបន្តៗ ទៅទៀតមិនចង់ឈប់ ។

វគ្គឬជំពូកជាការពូតផ្គុំសាច់រឿងតូចមួយ នៅក្នុងសាច់រឿងធំ របស់សៀវភៅមួយក្បាល មានន័យថា សៀវភៅរឿងមួយក្បាល គឺជាការប្រមូលចំនួនវគ្គជាច្រើនបញ្ចូលគ្នា រួមទាំងវគ្គដែលមានចង គំនួចអាឋិកំបាំងឬប្រស្នារបស់សាច់រឿង និងវគ្គទាំងឡាយទៀត ដែលមានការដោះស្រាយចំណោទប្រស្នាអាឋិកំបាំងទាំងអស់នោះ ។

ដូច្នេះ នៅក្នុងអត្ថបទមួយប្រធាន ឬសាច់រឿង មួយរឿង គេតែង សរសេរចែកអោយមានជាច្រើនវគ្គ ។ រួចនៅក្នុងមួយវគ្គតែងមាន ច្រើនល្បះ ។ ក្នុងមួយល្បះមានច្រើនឃ្លា ឬប្រយោគ ហើយក្នុង មួយប្រយោគមានបង្អែកឃ្លា និងកំណាត់ឃ្លាជាច្រើនរួមគ្នា ។ នៅ ក្នុងឃ្លានិមួយៗនោះសោត ក៏ត្រូវមានការប្រើអក្ខរាវិរុទ្ធ អោយបាន ត្រឹមត្រូវប្រពៃទៀតផង ដើម្បីអោយសាច់រឿងមានខ្លឹមសារនិង អត្ថន័យទូលំទូលាយគួរសណ្ដាប់ ។

=======================================

========================================

# ជំពូកទី៣
# អំពីទំរង់ និង
# បែបបទនិពន្ធ

========================================

ក. ទំរង់និពន្ធ ៖

ការនិពន្ធដែលមានប្រសិទ្ធភាព ពឹងផ្អែកទៅលើមូលដ្ឋានធំៗ បីយ៉ាង គឺ ផ្ដើមសេចក្ដី តួសេចក្ដី និង បញ្ចប់សេចក្ដី ។ មូលដ្ឋានទាំងបីនេះជាប់ទាក់ទងគ្នាជានិច្ចមិនអាចកាត់ផ្ដាច់បានទេ ។ បើកាលណាការសរសេររបស់យើងខ្វះមូលដ្ឋានណាមួយក្នុងចំណោមទាំងបីនេះ នោះសំណេររបស់យើងនឹងក្លាយជាសំណេរពិការ ពោលគឺមិនខុសអ្វីពីមនុស្សដែលមានមានក្បាល ដងខ្លួន តែខ្វះ អវយវៈមិនគ្រប់គ្រាន់នោះឡើយ ។

ក១. អំពី ផ្ដើមសេចក្ដី ៖

អ្នកនិពន្ធនិមួយៗត្រូវរៀនប្រើសន្ទេហវិធីប្លែកៗ ដើម្បីយកមកសរសេរនៅក្នុងសេចក្ដីផ្ដើមរបស់សំណេរ ពោលគឺការសរសេរដើម្បីបង្កើនចម្ងល់និងក្ដីសង្ស័យរបស់អ្នកអាន អោយគេនឹកត្រេកត្រអាល ចង់តាមដានសាច់រឿងនៅក្នុងតួសេចក្ដីរបស់យើង ដោយអន្ទះសាក្នុងចិត្ត ។ នៅក្នុងសេចក្ដីផ្ដើមនេះ អ្នកនិពន្ធត្រូវចេះចងគំនួចសាច់រឿង ដែលជាឫសគល់ ឬមូលដ្ឋានរបស់តួរឿងទាំងមូល ។

ឧទាហរណ៍ ៖

ឆាយសោជាមនុស្សដែលពិសេសគួរស្រករបំផុត ។ ឆរៈមិនដែលសម្លឹងនារីណាម្នាក់ក្នុងភូមិអោយចំភ្នែកឡើយ ត្បិតគេគិតថា នារី

ទាំងនោះគ្មានលក្ខណៈគ្រប់គ្រាន់ជាភរិយារបស់គេ ។ គេជាមនុស្ស ប្រកាន់ចរិតឆ្មើងឆ្មៃ មិនស្រដីលេងឡេះឡោះ ជាមួយនរណា ឡើយ ។ ស្រាប់តែថ្ងៃមួយនោះ អ្នកស្រុកអ្នកភូមិបានទទួលសំបុត្រ អញ្ជើញពីនាយសៅ គ្រប់ៗគ្នា អោយទៅចូលរួមពីធីមង្គលការ របស់នាយ ។

*នៅសំណេរខាងលើ អ្នកនិពន្ធបានបង្កើតចម្ងល់ដល់អ្នកអាន អោយមានចំណង់ចង់ដឹងថា នារីនោះជានរណា មានចរិតលក្ខណៈ វិសេសយ៉ាងណា ដែលធ្វើអោយនាយសៅរំដើបរំជួលចិត្ត រហូត ដល់ចូលស្តីដណ្តឹងរួបនាងរៀបការជាភរិយា ។ ដូច្នេះ អ្នកអានទាំង ឡាយប្រាកដជាមានចិត្តតាមអានសាច់រឿងជាបន្ត ដើម្បីជំរះនូវ ចម្ងល់នេះ ។ នៅពេលនោះហើយដែលអ្នកនិពន្ធត្រូវរកសន្ទេហវិធី ថ្មីមួយទៀត ដែលអាចបកស្រាយចម្ងល់នៅក្នុងតួសេចក្តីអោយបាន ស្រឡះផង រួចចងចម្ងល់ក្នុងរឿងបន្ថែមខ្លះទៀតផង ដើម្បីអោយ សំណេរនិពន្ធប្រទាក់ក្រឡាសាច់រឿងកាន់តែអាថ៌កំបាំង មុននឹងអ្នក និពន្ធសរសេរបំភ្លឺដំណោះស្រាយជំរះចម្ងល់ដាច់ស្រេច នៅទីបញ្ចប់ នៃរឿង ។*

*<u>ក២. តួសេចក្តី</u>* ៖

*នៅទីនេះ អ្នកនិពន្ធត្រូវពណ៌នាសាច់រឿងដែលឆ្លើយទៅនឹង គំនួចដែលស្មេរខ្លួនឯងបានចងទុកនៅក្នុងផ្តើមសេចក្តី ដើម្បីជំរះ ចម្ងល់អ្នកអាន ហើយអាចប្រើសន្ទេហវិធី ដើម្បីបង្កចម្ងល់ជាបន្តៗ ទៅទៀតរហូតដល់ដោះស្រាយអស់សាច់រឿង ។ ជាពិសេសបំផុត តួសេចក្តីនេះ ត្រូវតែជាប្រភពលាក់ខ្លឹមសារ និងអត្ថន័យរបស់ សាច់រឿង ជាទីបំផុត ហើយជាប្រភពដែលអ្នកនិពន្ធត្រូវបង្ហាញ នូវស្នាដៃវិភាគរបស់ខ្លួន ចំពោះគំនិតរបស់សាច់រឿង យ៉ាងប៉ិន ប្រសប់ដែរ ។*

*<u>ឧទាហរណ៍</u>* ៖

មនុស្សម្នាទាំងភូមិនាំគ្នាតែងខ្លួន ដើរក្លុកហៅបបួលគ្នាទៅចូលរួមពិធីមង្គលការរបស់នាយសៅយ៉ាងគគ្រឹកគគ្រេង ។ នៅពេលពួកគេបានមកដល់ចំពោះមុខរោងការភ្លាម ក៏ប្រទះនារីម្នាក់មួយរូបមានទឹកមុខក្រៀមៗ ទទ្ទូរក្រមា ស្លៀកសម្លៀកក្រុំក្រទុំរគត កំពុងរត់ចេញពីផ្ទះនោះយ៉ាងរហ័ស ។ រីឯមនុស្សម្នាដែលជាម្ចាស់ផ្ទះវិញក៏ហាក់ដូចជាមិនបានឃើញ ឬចាប់ភ្លឹកអំពីនារីនោះអ្វីបន្តិចសោះ ។ ពួកគេឆ្ងល់ណាស់តើនាងជានរណាទៅ ? ហេតុអ្វីបានជានាងឆ្លេឆ្លារត់គេចទៅយ៉ាងរហន់យ៉ាងនេះ ?

រំពេចនោះ ឪពុកម្ដាយនាយសៅចេញមកទទួលភ្ញៀវ ហើយក៏អញ្ជើញពួកគេឡើងចូលទៅក្នុងផ្ទះ ដែលមានការតុបតែងយ៉ាងប្រណិតគួរអោយចាប់ចេតនា ។ វង់ភ្លេងប្រពៃណីក៏ប្រគំបទភ្លេង ការយ៉ាងរន្ថើនអង្រួនដួងចិត្តមនុស្សម្នាទាំងឡាយអោយត្រេកត្រអាលរីករាយចំពោះថ្ងៃមហោឡារិកនេះ ។ បន្តិចមក ស្នូរឃ្មោះលាន់ឮរំពងឡើងយ៉ាងខ្លាំង ។ វាំងននបើកហើយ… ទាំងកូន កម្លោះទាំងមេបាចាស់ទុំ និងភ្ញៀវទាំងឡាយ នាំគ្នាងាកកបែររកមើលតួអង្គកូនក្រមុំដែលបំរុងនឹងលេចខ្លួនមក ។ ចៃដន្យ ស្នូរឃ្មោះលាន់សូរបីដង បួនដង ច្រើនដងបន្ថែមទៀត ប៉ុន្តែ គេនៅតែមិនឃើញកូនក្រមុំចេញមុខមកសោះ ។ អ្នកទាំងឡាយក៏មើលមុខគ្នាសម្តែងភាពអន្ទះសានិងងឿងឆ្ងល់បំផុត ។

បន្តិចមក ស្រាប់តែមានលាន់ឮសំរែកស្រែកឆោឡោឡើងថាកូនក្រមុំកំពុងដួលដេកសន្លប់លើគ្រែក្នុងបន្ទប់…

*(សាច់រឿងក៏ចេះតែមានបន្តទៅរហូតដល់ចប់ ដែលនាយសៅត្រូវបានរៀបការជាមួយនាងសុក្រជាគូជីវិត)*

*នៅក្នុងតួសេចក្ដីនេះ អ្នកនិពន្ធបានចងគំនួចរឿងបន្ថែមទៀតគឺនារីដែលទទ្ទូរក្រមារត់គេចពីរោងការទៅ នៅពេលដែលអ្នកអានកំពុងចង់ស្គាល់តួអង្គកូនក្រមុំ ។ ពេលនេះ អ្នកអានច្បាស់ជានឹកសង្ស័យថានារីនោះជាកូនក្រមុំ ឬក៏ជានរណាម្នាក់ផ្សេងទៀត ហើយ*

ក៏នឹកឆ្ងល់ថា តើហេតុអ្វីនាងរត់ចេញពីផ្ទះការនោះ ? បន្ទាប់មក ស្មេរក៏នាំអ្នកអាន អោយទៅជួបកូនក្រមុំដែលកំពុងដេកសន្លប់ក្នុង បន្ទប់ ក្នុងឱកាសដែលឃ្មោះការលាន់រន្លើន បើកវាំងននហៅនាង ចូលផ្ទឹម ។ ក្នុងខណៈថ្មីនេះ អ្នកអានច្បាស់ជាកើតមានចម្ងល់ថ្មីថា តើហេតុអ្វីកូនក្រមុំនោះបែរជាមកដួលដេកសន្លប់លើគ្រែ នៅពេល ដែលនាងត្រូវចេញមកផ្ទឹមជាមួយនាយសៅយ៉ាងដូច្នោះ ហើយតើ នារីដែលរត់ចេញទៅក្រៅអំបាញ់មិញនោះជានរណាដែរ ? ដូច្នេះ អ្នកអានពិតជាមានចិត្តអន្ទះសាចង់ដឹងថា តើអ្នកនិពន្ធនឹងស្រាយ សាច់រឿងរបស់ខ្លួនយ៉ាងណាតទៅទៀត ?

សន្ទុះហាវិធីបែបខាងលើនេះ ជារបៀបទាក់ទាញអារម្មណ៍អ្នក អាន អោយកាន់តែយន់អារម្មណ៍ជ្រៅទៅក្នុងចម្ងល់ ចង់ដឹងពី ហេតុការណ៍អាថ៌កំបាំងទាំងនោះ រួចហើយត្រូវតែបើកទំព័រអាន តាមដានសម្រាយចម្ងល់របស់គេជាបន្តទៅទៀត មិនឈប់ឈរ ។ ពេលនោះឯងហើយ ដែលអ្នកនិពន្ធត្រូវសរសេរបញ្ចេញសាច់រឿង ល្អៗ ជាបន្តៗទៅទៀត ដោយមានលាក់អាថ៌កំបាំងថែមទៀតខ្លះ ស្រាយចេញខ្លះ តៗគ្នា រហូតដល់ចប់សាច់រឿង ដើម្បីនាំអ្នកអាន អោយកាន់តែត្រេកត្រអាលនឹងអ្វីដែលជាអាថ៌កំបាំងផង ហើយមាន ចិត្តសោមនស្សរីករាយចំពោះលទ្ធផល ដែលអ្នកនិពន្ធកំពុងដោះ ស្រាយគំនួចសាច់រឿងជាបន្តៗ ថែមទៀតផង ។

<u>ក៣. បញ្ចប់សេចក្តី</u> ៖

នៅក្នុងវគ្គបញ្ចប់សេចក្តី អ្នកនិពន្ធត្រូវសង្ខេបគតិរបស់រឿង ផង ផ្តល់មតិយោបល់របស់អ្នកនិពន្ធផង ជូនក៏ទាមទារអោយអ្នក អានចូលរួមធ្វើការសន្និដ្ឋានជាមួយស្មេរផង តាមដែលគេចូលចិត្ត ។ សាច់រឿងដែលមានខ្លឹមសារបំផុត គឺនៅទីបញ្ចប់នេះហើយ ព្រោះ អីពេលនេះ អ្នកអាននឹងបានដឹងថា ស្មេរបញ្ចប់រឿងដោយឆន្ទៈ

*របៀបណា ហើយឆន្ទៈនោះនាំអ្នកអានអោយយល់ឃើញនូវសារប្រយោជន៍សំរាប់ខ្លួនគេអ្នកអាន បន្ទាប់ពីគេបិទសៀវភៅទៅ ។*

*ឧទាហរណ៍* ៖

ពិតមែនតែនាងសុក្រមានរូបរាងសោភ័ណ មិនជាស្រស់ស្អាត យ៉ាងណាក៏ដោយ ក៏មាណវីយើង មានលាក់គំនូចសោភ័ណយ៉ាងស្រស់ត្រកាលមួយដែលនាយសៅប្រកែកមិនទទួលមិនបាន នោះគឺសន្តានចិត្តដ៏ល្អប្រពៃ និងមនសិការរបស់នាងតែម្តង ។ បើសិនជាមិនបានរូបនាងជ្រោមជ្រែងទាំងកម្លាំងកាយចិត្តទេនោះ ពេលនេះម៉្លេះសមនាយសៅ ក្លាយខ្លួនជាបុរសចិត្តប្រេត ដោយសារការ ប្រមាថស្រីៗ និងការមិនគោរពម្តាយ ដោយអាងខ្លួនជាអ្នករកទ្រព្យ ផ្គត់ផ្គង់គ្រួសារតាំងពីឪពុករបស់ខ្លួនអនិច្ចកម្មទៅ ។ ចៃដន្យ នាងសុក្របានយកភាពទន់ភ្លន់របស់នាង មកបំបែកភាពចចេសរឹងរូសរបស់សៅបាន ហើយថែមទាំងនាំអោយសៅបែរមកទទួលស្គាល់ម្តាយរបស់នាយវិញដោយសេចក្តីគោរពពេញបេះដូង ។ នេះហើយជាតម្លៃនៃឧត្តមភរិយា ។ ចាប់ពីពេលនេះតទៅ នាយសៅនិងក្រុមគ្រួសារនឹងបានប្រទះតែសុភមង្គលរៀងរហូតរៀងទៅ ។ ប៉ុន្តែ... តើយើងអាចទុកចិត្តបានទេ ថានាយសៅនឹងឈប់វាយឫកពីរសអើងឆ្មើងកន្ត្រើងតទៅទៀត ?...

*នៅក្នុងសាច់រឿងបញ្ចប់សេចក្តីនេះ អ្នកនិពន្ធបានបង្ហាញនូវឆន្ទៈរបស់សាច់រឿង គឺភាពទន់ភ្លន់ សន្តានចិត្តប្រពៃ និងមនសិការដ៏ខ្ពង់ខ្ពស់របស់នាងសុក្រ បានធ្វើអោយនាយសៅផ្លាស់ប្តូរមារយាទរបស់ខ្លួនមកល្អវិញ ។ ពេលនេះ អ្នកនិពន្ធបានបង្ហើមសេចក្តីសន្និដ្ឋានថា នាយសៅនិងក្រុមគ្រួសារប្រាកដជានឹងបានជួបនូវសេចក្តីសុខសុភមង្គលមិនខាន ព្រោះតែនាងសុក្រជាឧត្តមភរិយា ។ ព្រមជាមួយគ្នានេះដែរ ស្មេរក៏បានបន្ថែមប្រយោគចុងក្រោយ ដោយអញ្ជើញអ្នកអានមកជួយគិត ហើយជួយបញ្ចេញមតិរបស់ខ្លួន ចំពោះសាច់រឿងមួយនេះនៅពេលគេបិទសៀវភៅទៅ*

ថាតើនាយសៅនឹងកែខ្លួនតរៀងទៅឬយ៉ាងណា ។ តើគុណសម្បត្តិរបស់នាងសុក្រនឹងមានប្រសិទ្ធិភាពលើនាយសៅ រហូតដែរឬទេ ? ការសរសេររបៀបនេះ គឺជាសន្ទេហវិធី ដែលនាំអោយអ្នកអានគិតពិចារណាអំពីសាច់រឿងផង ហើយគិតរកមធ្យោបាយឆ្លើយតបទៅសាច់រឿងវិញផង នៅពេលគេបានអានចប់សេចក្តីហើយ ។

<u>ក៨. យោបល់</u> ៖

អត្ថរសរបស់សំណេរ ដែលមានប្រសិទ្ធិភាពនេះជាងគេបំផុតនោះ គឺការបញ្ចេញឆន្ទៈ គំហើញ និងយោបល់របស់ស្មេរនៅក្នុងបញ្ចប់សេចក្តី ចំពោះសាច់រឿងដែលអ្នកនិពន្ធបានវិភាគនៅក្នុងតួសេចក្តីរួចមកហើយ ។ នៅក្នុងសង្គមខ្មែរយើង មានស្មេរច្រើនណាស់ ដែលបានចងក្រងស្នាដៃរបស់ខ្លួនចេញមកជាសៀវភៅចែកចាយទៅសង្គម ប៉ុន្តែស្មេរជាច្រើនចូលចិត្តសរសេរមានផ្តើមសេចក្តីនិងតួសេចក្តី តែមិនសូវបញ្ចប់សាច់រឿងរបស់គេ អោយជ្រះស្រឡះ ដោយការបញ្ចេញឆន្ទៈ ឬមតិយោបល់ ប្លែកៗ ផ្សេងៗឡើយ ។ នោះជាការបង្ហាញអោយឃើញថា អ្នកនិពន្ធទាល់មតិ មិនហ៊ានបញ្ចេញមតិ ឬក៏មិនមានជំនឿថា មតិយោបល់របស់ខ្លួន នឹងមានប្រសិទ្ធភាពទៅលើគំនិតរបស់អ្នកអាន ។ ម្ល៉ោះហើយអ្នកនិពន្ធភាគច្រើនមិនសូវហ៊ានសរសេរបញ្ចប់សេចក្តី ដោយបញ្ចេញមតិអ្វីឲ្យអ្នកអានបានយល់នឹង អំពីគំនិតផ្ទាល់ខ្លួនរបស់អ្នកនិពន្ធឡើយ ។ គេច្រើនតែរង់ចាំអោយអ្នកអានងាកស្វែងរកចម្លើយ ដោយខ្លួនឯងជំនួសអ្នកនិពន្ធទៅវិញ ។ នោះគឺជាចំណុចខ្សោយមួយ ដែលស្មេរទាំងឡាយគួរគិតអោយដិតដល់បំផុត ។

នៅក្នុងអត្ថបទអក្សរសិល្ប៍និមួយៗ ការនិពន្ធដោយខ្វះមតិ យោបល់ ខ្វះឆន្ទៈ និងគំហើញរបស់អ្នកនិពន្ធ នៅក្នុងបញ្ចប់សេចក្តីជាការបញ្ជាក់អោយឃើញថា ស្មេរបានប្រើត្រឹមតែវិញ្ញាណប្រាំបី

ក្នុងការនិពន្ធសំណេររបស់ខ្លួន តែមិនទាន់ឈានដល់ការអូសយក
វិញ្ញាណពីរទៀតមកប្រើ ក្នុងការនិពន្ធចងក្រងឲ្យពេញលក្ខណៈ
នៅឡើយ មានន័យថា សំណេររបស់គេមិនសូវមានប្រសិទ្ធភាព
ពេញលេញទៅលើអារម្មណ៍ និងគំនិតរបស់អ្នកអានប៉ុន្មានឡើយ ។
អ្នកនិពន្ធរូបនោះគួរសិក្សាបន្ថែមទៀត អំពីការប្រើអរូបវិញ្ញាណ
ទាំងប្រាំ ពីលើរូបវិញ្ញាណទាំងប្រាំដែលគេធ្លាប់ប្រើរួចហើយ ដើម្បី
ជួយរចនាស្នាដៃរបស់គេ អោយប្រកបដោយឆន្ទៈភ្លឺស្វាង និង
ប្រសិទ្ធភាពប្រសើរឧត្តម ។

***សូមអញ្ជើញអានជំពូកក្រោយៗ ដែលមានការអធិប្បាយយ៉ាង ពិស្តារ អំពីប្រសិទ្ធភាពនៃការនិពន្ធដោយប្រើវិញ្ញាណទាំង ១០ ។***

ម្យ៉ាងវិញទៀត នៅពេលដែលអ្នកនិពន្ធខ្លះចូលចិត្តរៀបរាប់
បង្អូសការពណ៌នាអ្វីៗអោយវែងអន្លាយ រៀបរាប់ឆ្វេង រៀបរាប់ស្តាំ
មុននឹងចូលដល់សាច់រឿង ដើម្បីទាញសំណេររបស់ខ្លួនអោយកើន
ទំព័រកាន់តែច្រើនទៅៗ មិនមែនមានន័យថា គេជាមនុស្សពូកែ
ខាងនិពន្ធនោះទេ ព្រោះថាសំណេរដែលមានតម្លៃល្អពិត គឺស្ថិតនៅ
លើពំនូតអក្សរសនៃគំនិតជ្រៅជ្រះភ្លឺថ្លា ដែលអ្នកអានអាចត្រងយក
បានពីអត្ថបទនិពន្ធនោះ តែមិនមែនចំនួនទំព័រឡើយ ។ ដូច្នេះ
អ្នកនិពន្ធនិមួយៗ គួរប្រយ័ត្នចៀសវៀងនូវការសរសេររៀបរាប់
វែងអន្លាយ ដើម្បីពន្លូតយកចំនួនទំព័រ រហូតបែរភ្លេចគិតអំពីការ
បង្ហាញខ្លឹមអក្សរសពិតប្រាកដរបស់សាច់រឿងដែលខ្លួនកំពុងសរសេរ
នោះ មិនខុសឡើយអំពីការវេចអន្សម ដោយខ្ចប់ស្លឹកចេកយ៉ាង
ក្រាស់ អោយឃើញនំធំធាត់ល្អ ប៉ុន្តែសាច់ក្នុងវិញបែរជាតូច នឹមិន
ពេញមាត់ យ៉ាងដូច្នោះឯង ។

ចំណុចមួយទៀត ដែលអ្នកនិពន្ធត្រូវប្រយ័ត្នគឺការសរសេរឲ្យ
មានចំណុចគោលដៅ ដើម្បីបញ្ចប់សាច់រឿង មិនមែនចេះតែ

សរសេរបង្ហួសៗសាច់រឿងយូរៗទៅ រួចស្រាប់តែអស់ពាក្យ អស់គំនិត រកកន្លែងបញ្ចប់មិនឃើញនោះឡើយ ។ ដើម្បីអោយងាយយល់ យើងសូមប្រៀបធៀបសាច់រឿងមួយទៅនឹងឡានដែលមានសាំងមួយធុង គឺនៅមុនពេលចេញដំណើរទៅ យើងត្រូវប្រមាណនូវចម្ងាយដែលសាំងឡានអាចគ្រប់គ្រងរហូតទៅដល់ទីដៅ ។ ដូចគ្នានេះដែរ អ្នកនិពន្ធត្រូវត្រៀមគម្រោងរឿង អំពីចំណុចដែលត្រូវចាប់ផ្ដើម ចំណុចដែលត្រូវធ្វើដំណើរឆ្លងកាត់ និងចំណុចដែលត្រូវបញ្ចប់ ។ បន្ថែមពីលើនោះ អ្នកនិពន្ធគួរពិចារណាថា តើអ្នកកាន់ចង្កូតមានអារម្មណ៍យ៉ាងណា បើសិនឡានត្រូវគាំងដំណើរ ចរមិនដល់គោលដៅ ? ចំណែកឯអ្នកជិះឡានមកជាមួយនោះ តើគេនឹងមានអារម្មណ៍យ៉ាងណាដែរ កាលបើម្ចាស់ឡានបណ្ដោយអោយឡានអស់សាំងកណ្ដាលផ្លូវដូច្នោះ ?

បែរមករឿងនិពន្ធអត្ថបទអក្សរសិល្ប៍វិញ ក៏មិនខុសអ្វីអំពីការបើកបរចរនាំអ្នកអានសំដៅឆ្ពោះទៅគោលដៅមួយនៅទីចុងក្រោយនោះឡើយ ។ ដូច្នេះ អ្នកនិពន្ធម្នាក់ៗគួរគប្បីត្រៀមជាមុន នូវគម្រោង ដំណើររឿងនិងចំណុចគោលដៅដែលយើងត្រូវនាំអ្នកអានធ្វើដំណើរទៅ ។ កាលបើយើងសម្លឹងឃើញទីដៅសំរាប់បញ្ចប់សាច់រឿងហើយ នោះទើបយើងចាប់ផ្ដើមសរសេររៀបគម្រោងឡើងអោយ ក្លាយជាសាច់រឿងពេញអត្ថន័យ ដើម្បីកុំអោយវង្វេងដំណើរ ឬត្រូវគាំងដំណើរ រកទីបញ្ចប់មិនឃើញ ។

<u>ខ. កំរិតកោសល្យនិពន្ធ</u> ៖

កំរិតកោសល្យនិពន្ធចែកជាបីកំរិត យោងទៅតាមសង្គមអ្នកអានដែលស្នេរចង់អោយគេចាប់អារម្មណ៍ ហើយទទួលយកនូវឥទ្ធិពលស្នាដៃរបស់ខ្លួន ។

<u>ខ១. កំរិតទីមួយ</u> ៖

*តាមធម្មតា ពេលគេតែងសេចក្ដីអំពីអ្វីមួយគេត្រូវការទំរង់បីមកសរសេរ គឺ ផ្ដើមសេចក្ដី តួសេចក្ដី និងបញ្ចប់សេចក្ដី ។ បើខ្វះទំរង់ណាមួយក្នុងបីនេះ ការនិពន្ធរបស់ស្មេរមិនទាន់គ្រប់លក្ខណៈនៅឡើយទេ មិនខុសពីមនុស្សដែលមានទ្រង់ទ្រាយមិនគ្រប់លក្ខណៈ ខ្វះដៃខ្វះជើងងងខ្លួននិងក្បាលណាមួយ ដូច្នោះដែរ ។*

*<u>ឧទាហរណ៍</u> ៖ ចូរសរសេរអំពីវិបត្តិនៃជំងឺគ្រុនក្ដៅ ។*

*សំណេរ ៖*

*<u>ផ្ដើមសេចក្ដី</u> ៖ (ការណែនាំប្រធានបទ)*

កាលពីក្មេង ខ្ញុំធ្លាប់មានជំងឺគ្រុនក្ដៅនេះញឹកញាប់ណាស់ ។ តើជំងឺនេះធ្វើទុក្ខរូបខ្ញុំយ៉ាងណាដែរ ?

*<u>តួសេចក្ដី</u> ៖ (ការស្រាយបំភ្លឺសេចក្ដីជូនប្រធានបទ)*

ពេលខ្ញុំក្ដៅខ្លួនម្ដងៗ ខ្ញុំមានអារម្មណ៍អន្ទះអន្ទែង គេងមិន លក់បាយមិនបាន ។ អាហារដែលធ្លាប់មានរសជាតិ បែរក្លាយ ជាជុំគ្រូសអស់រសជាតិរលីង ។ មិនតែប៉ុណ្ណោះ ខ្ញុំត្រូវគេងគ្រលុំភួយ រួចហើយត្រូវបរិភោគថ្នាំជំសែនល្វីងជាទីបំផុត ។

*<u>បញ្ចប់សេចក្ដី</u> ៖ (ការបំភ្លឺមតិយោបល់ ឬឆន្ទៈល្អៗ)*

ពេលខ្ញុំជាពីគ្រុនក្ដៅនេះមកវិញ ខ្ញុំមិនចង់ឈឺសាជាថ្មីទេ ព្រោះជំងឺគ្រុនក្ដៅគ្រោះថ្នាក់ណាស់ ។ បើព្យាបាលមិនទាន់ទេ យើងអាចទទួលគ្រោះថ្នាក់ដល់ជីវិត ។

*នៅក្នុងសំណេរខាងលើ ស្មេរបានសរសេរគ្រប់ទំរង់ទាំងបី គឺមានផ្ដើមសេចក្ដី តួសេចក្ដី និងបញ្ចប់សេចក្ដីដែលអ្នកនិពន្ធបានបញ្ចេញមតិពីផលវិបាកនៃជំងឺគ្រុនក្ដៅ គ្រាន់តែគេសរសេររបៀបខ្លីៗរាក់ៗទំនងជាសិស្សដែលទើបរៀនសរសេរតែងសេចក្ដីដំបូង ។ នៅក៏វិតនេះផងដែរ អ្នកនិពន្ធច្រើនសរសេរសំណេររបៀបកំណត់ត្រាផ្ទាល់ខ្លួនប្រចាំថ្ងៃរបស់អ្នកនិពន្ធ ។ គេច្រើនបញ្ចូលខ្លួនឯងទៅក្នុងសាច់រឿងដោយប្រើពាក្យថា " ខ្ញុំ " ជាតួអង្គនៅក្នុង*

រឿងតែម្ដង រួចហើយក៏បរិយាយអំពីអារម្មណ៍ និងការគិតរបស់បុគ្គលមួយរូបនោះ រហូតដល់ទីបញ្ចប់នៃសាច់រឿងនោះ ។ បើសិនជាគេចង់សរសេរបង្ហាញអំពីគំនិត ឬពីអារម្មណ៍របស់តួអង្គផ្សេងៗទៀតនៅក្នុងសាច់រឿង អ្នកនិពន្ធបែបនោះច្រើនសរសេរជាកំណាត់ហេតុបែបសន្ទនា ដើម្បីអោយតួម្នាងទៀត និយាយតបមកវិញ ជាសំនួនវោហារឆ្លើយឆ្លងទៅវិញទៅមកជាមួយតួអង្គ "ខ្ញុំ " ដែលអ្នកនិពន្ធបានប្រឌិតរួចមកហើយ ។ ការសរសេរបែបនោះ ជួនកាលអាចធ្វើអោយអ្នកអានយល់ច្រឡំថា តួអង្គ "ខ្ញុំ " នោះ គឺជាអ្នកនិពន្ធផ្ទាល់តែម្ដង ថ្វីបើគេដឹងថា សាច់រឿងដែលអ្នកនិពន្ធសរសេរមកនោះគ្រាន់តែជាសាច់រឿងប្រឌិតក៏ដោយ ។ ដូច្នេះ តើយើងគួរធ្វើយ៉ាងណា ដើម្បីអោយអ្នកនិពន្ធអាចសរសេរអំពីគំនិត និងអារម្មណ៍របស់តួអង្គផ្សេងៗទៀត នៅក្នុងរឿងដដែលបាន ? សូមអញ្ជើញអាននូវការវិភាគជាបន្តទៅទៀត ។

<u>៦២. ករិតទីពីរ</u> ៖

សូមអានរឿងនាងសុក្រនិងនាយសៅ ដែលជាឧទាហរណ៍ នៅក្នុងទម្រង់និពន្ធខាងលើកន្លងមក ។ នោះគឺជាការសរសេរចងក្រងករិតមធ្យម មានន័យថា សាច់រឿងមានអាថ៌កំបាំងខ្លះៗ មានពាក្យខ្ពស់ពាក្យរាយខ្លះលាយចូលគ្នា តែសាច់រឿងមានដំណើរត្រង់ៗតាមអត្ថន័យអត្ថានុរូប មិនសូវមានលាក់អត្ថន័យបញ្ឆិតបញ្ឆៀង អោយអ្នកអានពិបាកនឹងពិចារណាច្រើនឡើយ ។ អ្នកអានអាចត្រងត្រេកសាច់រឿងតាមតែដំណើរលេខរៀងនៃពេលវេលាក្នុងរឿង ដោយមិនបាច់ប្រឹងត្រិះរិះគិតពីកាលវេលាថា ហេតុការណ៍មួយណាឧប្បត្តិកមុន ហេតុការណ៍មួយណាឧប្បត្តិកឡើងតាមក្រោយទេ ថ្វីបើស្មេរបានលួចលាក់គំនួចចម្ងល់ ខ្លះៗទៀត អោយអ្នកអានតាមរកមុខស្រាយវិញជាបន្តក៏ដោយ ។

នៅក្នុងកវិតនេះ អ្នកនិពន្ធបានដកខ្លួនចេញមកក្រៅសាច់រឿង វិញ ហើយដើរតួជាអ្នកសង្កេតស្ថានការណ៍សរសេរកំណត់ហេតុទាំងឡាយដែលតួអង្គទាំងឡាយនៅក្នុងសាច់រឿងបានជួបប្រទះ ។ នៅពេលនេះ អ្នកនិពន្ធអាចសម្លឹងមើលស្ថានការណ៍ពីជ្រុង ផ្សេងៗគ្នាបានច្រើនមុំ ច្រើនជ្រុងជ្រោយ អាចនិពន្ធអំពីគំនិតនិងអារម្មណ៍របស់តួអង្គជាច្រើនៗផ្សេងៗគ្នាបាន ដោយមិនសរសេរទាល់ច្រកត្រឹមតែគំនិតនិងអារម្មណ៍របស់តួអង្គតែម្នាក់ ដូចនៅក្នុងកម្រិតទីមួយឡើយ ។

<u>៥៣. កវិតទីបី</u> ៖

នៅកវិតនេះ អ្នកនិពន្ធនឹងប្រឡែងលេងជាមួយអ្នកអានដោយល្បិចសរសេរច្រើនជាងមុន ថ្វីបើគេនៅប្រើទំរង់មូលដ្ឋាន ផ្ដើមសេចក្ដី តួសេចក្ដី និង បញ្ចប់សេចក្ដី ដដែលក៏ដោយ មានន័យថា អ្នកនិពន្ធប្រើល្បិចលលេងប្រាជ្ញាអ្នកអាន អោយតាមដានសាច់រឿងផង អោយពិចារណាលេងៗតាមផ្លូវផង ថាតើអ្នកនិពន្ធនិងនាំសាច់រឿងចេញទៅច្រកណាខ្លះ ដើម្បីស្រាយបំភ្លឺខ្ចចម្ងល់ដែលស្មេរបានចងនៅក្នុងរឿង ។ និយាយអោយពិតទៅ នៅក្នុងកវិតនេះ អ្នកនិពន្ធនឹងបែងក្រឡាសាច់រឿងជាបំណែកដុំៗ ហើយសរសេរបំភ្លែងលិច បំភ្លែងកើត ជាក្រឡាប្រទាក់គ្នាបត់ចុះបត់ឡើង មិនឲ្យសាច់រឿងធ្វើដំណើរតាមលេខរៀងនៃពេលវេលា ឬ ជីវិតរបស់តួអង្គឡើយ ។ គេសរសេរបែបវិធីក្រឡុកលេខឆ្នោត គឺជួនកាលគេសរសេរយកសាច់រឿងចុងចប់យកមកដាក់ខាងដើមសៀវភៅ រួចយកសាច់រឿងដើមទៅដាក់នៅខាងក្រោយ ឬកណ្ដាលរឿងទៅវិញវិលវល់ទៅមក ទុកអោយអ្នកអានរើសបំណែករឿង យកមកផ្គុំជាសាច់រឿងទាំងមូលដោយខ្លួនឯង ។ ក្រៅពីនោះទៀតសោត អ្នកនិពន្ធមានបន្ថែមការសរសេរលាក់អក្សរសជីវិត ដែលស្មេរត្រូវប្រើ

វិញ្ញាណទាំង១០ជាជំនួយ មកពណ៌នានិងដោះស្រាយខ្នួចចម្ងល់ជូនមិត្តអ្នកអានយ៉ាងក្បោះក្បាយហើយមានទឹកដមអត្ថន័យប្រសើរ ។

ចំពោះអ្នកអាន ដែលចូលចិត្តឬធ្លាប់អានការនិពន្ធ កវិតទី២ កាលបើគេប្រទះកវិតទីបីនេះ ជួនកាលគេ គិតថាសំណោរកវិតទីបីពិបាកតាមដានណាស់ រួចហើយក៏អស់ទឹកចិត្ត លែងចង់អានបន្តទៅទៀត ។ ប៉ុន្តែ បើសិនអ្នកអាននោះអាចឆ្លង ផុតភាពធុញទ្រាន់ក្នុងការតាមដានភាពក្រវិកក្រវក់របស់សាច់រឿង ក្នុងកម្រិតទី៣ ហើយប្រឹងអានរហូតដល់យល់សាច់រឿងមកវិញនោះ គេនឹងចូលចិត្តការសរសេរសាច់រឿងបែបទីបីនេះមិនខានឡើយ ត្បិតគេនឹងបានសប្បាយប្រើប្រាជ្ញរបស់គេ ដើម្បីផ្គុំសាច់រឿងទាំងមូលបានយល់អត្ថន័យវិញផង សប្បាយនឹងទាយសាច់រឿងជាមុនផង ហើយក៏បានទទួលអត្ថរសពីសំណោរយ៉ាងសប្បាយអារម្មណ៍បំផុត នៅពេល អ្នកនិពន្ធស្រាយសាច់រឿងអោយគេអានប្រកប ដោយសន្ទេហវិធីដែលគេមិនអាចស្មានត្រូវជាមុនផង ។

បើសិនជាមានឱកាស សូមអានរឿង ផ្កាយវង្វេងមេឃ ឬក៏ រឿង ក្លិនផ្កាមារតី ដែលអ្នកនិពន្ធខ្ញុំបានបោះពុម្ពរួចមកហើយ ។ នៅក្នុងប្រលោមលោកទាំងពីរនេះ ស្មេរបានយកសិល្បវិធីកវិតទី៣ មកសរសេរសាច់រឿង និងដោះស្រាយខ្នួចអាថ៌កំបាំងរបស់រឿងទាំងមូល ។ ថ្វីបើសាច់រឿងមើលទៅហាក់ដូចជាកំណិតកំណាត់បន្តិច ប៉ុន្តែ បើសិនជាអ្នកអានបានបណ្ដើរអារម្មណ៍របស់ខ្លួនមកដល់ពាក់កណ្ដាលសៀវភៅហើយនោះ គេនឹងចាប់ផ្ដើមត្រេកត្រអាល ចង់ដឹងតទៅទៀតនូវសាច់រឿងពាក់កណ្ដាលចុងក្រោយមិនខាន ។ លុះដល់ពេលគេអានរឿងចប់ គេនឹងដឹងថាអត្ថរសនៃការសរសេរកវិតទីបីមានទឹកដមឈ្ងុយឆ្ងាញ់ប៉ុនណា សំរាប់អ្នកអានកំសាន្តអារម្មណ៍ និងប្រឡែងប្រាជ្ញជាមួយអត្ថបទ ។

អ្នកនិពន្ធខ្មែរទូទៅច្រើនសរសេរ បែបកិរិតទីមួយនិងទីពីរ តែមិនសូវមានអ្នកនិពន្ធណាចូលចិត្តសរសេរបែបកិរិតបីទេ ព្រោះគេត្រូវការពេលវេលាច្រើនណាស់ក្នុងការចងក្រងរឿងនិមួយៗ ដោយការប្រើវិញ្ញាណទាំង១០ គឺគេគិតមិនសូវបានសំរាកទេ ក្នុងពេលគេច្នៃប្រឌិតកន្លុកកន្លៀតរបស់អត្ថបទទាំងនោះ កុំអោយអ្នកអានអាចទាយសាច់រឿងរបស់គេដឹងអស់ជាមុន ។ មានតែអ្នកនិពន្ធមួយចំនួនតូចប៉ុណ្ណោះ ដែលសរសេរតាមលក្ខណៈបែបកិរិតទីបី ហើយក៏មានអ្នកអានមួយចំនួនតូចដែរ ដែលចូលចិត្តអានសាច់រឿងកម្រិតទី៣នេះ ព្រោះថា អ្នកអានខ្លះមិនសូវមានតម្រេះវិជ្ជាខ្ពង់ខ្ពស់ល្មម នឹងអាចតាមទាន់ការសរសេរបែបកិរិតទីបីនេះទេ ម្ល៉ោះហើយអ្នកអានមិនសូវចូលចិត្តប្រើអារម្មណ៍ គិតជាមួយសាច់រឿងបែបនោះឡើយ ។ គេចូលចិត្តសំរាកសំរួលអារម្មណ៍របស់គេជាជាង ។ ដូចនេះ អ្នកអានបែបនោះច្រើនបែរទៅរកទឹកដៃសរសេរកិរិតកណ្តាលវិញ ដើម្បីងាយយល់ហើយមិនបាច់គិតច្រើន ។ នេះក៏មិនជាការខុសទាស់អ្វីដែរ ។ អ្នកអានមានសិទ្ធិជ្រើសរើសនូវអ្វីដែលគេចង់អាន ដោយសេរី គ្មានការបង្ខិតបង្ខំឡើយ ។

ទោះបីជាយ៉ាងនេះក៏ដោយ អ្នកនិពន្ធទាំងឡាយមិនគួរអស់ទឹកចិត្តនឹងសរសេរបែបទកិរិតទីបីទេ ព្រោះថា នៅក្នុងសង្គមខ្មែរយើងបច្ចុប្បន្ននេះ នៅមិនទាន់បរិបូណ៌ដោយអ្នកនិពន្ធដែលសរសេរសៀវភៅរឿងផ្សេងៗ កិរិតទីបីនេះនៅឡើយទេ ជាពិសេសគឺការសរសេរព្យួរសាច់រឿង និងការសរសេរស្រាយសាច់រឿងមកវិញអោយមានរសខ្លឹមសារសំរាប់ជីវិតអ្នកអាន ឬសំរាប់អារម្មណ៍របស់អ្នកអាន ។ រីសង្គមខ្មែរទូទៅក៏ស្ទើរតែពុំបានភ្លក្សរសជាតិនៃស្នាដៃរបៀបនេះដែរ ត្បិតយើងមិនសូវសំបូរសំណេរកិរិតនេះជាការអានទូទៅដូចសំណេរដទៃ ។ ដូច្នេះ យើងគប្បីចាប់ផ្តើមបង្កើនការ

សរសេរសំណេរកម្រិតនេះ អោយមិត្តអ្នកអាន បានទទួលស្គាល់សំណេរបែបនេះអោយបានច្រើនបំផុត ព្រោះការសរសេរនេះមិនត្រឹមតែធ្វើអោយអ្នកនិពន្ធប្រឹងបណ្ដុះបណ្ដាលសតិបញ្ញានោះទេ តែអាចមានអនុភាពធ្វើអោយអ្នកអានយកប្រាជ្ញ មកគិតជាមួយអ្នកនិពន្ធយ៉ាងសស្រាក់សស្រាំក្នុងពេលដែលគេអាននោះផងដែរ ។ ព្រមជាមួយគ្នានេះដែរ នៅសម័យខ្មែរអភិវឌ្ឍន៍ បន្ទាប់ពីជំនាន់អ៊ុនតាក់ឆ្នាំ១៩៩៣តរៀងមក បច្ចាជនក្រោយៗបានចូលរៀនដុះខាត់វិជ្ជារបស់គេរហូតបានភ្លឺខ្លង់ខ្លស់ឧត្តុង្គឧត្តម ។ ចំនួនបញ្ញវន្ត័ក៏កាន់តែកើនចំនួនច្រើនឡើងជាលំដាប់ លើសពីចំនួនបញ្ញវន្តនៅអតីតកាលកន្លងមក ។ ដូច្នេះ ស្មេរត្រូវតែប្រឹងខំព្យាយាមបញ្ចេញស្នាដៃអោយបានច្រើនបំផុត ដើម្បីអោយទាន់សេចក្ដីត្រូវការរបស់អ្នកអាន ដែលកំពុងលូតលាស់វិជ្ជាសិក្សាគ្រប់ៗផ្នែកទាំងអស់ ។ ដោយមូលហេតុនេះហើយ យើងសង្ឃឹមថាមិនយូរមិនឆាប់ ស្នាដៃកវិតទីបីនេះនឹងក្លាយទៅជាសំណេរ ដែលមានប្រជាប្រិយភាពបំផុតនៅប្រទេសខ្មែរ ក្នុងសម័យបច្ចុប្បន្ននេះ ។

<u>គ. អំពីបែបបទនិពន្ធ</u> ៖

ការនិពន្ធអត្ថបទឬរឿងផ្សេងៗ មានចែកចេញជាពីរបែប គឺ ការនិពន្ធបែបមិនប្រឌិត និងការនិពន្ធបែបប្រឌិត ។

<u>គ១. បែបមិនប្រឌិត (Non-Fiction)</u> ៖

នេះជាការនិពន្ធដែលចេញពីការពិតសុទ្ធសាធ ឧទាហរណ៍ដូចជាការសរសេរសៀវភៅប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វិធីធ្វើម្ហូបចំណីវិជ្ជាកាត់ដេរ វិធីថែរក្សាសុខភាព វិធីអប់រំកុមារ សៀវភៅធម៌សៀវភៅគណិតវិទ្យា រូបវិទ្យា សៀវភៅវេយ្យាករណ៍វចនានុក្រម អត្ថបទស្រាវជ្រាវ សារណាផ្សេងៗរបស់បញ្ញវន្ត័និងនិស្សិត ឬសំណេរអំពីជីវប្រវត្តិរបស់បុគ្គលល្បីឈ្មោះក្នុងសង្គមជាដើម ។ល ។

ដែលទាក់ទងទៅនឹងការពិតទាំងស្រុង មិនបំផ្លើសថែមថយទៅតាមមនោសញ្ចេតនា ឬក្តីស្រមើស្រមៃរបស់អ្នកនិពន្ធឡើយ ។

អ្នកនិពន្ធដែលសរសេរអត្ថបទទាំងឡាយខាងលើនេះ ត្រូវតែធ្វើការស្រាវជ្រាវយ៉ាងហ្មត់ចត់មុននឹងចាប់ផ្តើមសរសេរ ព្រោះគេត្រូវរក្សាសច្ចភាពរបស់សាច់រឿងមិនឲ្យខុសពីការពិតឡើយ ។ គេត្រូវស្រង់យកឯកសារផ្សេងៗរបស់អ្នកនិពន្ធដទៃ មកធ្វើជាគោលបង្អែកផង ដើម្បីជាភស្តុតាងបញ្ជាក់នូវសច្ចភាពនៃសំណេររបស់គេ ។ ជួនកាល បើសិនជាគ្មានឯកសារយោងសំរាប់ជាគោលបង្អែកទេ គេត្រូវធ្វើការសម្ភាសន៍ជាមួយនរជនណា ដែលនឹងប្រវត្តិពិតជាក់ស្តែង ។ នោះគឺភាពការស្វែងរកភាពជាក់លាក់ និងពិតប្រាកដរបស់សាច់រឿង ។ នៅក្នុងផ្នែកនេះ អ្នកនិពន្ធត្រូវចាយពេលវេលាច្រើនណាស់ ដើម្បីស្រាវជ្រាវស្រង់គោលមូលដ្ឋានល្អៗ មកយោងសំណេររបស់ខ្លួនជាចាំបាច់ ចៀសវាងមិនបានឡើយ ។

ការនិពន្ធសំណេរបែបរឿងពិត មានសាខាច្រើនយ៉ាងដូចជា :

- សំណេរពីជីវប្រវត្តិរបស់អ្នកប្រាជ្ញឬវិរជនគំរូ
- សំណេរពីប្រវត្តិសាស្ត្រ
- សំណេរអំពីសង្គមធម៌ សីលធម៌ វប្បធម៌ជាតិណាមួយ
- សំណេរអំពីវិជ្ជាសិក្សាទូទៅ
- សំណេរអំពីវិជ្ជាថែរក្សាសុខភាព
- សំណេរអំពីរបៀបដណ្តាំម្ហូបអាហារ ។ល ។
- សំណេរអំពីរបៀបកាត់ដេរម៉ូដខោអាវបុរាណនិងសម័យ ។ល ។

<u>គ២. បែបប្រឌិត (Fiction/ Imagination)</u> ៖

សំណេរនេះជាការនិពន្ធ ដែលប្រឌិតចេញពីក្តីស្រមៃរបស់អ្នកនិពន្ធសុទ្ធសាធ ដូចជាការសរសេរប្រលោមលោកជីវិត ប្រលោម

លោករឿងបុរាណ រឿងកុមារ រឿងកំប្លែង សរសេររឿងកុន រឿងល្ខោន កំណាព្យមនោសញ្ចេតនា ទំនុកច្រៀង អត្ថបទកំសាន្ត ខ្លីៗ អត្ថបទទស្សនាវដ្តីខ្លះៗ ។ល ។ នៅប្រទេសខ្មែរបច្ចុប្បន្ននេះ មនុស្សទូទៅនិយមអានសៀវភៅសរសេរប្រឌិតជាជាង សៀវភៅមិនប្រឌិត វៀរលែងតែនរជននោះជានិស្សិតឬបញ្ញវ័ន្តទេ ទើបគេស្រវាស្រទេញរកសំណេរបែបពិត ដែលមានមូលដ្ឋានបណ្តុះចំណេះ និងគំនិត ដើម្បីជាប្រយោជន៍ត្រលប់ដល់ការសិក្សារបស់គេវិញ ។

ចំពោះការនិពន្ធរឿងប្រឌិតនេះសោត អ្នកនិពន្ធនិមួយៗអាចមានសេរីភាពគ្រប់គ្រាន់ក្នុងប្រឌិតស្នាដៃ អោយចេញជារូបរាងឡើង ជាសាច់រឿងបែបណាក៏បាន មិនចាំបាច់តែជារឿងដែលឆ្លុះអំពីជីវិតពិតៗរបស់សង្គមខ្មែរនាបច្ចុប្បន្នតែម្យ៉ាងនោះឡើយ ។ អ្នកនិពន្ធគប្បីចេះបើកចិត្តបើកអារម្មណ៍អោយទូលាយ ដើម្បីសរសេរសាច់រឿងអោយបានល្អហើយប្លែកៗ ។

ឯការសរសេររឿងប្រឌិតទៀតសោត ក៏បែងចែកទៅជាច្រើនផ្នែកតទៅទៀតដែរ តាមករិតវ័យអ្នកអាន តាមចំណង់ចំណូលរបស់សង្គមអ្នកអាន តាមការស្រម័យរបស់អ្នកនិពន្ធ និងតាមជំនោរជីវិត និងតាមជីវភាពរបស់សង្គមទាំងមូល ។ សាខាសំណេរមានរួមបញ្ចូលដូចជា ៖

- ការនិពន្ធបែបប្រលោមលោកមនោសញ្ចេតនាអំពីជីវិត
- ការចងក្រងរឿងនិទានឬរឿងព្រេង
- ការនិពន្ធបែបកំប្លែងសើចសប្បាយ
- ការនិពន្ធប្រឌិតរឿងដើម្បីអប់រំមនុស្ស
- ការនិពន្ធដោយប្រឌិតនូវភាពអច្ឆរិយៈ ឬបង្កើតបាតុភូតចម្លែកៗ ដូចជាសិល្ប៍ហោះហើរដើរលើអាកាស ជប់ខ្លួនបំបាំងបាត់ជាដើម ។ ភាគច្រើន គេប្រឌិតសំណេររបៀបនេះ ឲ្យទៅជាសាច់រឿងបុរាណ

ទៅវិញ រហូតដល់មានអ្នកអានខ្លះយល់ច្រឡំរឿងប្រឌិតទាំងនោះថាជាសាច់រឿងប្រវត្តិសាស្ត្រទៅវិញទៀតផង ។ បើសិនជាគេប្រឌិតអច្ឆរិយភាពនៅក្នុងសាច់រឿងសម័យវិញ សំណេរទាំងនោះច្រើនតែជារឿងខ្មោច យល់សប្តិ រឿងចាំជាតិ ឬរឿងដែលបំភ្លៃដោយវិទ្យាសាស្ត្រកំព្យូទ័រ ។

- ការសរសេរបែបខ្សែភាពយន្ត ៖ នៅក្នុងនេះ អ្នកនិពន្ធសរសេរបែបសន្ទនាតាំងពីដើមរឿងរហូតដល់ចប់រឿង តែគេមិនបាច់អោយតួអង្គនិយាយច្រើនពេកទេ ព្រោះនៅក្នុងខ្សែភាពយន្ត គេអាចយកសកម្មភាពនិងកាយវិការរបស់តួអង្គ មកបរិយាយសាច់រឿងជំនួសរួចទៅហើយ ដោយមិនបាច់អោយតួអង្គស្ទួនការសន្ទនា បញ្ជាក់ម្តងទៀត នាំតែអ្នកទស្សនាមានអារម្មណ៍ធុញទ្រាន់នោះឡើយ ។

- ការសរសេរបែបល្ខោននិយាយ : កន្លែងនេះ ស្មេរត្រូវសរសេរពីប្រយោគសន្ទនាដោយមានយកតួអង្គមកជួយរៀបរាប់ស្ថានការណ៍អោយអ្នកស្តាប់យល់សាច់រឿងថែមទៀត គឺខុសប្លែកពីការសរសេរសំរាប់ភាពយន្តបន្តិច ត្រង់អ្នកនិពន្ធត្រូវយកភាសាសន្ទនា ដើម្បីបង្ហាញនូវស្ថានភាពនិងបរិយាកាសរបស់សាច់រឿង ។

- ការសរសេររឿងបែបសរសេរសំបុត្រឆ្លើយឆ្លង ៖ នៅប្រទេសខ្មែរយើង មានអ្នកនិពន្ធតិចតួចណាស់ ដែលសរសេរអត្ថបទបែបនេះ ។ នោះគឺជាសំណេរ ដែលគេប្រឌិតអោយតួអង្គសរសេរសំបុត្រឆ្លើយឆ្លងគ្នាពីដើមដល់ចប់ ដោយយកសេចក្តីនៅក្នុងសំបុត្រនោះឯងជាអ្នកបរិយាយសាច់រឿង និងស្ថានការណ៍ទាំងឡាយរបស់សាច់រឿង តាំងពីដើមរហូតដល់ចប់ ។

រួមសេចក្តីមក អ្នកនិពន្ធមានផ្លូវជ្រើសរើសច្រើនណាស់សំរាប់ការសរសេរសៀវភៅផ្សេងៗ មិនថាជាសៀវភៅសិក្សា ឬគ្រាន់តែជារឿងប្រឌិតទេ ។ គេអាចនិពន្ធអត្ថបទយ៉ាងណា ក៏វិតណា បែប

បទយ៉ាងណាក៏ដោយ ឲ្យតែអាចបញ្ចេញស្នាដៃមកបាន នោះយូរៗទៅប្រទេសយើងនឹងបរិបូណ៌ទៅដោយអ្នកនិពន្ធល្បីៗ ព្រមទាំងបរិបូណ៌ទៅដោយបណ្ណាល័យ ដែលផ្ទុកទៅដោយសៀវភៅចំនួនយ៉ាងច្រើនមហិមា សំរាប់ផ្តល់ទៅបច្ឆាជនខ្មែរ បន្តការស្រាវជ្រាវពង្រីកការចេះដឹងរបស់គេជាបន្តៗទៅទៀត ។

<u>គ៣. ការវែកញែកបញ្ជាក់</u> ៖

នៅពេលអ្នកនិពន្ធម្នាក់សរសេរអំពីរឿងប្រឌិតមួយ ដែលកើតឡើងនៅប្រទេសកម្ពុជា ដោយបានបង្កើតស្ថានការណ៍ខ្លះៗនៅក្នុងសាច់រឿង ដែលមិនសមស្របនឹងស្ថានការណ៍ស្រុកទេសបច្ចុប្បន្ន ដូចជា អ្នកនិពន្ធបានប្រឌិតអោយតុលាការក្នុងក្រុងភ្នំពេញប្រកបដោយគតិយុត្តិធម៌ពេញលក្ខណៈ ដូចប្រទេសប្រជាធិបតេយ្យនានាក្នុងសកលលោក (ដូចជាសហរដ្ឋអាមេរិក នូស៊ីឡែន កាណាដា ណរវេ ជាដើម) មានអ្នកអានខ្លះរិះគន់ថា អ្នកនិពន្ធនោះនិយាយបំផ្លើស បំភ្លៃស្ថានការណ៍ និយាយមិនដូចការពិត ... ថាអ្នកនិពន្ធមិនស្គាល់ស្ថានភាពនយោបាយ និងសង្គមរស់នៅរបស់ខ្មែរបច្ចុប្បន្ននៅក្នុងប្រទេស នៅពេលដែលគេសរសេរសាច់រឿងនោះ ទើបអ្នកនិពន្ធសរសេរវង្វេងមិនសមស្របនឹងការពិត ដែលកើតមាននៅក្នុងប្រទេសខ្មែរ ឬមិនសមហេតុផលតាមកាលៈទេសៈរបស់ស្ថានភាពនយោបាយនៃមាតុភូមិរបស់ខ្លួន ។

សូមសួរថា តើការរិះគន់របស់អ្នកអានបែបនោះធ្វើអោយយើងដែលជាអ្នកនិពន្ធគិតយ៉ាងណាវិញ ?

សេចក្តីបំភ្លឺមានដូចខាងក្រោមនេះ ៖

គឺថា អ្នកអានមានសិទ្ធិរិះគន់ពេញសេរី ចំពោះស្នាដៃទាំងឡាយដែលអ្នកនិពន្ធចងក្រងមក ព្រោះការរិះគន់ជួយអោយអ្នកនិពន្ធគិតត្រិះរិះស្វែងរកមធ្យោបាយប្រសើរៗ សំរាប់យកមកកែឆ្នៃ

ស្នាដៃរបស់ខ្លួន អោយកាន់តែលេចត្រដែតបន្ថែមឡើងទៀត ។ ប៉ុន្តែ នៅក្នុងគំនិតរិះគន់ខាងលើ អ្នកអានទាំងឡាយនោះ ភ្លេចគិតថា សាច់រឿងដែលគេកំពុងអាន គឺជាសាច់រឿងប្រឌិតសុទ្ធសាធ ហើយ កាលបើរឿងនោះជារឿងប្រឌិត ដូច្នេះអ្នកនិពន្ធអាចមានសេរីភាពគ្រប់គ្រាន់ក្នុងការប្រើចុងប៉ាកកាទិញ ជប់ស្ថានភាព និង បរិយាកាស នៅក្នុងសាច់រឿង អោយបែរទៅទិសណាក៏បានដែរ មិនខុសពីការសាច់រឿងដែលគេជប់អោយផ្ទះហោះ អោយសត្វចេះនិយាយ អោយមនុស្សរស់នៅក្នុងទឹកបានដូចត្រី នានានោះដែរ ។ អាស្រ័យហេតុនេះ អ្នកនិពន្ធទាំងឡាយអាចប្រើអនុភាពចុងប៉ាកកាជប់សាច់រឿងទាំងឡាយ អោយដើរទៅតាមក្តីស្រម័យរបស់ខ្លួនបាន ដោយមិនមានកំហុស ។ គេអាចចាត់សំណេរមួយនោះ ថា ជាសំណេរដែលមានលក្ខណៈគ្រប់គ្រាន់ បើសិនជាការប្រឌិតនិពន្ធនោះមានគំនួចប្រស្នា និងមានដំណោះស្រាយប្រស្នា បំភ្លឺអាថ៌កំបាំងនានា ចប់ចុងចប់ដើម ។

ម្យ៉ាងទៀត បើសំណៅនិពន្ធដូចការពិតទាំងស្រុង ស្នាដៃនិពន្ធមួយនោះលែងចាត់ទុកថា ជាពពួករឿងប្រឌិត (Fiction) ហើយ ។ គេត្រូវហៅសំណេរនោះថា ជារឿងមិនប្រឌិត (Non-Fiction) ។ ហើយបើសំណៅនោះជារឿងពិតវិញ តួអង្គក្នុងរឿងត្រូវតែជាតួពិតមានឈ្មោះពិតក្នុងសង្គម ហើយត្រូវមានសាច់រឿងជីវិតពិតៗ គឺមិនអាចប្រឌិតថែមថយ ទៅតាមអារម្មណ៍របស់អ្នកនិពន្ធ អ្វីបន្តិចបានឡើយ ។

ហេតុដូច្នេះហើយ ទាំងអ្នកនិពន្ធ ទាំងអ្នកអាន គួររៀនកត់ សំគាល់នូវព្រំដែនបែងចែករវាងការនិពន្ធរឿងប្រឌិត និង ការនិពន្ធរឿងមិនប្រឌិត អោយបានជាក់លាក់ ថាតើសំណេរដែលគេកំពុងរិះគន់នោះជាសំណេរប្រភេទមួយណា ។

តាមធម្មតា អ្នកនិពន្ធរឿងសម័យ តែងស្រង់យកភូមិសាស្ត្រ ឬប្រវត្តិស្រុកទេសពិតប្រាកដ មកដាក់ក្នុងសាច់រឿង ដូចជាស្ទឹងសង្កែ ភ្នំបូកគោ អង្គរវត្ត ទឹកជ្រោះក្បាលឆាយ ឧទ្យានគីរីរម្យ ។ល ។ នៅពេលដែលអ្នកនិពន្ធប្រឌិតតួអង្គក្លែងក្លាយ អោយមកដើរតួនៅក្នុងសាច់រឿងរបស់ខ្លួន ។ អ្នកនិពន្ធធ្វើបែបនោះគឺមានគោលបំណងនាំអ្នកអានអោយបង្កការស្រម័យ និងចងភ្ជាប់អារម្មណ៍របស់គេទៅក្នុងសាច់រឿង អានហើយ ក៏បានយល់ស្ថានភាពភូមិសាស្ត្រ របស់សាច់រឿងកាន់តែជាក់ច្បាស់ថែមទៀត ។ ជាពិសេសបើសិនជាអ្នកអាននោះធ្លាប់ស្គាល់ ធ្លាប់រស់នៅទីកន្លែងភូមិសាស្ត្រទាំងនោះពីមុនមក គេនឹងមានចិត្តសប្បាយត្រេកត្រអាលនឹងអានរឿងនោះ កាន់តែខ្លាំងថែមទៀត ។

ការសរសេរបែបនោះ មានន័យថា អ្នកនិពន្ធកំពុងប្រមូលអត្ថរសរបស់សាច់រឿង ដោយការទាក់ទាញចំណាប់អារម្មណ៍របស់អ្នកអាន ទៅលើទឹកដីដែលគេធ្លាប់ស្គាល់ធ្លាប់ស្រឡាញ់ ធ្លាប់រស់នៅ ឬ ក៏ធ្លាប់មានអនុស្សាវរីយ៍ពីអតីតកាល ។ ប៉ុន្តែ សូមកត់សំគាល់ថាការសរសេរបែបនោះមិនអាចហៅថា ជាការនិពន្ធបែបមិនប្រឌិតបានទេ ត្បិតសាច់រឿងទាំងមូលរបស់អ្នកនិពន្ធ ជាសាច់រឿងប្រឌិតរួចទៅហើយ ។

========================================

**ចុះស្ទឹងអោយមើលជ្រោះ**

**ចៀសផុតគ្រោះ ព្រោះប្រាជ្ញា**

*អ្នកស្រី កែវ ចន្ទ័បូរណ៍*

========================================

========================================

# ជំពូកទី៤
# អំពីអត្ថសញ្ញាណ
# របស់សៀវភៅ

========================================

## ក. ចំណងជើងនិងអត្ថសញ្ញាណសៀវភៅ ៖

### ក១. ចំណងជើង ៖

នៅក្នុងវប្បធម៌ប្រពៃណីខ្មែរ ប្រជាពលរដ្ឋទូទៅតែងមានជំនឿទៅលើការដាក់ឈ្មោះអោយកូនចៅ ដាក់ងារស្មាដៃ ឬដាក់នាមថ្មីអោយអ្នកទទួលមេដៃមាស ដាក់ឈ្មោះអោយវត្ត ឬសាលារៀនជាដើម ដោយការជ្រើសរើសពាក្យដែលមានអត្ថន័យល្អពិរោះ ត្បិតគិតថា ឈ្មោះនោះនឹងនាំលាភសិរីសួស្តី ជូនម្ចាស់សាម៉ីនាមវិញយ៉ាងខ្ពង់ខ្ពស់ប្រសើរ ។

ប៉ុន្តែ ឈ្មោះទាំងឡាយនោះ ក៏អាចឆ្លុះបញ្ចាំងអោយឃើញនូវវិជ្ជានឹងករិតវប្បធម៌របស់អ្នកដែលដាក់ងារ ឬដាក់នាម ដល់គេដែរ ឧទាហរណ៍ដូចជា អ្នកស្រុកចុងកាត់មាត់ញកម្នាក់ដាក់ ឈ្មោះកូន ថា "ផ្កាយ" ព្រោះគិតថា កូននោះនឹងមានរាសីល្អពណ្ណរាយ ដូចផ្កាយ ។ ក្នុងន័យតែមួយ អ្នកទីក្រុងម្នាក់ដែលមានករិតសិក្សា ខ្ពង់ជាងបន្តិចបែរដាក់ឈ្មោះកូនថា "តារា" ទៅវិញ ត្បិតគេច្រើន គិតថា "តារា" មានន័យខ្ពស់ប្រសើរជាង "ផ្កាយ" ដែលជាពាក្យរយ រាយសាមញ្ញ ។ ចំដែនទៀ អ្នកដែលរស់នៅក្នុងវណ្ណៈឋានៈអភិជន វណ្ណៈមន្ត្រី វណ្ណៈក្សត្រ គេច្រើនមានជំនឿទៅលើលោកគ្រូសង្ក្រាជ ព្រះភិក្ខុល្បីៗប្រចាំវត្ត ដែលគេគោរពនិងមានជំនឿលើព្រះអង្គ ឲ្យដាក់ឈ្មោះកូនចៅរបស់គេ ឬ ឈ្មោះញាតិឯទៀតដែលគេស្រឡាញ់

ឧទាហរណ៍ ដូចជាដាក់ឈ្មោះអោយកូនគេថា ថា"តារាឫទ្ធិ តារារង្សី តារាស្មី ច័ន្ទតារា" ទៅតាមក៏រិតអក្សរសាស្ត្របាលីសំស្រ្កឹត របស់ព្រះគ្រូដែលយល់ដឹងនូវជំរៅអត្ថន័យរបស់ពាក្យ ដើម្បីតម្រូវទៅតាមទឹកចិត្តនិងសេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅរបស់ឪពុកម្តាយ ។ ព្រមពេលជាមួយគ្នានេះដែរ អ្នកនិពន្ធខ្លះក៏នៅមានគតិវិន័យខ្ពង់ខ្ពស់ ក្នុងការជ្រើសរើសចំណងជើងអោយសៀវភៅរបស់ខ្លួន ។ អ្នកនិពន្ធទាំងនោះច្រើនជ្រើសរើសយកតែនាមល្អៗ ពាក្យពេចន៍ល្អប្រពៃ ជាចាំបាច់ មកបោះត្រាជាឈ្មោះអោយសំណេររបស់គេ ត្បិតគេមានជំនឿថា ចំណងជើងល្អជាឆ្នាក់ទាក់រាសីល្អដល់សៀវភៅរបស់គេ ។

តាមការពិត ការដែលយើងប្រើភាសាប្រពៃដាក់នាមឲ្យចំណងជើងបានពិរោះសមសួន គឺជាវិធីមួយសំរាប់ទាក់ទាញចិត្តអ្នកអានអោយចង់ស្វែងយល់អត្ថរស ដែលលាក់នៅខាងក្នុងសៀវភៅរបស់ខ្លួន ព្រោះអ្នកអាននឹងគិតថា កាលបើចំណងជើងមានភាពផ្ចិតផ្ចង់មានរបៀបបែបនោះ ច្បាស់ជាអ្នកនិពន្ធរូបនោះបានសម្រាំងសម្រិតស្នាដៃរបស់ខ្លួនណាស់ ហើយបើដូច្នោះពិតមែន សាច់រឿងប្រាកដជាប្រកបដោយ អត្ថន័យ អត្ថរសប្រសើរគួរឲ្យចង់អានមិនខាន ។

មួយវិញទៀត ការដាក់នាមខ្ជីខ្ជាអោយសៀវភៅដែលខ្លួនបានចងក្រង ជួនកាល ក៏ជាការបង្ហាញនូវភាពធ្វេសប្រហែសរបស់អ្នកនិពន្ធផង បង្ហាញនូវកិរិយាមារយាទ ឫគំនិតសើរើមមើមមាយរបស់អ្នកនិពន្ធផង ។ កាលបើចំណងជើងមានគតិសើរើ អ្នកអានក៏នឹងច្រឡំគិតថាសាច់រឿងនៅក្នុងសៀវភៅ ក៏ប្រហែលជាដូចគ្នាដែរ ថ្វីបើម្ចាស់សំណេរមួយនោះបានចាយពេលប្រឹងប្រែងសរសេរ អស់ពីទឹកចិត្តរបស់គេក៏ដោយ ។ នៅពេលនោះ អ្នកអានខ្លះអាចបែរដើរគេចសៀវភៅមួយក្បាលនោះ ដោយមិនទាន់ទាំងបានអាន

សេចក្តីនៅក្នុងសំណេរនៅឡើយ ។ នោះហើយលទ្ធផលនៃភាពធ្វេសប្រហែសរបស់អ្នកនិពន្ធ ដែលអាចនាំអោយមានការស្រេកស្រុតចំនួនអ្នកអានមួយចំនួន ព្រោះតែគេមិនបានប្រុងប្រយ័ត្នអោយហ្មត់ចត់ជាមុន ក្នុងការជ្រើសចំណងជើងដល់សៀវភៅរបស់ខ្លួន ។

<u>ក២. អត្តសញ្ញាណរបស់សៀវភៅ</u> ៖

ចំណងជើងគឺការពូតផ្តុំរបស់អត្ថន័យនិងអត្ថរសរបស់សាច់រឿងនិពន្ធទាំងមូល ពោលគឺ ចំណងជើងជាប្រស្នានាំចិត្តអ្នកអានអោយរសាប់រសល់ចង់អាននូវអត្ថរសនៃស្នាដៃនិពន្ធមួយនោះ ចៀសមិនបាន ។ អ្នកនិពន្ធទាំងឡាយគប្បីចងចាំថា ចំណងជើងរបស់សៀវភៅនិមួយៗមានសារៈសំខាន់ណាស់ ត្បិតចំណងជើងមួយ ជាអត្តសញ្ញាណរបស់សៀវភៅមួយទាំងមូល ។

ឧទាហរណ៍ដូចជា សៀវភៅមួយក្បាលមានចំណងជើងថា វិជ្ជាកាត់ដេរខោអាវខ្មែរបុរាណនិងសម័យ មានន័យថាសៀវភៅនោះជាសំណៅប្រមូលផ្តុំនូវវិធីប្លែកៗ ក្នុងការបង្រៀនអ្នកអានអោយរៀនកាត់ដេរខោអាវម៉ូដបុរាណនិងម៉ូដសម័យ ។ ឧបមាថាបើសិនជាសំណេររបស់អ្នកនិពន្ធនៅក្នុងសៀវភៅមួយនោះ មិនឆ្លើយតបនិងខ្លឹមសាររបស់ចំណងជើង ដូចជាសៀវភៅដែលមានចំណងជើងថា វិធីបង្រៀនកាត់ដេរ តែនៅក្នុងសៀវភៅ មិនមានបង្ហាញ អំពីរបៀបកាត់ដេរផ្តុំម៉ូដអាវទៅវិញ ។ នោះអ្នកអានអាចសន្មតថា អ្នកនិពន្ធរូបនោះមិនរក្សាសច្ចភាព អោយចំណងជើងសៀវភៅរបស់ខ្លួន ពោលគឺ សៀវភៅមួយច្បាប់នោះ ជាសៀវភៅមួយក្បាលដែលវង្វេង អត្តសញ្ញាណ តែម្តង ។

ហេតុដូច្នេះហើយ អ្នកនិពន្ធទាំងឡាយគប្បីប្រុងប្រយត្ន័បំផុត ក្នុងការដាក់នាម ដាក់ចំណងជើងអោយសំណេររបស់ខ្លួន ឲ្យសមស្របទៅនិងអត្ថន័យនៅក្នុងសាច់រឿង ។

នៅសម័យកាលបច្ចុប្បន្ន ដែលគេប្រើម៉ាស៊ីនកំព្យូទ័រជាយានជួយសម្រាលការងារនានា គេនិយមប្រើតួលេខជា "បារខូដ" (bar code) ដើម្បីជាសញ្ញាកត់សំគាល់អត្តសញ្ញាណ ឬ ចំណងជើងរបស់សៀវភៅនិមួយៗ ពេលគេដំកល់សៀវភៅទាំងនោះទុកនៅក្នុងបណ្ណាល័យជាតិ បណ្ណាល័យសាលា បណ្ណាគារក្នុងប្រទេសនិងក្រៅប្រទេស ជាដើម ។ លេខបារខូដនិមួយៗជាលេខអត្តសញ្ញាណតំណាងអោយចំណងជើងរបស់សៀវភៅមួយ ដែលបានទទួលការអនុញ្ញាតិពីបណ្ណាល័យជាតិ ដើម្បីបោះពុម្ពរួចហើយ ។

ខាងក្រោមនេះ គឺជាគម្រូលេខអត្តសញ្ញាណរបស់សៀវភៅមួយក្បាល ៖

ISBN 978-0-7334-2609-4

9780733426094

<u>ក៣. ការដាក់ពាក្យសុំលេខអត្តសញ្ញាណ</u> ៖

នៅប្រទេសកម្ពុជា កវីនិពន្ធ ឬគន្ថការីទាំងឡាយ អាចដាក់

ពាក្យសុំលេខអត្តសញ្ញាណនេះ នៅមន្ទីរបណ្ណាល័យជាតិ ដែលមាន អសយដ្ឋានដូចខាងក្រោមនេះ ៖

===================================

បណ្ណាល័យជាតិកម្ពុជា
លេខ ៩២ ផ្លូវគ្រីស្តូហ្វ័រ ខណ្ឌដូនពេញ ក្រុងភ្នំពេញ
ទូរស័ព្ទ ០២៣-៤៣០-៦០៩
០១២-៨៣១-២០៤
អ៊ីមែល mony@bnc-nlc.info

===================================

នៅពេលដាក់ពាក្យសុំលេងអត្តសញ្ញាណនេះ អ្នកនិពន្ធត្រូវបង់ពន្ធបន្តិចបន្តួច ជារៀងរាល់ឆ្នាំ ដើម្បីរក្សាលេខអត្តសញ្ញាណ អោយនៅមានជំនាប់សុពលភាពពេញលេញជាអចិន្ត្រៃយ៍ នៅក្នុងបណ្តាញបណ្ណាល័យ និងបណ្ណាគារនានាក្នុងស្រុក និងនៅអន្តរជាតិ ។

<u>ខ. អំពីការរចនាក្របនិងការជ្រើសរើសសន្លឹកក្រប</u> ៖

<u>ខ១. ក្របសំរាប់សៀវភៅសិក្សានិងអប់រំ</u> ៖

ចំពោះសៀវភៅសិក្សាសំខាន់ដូចជាការសរសេររចនានុក្រមឬសំណៅសំខាន់ៗ ដែលមានប្រយោជន៍ដល់ពលរដ្ឋខ្មែរទូទៅ ហើយដែលនឹងត្រូវរក្សាយូរយារទៅមុខទៀត គេតែងតែបោះពុម្ពក្របក្រាស់ៗ ហើយមាំ ត្បិតសៀវភៅនោះនឹងត្រូវយកមកប្រើច្រើនញឹកញាប់ ម្ល៉ោះហើយ ការបោះពុម្ពក្របស្តើងៗ ពិតជាមិនអាចរក្សាអាយុសៀវភៅអោយគង់វង្ស បានយូរអង្វែងឡើយ ។ សំណៅសិក្សាខ្លះក៏ត្រូវបានបោះពុម្ពនៅក្នុងក្របស្តើងៗ ល្មមៗ ដោយយោងទៅតាមថវិកាបោះពុម្ព តាមការប្រើច្រើនឬតិច តាមឆ្នាំ

សិក្សា ឬតាមសេចក្តីត្រូវការរបស់សិក្ខាជនក្នុងសាលា ។ ភាគច្រើន សៀវភៅសិក្សាទាំងនោះ មិនសូវមានផ្តិតរូបភាពញីរញ៉ៃសាំញ៉ាំ នៅលើសំបកក្រុបទេ ដើម្បីកុំអោយអ្នកអានបែកអារម្មណ៍ឆ្ងាយពីការសិក្សា ដូច្នេះអ្នកនិពន្ធ ឬក្រុមនិពន្ធ ច្រើនជ្រើសរើសដាក់តែចំណងជើង ឈ្មោះអ្នកនិពន្ធ និងរូបភាពបន្តិចបន្តួច បើសិនជាមាន គឺគ្រាន់នឹងពន្យល់អត្ថរសនៅក្នុងសៀវភៅ តែប៉ុណ្ណោះ ។

<u>១២. ក្របសៀវភៅរឿងនិងទស្សនាវដ្តី</u> ៖

នៅប្រទេសកម្ពុជាបច្ចុប្បន្ន អ្នកនិពន្ធដែលនៅរក្សាការរចនាក្របដូចកាលជំនាន់សង្គមរាស្ត្រនិយម ឬសង្គមសាធារណរដ្ឋ ក៏នៅមានចំនួនច្រើនរាប់មិនអស់ តែក៏មានអ្នកនិពន្ធដទៃទៀតដែរដែលមានការអភិវឌ្ឍន៍ផ្លាស់ប្តូរម៉ូដប្លែកៗថ្មីៗ ។ ខ្លះបែកប្រាជ្ញឆ្នៃការរចនាក្របដោយសិល្ប:បែបខ្មែរ ខ្លះទៀតក៏ចម្លងការរចនាក្របបែបអឺរ៉ុប ឬបែបអាមេរិក ជាដើម ។

តាមធម្មតា ការរចនាក្របនិមួយៗសុទ្ធតែយោងទៅតាមចំណុចច្រើនយ៉ាងដូចជា ៖

- ចំណងជើងនិងអត្ថន័យរបស់អត្ថបទនៅក្នុងសៀវភៅ
- សង្គមអ្នកអាន
- ឆន្ទ:របស់អ្នកនិពន្ធ
- ស្នាដៃទេព្យកោសល្យរបស់ជាងរចនា
- មធ្យោបាយនិងសម្ភារ:សំរាប់ការរចនាក្រប

ឧទាហរណ៍ដូចជា សៀវភៅមួយក្បាល អាចមានការរចនាក្របបែបខុសៗគ្នា ។ ខ្លះរចនារូបភាពអោយស្របតាមសាច់រឿងរបស់សៀវភៅ ។ ខ្លះទៀតរចនាតាមរសជាតិចំណាប់អារម្មណ៍របស់អ្នកអាន ដូចជាការដាក់រូបភាពអាក្រាតលេចមុខលេចក្រោយ ដើម្បីទាក់ទាញសម្រើបអារម្មណ៍របស់អ្នកអាន ។ ខ្លះទៀតរចនាក្រប

អោយស្របនឹងឆន្ទៈរបស់ខ្លួនដែលជាអ្នកនិពន្ធ ដូចជាដាក់រូបភាព ឬភាសា ដែលផ្តោតភ្ជាប់នូវអារម្មណ៍របស់អ្នកនិពន្ធ នៅលើក្រប សៀវភៅតែម្តង ។ ខ្លះទៀតពឹងលើជាងគំនូរអោយបញ្ចេញស្នាដៃ តាមដែលគេចង់បាន ។ ចែដន្យ ជាងគំនូរខ្លះដែលពុំមានទេព កោសល្យគ្រប់គ្រាន់ សំរាប់រចនាក្របអោយសមតាមសាច់រឿងបាន ក៏ចេះតែរចនាតាមតែអាចធ្វើបានទៅ ។ នៅស្រុកខ្មែរឥឡូវនេះ អ្នកនិពន្ធខ្លះនៅនិយមការរចនាក្រប ដោយពឹងផ្អែកលើជាងគំនូរ ផាត់រូបគូសវាស ដូចកាលពី៣០-៤០ឆ្នាំមុននៅឡើយ ។ ខ្លះក៏វិវត្ត ទៅមុខ តាមកាលសម័យដែលប្រើគ្រឿងកំព្យូទ័រជាយាន សំរាប់ រចនាម៉ូដក្របស្អាតៗ ដើម្បីបោះពុម្ពទាក់ទាញអ្នកអានជាជំនួស វិញ ។

ថ្វីបើអ្នកនិពន្ធទាំងឡាយអាចមានសិទ្ធិសេរីភាពគ្រប់គ្រាន់ នឹង ជ្រើសរើសម៉ូដប្លែកៗ សំរាប់រចនាក្របសៀវភៅរបស់ខ្លួនក៏ដោយ ក៏អ្នកនិពន្ធទាំងឡាយ គួររក្សាព្រំដែននៃការរចនាម៉ូដក្របរបស់ខ្លួន អោយសមស្របតាមសង្គមអ្នកអានដែរ ។ ឧទាហរណ៍ថា បើអ្នក និពន្ធម្នាក់នោះសរសេរអំពីរឿងកុមារ គួរណាស់តែរចនាក្របអោយ សមតាមវ័យរបស់អ្នកអាន មិនត្រូវរចនាក្របដែលបង្កអោយមាន សម្រើបខុសវ័យនោះទេ ។ ម្យ៉ាងទៀត បើសិនជាសាច់រឿងមាន បង្កនូវភាពហឹង្សាទៅលើមនុស្សណាមួយ ឬការចាប់រំលោភផ្លូវភេទ លើក្មេង លើនារីជាដើម មិនគួរអ្នកនិពន្ធយកគំនូររចនាពាលា បែប នោះមករចនានៅលើក្របសៀវភៅរបស់ខ្លួន ដើម្បីទាក់ទាញ អារម្មណ៍អ្នកអានឡើយ ត្បិតនោះជាការបង្ហាញនូវអំពើយង់ឃ្នង បង្កនូវភាពរន្ធត់តក់ស្លុត និងបញ្ចេញការប្រមាថទៅលើអារម្មណ៍ របស់អ្នកអានតែម្តង ជាពិសេសបើអ្នកអាននោះជាកុមារ ជាស្ត្រី ភេទ ជាជនរងគ្រោះ ឬ ជាសាច់ញាតិរបស់ជនដែលរងគ្រោះ

ដោយការចាប់រំលោភ ឬដោយអំពើព្រៃផ្សៃណាមួយ ។ ដូច្នេះ អ្នកនិពន្ធគួររក្សាព្រំដែនសីលធម៌របស់ខ្លួនក្នុងរង្វង់មួយ ដែលអ្នកអានទាំងឡាយគ្រប់ៗគ្នា គោរពហើយអាចទទួលយកបាន ទាំងស្នាដៃ និងឆន្ទៈរបស់អ្នកនិពន្ធ ដោយមិនមានអារម្មណ៍ទើសទាល់នៅក្នុងដួងចិត្តរបស់គេ ។

ហេតុដូច្នេះ ចំពោះអ្នកនិពន្ធទាំងឡាយ ដែលមានជំនឿមុតមាំទៅលើទឹកដមស្នាដៃនិពន្ធរបស់ខ្លួន ទៅលើសុឆន្ទៈរបស់ខ្លួន ទៅលើកម្រិតវប្បធម៌របស់ខ្លួន នោះគេមិនត្រូវប្រឹងខំស្វះស្វែងរកការរចនាក្របបែបកិរិតវប្បធម៌យ៉ាងរហេមរហាម អោយមកជួយផ្សាយស្នាដៃរបស់គេឲ្យល្បីនោះឡើយ វៀរលែងតែអ្នកនិពន្ធទាំងនោះពុំទាន់មានជំនឿថា ស្នាដៃរបស់ខ្លួនមានប្រសិទ្ធិភាពនៅឡើយ ទើបគេខំប្រើការរចនាក្របសម្រុតខ្លឹមវប្បធម៌និងសីលធម៌ ដើម្បីជួយទាញចំណាប់អារម្មណ៍របស់អ្នកអានអោយបានច្រើនមកវិញ ។

<u>គ. អំពីការផ្សាយពាណិជ្ជកម្មនៅលើក្រប</u> ៖

នៅជំនាន់ថ្មីៗនេះ អ្នកនិពន្ធអាជីពខ្លះផ្តោតស្នាដៃរបស់ខ្លួនទៅលើប្រាក់ចំណូលខ្លាំងពេក ទើបខ្លះសំរេចចិត្តអនុញ្ញាតអោយមានការបោះពុម្ពផ្សាយពាណិជ្ជកម្មលើសៀវភៅរបស់ខ្លួន សូម្បីតែខ្លួនគេបានដឹងហើយឃើញហើយថា ការផ្សាយពាណិជ្ជកម្មនោះមិនល្អសមរម្យស្របជាមួយឆន្ទៈមនសិការ នៅក្នុងស្នាដៃរបស់ខ្លួននោះ ក៏ដោយ ។

ឧទាហរណ៍ដូចជា អ្នកនិពន្ធសរសេរអំពីអត្ថបទអប់រំយុវជនយុវនារីអោយដើរនៅក្នុងផ្លូវត់សីលធម៌ មារយាទប្រពៃ សមជាកុលបុត្រ កុលធីតារបស់គ្រួសារ តែគេបែរជាបោះពុម្ពផ្សាយនៅលើក្របសៀវភៅរបស់គេ នូវដំណឹងពាណិជ្ជកម្មលក់ស្រា លក់បៀរ លក់បារី លក់ស្រោមអនាម័យ ដោយមានតួអង្គយុវជនយុវនារីរូប

ស្រស់ស្អាតក្មេងៗ មកសំដែងនៅលើអត្ថបទផ្សាយពាណិជ្ជកម្មនោះ ទៅវិញ ។

ទង្វើរបស់អ្នកនិពន្ធលក្ខណ:ខាងលើនេះ បានសបញ្ជាក់អោយ ឃើញនូវចំណាប់ចិត្តរបស់អ្នកនិពន្ធថា ការសរសេររបស់គេនោះ មិនមែនដើម្បីបំរើប្រយោជន៍សាធារណ៍ទេ តែជាការបម្រើសេចក្តី ត្រូវការសួនតួ គឺស្វែងរកប្រាក់ចំណូលអោយបានខ្ពស់ ដោយមិន គិតពីតម្លៃអក្សរសិល្ប៍របស់ខ្លួនប៉ុន្មានឡើយ ។

ប៉ុន្តែ អ្នកនិពន្ធទាំងឡាយមិនមានឆន្ទ:ទាញយកផលប្រយោជន៍ ពីស្នាដៃរបស់ខ្លួន ដូចៗគ្នានោះឡើយ ។ ខ្លះនិពន្ធបោះពុម្ពផ្សាយ ស្នាដៃក្នុងគោលបំណងតែម្យ៉ាង គឺផ្សព្វផ្សាយឧត្តមគតិរបស់គេ ចែកចាយជូនញាតិសិក្សា ។ ខ្លះទៀតក៏សរសេរដើម្បីក្រពះ ។ ខ្លះ សរសេរ ដើម្បីបន្ធូរភាពស្មុគស្មាញនៅក្នុងចិត្ត នៅក្នុងអារម្មណ៍ របស់គេ ។ ខ្លះសរសេរដើម្បីចងក្រងទុករឿងរបស់ខ្លួន ចែកចាយ អោយកូនចៅរបស់គេអោយបានយល់នឹងគ្រប់គ្នា ។ ព្រមពេលជា មួយគ្នានេះដែរ ខ្លះក៏ខំសញ្ជឹងស្វែងរកផលថវិកា សំរាប់បោះពុម្ព ផ្សាយសៀវភៅរបស់ខ្លួនពីមជ្ឈដ្ឋានក្រៅ នៅពេលដែលអ្នកខ្លះ ទៀត ចាយប្រាក់ផ្ទាល់ខ្លួន ដើម្បីបោះពុម្ពជាប្រយោជន៍សាធារណ៍ ។

ទោះបីយ៉ាងណាក៏ដោយ អ្នកនិពន្ធទាំងឡាយ គួរអោយតម្លៃ ទៅលើតម្លៃឧត្តមគតិនៅក្នុងស្នាដៃរបស់ខ្លួន យ៉ាងខ្ពង់ខ្ពស់ប្រសើរ ជាជាងចំណូលប្រាក់កម្រៃមួយពេលៗ ដែលខ្លួនទទួលយកបានពី ការ អនុញ្ញាត្តិអោយបោះពុម្ពផ្សាយពាណិជ្ជកម្ម លើក្របសៀវភៅ របស់ខ្លួន ត្បិតការបោះពុម្ពផ្សាយពាណិជ្ជកម្មនៅលើក្រប ដែល ប្រឆាំងនឹងឆន្ទ:របស់អ្នកនិពន្ធនៅក្នុងសៀវភៅ ជាការបង្ហាញនូវ ស្មារតីធ្វេសប្រហែសរបស់អ្នកនិពន្ធ ដែលមិនផ្តល់ក្តីគោរពចំពោះ មនសិការរបស់ខ្លួនឯង ហើយក៏ជាកត្តាបង្ហាញ នូវស្មារតីធ្វេស

ប្រហែសរបស់អ្នកនិពន្ធ ចំពោះសង្គមអ្នកអានទាំងមូល ។ ពេលនោះ ប្រិយភាពនិងតម្លៃនៃស្នាដៃរបស់អ្នកនិពន្ធនោះ នឹងស្រកស្រុតមួយកម្រិតមកវិញ គួរអោយសោកស្តាយ ។

========================================

# ភ្លឺអ្វីមិនស្មើព្រាជ្ញ
# ផ្កាអ្វីមិនស្មើនិងសតិ

អ្នកស្រី កែវចន័្ទបូរណ៍

========================================

=========================================

# ជំពូកទី៥
# សច្ចភាពនិង
# អត្ថរសរបស់សំណេរ

==========================================

មុននឹងសំណេរនិមួយៗអាចមានទឹកដម ទាក់ទាញប្រជាប្រិយភាពនិងចំណាប់អារម្មណ៍ពីអ្នកអានអោយបានជោគជ័យប្រសើរបានលុះណាតែអត្ថបទនិពន្ធន៍នោះមានសច្ចភាព និងមានអត្ថរសល្អខ្ពង់ខ្ពស់ អាចនាំចិត្តអ្នកអានអោយត្រេកត្រអាលជក់អារម្មណ៍ ចំពោះអត្ថន័យដ៏មានខ្លឹមសាររបស់សំណេរ នៅក្នុងវេលាដែលគេកំពុងអាន រួចហើយក៏មានអំណរសោមនស្ស និងមានមោទនភាពចំពោះខ្លួនឯង ដែលបានជ្រើសរើសសៀវភៅនោះយកមកអាន ។ ជាពិសេសបំផុត គឺគេមិនខ្មាសអៀននឹងហុចសៀវភៅមួយក្បាលនោះ ទៅញាតិមិត្តដទៃទៀតគ្រប់វ័យ អោយអានយ៉ាងពេញមុខបន្ទាប់ពីគេបានអានសំណេរចប់ហើយ ។

<u>ក. សច្ចភាពរបស់សំណេរ</u> ៖

សច្ចភាពរបស់សំណេរគឺជាការរក្សាសាច់រឿង អោយសមហេតុសមផល ។ ថ្វីបើសាច់រឿងនិពន្ធនោះជារឿងប្រឌិតក៏ដោយ ក៏សំណេរនោះត្រូវរក្សាភាពសុពលភាព នៃការសមហេតុសមផលដើម្បីបង្កជំនឿនិងទំនុកចិត្តរបស់អ្នកអាន ទៅលើសាច់រឿង ។

<u>ឧទាហរណ៍ទីមួយ</u> ៖

ក្នុងវ័យ១៩ឆ្នាំ កញ្ញា ពៅទេវី គឺជាមេធាវីដ៏ស្រស់ស្អាតម្នាក់
ដែលមានស្នាដៃយ៉ាងល្បីឆ្មើម នៅទីក្រុងភ្នំពេញ។

យើងគិតសិនទៅមើល ថាតើការសរសេរនេះខាងលើនេះ មានសច្ចភាពឬទេ ? ចម្លើយគឺសំណោរមួយនេះពិតជាខ្វះសច្ចភាពទាំងស្រុងតែម្តង ត្បិតអ្នកអានគ្រប់រូបនឹងឆ្ងល់ថា តើនាងបញ្ចប់មធ្យមសិក្សានៅអាយុប៉ុន្មាន ហើយត្រូវចាយពេលសិក្សាប៉ុន្មានឆ្នាំទៀតនៅមហាវិទ្យាល័យច្បាប់ មុននឹងប្រឡងអាចជាប់ចេញធ្វើការជាមេធាវី ។ បន្ទាប់មកទៀត តើនាងត្រូវចាយពេលធ្វើការចំនួនប៉ុន្មានឆ្នាំ ដើម្បីបង្ហាញនូវស្នាដៃទេពកោសល្យនិងចំណេះរបស់ខ្លួន យ៉ាងមធ្យ័តល្អល្អះ ក្នុងពេលចេញហ្វឹកហ្វឺនការងារ មុននឹងអាចក្លាយជាមេធាវីយ៉ាងល្បីឆ្មើមដូច្នេះបាន ។ ដូចនេះ អ្នកនិពន្ធខាងលើបានភ្លេចគិតបូកលេខចំនួនអាយុរបស់តួអង្គនារីនោះ អោយសក្តិសមនឹងមុខនាទីការងាររបស់នាង មានន័យថាគេមិនចេះតែអាចដាក់អាយុតាមតែនឹកឃើញនោះទេ ។

<u>ឧទាហរណ៍ទីពីរ</u> ៖

នៅក្នុងការសរសេរចងក្រងរឿងព្រេងបុរាណរបស់ខ្មែរ ដូចជារឿង ធនញ្ជ័យ ជាដើម ដែលអ្នកនិពន្ធប្រឌិតអោយអ្នកប្រាជ្ញស្រុកចិនសួរសំនួរដេញប្រាជ្ញានាយជ័យដ៏ឆ្លៀវឆ្លាតខុសគេខុសឯង នៅក្នុងប្រទេសខ្មែរ ថា តើនៅក្នុងផ្លែឪឡឹកនិមួយៗមានគ្រាប់ប៉ុន្មាន ? លុះធនញ្ជ័យទាល់ច្រករកចម្លើយមិនឃើញ ក៏ទៅលោតទឹកសម្លាប់ខ្លួន ។ ចៃដន្យល្អ ធនញ្ជ័យក៏បានទៅស្តាប់ឮអ្នកប្រាជ្ញចិនពិគ្រោះគ្នាអំពីចំនួនគ្រាប់នៅក្នុងផ្លែឪឡឹកទាំងនោះ ។ ស្អែកឡើង ធនញ្ជ័យក៏ឈ្នះការប្រកួតភ្នាល់ជាមួយអ្នកប្រាជ្ញស្រុកចិននោះទៅ ។

តើការប្រឌិតនេះមានសច្ចភាពដែរឬទេ ?

ចម្លើយគឺ ថ្វីបើរឿងធនញ្ជ័យ ជារឿងប្រឌិតនោះក៏ដោយ តែសាច់រឿងក្នុងសំណោរនោះជាសាច់រឿងក្នុងសម័យកាលដែលមនុស្សមិនមានចេះសិល្ប៍មន្តអាគមជប់ផ្លែឈើអោយក្លាយជាអ្វីៗ បានតាម

ចិត្តនោះបានទេ ។ ដូច្នេះ មនុស្សណាក៏ដោយ ក៏មិនអាចដឹង ប្រាកដថា ក្នុងផ្លែឪឡឹកនិមួយៗមានគ្រាប់ប៉ុន្មាន នៅមុនពេលដែល គេពុះបំបែកផ្លែរាប់គ្រាប់នោះឡើយ ។ ឯការដែលអ្នកនិពន្ធបែរ ទៅប្រឌិត អោយមានភាពអច្ឆរិយៈ ដោយអោយអ្នកប្រាជ្ញចិនអាច ដឹងមុននូវចំនួនគ្រាប់ឪឡឹក ជាក់ប្រាកដ មុនពេលពុះឪឡឹករាប់ គ្រាប់នោះ គឺជាការសរសេរប្រឌិតសាច់រឿង ដោយមិនរក្សា សច្ចភាពអ្វីបន្តិចសោះឡើយ ។

ម្យ៉ាងវិញទៀត អ្នកនិពន្ធបានប្រឌិតអោយធនញ្ជ័យមានប្រាជ្ញ ឆ្លៀវឆ្លាតបំផុត ក្នុងការស្វែងរកមធ្យោបាយដោះទាល់ មួយគ្រាៗ ថ្វីបើការដោះស្រាយនោះជាការដោះស្រាយ ដោយលាយភាពកម្លៅ ខ្វះសតិក៏ដោយ ក៏នាយជ័យមិនទាល់ប្រាជ្ញានឹងដោះស្រាយប្រស្នា សូម្បីតែជាមួយនឹងការភ្ញាល់របស់ស្តេចខ្មែរ ។ ស្រាប់តែក្រោយមក អ្នកនិពន្ធបែរផ្លាស់ឥទ្ធិពលស្លាបប៉ាកកា មកសរសេរអោយធនញ្ជ័យ ប្រែក្លាយជាល្ងង់ទាល់ច្រក ទាល់ប្រាជ្ញ ចំពោះសំនួររបស់អ្នកប្រាជ្ញ ស្រុកចិន រហូតដល់ទៅហ៊ានប្រព្រឹត្តកម្លៅ ដោយការលោតទឹក សម្លាប់ខ្លួនយ៉ាងឥតអាមាសទៅវិញ ។ ការនិពន្ធបែបនេះ ធ្វើអោយ បាត់បង់សច្ចភាពរបស់សាច់រឿង ដែលគេនិពន្ធអោយ ធនញ្ជ័យ មានប្រាជ្ញ មិនទាល់ច្រកនោះ អស់រលីងតែម្តង ។

<u>ឧទាហរណ៍ទីបី</u> ៖

ជានីជានារីស្រែចំការមួយរូបដែលឧស្សាហ៍រហ័សរហួន ក្នុង ការងារ មានប្រាជ្ញឈ្លាសវៃ មានរូបឆោមលោមពណ៌ស្រស់ស្អាត គួរជាទីពេញចិត្តបុរសក្នុងភូមិ មានចង្កេះរាវ ត្រគៀកខ្ពស់ ដំណើរ ល្វតល្វន់ មានសាច់ដៃទន់ល្មើយគួរអោយចង់កាន់ថ្នមថៃ...

យើងសូមសួរថា តើអ្នកនិពន្ធមានរក្សាសច្ចភាពរបស់សំណេរ ដែរឬទេ ?

ចម្លើយគឺការនិពន្ធមួយនេះខ្វះសច្ចភាពទៀតហើយ ព្រោះថា បើសិនជាមាណវីមួយរូបនោះជាអ្នកចំការ ធ្វើការយ៉ាងឧស្សាហ៍ រហ័សរហួន នោះម្រាមដៃ បាតដៃរបស់នាងពិតជាគគ្រាតគគ្រើម មិនខាន មិនមែនទន់ល្មើយដូចនារីទាំងឡាយ ដែលថែខ្លួនក្នុងម្លប់ លំនៅយ៉ាងស្រណុកសុខស្រួលនោះទេ ។ ម្យ៉ាងទៀត បើនាងជា អ្នកចំការធ្វើការរហ័សរហួនពិតមែន នាងប្រហែលជាគ្មានពេលមក ធ្វើដំណើរបង្ហាញរាងល្វតល្វន់ទន់ភ្លន់អ្វីទាំងនោះដែរ ត្បិតអ្នកស្រែ ចំការដែលរហ័សរហួន តែងមានដំណើរមាំមួនរឹងប៉ឹងដូចអ្នកកីឡា មិនអាចនៅដើរអាល័យ រាប់ទងផ្កាតាមផ្លូវដូចកូនស្រីសេដ្ឋី ឬ រាជធិតា ម្ចាស់ក្សត្រិយ៍ នោះបានឡើយ ។

<u>ខ. អត្ថរសរបស់សំណេរ</u> ៖

ពាក្យសុភាសិតពីបុរាណបានថែងថា "អ្នកចេះដប់មិនស្មើនឹង អ្នកប្រសប់មួយ " មានន័យថា ការដែលយើងមានការចេះដឹងក្នុង ភាសាខ្មែរខ្ពស់ហើយ ទាំងអក្ខរាវិរុទ្ធនិងវេយ្យាករណ៍ ព្រមទាំងករិត វប្បធម៌សីលធម៌ខ្មែរយ៉ាងប្រពៃហើយ មិនមែនបានន័យថា យើង ទាំងអស់សុទ្ធតែអាចចាត់ទុកបានថា ជាអ្នកកវីនិពន្ធម្នាក់យ៉ាងប៉ិន ប្រសប់នោះបានឡើយ ។ ការនិពន្ធសំណេរអត្ថបទនិមួយៗត្រូវការ ទេពកោសល្យច្រើនណាស់ ដើម្បីអោយសាច់រឿងក្នុងអត្ថបទមាន ទឹកដម មានអត្ថរសខ្លឹមសារ គួរជាទីចាប់អារម្មណ៍ ។ ការដែល យើងនិពន្ធត្រឹមតែប្រើពាក្យពេចន៍ពិរោះ ភាសាល្អប្រពៃ តែខ្វះការ បញ្ចូលអារម្មណ៍អោយសំណេរមានព្រលឹង ក៏ស្មាដៃមួយនោះមិន មានអត្ថរសទឹកដមពេញលេញដែរ ។ ម្យ៉ាងវិញទៀត បើសិនជា អ្នកនិពន្ធនោះបញ្ចូលអារម្មណ៍ផ្ទាល់ខ្លួនខ្លាំងជ្រុលហួសបរិមាណ ដូច ជា ការបញ្ចេញកំហឹងខ្លាំងពេក ស្រណោះស្រណោកខ្លាំងពេក ស្រើបស្រាលខ្លាំងពេក ឬស្បាខ្លាំងពេក ហើយភ្លេចគិតដល់អារម្មណ៍

របស់អ្នកអាននោះ ក៏អាចធ្វើអោយស្នាដៃរបស់ខ្លួន ស្រកស្រុតនូវអត្ថរស មួយកម្រិតមកវិញដែរ មិនខុសអ្វីពីសម្លម្ហូយឆ្នាំងដែលដាក់អំបិលជ្រុលដៃ ដាក់ស្ករជ្រុលដៃ ឬដាក់ម្ទេសជ្រុលដៃនោះដែរ ។

<u>ឧទាហរណ៍</u>៖

អ្នកនិពន្ធខ្លះដែលធ្លាប់រស់នៅរងភាពខ្លោចផ្សាក្នុងជីវិត ដោយសារឥទ្ធិពលនយោបាយក្នុងប្រទេសខ្មែរ ឬក៏មានសមាជិកក្រុមគ្រួសារ ដែលធ្លាប់ទទួលរងគ្រោះ ដោយសារអំណាចផ្តាច់ការរបស់សង្គមអ្នកនយោបាយ ឬក៏មាននិន្នាការនយោបាយមិនដូចគ្នានឹងអ្នកកាន់កិច្ចការស្រុកទេសបច្ចុប្បន្នជាដើម តែងតែត្រងយកការឈឺចាប់ដ៏មហិមារបស់ខ្លួនទៅដាក់លើសំណេរនិពន្ធន៍ ដោយផ្តិតនូវអារម្មណ៍មុតមាំរបស់ខ្លួនយ៉ាងជ្រាលជ្រៅ ជាជាងសរសេរបំភ្លឺអំពីខ្លឹមសារនៃនយោបាយ ឬ ជាជាងការដោះស្រាយស្ថានការណ៍អោយធូរស្រាលសំរាប់អោយអ្នកអានស្តាប់ទៅវិញ ។

ដោយសារតែកម្លាំងអារម្មណ៍អ្នកនិពន្ធនោះមានកំស្វលខ្លាំងពេក អ្នកអានខ្លះក៏អាចទទួលអារម្មណ៍ធុញថប់ ចំពោះសំណេរមួយនោះ ព្រោះកំស្វលអារម្មណ៍របស់អ្នកនិពន្ធ អាចមានអនុភាពដុតរោលអារម្មណ៍អ្នកអាន អោយឆេះបានតាមរយៈទឹកខ្មៅដែលផ្តិតទៅលើក្រដាស ដោយខានមិនបាន ។

ក្នុងឧទាហរណ៍មួយទៀត អ្នកនិពន្ធខ្លះគិតថា ទាល់តែខ្លួនសរសេរអំពីរឿងដែលទាក់ទងនឹងរឿងនយោបាយ ទើបគេអាចហៅបានថា ជាអ្នកនិពន្ធដែលមានស្មារតីជាតិនិយម ម្ល៉ោះហើយគេច្រើនតែជ្រើសរើសសាច់រឿង ដែលមានស្ថានការណ៍នយោបាយដូចបេះបិទនឹងស្ថានភាពនយោបាយបច្ចុប្បន្ន ដែលខ្លួនគេកំពុងរស់នៅ ហើយក៏ប្រឌិតឈ្មោះតួអង្គនានាផ្សេងៗ ជាជំនួសឈ្មោះអ្នកនយោបាយពិតប្រាកដ ។ ថ្វីបើរឿងដែលគេកំពុងនិពន្ធនោះ ជា

រឿងប្រឌិតក៏ដោយ ក៏អ្នកនិពន្ធខ្លះនៅមិនព្រមដើរចៀសស្ថានភាពពិតក្នុងប្រទេស ដើម្បីស្វែងរកការប្រឌិតប្លែកៗ មកបញ្ចូលក្នុងសាច់រឿងរបស់ខ្លួនឡើយ ។

<u>គ. យោបល់ចំពោះអ្នកនិពន្ធទាំងឡាយ</u> ៖

តាមការពិតទៅ ការបង្ហាញនូវស្មារតីជាតិនិយមមិនចាំបាច់ប្រើក្បាច់ចំអក ក្បាច់ជេរ ក្បាច់រិះគន់ ក្បាច់តំអូញទូញយំស្រណោះស្រណោកសោកសៅអាល័យចំពោះជាតិអ្វីទាំងនោះឡើយ ត្បិតការសរសេរចំអកឡកឡឺយចំពោះស្ថានភាពស្រុកទេស គ្មានប្រយោជន៍ខ្លឹមសារអ្វី ក្រៅអំពីបង្កកំហឹងនិងការស្អប់ខ្ពើម អោយកាន់តែខ្លាំងឡើង រវាងគូបដិបក្ខទាំងឡាយនោះឡើយ ។ អ្នកនិពន្ធ ទាំងឡាយគប្បីតាំងខ្លួនជាភាគីកណ្តាល ដែលមានមន្តប្រាជ្ញអាចបង្ក្រាបរំលត់នូវភាពល្ងង់ខ្លៅ រំលាយទោសៈ មោហៈ ហើយបង្កបង្កើនស្មារតីមនសិការជាតិអោយកាន់តែខ្ពង់ខ្ពស់ ដោយមិនចាំបាច់ប្រើឱបាយវាយសម្រុក ធ្វើសង្គ្រាមប្រហារសង្គម ដោយភាសាញុះញង់អុជអាល ជាមួយអ្នកអានឡានាឡើយ ។ អ្នកនិពន្ធដែលមានស្នាដៃខ្ពស់ គឺជាអ្នកដែលអាចចងទំនាក់ទំនងភាគី ពីគ្រប់ជ្រុងជ្រោយ អោយធ្វើការជាមួយគ្នាបាន អោយទទួលគ្នាវិញជាញាតិ ជាមិត្តនឹងគ្នាបាន ហើយអាចសហការគ្នាបាន ក្នុងការស្វែងរកមាគ៌ាប្រសើរក្នុងការនាំជាតិខ្មែរ ឆ្ពោះទៅរកសន្តិភាព វឌ្ឍនភាព និងសុភមង្គល បានយ៉ាងប្រពៃបំផុត ។

អ្នកនិពន្ធទាំងឡាយគួរចងចាំដែរថា ជាតិជាសត្វស្រមោចរមែងស្រឡាញ់ស្ករដែលមានជាតិផ្អែម ។ យ៉ាងណាមិញ សំណេរនិពន្ធដោយខ្វះជាតិផ្អែមសំរាប់លាងអារម្មណ៍អ្នកអាន អោយគេទាំងនោះមានអារម្មណ៍រំភើបសោមនស្សរីករាយ ហើយមានមោទនភាព

ចំពោះខ្លួនឯងនោះ សំណេរមួយនោះនឹងស្រករសជាតិខ្លឹមសារ សំរាប់អ្នកអានក្រេបជញ្ជក់យក យ៉ាងឆ្ងុយឆ្ងោះដែរ ។

រីឯការបញ្ចូលរសជាតិផ្អែម ទៅក្នុងសំណេរនិមួយៗ មិនមែនជាការសរសេរបញ្ចោរចំពោះបុគ្គលណា ឬក្រុមបក្សណាទេ តែជាការសរសេរដែលធ្វើអោយមនុស្សទាំងឡាយ បានទទួលនូវគំនិតស្មារតីភ្លឺថ្លា ដោយសារភាសាពិរោះនៅក្នុងសំណេរ ដោយសារទឹកដមអត្ថន័យជ្រៅជ្រះ ដោយសារមនសិការជាកណ្តាល មិនកាន់ជើងស្ថានការណ៍ណាមួយ ឬក្រុមបក្សណាមួយ តែត្រូវប្រកាន់យកភាពសុទន្ធិ ភាពសន្តិ ភាពមធ្យ័ត និង ភាពស្ងប់នៅក្នុងការពន្យល់សាច់រឿងចំពោះអ្នកអាន ដើម្បីទាក់ទាញស្មារតីជាតិនិយមអោយត្រឡប់មកកន្លងយុត្តិធម៌មួយ ដែលពលរដ្ឋទូទៅនិងអ្នកដឹកនាំទូទៅអានហើយ អាចទទួលយកមកពិគ្រោះពិភាក្សាឬសិក្សាបានទាំងអស់គ្នា ដោយមិនមានកើតអារិចិត្តសៅហ្មងចំពោះអ្នកនិពន្ធ ឬចំពោះក្រុមបក្សណាមួយ ដែលមាននិន្នាការនយោបាយខុសៗគ្នា ។ នោះហើយ គឺអត្ថរសដ៏ផ្អែមពិតប្រាកដរបស់សាច់រឿង ។

ម្យ៉ាងវិញទៀត ការនិពន្ធសំណេរជាតិនិយម មិនចាំបាច់តម្រូវតែលើការសរសេរដែលទាក់ទងផ្នែកនយោបាយតែប៉ុណ្ណោះទេ តែអ្នកនិពន្ធនៅមានផ្លូវច្រើនទៀតរាប់មិនអស់ សម្រាប់ជ្រើសរើសសរសេរ ដូចជា វិធីរំលត់ហឹង្សានៅក្នុងគ្រួសារ វិធីការពារនិងព្យាបាលអ្នករងគ្រោះដោយគ្រឿងញៀន វិធីអប់រំកូនចៅក្នុងសម័យកាលសេរីនិយម វិធីរក្សាអនាម័យបរិស្ថាន អំពីរបៀបរកស៊ីចូលហ៊ុនគ្នាដើម្បីជោគជ័យ អំពីវិធីថែរក្សាសុខភាព អត្ថបទកំណាព្យអប់រំ អំពីវិន័យសីលធម៌ សំរាប់យុវជននារី អំពីវិធីសាងសង់ផ្ទះ អំពីវិធីបង្កើតអគ្គីសនី ដោយប្រើចរន្តខ្យល់ឬពន្លឺថ្ងៃ ។ល។ មានន័យថា អ្នកនិពន្ធអាចសរសេរអ្វីៗទាំងឡាយ ដែលអាចនាំនូវ

សារប្រយោជន៍ចំពោះជីវិតខ្មែរទូទៅ តាំងពីប្រជាពលរដ្ឋរហូតទៅដល់កម្រិតអ្នកដឹកនាំ គឺអត្ថបទទាំងឡាយដែលអាចជួយបណ្តុះពលរដ្ឋខ្មែរអោយដុះដាល រឹងមាំ ទាំងប្រាជ្ញាស្មារតី វិជ្ជាជីវៈ ទេពកោសល្យ និង ផ្នែកលុយកាក់ ដើម្បីជួយពលរដ្ឋខ្មែរ អោយក្លាយជាសសរយ៉ាងស្តុកស្តម្ភ សំរាប់ទ្រទ្រង់ជាតិ យ៉ាងប្រសើរឧត្តម ។ ស្នាដៃបែបនោះហើយដែលហៅថា ស្នាដៃប្រសិទ្ធ ដែលមានតម្លៃមិនតិចជាងកិច្ចការ របស់អ្នកនយោបាយដទៃទៀត ដែលកំពុងបម្រើជាតិ យ៉ាងសស្រាក់សស្រាំ នោះឡើយ ។

បន្ថែមពីលើនោះទៅទៀត សូមចងចាំថា អ្នកនិពន្ធគឺជាបុគ្គលដែលមានសេរីភាពជាងគេបង្អស់នៅលើលោកនោះ ព្រោះគេមានសេរីភាពអាចប្រើអារម្មណ៍ ចិត្តគំនិតរបស់គេអោយហោះហើរទៅដល់ទីណាក៏បាន ប្រឌិតអ្វីក៏បានតាមចិត្តចង់ ។ មិនថា អ្នកនិពន្ធនោះ ចង់ប្រឌិតពីរឿងសម័យ រឿងបុរាណ រឿងអច្ឆរិយៈ រឿងវិទ្យាសាស្ត្រ ឬសរសេរពីរឿងពិតអ្វីទេ អ្នកនិពន្ធនិមួយៗ គប្បីរក្សាវិន័យយ៉ាងមធ្យ័ត ដូចជា មិនលួចចម្លងសំណៅពីអ្នកដទៃ មិនសរសេរអ្វីៗទាំងឡាយ ដែលចាក់ដោតបង្កកំហឹងនិងគំនុំវិវាទ ឬស្យាព្យាបាទរវាងគ្នានឹងគ្នា មិនសរសេរអ្វីដែលជាកំស្ទួលនាំមនុស្សអោយស្រើបស្រាលវង្វេងស្មារតី ប្រាសចាកសីលធម៌ ចាកសេចក្តីគោរពស្រឡាញ់ចំពោះឪពុកម្តាយ ចំពោះញាតិ ចំពោះជាតិ ចាកវិន័យតម្រាជាដើម ពោលគឺមិនសរសេរនូវអ្វីដែលបង្កស្មារតីអ្នកអាន អោយវង្វេងសតិ មនសិការ សីលធម៌ គុណធម៌ និងភាពសុចរិត ។ កាលបើអ្នកនិពន្ធអាចឈានមកដល់កម្រិតនេះបានហើយ នោះមានន័យថា អ្នកនិពន្ធកំពុងសាងស្នាដៃជាតិនិយមមួយដែលមានតម្លៃដ៏ពិសិដ្ឋ ចំពោះសង្គមជាតិ ហើយដែលអ្នកអាន

ទាំងឡាយគោរពទ្រទ្រង់នូវគោលគំនិតនោះ រហូតយូរលង់អង្វែង តទៅមុខទៀត ។

=========================================

**ភ្នែកបើក ឃើញជិត**

**ភ្នែកបិទ ឃើញឆ្ងាយ**

អ្នកស្រីកែវចន្ទ័បូរណ៍

=========================================

=========================================

# ជំពូកទី៦
# ការជ្រើសប្រធានបទ
# បែបបទនៃការដោះស្រាយបញ្ហា
# និងការវិភាគសុទ្ធិ

=========================================

១. ការជ្រើសរើសប្រធានបទ ៖

អ្នកនិពន្ធទាំងឡាយគួរចងចាំថា គេមិនចាំបាច់ជ្រើសរើសយកប្រធានបទធំៗពេកទេ សំរាប់ការចងក្រងសំណេររបស់ខ្លួន ព្រោះបើរើសប្រធានបទធំពេក នឹងនាំឲ្យអ្នកនិពន្ធពិបាកគ្រប់គ្រងសាច់រឿងផង ពិបាករកឱបាយស្រាយបំភ្លឺជូនសាច់រឿងផង ហើយក៏ពិបាករកចំណុចសម្រាប់បញ្ចប់សាច់រឿងរបស់ខ្លួនផង ។ កន្លងមកមានអ្នកនិពន្ធខ្លះ ដែលចូលចិត្តលើកបញ្ហាសាច់រឿងនយោបាយនៅកម្ពុជាបច្ចុប្បន្ន យកមកសរសេរ ដោយផ្តោតភ្ជាប់នូវវិបត្តិសង្គមគ្រប់ផ្នែកដូចជាវិបត្តិសេដ្ឋកិច្ច វិបត្តិការងារ វិបត្តិអនាធិបតេយ្យ វិបត្តិនៅក្នុងផ្នែកសិក្សាអប់រំ វិបត្តិល្បែងស៊ីសង វិបត្តិនៃអំពើពុករលួយក្នុងជួរមន្ត្រីជាន់ខ្ពស់ វិបត្តិផ្នែកគ្រប់គ្រងប្រទេស គ្រប់គ្រងខេត្ត វិបត្តិផ្នែកសាសនា វិបត្តិផ្នែកយោធា និងព្រំដែន ប្រទេស និងវិបត្តិផ្សេងៗទៀត រាប់រយបែប ។ល ។ លុះសរសេរយូរៗអំពីវិបត្តិច្រើនពេកទៅ អ្នកនិពន្ធក៏បែរមកជួបនឹងភាពទាល់ច្រកដោយខ្វះសមត្ថភាព ខ្វះការចេះដឹង ក្នុងការស្វែងរកកមធ្យោបាយដែលមានប្រសិទ្ធិភាព ដើម្បីដោះស្រាយវិបត្តិមហិមាទាំងឡាយនោះឲ្យប្រែក្លាយស្រាលមកវិញ នៅគ្រាចុងបញ្ចប់នៃសាច់រឿង ។ ដោយ

សារភាពទាល់ច្រកនោះ អ្នកនិពន្ធក៏ត្រូវទុកចោលសាច់រឿងសាំញាំទាំងនោះ អោយនៅគាំងកណ្តាលផ្លូវតែម្តង ។ ចំពោះស្នាដៃបែបនេះ គេមិនទាន់អាចចាត់ទុកបានថា ជាស្នាដៃដែលមានអត្ថរសខ្លឹមសារពេញលេញបានទេ ត្បិតសំណេរនៅមានសាច់រឿងត្រូវមានដំណើរបន្តទៅទៀតនៅឡើយ បីដូចជាសម្លកកូរមួយឆ្នាំង ដែលគេស្លដាក់គ្រឿងផ្សំ ដាក់ត្រីបន្លែរួចហើយ តែអ្នកដាំស្លបែរជាភ្លេចមិនទាន់បង់អង្ករលីង បង់ប្រហុក ឬបង់ស្លឹកជីរបន្ថែម ដើម្បីអោយអាហារដែលមានលក្ខណៈ ជាសម្លកកូរដ៏ពេញរសជាតិនោះនៅឡើយ ។

ការពិតទៅ អ្នកនិពន្ធគ្មានកំហុសទេ ក្នុងការនិពន្ធបែបនេះគ្រាន់តែស្នាដៃរបស់គេនេះ មិនទាន់អាចចាត់ទុកបានថា ជាស្នាដៃជាតិនិយមបានឡើយ ត្បិតអីការសរសេររបស់គេ មានន័យត្រឹមតែជាការរិះគន់មើលបំណាំ ឬជាការរអ៊ូរត្អូញត្អែររបស់អ្នកនិពន្ធតែម្យ៉ាងប៉ុណ្ណោះ ព្រោះអ្នកនិពន្ធមិនបានសរសេរផ្តល់នូវគំនិតស្មារតីជាតិថាត្រូវធ្វើយ៉ាងណាវិញ ដើម្បីកែសម្រួលស្ថានការណ៍អោយប្រសើរនិងជួយផ្លាស់ប្តូរជីវិតពលរដ្ឋអោយបានជួបនឹងភាពរុងរឿង អោយការគ្រប់គ្រងក្នុងប្រទេសមានភាពយុត្តិធម៌ មានអធិបតេយ្យភាពនិងមានសណ្តាប់ធ្នាប់ ល្អជាងមុន ជាដើម ។ល ។

អាស្រ័យដោយប្រការដូចបរិយាយខាងលើ ការជ្រើសរើសយកការនិពន្ធ ដែលមានប្រសិទ្ធិភាព ហើយងាយស្រួលដោះស្រាយនោះគឺជាការសរសេរដោយជ្រើសរើសប្រធានបទតូចៗ ល្មមអ្នកនិពន្ធអាចមានចំណេះវិជ្ជា មានការចេះដឹង មានលទ្ធភាព សមត្ថភាពនិងសតិប្រាជ្ញអាចគ្រប់គ្រងសំណេររបស់ខ្លួនបាន ដោយផ្តោតយកអត្ថរសប្រសើរៗ សំរាប់អ្នកអានត្រងយកទៅសិក្សា ឬយកទៅអនុវត្តន៍ជាប្រយោជន៍សម្រាប់សង្គមជាតិនោះតែម្តង ។

សូមអញ្ជើញអានជំពូកទី១០នូវវិធីប្រើវិញ្ញាណទី៩ និងទី១០ ក្នុងការបណ្តុះបណ្តាលស្មារតីអោយកាន់តែប្រសើរថែមទៀត ។

២. ការស្រាយខ្នងរឿង ៖

២ក. ការស្រាយខ្នងរឿងបែបរិះគន់ ៖

អ្នកនិពន្ធទាំងឡាយគប្បីចងចាំទៀតដែរថា នៅក្នុងគម្រោងរឿងនិមួយៗ អ្នកនិពន្ធត្រូវប្រើសន្ទេហាវិធីលាក់ខ្នងរឿង និងវិធីដោះស្រាយប្រស្នានៅក្នុងរឿង អោយគ្រប់ចំនួនខ្នង ទើបអ្នកនិពន្ធចាប់ផ្តើមសរសេរបំពេញសេចក្តី ដើម្បីអោយសាច់រឿងមានអត្ថរសឡើង ។ ឯសិល្បវិធីដោះស្រាយខ្នងបញ្ហា នៅក្នុងរឿងនោះហើយដែលជាខ្លឹមសារពិតប្រាកដរបស់អត្ថបទអក្សរសិល្បនិមួយៗ ។

ឧទាហរណ៍ ៖

បើសិនណាអ្នកនិពន្ធម្នាក់សរសេររិះគន់អំពីម៉ូដអាវសម័យមួយ ថា មិនស្អាត មិនល្អ មិនទាន់និយម ដូច្នេះ អ្នកនិពន្ធដដែលគប្បីប្រឹងស្វែងរកម៉ូដថ្មីៗប្លែកៗ ដទៃទៀត ដើម្បីយកមកបង្ហាញអ្នកអាន អោយគេមានឱកាសបានឃើញគម្រូទាំងនោះ ហើយអាចប្រៀបធៀបបានថា តើការរចនាបង្កើតម៉ូដថ្មីៗទៀត ស្រស់ស្អាតជាងម៉ូដ ដែលអ្នកនិពន្ធសរសេររិះគន់នោះ យ៉ាងដូចម្តេចខ្លះ ។ ក្នុងឧទាហរណ៍មួយទៀត បើសិនជាអ្នកនិពន្ធរិះគន់តួអង្គបុរសម្នាក់ថា គេមានសក់កន្រ្ទើងថៃពេញក្បាល មិនដែលសិតអោយមានសណ្តាប់ធ្នាប់ មិនដែលកក់សក់សំអាត មិនដែលកាត់អោយសមរម្យ ប៉ុន្តែ អ្នកនិពន្ធបែរជាភ្លេចបង្ហាញថា តើពេលបុរសនោះកាត់សក់ចេញទៅ មុខប្រែស្អាតយ៉ាងណា...បើសិតបែបនេះ ស្អាតយ៉ាងនេះ ហើយបើសិតបែបនោះ ស្អាតយ៉ាងនោះ... រួចបើបានកក់សាប៊ូសំអាតថៃចេញ តើសរសៃប្រែរលោងស្អាត យ៉ាងណាវិញ ។ល ។ នោះមានសេចក្តីថា អ្នកនិពន្ធចេះត្រឹមតែចាប់ចំណុចបញ្ហាមក

និយាយរិះគន់ តែខ្វះសិល្បវិធីស្រាយបញ្ហា ឬ ធ្វើសំណូមពរសម្រាយបំភ្លឺនូវគំនិតប្លែកៗ ដែលអាចជួយសម្រាលបញ្ហាសាំញ៉ាំទាំងអស់នោះ អោយបែរធូរស្រាលភ្លឺថ្លារុងរឿងមកវិញ ។

ប្រការដូចគ្នានេះដែរ អ្នកនិពន្ធខ្លះចូលចិត្តសរសេររិះគន់អំពីស្ថានការណ៍នយោបាយក្នុងប្រទេស ថាខុសនេះ ខុសនោះ មិនចេះចប់មិនចេះហើយ ប៉ុន្តែពុំសូវសរសេរពន្យល់នូវសិល្បវិធីដោះស្រាយ ថាតើគួរធ្វើយ៉ាងណា ទើបបញ្ហាទាំងនោះបានធូរស្រាលមកវិញឡើយ ។ អ្នកនិពន្ធទាំងនោះច្រើនឆ្លើយវេះវៀងថា គេមិនត្រូវបញ្ចេញមតិអ្វីទេ ត្បិតខ្លាចទទួលទោសពីអ្នកនយោបាយជាន់ខ្ពស់ ។ ការឆ្លើយដោះសារយករួចខ្លួនរបស់អ្នកនិពន្ធបែបនោះ បានបញ្ជាក់នូវស្មារតីឆ្វេសប្រហែសរបស់អ្នកនិពន្ធ តែម្តង ។ សេចក្តីឆ្វេសនោះ គឺថា បើសិនជាអ្នកគ្រប់គ្រងទាំងនោះចង់ចាប់ទោស អូសដំណើរអ្នកនិពន្ធយើងពិតមែន គេមិនមែនចាប់ទោសដោយសារការធ្វើសំណូមពរអំពីសិល្បវិធីដោះស្រាយបញ្ហាជាតិនោះទេ ប៉ុន្តែ គេនឹងចាប់ទោសអ្នកនិពន្ធ ដោយសារការរិះគន់ដៀមដាមចំអកដ៏សែនគ្រោតគ្រាត ខ្វះសតិ របស់អ្នកនិពន្ធនោះ ទៅវិញទេតើ ។

បន្ថែមពីលើនោះទៀត ពេលដែលអ្នកនិពន្ធឆ្លើយថា ខ្លួនពុំមែនជាអ្នកនយោបាយ ដូច្នេះមិនអាចឆ្លើយដោះស្រាយបញ្ហាក្នុងរឿងដែលខ្លួនសរសេរនោះជូនអ្នកអានបានទេ ។ នោះជាចម្លើយដ៏ទាល់ច្រកមួយ ដែលធ្វើអោយស្មេរបាត់បង់មោទនភាព ជាអ្នកនិពន្ធតែម្តង ព្រោះថា កាលបើខ្លួនយើងដែលជាអ្នកនិពន្ធមានចុងប៉ាកកាទិព្វ ហេតុអ្វីពេលនេះ បែរជាមិនអាចជប់រំលាយឧបសគ្គនៅក្នុងរឿងនិពន្ធរបស់ខ្លួនបានសោះអញ្ចឹង ? បើសិនយើងបែរមើលតាមទ្រឹស្តីវិញ្ញាណ១០វិញ គឺមានន័យថា អ្នកនិពន្ធនោះមានសមត្ថភាពប្រើត្រឹមតែវិញ្ញាណ៨ សម្រាប់ការសរសេរនិពន្ធរបស់ខ្លួន តែមិន

ទាន់មានសមត្ថភាពគ្រប់គ្រាន់នៅឡើយទេ សំរាប់ប្រើវិញ្ញាណទី៩ និងទី១០ ឲ្យជួយបណ្តុះបណ្តាលសតិប្រាជ្ញារបស់ខ្លួន ដើម្បីត្រិះរិះគិតរកវិធីដោះស្រាយយ៉ាងប្លែកៗ សំរាប់ពលរដ្ឋនិងអ្នកគ្រប់គ្រងយកមកសិក្សា រកដំណោះស្រាយវិបត្តិ ផ្លាស់ប្តូរស្ថានភាពក្នុងសង្គមអោយបែរមករកភាពធូរស្រាលមកវិញជាដើម ។ល ។

<u>២ខ. ការស្រាយបញ្ហាដោយកម្លាំងបាយ</u> ៖

កន្លងមក អ្នកនិពន្ធខ្មែរជំនាន់ពីបុរាណ ច្រើនសរសេរចងបញ្ហារឿង ដោយការឈ្លោះទាស់ទែងផ្នែកឥទ្ធិពលអំណាច វណ្ណៈ និងទ្រព្យសម្បត្តិ ។ ចំណែកឯការដោះស្រាយបញ្ហានៅក្នុងរឿងវិញ សុទ្ធតែពោរពេញទៅដោយកលល្បិចរាប់រយជំពូក មានការចងកំហឹងទោសៈ គំនុំព្យាបាទ និងការចិញ្ចឹមចិត្តសងសឹកស្ងួពូជ រវាងគូបដិបក្ខទាំងសងខាង គ្មាននរណាអនុគ្រោះអធ្យាស្រ័យនរណាឡើយ ។ មិនត្រឹមតែតួអង្គអាក្រក់ទេដែលប្រព្រឹត្តឆ្កាំឆ្គង ឃោរឃៅយង់ឃ្នងកាប់សម្លាប់ និងធ្វើទារុណអ្នកដទៃ សូម្បីតួអង្គល្អៗនៅក្នុងរឿង ក៏នៅតែក្លាយជាពេជ្ឈឃាដសម្លាប់មនុស្ស ឬ ធ្វើការដាក់ទោសទារុណ ដល់គូបច្ចាមិត្ររបស់ខ្លួន នៅទីបញ្ចប់នៃសាច់រឿងដដែល មិនខុសអ្វីពីតួអាក្រក់ដទៃៗទៀតយ៉ាងដូច្នោះដែរ ។

រហូតមកដល់បច្ចុប្បន្ននេះ ការនិពន្ធរឿងបានផ្លាស់ប្តូរ ពីជិះហង្សមកជិះយន្តហោះ ប្តូរពីជិះដរីមកជិះឡានមែសឺដេស ប្តូរពីការបាញ់ធ្នូមកបាញ់កាំភ្លើង ប្តូរពីពាក់មាសមកពាក់ពេជ្រ ប្តូរពីសេកនាំសារមកប្រើទូរស័ព្ទដៃ ។ល ។ ប៉ុន្តែការនិពន្ធសាច់រឿង នៅតែរក្សាបែបផែនដដែល គឺ តួឯកបុរស នារី សុទ្ធតែត្រូវប្រឈមមុខនឹងគ្នៀបអំណាច វណ្ណៈ និងទ្រព្យធន ។ រីឯការដោះស្រាយបញ្ហាក្នុងរឿងវិញទៀតសោត ក៏នៅដដែលដូចគ្នា គឺការប្រើកម្លាំងបាយស្រាយគំនុំទោសៈ និងការចងអាឃាដព្យាបាទ សងសឹកស្ងួពូជ

រហូតដល់មានស្លាប់ម្ខាងៗដោយគ្មានការលើកលែងអ្វីបន្តិចឡើយ ។ យោងទៅតាមទ្រឹស្តីព្រះធម៌របស់ ពុទ្ធសាសនា ឬ គ្រីស្តសាសនា ការសម្លាប់ជីវិតមនុស្សគឺជាអំពើបាបយ៉ាងធ្ងន់ធ្ងរ ។ ឯស្រុកទេស ទាំងឡាយដែលអាចមានសន្តិភាពនិងអធិតេយ្យភាពបានល្អរុងរឿង បាន ក៏ដោយសារពលរដ្ឋ មានចិត្តធម៌មេត្តា មានក្តីសណ្តោស អនុគ្រោះអធ្យាស្រ័យចំពោះគ្នា ទៅវិញទៅមក និងចេះជួយឈឺ ឆ្អាលដោះស្រាយទុក្ខធុរៈពេលអាសន្នអន់ក្រ ពេលទីទាល់ច្រក មិន មែនដោយសារការកាប់ចាក់បាញ់សម្លាប់គ្នានោះទេ ។ ដូច្នេះ អ្នក និពន្ធគប្បីរៀនគិតអោយគ្រប់ជ្រុងជ្រោយ ថាតើការដោះស្រាយ បញ្ហានៅក្នុងរឿងរបស់យើង គួរប្រើកំហឹងសងសឹកដោយកម្លាំង បាយ និង កម្លាំងកលល្បិចបំផ្លាញគូបដិបក្ខតទៅទៀត ឬក៏ត្រូវ ប្រើបែបផែនថ្មី ដែលមានសន្ទេហវិធី និង សិល្បវិធីដោះស្រាយ បែបអភិវឌ្ឍន៍សតិប្រាជ្ញប្រពៃជាងហ្នឹង ហៅមិនឮ ?

ម្យ៉ាងទៀត នៅពេលបច្ចុប្បន្ន ប្រទេសជាតិបានវិវត្តន៍ទៅមុខ យ៉ាងរុងរឿង ខុសពីមុនឆ្ងាយណាស់ ។ សង្គមជាតិយើងមានការ សិក្សាខ្ពង់ខ្ពស់ មានសន្តិភាព មានស្ថេរភាព និង អធិបតេយ្យ ភាព ។ ពលរដ្ឋក៏បែរមកចាប់យកការសិក្សាយ៉ាងរីកចំរើនដុះដាល លើសពីពេលណាៗ ទាំងអស់ នៅក្នុងប្រវត្តិសាស្ត្រប្រទេសខ្មែរ ។ ដូច្នេះ ពលរដ្ឋទាំងឡាយ ក៏លែងស្ថិតនៅជាមនុស្សដែលចូលចិត្ត ដោះស្រាយបញ្ហានានាក្នុងជីវិត ដោយការប្រើកម្លាំងបាយកំហែង ទល់កំហល់ បែបមនុស្សព្រៃ ឬសត្វធាតុ ដូចគ្រាមុនទៀតហើយ ។ គេបានសិក្សាលូតលាស់ទាំងវិជ្ជា ទាំងចិត្តគំនិត ទាំងកិរិយា ទាំង កម្រិតប្រាជ្ញនិងកោសល្យ យ៉ាងប្រសើរ ដែលជាហេតុនាំអោយរូប គេទាំងឡាយនោះក្លាយខ្លួនជាមនុស្សភ្លឺស្វាង ហើយប្រពៃថ្លៃថ្នូរ ជាទីបំផុត ។ នៅពេលនេះឯងហើយ ដែលអ្នកនិពន្ធជំនាន់ថ្មី គប្បី

នាំគ្នាចាប់ផ្តើមប្រើសតិប្រាជ្ញា កសាងបណ្តុះ បណ្តាលសិល្បវិធីថ្មីៗ ប្លែកៗ ហើយមានប្រសិទ្ធិភាពយ៉ាងប្រសើរឧត្តម ដើម្បីជួយជំរុញ អោយអ្នកអានយើង បានកើនសមត្ថភាពនិងចំណេះចេះដឹង ល្មម អាចគ្រប់គ្រងជីវិត ដោយសុខសន្តិ និងអនិបតេយ្យ យ៉ាង បរិបូណ៌ ។

សរុបសេចក្តីមក អ្នកនិពន្ធទាំងឡាយណា ដែលអាចនាំសំណេរ របស់ខ្លួន អោយឈានមកដល់ចំណុចដោះស្រាយ ដោយគំនិត ប្រាជ្ញា និងសន្តិវិធី យ៉ាងឆ្លៀវឆ្លាតបែបនេះបាន អាចចាត់ទុកថា អ្នកនិពន្ធរូបនោះ ជាមនុស្សមានទេពកោសល្យប៉ិនប្រសប់ និងមាន ចិត្តវិជ្ជាអភិវឌ្ឍន៍យ៉ាងជឿនលឿន សមស្របតាមដំណើរវិវត្តន៍ រុងរឿង នៃសង្គមនានាក្នុងសកលលោកទាំងមូល នោះតែម្តង ។ មានន័យថា ការនិពន្ធបែបសម័យថ្មីរបស់យើងបច្ចុប្បន្ននេះ លែង ចម្លងបែបបទដោះស្រាយតាមការនិពន្ធបុរាណដោយការប្រើកម្លាំង បាយ កម្លាំងអាវុធ ឬកលល្បិចរាប់រយជំពូកនោះទៀតហើយ ។ យើងគ្រប់គ្នាគួរអភិវឌ្ឍន៍សិល្បវិធីនិពន្ធរបស់យើង ដោយប្រើ មធ្យោបាយសន្តិវិធីនិងសតិប្រាជ្ញាខ្ពង់ខ្ពស់ ជាងអក្សរសិល្ប៍ខ្មែរទាំង ឡាយនានាដទៃទៀត ក្នុងប្រវត្តិសាស្ត្រជាតិយើង កន្លងមក ។

<u>២គ. ការស្រាយខ្នួចរឿងដោយវណ្ណៈ</u> ៖

យើងបានឃើញរួចមកហើយថា អ្នកនិពន្ធខ្មែរយើងជំនាន់ មុនៗ ចូលចិត្តសរសេររឿងដែលលើកកំពស់អ្នកមានវណ្ណៈ និង មានអំណាច ហើយច្រើនដោះស្រាយសាច់រឿង ដោយក្តីលំអៀង ទន់ទោរ ទៅតាមនោះដែរ ។ នៅក្នុងរឿងបុរាណខ្លះៗ ដូចជា រឿងព្រះជិនវង្ស ព្រះធិនវង្សនាងពៅ នាងរំសាយសក់ នាងកាកី ទិព្វសុដាច័ន្ទ ទុំទាវ ជាដើម ។ បើសិនជាតួអង្គនោះជាបុរសមាន យសបុណ្យសក្តិទ្រព្យធន និងអំណាចចេស្តា តួអង្គនោះតែងទទួល

ការកាត់សេចក្តីពីអ្នកនិពន្ធ អោយនៅខាងភាគីជាអ្នកឈ្នះមានជោគជ័យជានិច្ច តួយ៉ាងដូចជាព្រះជិនវង្សជាដើម ដែលមានមហេសីដល់ទៅ៧នាក់ មានស្នំបំរើរាប់មិនអស់ តែព្រះជិនវង្សនៅតែជាអ្នក "ត្រូវ" ដដែល ទោះបីជាតួអង្គពុំមានភក្តីភាព ចំពោះស្នេហាស្មោះត្រង់មួយនឹងមួយនោះក៏ដោយ ។ ព្រមពេលជាមួយគ្នានេះដែរ កាកីបែរជាត្រូវអ្នកនិពន្ធកាត់ទោសបណ្តែតពោងពាយ អោយស្លាប់តែម្នាក់ឯងកណ្តាលសមុទ្ទ ដោយព្រោះគ្នាជាស្ត្រីភេទ ហើយជាមនុស្សដែលមានវណ្ណៈនិងអំណាច ខ្សោយជាងតួបុរសដែលនៅក្នុងរឿង ម្ល៉ោះហើយក៏ក្លាយទៅជាអ្នកខុសទាំងស្រុង ថ្វីបើទោសរបស់នាង មិនមានភាពធ្ងន់ធ្ងរ ស្មើនឹងព្រះជិនវង្សនៅឡើយក្តី ។ នៅក្នុងរឿងបុរាណមួយ ចៅភោគកុលកុមារបានក្បត់ចិត្តភរិយាដើម ទៅស្តីដណ្តឹងនាងរំសាយសក់មកអភិសេកជាមហេសី ដោយព្រោះភរិយាដើមមានវណ្ណៈត្រឹមជារាស្ត្រសាមញ្ញ មិនមែនជាវណ្ណៈក្សត្រ ។ លុះនាងកើតចិត្តមួម៉ៅប្រច័ណ្ឌ ហើយចេញមុខទៅរាំងឃាត់ចៅភោគកុល មិនអោយលើកបណ្ណាការសួយសារអាករទៅដណ្តឹងនាងរំសាយសក់ ចៅភោគកុលក៏រួមដៃនឹងរំសាយសក់សម្លាប់ស្រីដែលជាភរិយាដើមនោះចោលទៅ ហើយទាំងពីរនាក់ក៏រួមរស់សោយសុខ ដោយគ្មានទោសពៃរ៍អ្វីបន្តិចសោះ ត្បិតសង្គមជំនាន់នោះស្នេរសរសេរច្រើនលើកជើងអ្នកមានអំណាចចេស្តា ដោយបិទភ្នែកមិនអើពើដល់ជនរងគ្រោះឬជនដែលមានវណ្ណៈទាបឡើយ ។ ដូចគ្នានេះដែរ នៅក្នុងរឿងទិព្វសុដាច័ន្ទ ព្រះឥន្ទបានចុះពីស្ថានលើ មកចាប់បំបែកយកនាងទិព្វសុដាច័ន្ទ ពីទារករបស់នាងដែលនៅបៅដោះម្តាយនៅឡើយ និងពីចៅមាណពជាស្វាមី រួមរស់ជួបជុំគ្នាយ៉ាងសុខដុមរមនា អោយវិលត្រឡប់ទៅស្ថានលើវិញ ។ គ្រានោះ អ្នកនិពន្ធមិនបានដាក់ទោសព្រះឥន្ទាធិរាជ ដែលមកចាប់

ពង្រោត់ម្តាយពីកូនតូច ហើយបំបែកបំបាក់ក្រុមគ្រួសារអោយរស់វេទនាខ្លួងចិត្តទាំងសងខាង អ្វីបន្តិចឡើយ ។ នោះមកពីគេគិតថាព្រះឥន្ទជាបុគ្គលដែលមានអំណាច គ្មាននរណាអាចចាប់ដាក់ទោសបានទេ ថ្វីបើជាជននោះបានប្រព្រឹត្តអំពើខ្វះសប្បុរសធម៌ ខ្វះសីលធម៌ ខ្វះចិត្តសណ្តោសមេត្តា ចំពោះទារកតូច និងគ្រួសារក្រីក្រនោះក៏ដោយ ។ ចំណែកអ្នកក្រអ្នកខ្សត់ អ្នកខ្វះសិល្ប៍ ខ្វះអំណាចវិញ បែរជាទទួលរងគ្រោះជានិច្ចមិនថា វេលាណាទេ ហើយកន្លងមក អ្នករងគ្រោះទាំងនោះ ក៏មិនសូវដែលបានទទួលនូវយុត្តិធម៌ពីស្លាបប៉ាកកាអ្នកនិពន្ធ ណាមួយដែរ ។

សំណេរនិពន្ធខាងលើនេះ ជាភស្តុតាងយ៉ាងជាក់ច្បាស់ អំពីទស្សនៈអ្នកនិពន្ធដែលគាំទ្រភេទជាបុរស ទ្រទ្រង់អំណាចសក្តា និងទ្រព្យធនសម្បត្តិ ហើយបិទភ្នែករបស់ខ្លួន ក្នុងការស្វែងរកភាពយុត្តិធម៌ អោយតួអង្គរបស់ខ្លួនអោយបានត្រឹមត្រូវពិតប្រាកដ ។

ការសរសេរបែបនេះ ជួនកាលគ្រាន់តែជាការសរសេរដើម្បីឆ្លុះបញ្ចាំងនូវវប្បធម៌សង្គមជំនាន់បុរាណ ឬគ្រាន់តែសរសេរលើកជើងគាំទ្រសង្គមជំនាន់នោះ តែប៉ុណ្ណោះ តែមិនមែនជាការសរសេរដើម្បីស្រាយរកយុត្តិធម៌ ឬបណ្តុះសតិប្រាជ្ញអោយមនុស្សឆ្លៀវឆ្លាតស្គាល់ខុសស្គាល់ត្រូវ ស្គាល់មធ្យោបាយប្រពៃ ជួយខ្លួនអោយរួចផុតពីរណ្តៅជីវិត កុំអោយលិចលង់ តទៅទៀតនោះឡើយ ។

មកដល់បច្ចុប្បន្ននេះ ស្រុកទេសយើងបានទទួលសុខសន្តិភាព មានអធិបតេយ្យភាព មានការបង្កើតច្បាប់រក្សាសិទ្ធិមនុស្ស មានច្បាប់រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងសង្គម មានការសិក្សាអភិវឌ្ឍន៍ ទាំងផ្នែកវប្បធម៌ ចិត្តវិជ្ជា សង្គមវិជ្ជា និងវិទ្យាសាស្ត្រនានា ។ ពលរដ្ឋទាំងឡាយក៏កាន់តែមានការយល់ដឹងស្គាល់ច្បាប់ស្គាល់សិទ្ធិមនុស្ស ស្គាល់ការដោះស្រាយបញ្ហានានាដោយសន្តិវិធី

មានការអត់អោនយោគយល់អធ្យាស្រ័យ មានសប្បុរសធម៌ មាន មានសីលធម៌ មានមេត្តាធម៌ ។ល ។ គេទាំងឡាយកំពុងបោះជំហាន ចាកចេញពីការរស់នៅ ដូចមនុស្សព្រៃសាហាវយង់ឃ្នង មកជាមនុស្សដែលមានការអភិវឌ្ឍន៍ ទាំងចិត្តគំនិត និងការប្រព្រឹត្ត ស្គាល់ខុសស្គាល់ត្រូវ ស្គាល់អ្វីជាអំពើល្អ អ្វីជាអំពើពាលា ។ ដូច្នេះ អ្នកនិពន្ធទាំងឡាយ គួរតែចាប់ផ្តើមអភិវឌ្ឍន៍សំណេររបស់ខ្លួន អោយមានដំណើរវិវត្តន៍ សក្តិសមនឹងការផ្លាស់ប្តូររបស់សង្គមយើងផងដែរ ។ យើងមិនគួរនៅទ្រឹង ត្រឹមបែបផែនសរសេរបែបបុរាណ ដូចៗគ្នា ដដែលជាងដែលអញ្ចឹង រហូតតទៅទៀតទេ ។ យើងត្រូវតែមានដំណើរឈានមុខមុនអ្នកអានទាំងឡាយ ដោយយកគំនិតល្អៗ មកសរសេរជាគម្រូដឹកនាំមនុស្ស អោយដើរឆ្ពោះទៅរកភាពថ្កុំថ្កើង មានយុត្តិធម៌ សុវត្ថិភាព អធិបតេយ្យភាព សន្តិភាព នៅក្នុងសង្គម ពិតប្រាកដ ។

<u>២ឃ. អំពីការនិពន្ធបែបសនិងខ្មៅ</u> ៖

ចំណុចមួយទៀតដែលយើងគួរកត់សំគាល់ ហើយកែប្រែរបៀបនិពន្ធផងដែរ គឺ ក្នុងរយៈកន្លងមក អ្នកនិពន្ធភាគច្រើន ច្រើនជ្រើសរើសរបៀបសរសេរ បែបសនិងខ្មៅ មានន័យថា បើតួអង្គជាតួឯក គឺសុទ្ធតែជាមនុស្សល្អ ជាមនុស្សស្អាត ជាទេវតា ទេវបុត្រ ទេពធិតា ឬ នារីបញ្ចពិត្រកល្យាណី ។ ឯគូប្រជែងវិញ សុទ្ធតែជាតួយក្ស ជាបិសាច ជាមនុស្សពាលកោងកាច ជាចោរ ជាកាឡកណ្ណី ជាឆន្នា កាចឆ្នាសមិនមានអ្វីដែលភាពប្រពៃបន្តិចឡើយ ។

រួចហើយ ដើម្បីបន្ថែមភាពកំសត់របស់សាច់រឿងអោយកាន់តែស្រណោះស្រណោកថែមទៀតនោះ អ្នកនិពន្ធច្រើនតែបង្កើតស្ថានការណ៍ឲ្យតួអង្គប្រជែងសាងទារុណបន្ទុំល្បិច ញិចទោសតែលើតួឯករបស់សាច់រឿងពុំមានស្រាន្តរហូតដល់ទីបញ្ចប់ ។ ចំណែកឯតួអង្គ

ប្រជែងក៏ត្រូវតួឯកសម្លាប់នៅទីបញ្ចប់នៃសាច់រឿង ឬក៏ត្រូវស្លាប់ដោយការដាក់ទោសពីស្ថានអច្ឆរិយៈ ដូចជា ត្រូវរងគ្រោះស្លាប់ដោយធរណីស្រូប រន្ទះបាញ់ ព្យុះកំបុតត្បូង ជាដើម ។ល ។ ភាគច្រើន អ្នកនិពន្ធទាំងឡាយនោះមិនសូវនិពន្ធដោយទុកឱកាស ដល់អ្នកដែលមានកំហុសទាំងនោះ អោយមានពេលកែខ្លួន ឬក៏បានបង្ហាញនូវភាពល្អរបស់ខ្លួនមកវិញ រួចហើយក៏ក្លាយជាមិត្ត ជាញាតិសន្ដាននឹងគ្នាវិញទេ ។ គេនិយមសរសេរនិពន្ធ ត្រឹមតែរបៀបសនិងខ្មៅ អាក្រក់និងល្អ បើអាក្រក់គឺអាក្រក់ហួស បើល្អក៏ល្អហួស បើសក៏សជ្រុល បើខ្មៅក៏ខ្មៅជ្រុល បើស្អាត ក៏ស្អាតលើសគេ បើសង្ហាក៏សង្ហាគ្មានពីរតែម្ដង ។ រួចហើយគេច្រើនបញ្ចប់ដោយការពិឃាតតួប្រជែងចេញពីជីវិត មិនអោយនៅសល់ម្នាក់ឡើយ ។ នេះជាវិធីនិពន្ធមួយ ដែលធ្វើអោយអ្នកអាន អាចទាយដឹងរឿងមុនស្រេច ថាតើនរណាជាតួឯក នរណាជាតួ ដែលត្រូវស្លាប់ ជាប់គុក ឬត្រូវទទួលទោសផ្ដាន្ទា នៅគ្រាចុង បញ្ចប់នៃសាច់រឿង ។

ម្យ៉ាងវិញទៀត ចំពោះសាច់រឿងនិពន្ធបែប សនិងខ្មៅ ក៏ជាសាក្ខីភាពបង្ហាញអំពីអ្នកនិពន្ធខ្លួនឯង ថាជាចៅក្រមមួយរូប ដែលមិនផ្ដល់យុត្តិធម៌ដល់តួអង្គ និងសាច់រឿងរបស់ខ្លួន អ្វីបន្តិចឡើយ ។ តើមនុស្សណាទៅដែលសុខៗ ស្រាប់តែក្លាយជាមានភាពឆន្ទាឬស្យាចំពោះមនុស្សដូចគ្នា ដោយគ្មានហេតុផល ? តើមនុស្សឯណាដែលល្អឥតខ្ចោះ គ្មានកំហុសសោះនោះ ? តើមនុស្សឯណា ដែលជួបតែសំណោកជីវិតគ្មានវេលាស្រាន្តនោះ ? មេឃភ្លៀងគង់មានជួបថ្ងៃរះស្រឡះ ។ មេឃស្រឡះក៏គង់មានថ្ងៃជួបភ្លៀងព្យុះ ។ ដូច្នេះតួអង្គល្អ ក៏គង់មានថ្ងៃដែលខ្លួនជ្រុលប្រព្រឹត្តកំហុស មានខ្ចោះកិរិយាឬគំនិត ហើយតួអង្គអាក្រក់យ៉ាងណា ក៏គង់គេមានគុណសម្បត្តិល្អនៅកន្លែងត្រង់ណាមួយ ។ អ្នកនិពន្ធរបស់យើងច្រើនមានទំនោរថា

បើតួអាក្រក់ប៉ុនប៉ងសម្លាប់តួឯក នោះគឺជាកំហុសដ៏ធ្ងន់ មិនអាចអត់ឱនអោយបាន ។ ប៉ុន្តែបើតួឯកសម្លាប់តួអាក្រក់វិញ យើងគិតថាជាជោគជ័យប្រសើរ ។ ដូច្នេះ យើងគប្បីគិតម្តងទៀតទៅមើលថា តើយើងអោយកិត្តិយសតួឯក ថាជាមនុស្សប្រសើរយ៉ាងម៉េចកើត កាលបើតួមួយហ្នឹងក៏ជាឃាដករសម្លាប់មនុស្សដែរនោះ ?

ដូច្នេះ កាលបើអ្នកនិពន្ធសរសេរបំបិទចោលនូវភាពអាក្រក់របស់តួឯក ហើយបំបិទចោលនូវភាពល្អរបស់តួប្រដែង នោះគឺជាដំណើរបង្ហាញនូវការកាត់ក្តីរបស់អ្នកនិពន្ធ យ៉ាងលំអៀងជាទីបំផុតចំពោះតួអង្គនិមួយៗនៅក្នុងសាច់រឿងរបស់ខ្លួន ។

ចំពោះមូលហេតុនេះ តើយើងគួរធ្វើយ៉ាងណាវិញដើម្បីកុំអោយរូបយើងដែលជាអ្នកនិពន្ធនោះ ក្លាយជាចៅក្រមដែលមានដំណើរកាត់ក្តីដោយលំអៀង ចំពោះតួអង្គនៅក្នុងរឿងនិពន្ធរបស់ខ្លួន ?

គឺពេលនេះឯងហើយ ដែលអ្នកនិពន្ធត្រូវការប្រើសតិ ប្រាជ្ញយ៉ាងមុតមាំ ដើម្បីស្វែងរកភាពកណ្តាល ភាពមិនលំអៀងជូនតួអង្គរបស់ខ្លួន មិនថាតួអង្គនោះជាតួឯក ឬជាតួប្រដែងឡើយ ។ ដើម្បីអោយកាន់តែយល់ច្បាស់ សូមអ្នកនិពន្ធទាំងឡាយអញ្ជើញអានជំពូកទី៩ ដែលបរិយាយអំពីការប្រើសតិនិងប្រាជ្ញ ដើម្បីរក្សាសច្ចភាព និងអត្ថរសរបស់សំណេរ មិនអោយលំអៀង ។

ម្យ៉ាងទៀត នៅសម័យសង្គមអភិវឌ្ឍន៍ គេលែងប្រើកម្លាំងបាយមកដោះស្រាយ ឬមកផ្តន្ទាទោស ជនដែលមានកំហុសនោះទៀតហើយ ។ កាលបើយើងស្អប់អំពើយង់ឃ្នងឃោរឃៅឬស្បានោះយើងមិនគួររៀនដោះស្រាយបញ្ហា ដោយយកអំពើយង់ឃ្នងមកអនុវត្តន៍ កាត់ទោសអ្នកដទៃដូច្នោះវិញទេ ។ យើងគប្បីរៀនត្រិះរិះរកសិល្បវិធីប្រសើរៗ ដោះស្រាយវិបត្តិ កែមនុស្សពាលអោយមកជាមនុស្សល្អ ដោយឧបាយអប់រំ ប្លែកៗ ដែលមាន

ប្រសិទ្ធិភាពទៅលើចរិតនិងកិរិយារបស់មនុស្សទាំងនោះ ។ ហើយ វិធីប្លែកៗនោះឯង គឺជាទេពកោសល្យនៃមនុស្សដែលមានប្រាជ្ញ មានសតិស្មារតីខ្ពង់ខ្ពស់ មានការចេះដឹងខ្ពស់ ។ មកដល់ពេលនេះ តើអ្នកនិពន្ធម្នាក់ៗត្រូវប្រើប្រាជ្ញារបស់ខ្លួន សរសេរដោះស្រាយខ្ទួច វិបត្តិ នៅក្នុងអត្ថបទនិពន្ធយ៉ាងណាវិញដែរ កាលបើយើងត្រូវ អភិវឌ្ឍន៍ចិត្តគំនិត និងការអប់រំរបស់យើងអោយល្អជាងមុន មាន មនុស្សធម៌ មានសីលធម៌ជាងមុន មួយកម្រិតទៀត ? ជាពិសេស ចំពោះការដោះស្រាយបញ្ហាវិបត្តិជីវិតទាំងឡាយ នៅក្នុងសាច់រឿង និពន្ធ ដោយឈរនៅលើភាពអហឹង្សា និង វិន័យខ្ជាប់ខ្ជួន តើអ្នក និពន្ធត្រូវហ្វឹកហ្វឺនទេពកោសល្យរបស់ខ្លួនយ៉ាងណាវិញ ?

នៅពេលនេះតែម្តងដែលអ្នកនិពន្ធត្រូវសិក្សា អំពីសិល្បៈវិធីថ្មី មួយទៀត ដើម្បីដុសខាត់ទេពកោសល្យរបស់ខ្លួនអោយកាន់តែមាន ប្រសិទ្ធិភាពទៅលើសង្គមអ្នកអាន ។ នោះគឺការសិក្សាក្បួនពិសិដ្ឋ ក្នុងការប្រើវិញ្ញាណ១០ អោយបញ្ចេញមន្តអច្ឆរិយៈដណ្តប់ទឹកខ្មៅ ប៉ាកការបស់អ្នកនិពន្ធយើង អោយកាន់តែមានអនុភាពខ្ពង់ខ្ពស់ ប្រសើរឡើងយ៉ាងឧត្តុង្គឧត្តម ។

<u>៣. អំពីការវិភាគបែបសុទិដ្ឋិនិយម</u> ៖

ចំពោះ អ្នកនិពន្ធទាំងឡាយ ជាពិសេសអ្នកនិពន្ធដែលទើបនឹង ចាប់ផ្តើមសរសេរដំបូង មិនទាន់មានការពិសោធន៍ច្រើនក្នុងល្បិច និពន្ធនៅឡើយ គប្បីចៀសវាងជ្រើសរើសប្រធានបទធំៗ ហួស សមត្ថភាពខ្លួន ។ គេគួរតែជ្រើសរើសប្រធានបទ តូចៗល្មមដែល លាក់ចំណុចសំខាន់សំរាប់ពិគ្រោះ ច្រើនបែប ច្រើនជ្រុងជ្រោយ ដូចជា ការនិពន្ធរឿងដង្កូវនិងមេអំបៅជាដើម ។ នៅក្នុងប្រធាន បទដ៏តូចនេះ អ្នកនិពន្ធអាចមានសមត្ថភាពវែកញែក វិភាគតម្លៃ សត្វដង្កូវពីតម្លៃថោកទាប ទៅដង្កូវដែលមានតម្លៃបំផុត សំរាប់

ជីវិតមនុស្សគ្រប់រូប ។ ឧទាហរណ៍ ការវិភាគអំពីសត្វដង្កូវ ដូចជាដង្កូវលាមក និងដង្កូវនាង ។ ក្នុងលក្ខណៈជាសត្វដង្កូវដូចគ្នា មិនមែនដង្កូវទាំងអស់សុទ្ធតែចោកទាបគ្រប់បែបនោះទេ ។ ដង្កូវនាងជាដង្កូវដែលផ្ដល់ប្រយោជន៍ តាំងពីសូត្ររហូតដល់សាច់ ពោលគឺបំរើជាអាហារផង បំរើជាសម្លៀកស្រោបខ្លួនមនុស្ស អោយស្រស់ស្អាតសោភ័ណផង រួចហើយក៏ភ្ញាស់ពងបន្តពូជពង្ស បម្រើសេចក្ដីត្រូវការរបស់មនុស្សតាំង ពីវណ្ណរាស្ត្រដល់វណ្ណៈរាជក្សត្រ ។ ដង្កូវនាងបានផ្ដល់នូវសូត្រយ៉ាងល្អប្រណីត សំរាប់ត្បាញជាហូល ផាមួងអន្លូញ ចរបាប់ កន្សែង កម្រាលពូក វាំងនន ដែលមានសោភ័ណសោភា គ្មានក្រណាត់ដទៃណាមកប្រដូចបានឡើយ ។ ជាពិសេសទៅទៀត ផ្ទាំងសំពត់សូត្រទាំងនោះក៏មានតម្លៃជាងគេបំផុតនៅក្នុងទីផ្សារ ហើយក៏មានប្រជាប្រិយភាពនៅក្នុងរង្វង់សង្គមថ្លៃថ្នូរយ៉ាងវិសេសវិសាលទៀតផង ។

ដូច្នេះ អ្នកនិពន្ធគប្បីផ្ដល់ការវិភាគវែកញែកនូវគុណសម្បត្តិរបស់ដង្កូវមិនអោយលំអៀងឡើយ ថ្វីបើអ្នកនិពន្ធនោះនៅមានចិត្តចង់រក្សាការវិភាគគុណវិបត្តិរបស់ដង្កូវ តាមរបៀបសរសេររបស់កវីនិពន្ធខ្មែរជំនាន់ដើមក៏ដោយ ។ យើងត្រូវរៀនរិះរករបៀបវិភាគបែបថ្មីៗ បន្ថែមទៀត ដែលមិនផ្ដោតភ្ជាប់នូវទុទ្ទិដ្ឋិគតិ ទៅលើការវិភាគរបស់ខ្លួនតែមួយចំហៀងខ្លាំងជ្រុលពេក ។ មានន័យថាយើងគប្បីត្រិះរិះរកការសរសេរវែកញែក ដោយប្រើគំនិតសុទិដ្ឋិមកវិភាគអ្វីៗ ដែលជាគុណសម្បត្តិគួរត្រងត្រេកជាគំនិតសិក្សា បណ្ដុះគំនិតស្មារតីរបស់យើងបានទទួលនូវភាពទូលំទូលាយចម្រុងចម្រើន ហើយ បរិបូណ៌ដោយភាពថ្លៃថ្នូរ ហើយបំបាត់ភាពនិន្ទាឫស្យា មិនភាពលំអៀង និងការប្រមាទទាំងឡាយដែលសង្គមយើងធ្លាប់មានកន្លងមក ។

រីឯការវិភាគមេអំបៅវិញក៏ដូចគ្នា អ្នកនិពន្ធអាចវិភាគនូវភាពឆើតឆាយរបស់មេអំបៅ ដែលអាចនាំទុក្ខដល់អាត្មាវិញ ដោយសារការត្រេកត្រអាលវង្វេងនឹងសោភ័ណសម្ផស្សរបស់ខ្លួន ។ ព្រមពេលជាមួយនោះដែរ អ្នកនិពន្ធក៏អាចពិគ្រោះអំពីឧទ្យានកំសាន្ត ដូចជាថា កាលបើមានផ្ការីក មានសត្វមេអំបៅហើររេរាំពេញសួន តើឧទ្យាននិមួយៗ ស្រស់ស្អាតយ៉ាងណា ធ្វើអោយមនុស្សគ្រប់វ័យគ្រប់វណ្ណៈត្រេកត្រអាលនឹងទិដ្ឋភាពយ៉ាងប្រណិតនៃឧទ្យាន ប៉ុនណា ឬក៏ សប្បាយចិត្តប៉ុនណា បើសិនគេបានមកដើរកំសាន្តនៅទីសួនដ៏ស្រស់បំព្រងបែបនោះ ។ ម្យ៉ាងទៀត អ្នកនិពន្ធអាចឆ្លៀតយកគំនិតបែបធម្មជាតិវិទ្យា មកបង្រៀនមនុស្ស តាមរយៈសំណេររបស់ខ្លួន ដូចជាការដែលមេអំបៅហើររេរាក្រេបលំអងផ្កា ពីផ្កាមួយទៅផ្កាមួយទៀត ហាក់បីដូចជាដំណើរនាំលំអងផ្កាឈ្មោលអោយទៅជួបនឹងផ្កាញី ជាហេតុនាំអោយដំណាំក៏បង្កបង្កើនជាផ្លែព្រោងព្រាត ផ្តល់ផលសំបូរសប្បាយ ដល់ជីវិតមនុស្សរស់នៅ ដោយសារតែគុណសម្បត្តិរបស់មេអំបៅទាំងឡាយនោះជាដើម ។ ដូច្នេះ ជាតិជាមេអំបៅដែលមានសោភ័ណស្រស់ស្អាត មិនមែនសុទ្ធតែរស់នៅក្នុងគ្រោះថ្នាក់ដល់ជីវិតរបៀបហ្នឹងតែរហូតនោះដែរ ។ តាមការពិតនៅក្នុងលោកយើងនេះ មនុស្សលោកនានាក៏មិនដែលគិតឃើញដល់រឿងធ្វើបាបមេអំបៅទាំងនោះផង ត្បិតសត្វទាំងឡាយនេះជាសត្វដែលស្លូតជាទីបំផុត មិនដែលបង្កផលវិបាកអ្វីដល់ជីវិតមនុស្សអ្វីបន្តិចសោះ ។ ដូច្នេះ តើហេតុអ្វីក៏អ្នកនិពន្ធភាគច្រើន បែរជាវាយតម្លៃអោយមេអំបៅយ៉ាងថោកទាបអាប់អោន រៀងរាល់ពេលដូច្នេះទៅវិញ ? ហើយបើសិនណាយើងជាអ្នកនិពន្ធវិញ តើយើងគួរស្រង់យកគំនិតតាមអ្នកនិពន្ធជំនាន់ចាស់ៗ ស្ទួនចម្លងទ្រឹស្តីរបស់លោក យកមកសរសេរជាបន្តៗ ដោយមិនកែប្រែរចនា

អ្វីបន្តិច ឬក៏យើងគួរបណ្តុះគំនិតថ្មី បណ្តុះរបៀបវិភាគវែកញែកថ្មី ដោយប្រើទ្រឹស្តី ប្លែកៗ ដទៃៗទៀត ដែលមានអត្ថរសល្អប្រសើរ មិនចាញ់គំនិត និងគុណសម្បត្តិដ៏ល្អនានា របស់បុព្វបុរសខ្មែរ ពីបុរាណនោះ ?

ឧទាហរណ៍មួយទៀតដូចជាការសរសេរវិភាគអំពីអំពិលអំពែក តាមរបៀបបែបបថផ្ទត់គំនិតចាស់របស់យើង ។ កាលដើមឡើយ យើងតែងប្រៀបធៀបអំពិលអំពែក ទៅអ្វីៗដែលមិនច្បាស់លាស់ ងងឹតភ្លឺៗ តាមតែនឹកឃើញ ដូចការដែលកូនសិស្សចូលមករៀន ក្នុងថ្នាក់មិនទៀងទាត់ បាត់ៗ ឃើញៗ ដូចអំពិលអំពែក ។ នៅក្នុងការវិភាគថ្មីមួយទៀត អ្នកនិពន្ធអាចសរសេរប្រៀបធៀបពន្លឺដ៏ពណ្ណរាយរបស់សត្វអំពិលអំពែក ដែលភ្លឺចាំងចិញ្ចាច ពុះជ្រែកស្បែរាត្រី ដោយមិនដេករំពឹងរង់ចាំពន្លឺខែ អោយមកលំអ កំដរភាពងងឹតអន្ធការនៃរាត្រី ទៅនឹងប្រាជ្ញ និង ការចេះដឹងរបស់មនុស្ស ដែលមានពន្លឺចាំងឆ្លុះយ៉ាងពណ្ណរាយជ្រែកភាពងងឹតល្ងង់ខ្លៅ អោយរលាយថមថយទៅវិញ យ៉ាងនោះដែរ ។

ដូច្នេះ អ្នកនិពន្ធគ្រប់រូបគប្បីរៀនវិភាគទាំងជ្រុងងងឹត និង ជ្រុងដែលមានពន្លឺ មិនអោយមានលំអៀង ដោយការបើកចិត្ត បើកអារម្មណ៍អោយទូលំទូលាយមិនចង្អៀតចង្អល់ ក្នុងការពិនិត្យសង្កេតពិចារណាអ្វីៗទាំងឡាយ ។ បើសិនណាអ្នកនិពន្ធណាម្នាក់អាចធ្វើដូច្នេះបាន ការសរសេររបស់គេក៏លែងមានភាពអគតិ អសុរស ហើយទាល់ច្រកតទៅទៀតដែរ ។ ហើយការវិភាគប្លែកៗ ល្អៗ ខុសពីឧត្តមគតិអ្នកណាៗទាំងអស់ពីមុនកន្លងមក នឹងបង្ហាញនូវទេពកោសល្យដ៏ប៉ិនប្រសប់របស់អ្នកនិពន្ធ ព្រមទាំងសតិបញ្ញាឆ្លៀវឆ្លាតភ្លឺស្វាងត្រចះត្រចង់របស់អ្នកនិពន្ធនោះ ថែមទៀតផង ។

កត្តាទាំងនេះបានបញ្ជាក់អោយឃើញថា ការដែលអ្នកនិពន្ធអាចបណ្តុះគំនិតបានទូលំទូលាយ ហើយខ្ពង់ខ្ពស់ប្រពៃ ប្លែកអំពីគំនិតរបស់អ្នកប្រាជ្ញបុរាណនោះ មិនមែនអាចយកជាកត្តាដែលគួរអោយថ្កោលទោសអ្នកនិពន្ធ ថា គេមិនគោរពគំនិតអ្នកប្រាជ្ញចាស់បុរាណនោះបានដែរ ។ តាមការពិតទៅ ប្រសិនបើអ្នកនិពន្ធណាម្នាក់អាចធ្វើដូច្នោះ បានមែននោះ ពិតជាអាចចាត់ទុកបានថាគេជាអ្នកនិពន្ធដែលមានប្រាជ្ញ មានទេពកោសល្យខ្ពង់ខ្ពស់ពិតប្រាកដ ហើយក៏ជាមនុស្ស ដែលគោរពរក្សានិងសិទ្ធិបញ្ញា ជូនរៀមច្បងរបស់យើង ជាងនរណាៗទាំងអស់ ត្បិតគេមិនព្រមចម្លងគម្រូគំនិត ឬ វិធីសាស្ត្រ ដែលបានបោះចេញផ្សាយរួចមកហើយ ។ អ្វីដែលគួរអោយសរសើរបំផុតនោះ គឺគេអាចប្រឌិតបាននូវសិល្ប៍វិធីថ្មីដែលមិនមានលួចចម្លងម៉ូដពីរៀមច្បងណាមួយ ហើយគេក៏អាចនៅរក្សាអត្ថរសរបស់សំណេរ អោយស្ថិតក្នុងឧត្តមភាព យ៉ាងប្រសិទ្ធ មិនចាញ់អក្សរសិល្ប៍ពីបុរាណនោះ ថែមទៀតផង ។

បន្ថែមពីលើនេះ អ្នកនិពន្ធទាំងឡាយគួរចងចាំបន្ថែមទៀតផង ថា អត្ថន័យ ទំពាំងស្នងឫស្សី មិនមែនន័យថា យើងត្រូវចម្លងគម្រូចាស់បុរាណ ទាំងស្រុងទេ ថ្វីបើយើងត្រូវរៀនស្រង់យកគំនិតល្អៗពីលោកក៏ដោយ ។ ដើម្បីឲ្យងាយស្រួលយល់ សូមប្រៀបធៀបរូបយើងទៅជាអ្នកនិពន្ធទំពាំងថ្មីដែលកំពុងដុះស្នងឫស្សីចាស់ គឺមានន័យថា កាលបើយើងជាកូនទំពាំងសម័យថ្មី ទំពាំងនោះត្រូវតែខំប្រឹងដុះលូតលាស់អោយធំជាងឫស្សីមុន ឲ្យល្អរឹងមាំត្រសុំត្រសាយជាងឫស្សីមុន អោយភ្លោះកូនទំពាំងច្រើនជាងមុន នោះទើបឫស្សីអាចសាយគុម្ពវាតទីធំទូលាយពោរពាសហៀរចំការ ហើយផ្តល់ផលបរិបូរណ៍សម្បូណ៌សប្បាយជាងមុន ប្រៀបដូចជាប្រទេសមួយដែលមានពលរដ្ឋជំនាន់ក្រោយ ភ្លោះបែកគំនិតថ្មីៗច្រើន មានសតិ

ប្រាជ្ញខ្ពង់ខ្ពស់ប្រសើរឧត្តុង្គឧត្តមជាងមុន មានជំនាញទេពកោសល្យ ល្អជាងមុន នោះនឹងធ្វើអោយប្រទេសយើងក្លាយជាអាណាចក្រ ដ៏ថ្កុំថ្កើងមានអភិវឌ្ឍន៍ជាងមុន ជាក់ជាប្រាកដ ។ ផ្ទុយទៅវិញ បើទំពាំងនោះទទួលយកត្រឹមតម្រូគំនិតចាស់ៗ មិនប្រឹងបណ្តុះ បណ្តាល បំបែកគំនិតថ្មីៗ ដែលមានប្រយោជន៍ល្អប្រសើរជាងមុន បន្ថែមទៀតទេ តើឫស្សីក្នុងចំការអាចសាយគុម្ពគុះដាលវាតទី បាន ត្រសុំត្រសាយ បានដល់កម្រិតណាដែរ ?

ដូច្នេះ ក្នុងសម័យកាលបច្ចុប្បន្ន ទំពាំងជំនាន់ថ្មីគប្បីសាងខ្លួន អោយប្រសើរជាងបុព្វបុរសយើង ទាំងសតិ ប្រាជ្ញ ស្មារតី ទេព កោសល្យ និងចំណេះចេះដឹង នោះទើបយើងអាចនាំប្រទេសជាតិ ដើរឆ្ពោះទៅកាន់ភាពថ្កុំថ្កើងអភិវឌ្ឍន៍សម្បូណ៌សប្បាយ ហើយខ្ពង់ ខ្ពស់ប្រសើរឧត្តម ជាងភាពរុងរឿង ដែលប្រទេសខ្មែរយើងធ្លាប់ បានទទួល កាលពីអតីតកាល ។ នេះជាការពិតដែលយើងគួរកត់ សំគាល់អោយបានគ្រប់គ្នា ! ! !

========================================

## ផនខ្មៅ អាង កម្លាំង

## ផនខ្លាំង អាង ប្រាជ្ញា

អ្នកស្រីកែវចន្ទ័បូរណ៌

========================================

=======================================

# ជំពូកទី៧
# ការសិក្សាអំពី
# វិញ្ញាណទាំង១០

=======================================

## អំពីរូបវិញ្ញាណ

=======================================

ដើម្បីអោយមានប្រសិទ្ធិភាពក្នុងការសរសេរ អ្នកនិពន្ធម្នាក់ៗ ត្រូវការប្រើវិញ្ញាណទាំង១០យ៉ាង ជាគោល ដែលមានបែកចេញជាពីរសាខា គឺ រូបវិញ្ញាណ និង អរូបវិញ្ញាណ ។

ភាគច្រើន យើងគ្រប់គ្នាបានសិក្សានិងបានស្គាល់ជាក់ច្បាស់ នូវវិញ្ញាណទាំងប្រាំ តាំងពីយើងនៅរៀននៅបឋមសិក្សា ថែមទាំងធ្លាប់រៀនចម្រៀងដែលនិពន្ធដោយលោក ម៉ៅ វិណ្ណា នៅសម័យ សង្គមរាស្ត្រនិយម ក្រោមការគ្រប់គ្រងរបស់សម្តេច នរោត្តមសីហនុ ដើម្បីអោយកុមារាកុមារីរៀនស្គាល់និងយល់ច្បាស់អំពីអត្ថន័យជំរៅរបស់វិញ្ញាណទាំងប្រាំនោះទៀតផង ។ ចំរៀងនោះមានសេចក្តីដូចតទៅ ៖

១. ខ្ញុំមានមាត់សំរាប់និយាយ បើសប្បាយចិត្ត ខ្ញុំច្រៀងលេង<br>
មានត្រចៀកស្តាប់សូរសម្លេង មានទាំងធ្មេញទុកទំពារអាហារ<br>
មែនហើយ ទុកទំពារអាហារ ។

២. ច្រមុះប៉ុនហិតក្លិនឆាឆា មានមុខងារសំខាន់អស្ចារ្យ<br>
គឺស្រូបខ្យល់ចូលក្នុងឱរា ទ្រទ្រង់កាយាអោយបានរស់រាន<br>
មែនហើយ អោយបានរស់រាន ។

៣. ភ្នែកទាំងគូសំរាប់មើលគេ ជើងទាំងទ្វេសំរាប់ដើរឈាន

ដៃទាំងពីរជាកាយវិញ្ញាណ ប្រើចាប់កាន់ដឹងត្រជាក់ឬក្តៅ
មែនហើយ ដឹងត្រជាក់ឬក្តៅ ។

*យោងទៅតាមបទចំរៀងខាងលើ យើងបានឃើញហើយថា លោក ម៉ៅ វិណ្ណា បានប្រមូលពូតយកអត្ថន័យនៃវិញ្ញាណទាំង៥ មកបញ្ចូលនៅក្នុងបទចម្រៀងកុមារតែមួយ ។ នៅក្នុងចម្រៀងនោះយើងឃើញមានអត្ថន័យចែកចេញជាប្រាំមែកធាង គឺ*

១ក. ចក្ខុវិញ្ញាណ ៖ ការមើលឃើញដោយភ្នែក
១ខ. សោតវិញ្ញាណ ៖ ការស្តាប់ឮដោយត្រចៀក
១គ. ឃានវិញ្ញាណ ៖ ការទទួលក្លិនដោយច្រមុះ
១ឃ. ជីវ្ហាវិញ្ញាណ ៖ ការទទួលរសជាតិដោយអណ្តាត
១ង. កាយវិញ្ញាណ៖ ការទទួលកំដៅឬភាពរឹងទន់ដោយស្បែក

*អ្នកនិពន្ធទាំងឡាយសុទ្ធតែយល់ដឹងអំពីវិញ្ញាណនេះ គ្រប់ៗគ្នាមិនរំលងឡើយ ។ វិញ្ញាណទាំង៥ខាងលើនេះមានចំណាត់ចាត់ទុកនៅក្នុងផ្នែករូបវិញ្ញាណ ត្បិតជាអារម្មណ៍នានាដែលមនុស្សទទួលដឹងដោយសាររូប ។ ហេតុអ្វីទើបយើងចាត់ទុក វិញ្ញាណទាំង៥ខាងលើនេះ នៅក្នុងក្រុមរូបវិញ្ញាណ ?*

*<u>ក. អំពីចក្ខុវិញ្ញាណ</u>* ៖

*នេះគឺជារូបវិញ្ញាណដែលបានទទួល តាមរយៈការប្រើកែវភ្នែកអោយយើង មើលឃើញនូវ ខ្នាតទំហំ ចម្ងាយ កំពស់ ពណ៌ ពន្លឺ និងស្រមោល ជាដើម ។ អ្នកនិពន្ធខ្មែរភាគច្រើននិយមប្រើវិធីនិពន្ធ នៅក្នុងវិស័យចក្ខុវិញ្ញាណ នៅពេលគេចាប់ផ្តើមសរសេរសាច់រឿងរបស់គេ ជាពិសេសនៅក្នុងវគ្គទីមួយតែម្តង ។*

*<u>ឧទាហរណ៍</u>* ៖

ព្រះអាទិត្យរះព្រឿងៗពីទិសខាងកើត បញ្ចេញរស្មីពណ៌មាស ជះទៅលើវេហាស៍ដ៏សែនល្វឹងល្វើយ ដែលជណ្តប់ទៅដោយផ្ទាំងពពកស្រកាតាគ តារដ្ឋវប្រាំង មុនចូលឆ្នាំខ្មែរ។ នៅឯតាយជើងភ្នំ

មានព្រឹក្សាដុះខៀវស្រងាត់ មានទឹកជ្រោះហូរធ្លាក់ឈូឆរលើផ្ទាំងថ្ម ដាបែកពពុះសខ្វាយសាយរាយ ប្រៀបបាននឹងផ្សែងអ័ពសន្សើម យ៉ាងត្រជាក់ ហើយគួរអោយចាប់ចិត្តចេតនាពេកក្រៃ ។ សន្ទុះ កំសួលទឹកហូរបានបង្កជាស្ទឹង ហូរនាំទឹកពីជើងភ្នំកាត់វាលស្រែសំដៅរកទីភូមិដែលមានមនុស្សម្នាសង់ខ្ទមរកេតរកូត រស់នៅតាមរបៀបអ្នកស្រែចំការដែលស្រឡាញ់ធម្មជាតិ...

នៅផ្ទះស្បូវមួយតូច សង់ក្បែរមាត់ទឹក ក្រោមដើមអំពិលដ៏ធំ សាខាមួយបុរសម្នាក់មានសក់ល្បាយអាចម៍ខ្លា មាឌដំបង សម្បុរខ្មៅជ្រះកំពុងដើរចេញពីក្នុងផ្ទះសំដៅទៅក្រោលគោ ដោយមានកាន់ខ្សែមួយចង្វាយទៅផង ។ នៅខាងក្រោយផ្ទះ មានស្ត្រីមួយរូប ឈរបែរខ្នងកំពុងកាន់ចង្អេរស្រិតអង្ករ ធ្វើខ្លួនងិកងក់ៗ យោលជា ចង្វាក់ដើម្បីទទាក់ស្រូវចេញពីអង្ករ...

*នៅក្នុងឧទាហរណ៍ខាងលើនេះ អ្នកនិពន្ធបានប្រើចក្ខុវិញ្ញាណតែម្យ៉ាងប៉ុណ្ណោះ ដើម្បីសង្កេតនិងពណ៌នាអំពីទិដ្ឋភាពមួយនាព្រឹកព្រហាមតាមដងស្ទឹងក្បែរមាត់អូរ និងអំពីអ្នកភូមិពីរនាក់ដែលអ្នកនិពន្ធបានសង្កេតឃើញមុនគេ ។*

*ខ. អំពីសោតវិញ្ញាណ* ៖

*ទីនេះគឺជារូបវិញ្ញាណដែលបានទទួល តាមរយៈត្រចៀកអោយយើងបានស្តាប់ឮនូវសម្លេងផ្សេងៗ ដូចជា សំដីសន្ទនា ចម្រៀង សម្លេងសត្វយំ សម្លេងទឹកហូរ សម្លេងខ្យល់ សម្លេងម៉ាស៊ីន ឬក៏ សម្លេងសូត្រធម៌ជាដើម ។ នៅក្នុងផ្នែកនេះ អ្នកនិពន្ធខ្មែរយើង ភាគច្រើនចូលចិត្តប្រើដើម្បីអបការពណ៌នារបស់ខ្លួនទៅក្នុងសាច់ រឿងអោយអត្ថបទមានន័យខ្លឹមសារ ជាងមុន ។*

*ឧទាហរណ៍* ៖

សូរសម្លេងមាន់រងាវអឺងកងឆ្លើយឆ្លងគ្នានៅវេនទីបី ហាក់បីដូចជាចង់ដាស់អ្នកភូមិទាំងអស់អោយតើនឡើងដើម្បីប្រកបការងារទាន់ពេលនៅព្រឹកព្រហាមត្រជាក់នៅឡើយ ។ រំពេចនោះ សូរកង់រទេះគោបរងេតង៉ុត ឆ្លងកាត់វាលស្រែ នាំអ្នកភូមិធ្វើដំណើរឆ្ពោះ

ទៅកាន់លានប្រមូលផលស្រែប្រាំងជាកិច្ចបង្ហើយរដូវ មុនអ្នកភូមិរៀបចំខ្លួនទទួលចូលឆ្នាំខ្មែរ តាមទំនៀមទម្លាប់ប្រពៃណីយ៍ ។ សូរសម្លេងមនុស្សកូកហៅគ្នា លាយឡំនិងសម្លេងទារកយំមកពីផ្ទះជិតខាងបានធ្វើអោយយើងដឹងថា នៅក្នុងភូមិ មានមនុស្សរស់នៅជិតជិតគ្នាជាច្រើន ឬប្រហែលជាអ្នកភូមិទាំងនោះជាបងប្អូនសាច់សាលោហិតនឹងគ្នាទៀតផង ក៏មិនដឹង ។

*នៅទីនេះ អ្នកនិពន្ធបានប្រើរូបវិញ្ញាណសង្កេតតែសម្លេងនានា ដូចជាសម្លេងមាន់រងាវ សម្លេងកង់រទេះសង្កៀតគ្នា សម្លេងកូក ហៅគ្នា សម្លេងទារកជាដើម ។ នេះជាវិធីមួយដែលមានបង្អែក ទៅលើវិស័យសោតវិញ្ញាណដែលអ្នកនិពន្ធតែងយកមកប្រើនៅពេលពណ៌នាអំពីស្ថានភាពទីកន្លែងណាមួយរបស់សាច់រឿង ។*

## <u>*គ. អំពីឃានវិញ្ញាណ*</u> ៖

*នេះជារូបវិញ្ញាណ ដែលបានទទួលតាមរយៈច្រមុះ អោយយើងបានទទួលស្គាល់នូវក្លិនផ្សេងៗ ដូចជា ក្លិនញើស ក្លិនអាហារ ក្លិន ផ្កា ក្លិនដីល្បៀម ក្លិនអាចម៍គោ ជាដើម ។ល ។ នៅទីនេះដែរ អ្នកនិពន្ធខ្មែររមែងប្រើវិញ្ញាណនេះទៅក្នុងការពណ៌នាសាច់រឿង អោយអ្នកអានទទួលអារម្មណ៍ថា ខ្លួនហាក់បានទៅដល់ទីនោះ ទទួលនូវអារម្មណ៍នោះដោយផ្ទាល់ ។*

<u>*ឧទាហរណ៍*</u> ៖

បុរសចំណាស់បានឡើងបររទេះគោចេញទៅបាត់តាំងពីព្រហាម តែម្នាក់ឯង ។ រីឯស្ត្រីចំណាស់មួយរូបនោះវិញ បន្ទាប់ពីបុកស្រូវ ស្រិតអង្ករហើយគាត់ក៏កូកហៅកូនស្រីដែលកំពុងរែកទឹក អោយ មកយកអង្ករទៅដណ្ដំដើម្បីយកទៅជូនឪពុកដែលធ្វើការនៅឯ លានហាលស្រូវ ។ មិនយូរប៉ុន្មានក្លិនបាយស្រូវថ្មីបានសាយក្លិន ចេញពីបន្ទប់ចង្ក្រានខាងក្រោយផ្ទះលាយឡំនឹងក្លិនសម្លប្រហើរបង់ ប្រហុកចៃមជីរ ស ជះភាយៗតាមជំនោរខ្យល់ធ្វើអោយអ្នកភូមិ ទាំងឡាយដែលដើរកាត់ទីនោះលួចលេបទឹកមាត់ជាញយៗ ។

*នៅក្នុងល្បះខាងលើ អ្នកនិពន្ធបានទាក់ទាញអារម្មណ៍អ្នកអានអោយទទួលនូវក្លិនអាហារ តាមរយៈការពណ៌នារបស់ខ្លួនដោយប្រើ វិញ្ញាណទីបីគឺការទទួលក្លិនដោយឃានវិញ្ញាណ ។*

<u>*ឃ. អំពីជីវហាវិញ្ញាណ*</u> ៖

*នេះជាការទទួលអារម្មណ៍រូបវិញ្ញាណតាមរយៈអណ្តាត ដើម្បីឲ្យយើងបានស្គាល់នូវរសជាតិនានា ដូចជារសជាតិអាហារ ឱជារសផ្លែ ឈើ ឬចំណីផ្សេងៗ ។ អ្នកនិពន្ធខ្លះចូលចិត្តប្រើវិញ្ញាណនេះ ដើម្បីបង្កនូវអារម្មណ៍អោយត្រេកត្រអាលរបស់អ្នកអាន ចំពោះរសជាតិ ចំណីអាហារ ឬក៏ផ្លែឈើនានារបស់ខ្មែរ ដែលគេសរសេរបញ្ចូលទៅ ក្នុងសាច់រឿង ។*

<u>*ឧទាហរណ៍*</u> ៖

- យី ! សម្លប្រហើរនេះប្រែចម្លែកម្ល៉េះ មីអូន ?
- ចាស៎ម៉ែ ! ខ្ញុំបង់ប្រហុកជ្រុលដៃបន្តិច ។
- អញ្ចឹង កូនថែមបន្លែស្លឹកបាសនិងនោង បន្តិចទៀតទៅ ក្រែងបន្សាបបានខ្លះ ។ ហើយចុះស្វាយដែលឯងបេះមកបន្ទំនោះ យ៉ាងណាទៅហើយ កូន ?
- ចាស ! ស្វាយទាំងនោះទុំក្រអូបហើយផ្អែមផង ។ ខ្ញុំបានចិតវាពីរបីដាក់ផ្ញើពុកនៅឯលានហាលស្រូវផងដែរ ។ នេះ ! ម៉ែអញ្ជើញពិសារស្វាយរបស់យើងសាកមើល គឺផ្អែមឆ្ងាញ់មែនណាំម៉ែ !
- អឺ ! ម៉ែសាកអំបាញមិញមួយហើយ ហើយម៉ែគិតថា វាដូចជា នៅជូរបន្តិច ព្រោះមើលទៅស្វាយនោះហាក់ដូចជាមិនទាន់ពេញចំណាស់ស្រួលបួលសម្រាប់បេះបន្ទំនៅឡើយទេ ។

*នៅក្នុងប្រយោគខាងលើនេះ អ្នកនិពន្ធយើងបានប្រើជីវហា វិញ្ញាណ បរិយាយអំពីរសជាតិរបស់សម្លប្រហើរ និងរសជាតិផ្លែ ស្វាយដែលគេបេះមកបន្ទំ ដើម្បីបង្កទឹកដមទាក់ទាញអារម្មណ៍អ្នកអានអោយស្រក់ទឹកមាត់ជាមួយនិងការពណ៌នារបស់គេនោះ ។ នេះ គេហៅថា ការបង្កឥទ្ធិពលនៃចុងប៉ាកការបស់អ្នកនិពន្ធ តាមរយៈ ការប្រើជីវហាវិញ្ញាណ ដើម្បីពណ៌នា ។*

<u>*ង. អំពីកាយវិញ្ញាណ*</u> ៖

*នេះជាការទទួលអារម្មណ៍រូបវិញ្ញាណ តាមរយៈស្បែកដណ្តប់សពាង្គកាយ អោយយើងអាចកត់សម្គាល់បាន នូវសីតុណ្ហភាព អាកាស ឬក៏អោយដឹងអំពីភាពរឹងទន់របស់វត្ថុនានាជាដើម ។ នៅ ក្នុងចំណុចនេះ*

*យើងសង្កេតឃើញថា អ្នកនិពន្ធខ្មែរទូទៅចូលចិត្ត ប្រើញឹកញាប់ជាងគេ ប្រហាក់ប្រហែលនឹងការប្រើចក្ខុវិញ្ញាណ ដូច្នេះ មិនខុសគ្នាប៉ុន្មានឡើយ ។*

<u>*ឧទាហរណ៍*</u> ៖

ខ្យល់ខែប្រាំងបក់រំភើយៗត្រសៀកៗ ពេលព្រឹកព្រហាម ហាក់នាំជំនោរត្រជាក់មកបបោសប្រាណអ្នកធ្វើដំណើរទាំងឡាយ អោយទទួលនូវអារម្មណ៍ក្សេមក្សាន្ត ចាកផុតភាពសៅហ្មងទាំងឡាយក្នុង អារម្មណ៍ ថ្វីបើព្រះអាទិត្យខំត្រដរអើតកាយាបន្តិចម្តងៗ ដើម្បីយាងនាំកំដៅមកជះដណ្តប់លោកនេះទាំងព្រហាមក៏ដោយ ។

នៅតាមភ្លឺស្រែខ្វែងខ្វាត់ឯខាងក្រោយភូមិ អ្នកស្រុកធ្វើដំណើររចល់ដោយជើងទទេ សំដៅទៅរកទីការងារដែលខ្លួនត្រូវបំពេញ ប្រចាំថ្ងៃ។ រដូវនេះជាដើមរដូវប្រាំង ជារដូវបង្ហើយកិច្ចការប្រមូល ស្រូវប្រាំង ជារដូវដែលមានដីស្ងួត ហើយចាប់ផ្តើមបែកក្រហែង បន្តិចម្តងៗ។ ចំពោះអ្នកស្រុកដែលធ្វើដំណើរដោយជើងទទេ គេ ប្រាកដជាដឹងហើយថាដីស្រែរដូវប្រាំង រឹងយ៉ាងណា កាចយ៉ាងណា ចំពោះបាតជើងគេគ្រប់គ្នា នៅពេលគេចេញដើរធ្វើការងារ ។ ប៉ុន្តែ ថ្វីបើយ៉ាងនេះក៏ដោយ ក៏អ្នកស្រុកទាំងឡាយនោះមិនដែលរអ៊ូត្អូញ ត្អែ ចំពោះជីវិតរបស់ខ្លួនអ្វីបន្តិចសោះឡើយ ។ ផ្ទុយទៅវិញ គេទាំងឡាយបែរជាមានកម្លាំងចិត្ត មានមោទនភាពខ្ពស់ មានសេចក្តីព្យាយាមយ៉ាងមោះមុត ចំពោះមុខនាទីរបស់ខ្លួនក្នុងការប្រកបរបរចិញ្ចឹមជីវិតជាអ្នកស្រែចំការ ។

*នៅប្រយោគខាងលើនេះ អ្នកនិពន្ធបានប្រើកាយវិញ្ញាណរៀបរាប់នូវការប៉ះពាល់ទទួលអារម្មណ៍តាមរយៈស្បែក ដូចជាការទទួលនឹងនូវភាពត្រជាក់របស់ជំនោរខ្យល់មកលើខ្លួនប្រាណ ឬ ការទទួលនឹងនូវភាពរឹងរបស់ដីបែកក្រហែងនៅក្រោមបាតជើងទទេជាដើម ។ល ។*

*រួមសេចក្តីមក ការនិពន្ធដោយប្រើរូបវិញ្ញាណប្រាំពិតជាមានទឹកដមគួរអោយកត់សំគាល់ពិតមែន ។ ប៉ុន្តែ យើងជាអ្នកនិពន្ធមានសង្កេតបន្ថែមទេថា នៅក្នុងការនិពន្ធ ដោយប្រើវិញ្ញាណទាំងប្រាំ ខាងលើនេះ មិនមានបូកបញ្ចូលអារម្មណ៍អ្វីផ្សេងទៀតឡើយ ទៅ ក្នុងសំណេរ ដូចជាការឈឺចាប់ ការនឹករលឹក ការប្រព្រឹត្តកំហុស វិប្បដិសារី កំហឹង*

*ការដោះស្រាយវិបត្តិក្នុងជីវិត ជាដើម ? នៅពេលនេះ តើអ្នកនិពន្ធត្រូវប្រើវិញ្ញាណអ្វី ដើម្បីស្រង់យករស ជាតិជីវិត មកសរសេរនិពន្ធអត្ថបទរបស់ខ្លួនអោយកាន់តែមាន អត្ថន័យ មានអត្ថរសខ្លឹមសារកាន់តែខ្លាំងឡើងៗថែមទៀត ? គឺពេលនេះឯងហើយ ដែលអ្នកនិពន្ធទាំងឡាយត្រូវសិក្សាបន្ត នូវការប្រើវិញ្ញាណមួយកម្រិតទៀត ដែលគ្មានរូប នោះគឺការសិក្សា អំពីអរូបវិញ្ញាណទាំងប្រាំតែម្តង ។*

========================================

## ចង់រាក់អោយជីក ចង់រីកអោយឃោលថ្ងៃ

*សុភាសិតបុរាណ*

========================================

=========================================

# ជំពូកទី៨

# ការសិក្សាអំពី

# វិញ្ញាណទាំង១០

=========================================

## អំពីអរូបវិញ្ញាណ

=========================================

តើអ្វីទៅដែលហៅថា អរូបវិញ្ញាណ ?

យើងគ្រប់គ្នាបានសិក្សារួចមកហើយ នូវរូបវិញ្ញាណទាំងប្រាំ គឺការទទួលដឹងនូវអ្វីៗផ្សេងជុំវិញខ្លួន តាមរយៈរូបកាយខាងក្រៅ របស់យើង ដូចជា ភ្នែក ច្រមុះ ត្រចៀក អណ្តាត និងស្បែក ។ នៅពេលបន្ទាប់តទៅនេះ យើងនឹងសិក្សាអំពីអរូបវិញ្ញាណ ដែល ជាវិញ្ញាណ ដែលជួយអោយយើងទទួលដឹងអំពីជីវិតរបស់ខ្លួនឯង អំពីអារម្មណ៍ផ្ទាល់ខ្លួន អំពីគំនិតស្មារតី មនសិការ សម្បជ្ជញ្ញៈ របស់ខ្លួន និងអ្វីៗផ្សេងៗទៀតជាច្រើន ។ល ។

អរូបវិញ្ញាណមានបែងចែកជាប្រាំប្រភេទផ្សេងៗគ្នា គឺ

ក. ព្រលឹងវិញ្ញាណ

ខ. តុលាវិញ្ញាណ

គ. ចិត្តវិញ្ញាណ

ឃ. សតិវិញ្ញាណ

ង. ប្រាជ្ញវិញ្ញាណ

តើវិញ្ញាណទាំងប្រាំខាងលើនេះ មានប្រយោជន៍សំខាន់យ៉ាងណា ចំពោះរូបយើងជាមនុស្ស ? ហើយតើយើងអាចប្រើវិញ្ញាណទាំងនេះអោយបង្កសារប្រយោជន៍សំរាប់សង្គមជាតិបានដូចម្តេចខ្លះ ?

១. វិញ្ញាណទី៦ ឬ ព្រលឹងវិញ្ញាណ ៖

*នេះគឺជាវិញ្ញាណដែលធ្វើអោយយើងម្នាក់ៗទទួលដឹងថា យើង កំពុងមានជីវិត ។ វិញ្ញាណនេះអាចជួយធ្វើអោយយើងកត់សំគាល់ ហើយបែងចែកជីវិតរបស់យើងជាពីរបែប... មួយគឺជីវិតដែល យើងរស់នៅពិតៗ មួយទៀត គឺជាសុបិន ជាការភ្លឹកអារម្មណ៍ ជាក្តីស្រមៃ ជាប្រផ្នូលប្លែកៗ ផ្សេងៗ ។*

*នៅក្នុងផ្នែកនេះ សង្គមខ្មែរយើងទូទៅ ចំណាំហៅវិញ្ញាណនេះ ថាជា វិញ្ញាណទី៦ គឺសំដៅទៅលើព្រលឹងរបស់មនុស្សតែម្តង ជា ពិសេសនៅពេលគេនិពន្ធអំពីរឿងខ្មោចព្រាយបិសាចផ្សេងៗ ។*

*ឧទាហរណ៍៖*

ចៅសុខបរិភោគបាយហើយក៏ប្រាសខ្លួនទៅលើគ្រែឫស្សីក្រោម ដើមអំពិលមុខផ្ទះ បិទភ្នែកសម្រាកយកកម្លាំង ស្រាប់តែមានស្ត្រី ចាស់ម្នាក់ដើរមកដល់ហើយប្រាប់ថា "កូនអើយ ! ក្រោកឡើង ! ពុកឯងមានប្រសាសន៍អោយឯងទៅជួបគាត់នៅឯវត្តមួយភ្លែត " ។ ចៅសុខភ្ញាក់ក្រញាង ស្ទុះក្រោកឡើងបែរមើលជុំវិញខ្លួន មិនឃើញ មាននរណានៅទីនោះសោះ ។ នាយយកដៃញីភ្នែកហើយរំពៃមើល ជុំវិញខ្លួនសាជាថ្មី ទើបដឹងថា អំបាញមិញនេះ គេកំពុងគេងយល់ សប្តិសោះ ត្បិតអីរូបគេជាក្មេងកំព្រាម្តាយឪពុកតាំងពីតូចក្រូចឆ្មារ មកម្ល៉េះ ។ ចៅសុខបែរក្រោយ សម្លឹងមើលទៅខ្ទមស្បូវដែលខ្លួនកំពុងរស់ នៅជាមួយជីដូន នឹកស្រមៃទៅដល់សំនៀងម្តាយដែលធ្លាប់ច្រៀង បំពេរមុនពេលចៅសុខចូលគេង នឹកឃើញដល់សំណើចរបស់ឪពុក ពេលនិទានរឿងកំប្លែងចែកកូនស្តាប់ ។ តាមការពិត តាំងពីឪពុក ម្តាយរបស់ខ្លួនស្លាប់ទៅ ចៅសុខមិនដែលយល់សប្តិឃើញគាត់ទេ ទើបតែពេលនេះឯង ដែលនាយបានយល់សប្តិ ឃើញគាត់ យ៉ាង ច្បាស់ទាំងកណ្តាលថ្ងៃ មិនដឹងថា នោះគ្រាន់តែជាយល់សប្តិ ឬជា ប្រផ្នូលអ្វីម្យ៉ាង ។ ពេលនោះ ចៅសុខកើតមានចិត្តរសាប់រសល់មិន អស់មិនហើយ ថាហេតុអីក៏ម្តាយរបស់ខ្លួន មកពន្យល់សប្តិដូច្នោះ ។ គិតចុះគិតឡើង ចៅសុខក៏ដាច់ចិត្តស្ទុះងើបឡើងចេញពីគ្រែឫស្សី រត់សំដៅទៅវត្តនៅឯជាយភូមិយ៉ាងលឿនត្របាញ់ ។

នៅក្នុងឧទាហរណ៍ខាងលើ ចៅសុខបានចែកដាច់ នូវជីវិតពីរចេញពីគ្នា មួយគឺជីវិតពិតដែលខ្លួនជាក្មេងកំព្រា ពីរគឺការយល់សប្តិឃើញម្តាយមកហៅ ។ តែដោយខ្លួនមិនដែលយល់សប្តិឃើញម្តាយពីពេលមុនមក ចៅសុខបែរជាមានអារម្មណ៍ថា ខ្លួនមានប្រផ្នូលចម្លែក ដែលខ្លួនមិនដែលមានពីមុនមក ។ មួយវិញទៀត ចៅសុខបានប្រើអារម្មណ៍របស់ខ្លួននឹកស្រមៃទៅដល់អតីតកាល ។ ថ្វីបើអតីតកាលនោះជាការពិត តែពេលនេះ ការពិតនោះមានសល់ត្រឹមតែស្រមោលនៅនាបច្ចុប្បន្ននេះ ហើយមានតែព្រលឹងវិញ្ញាណប៉ុណ្ណោះ ដែលអាចនាំចិត្តចៅសុខអោយទៅឃើញអតីតកាលរបស់ខ្លួនបាន តាមក្តីស្រមៃនោះឯង ។

ដូច្នេះ ព្រលឹងវិញ្ញាណគឺជាវិញ្ញាណពិសេសបំផុត សំរាប់នាំឲ្យយើងគ្រប់គ្នាទទួលដឹងថា ខ្លួនកំពុងមានជីវិតរស់នៅ គឺជាជីវិតដែលមិនមែនជាក្តីស្រមៃ មិនមែនយល់សប្តិ មិនមែនប្រផ្នូល មិនមែនជាការភ្លឹកអារម្មណ៍ ឬអ្វីៗនោះឡើយ ។ ព្រលឹងវិញ្ញាណមានប្រយោជន៍ ក្នុងការនាំអោយយើងទទួលស្គាល់អារម្មណ៍ផ្សេងៗទៀត ដូចជាការ មើលឃើញ ការស្តាប់ឮ ការទទួលក្លិន ការទទួលរសជាតិ និងការទទួលសភាពបរិយាកាសជុំវិញខ្លួន ។

នៅចំណុចមួយនេះ មានអ្នកនិពន្ធយើងខ្លះបានសរសេរប្រឌិតអោយព្រលឹងវិញ្ញាណដើរចេញពីរូបកាយរបស់គេ ទៅបង្កហេតុប្លែកៗផ្សេងៗនៅក្នុងជីវិតមនុស្សក្នុងផ្ទះ ក្នុងភូមិ ក្នុងសង្គម ជាដើម ។ ខ្លះសរសេរអោយព្រលឹងនោះជាព្រលឹងឬស្យា មានគំនុំគុំគួនសងសឹក បង្កភាពភ័យខ្លាចដល់អ្នកស្រុកទាំងឡាយ ។ អ្នកនិពន្ធខ្លះទៀតក៏សរសេរអោយព្រលឹងនោះ ជាវិញ្ញាណសំរាប់ដាស់តឿនសតិស្មារតីរបស់តួអង្គ នៅក្នុងសាច់រឿងអោយមានសតិ ក្នុងការស្វែងរកផ្លូវល្អ សំរាប់ជីវិតរបស់គេអោយប្រពៃមកវិញ ។ ខ្លះ

ក៏សរសេររបៀបសរីរវិទ្យា បែបមនុស្សភ្លឹកដោយសារជំងឺ ដោយសារគ្រោះថ្នាក់ ឬមូលហេតុធំៗផ្សេងៗ ហើយត្រូវគ្រូពេទ្យរកមធ្យោបាយព្យាបាលផ្សេងៗ ដើម្បីអោយមនុស្សនោះបានទទួលនូវព្រលឹងវិញ្ញាណ រស់រានមានជីវិតសាជាថ្មី ។

ប៉ុន្តែ មិនថាអ្នកនិពន្ធសរសេរប្រឌិតបែបណាទេ ព្រលឹងវិញ្ញាណនៅតែទ្រទ្រង់អារម្មណ៍មនុស្សជានិច្ច អោយមនុស្សគ្រប់គ្នាទទួលដឹងថា ខ្លួនគេកំពុងមានជីវិតនៅឡើយ ។ បើសិនណាមនុស្សណាម្នាក់ខ្វះព្រលឹងវិញ្ញាណហើយ រូបគេនឹងក្លាយជាមនុស្សស្លាប់ លែងមានលទ្ធភាពនឹងទទួលដឹងនូវអារម្មណ៍អ្វីៗផ្សេងទៀតទាំងអស់ មិនថាជាការយល់សប្តិ ជាក្តីស្រមៃ ឬជាប្រផ្នូលអ្វីឡើយ ។

## <u>២. វិញ្ញាណទី៧ ឬ តុលាវិញ្ញាណ</u> ៖

នេះជាវិញ្ញាណដែលធ្វើឲ្យយើងដឹងថា តើខ្លួនរបស់យើងមានជំហរជាប់ដោយសារទំនាញផែនដី ពោលគឺវិញ្ញាណដែលអាចជួយអោយយើងមានអារម្មណ៍ថា តើខ្លួនរបស់យើងមានលំនឹងឬទេ រួចហើយ តើយើងត្រូវធ្វើយ៉ាងណា ដើម្បីរក្សាលំនឹងខ្លួន កុំអោយទំនាញផែនដីទាញយើងអោយមានគ្រោះថ្នាក់ដួលរលំឈឺខ្លួន ។

<u>ឧទាហរណ៍</u>ទី១ ៖

នៅពេលឡើងជិះកង់ តើកុមារម្នាក់ត្រូវទប់ខ្លួន កាច់ចង្កូត កាច់ចង្កេះ យោលគ្រលែងខ្លួនបែបណា ដើម្បីអោយកង់មានលំនឹង រួចហើយនៅពេលធាក់បត់ចង្កូតកង់ទៅស្តាំឬទៅឆ្វេង តើកុមារត្រូវរេងខ្លួនយ៉ាងណា ដើម្បីរក្សាលំនឹងកង់អោយនៅស្មើ មិនអោយដួលបាន ? គឺកុមារត្រូវផ្អៀកកង់ឬផ្អៀកខ្លួន ផ្អៀងស្មាទៅតាមល្បឿនកង់ និងទៅតាមទិសដែលខ្លួនបត់កង់ទៅ ។ ដើម្បីនឹងមានលទ្ធភាពធ្វើ

ដូច្នេះបានដោយមិនប្រសព្វ កុមារតូចត្រូវការតុលាវិញ្ញាណជាចាំបាច់សំរាប់ហ្វឹកហ្វឺនការរៀនជិះកង់អោយបានជោគជ័យ ។

<u>ឧទាហរណ៍ទី២</u> ៖

ពេលយើងដើរស្ពួស្ពានឫស្សីតូចៗ តុលាវិញ្ញាណនឹងប្រាប់យើងអោយលើកដៃឆ្វេង លើដៃស្តាំ បះចុះបះឡើង ដើម្បីទប់ខ្លួនឲ្យមានលំនឹង កុំអោយឃ្លោងជំហារ ក្រែងត្រូវធ្លាក់ពីលើស្ពាន ។ បើសិនជាយើងមិនមានតុលាវិញ្ញាណជួយប្រាប់យើង អោយបញ្ចេញកិរិយាកម្មបែបនោះទេ យើងពិតជាមិនអាចដឹងថា ត្រូវធ្វើយ៉ាងម៉េចដើម្បីរកលំនឹងខ្លួនឃើញនោះឡើយ ។

<u>ឧទាហរណ៍ទី៣</u> ៖

នៅពេលយើងរែកទឹក យើងដើរយោលចុះយោលឡើង ដើម្បីធ្វើយ៉ាងណាកុំអោយទឹកក្រឡុកចេញពីធុងផង ដើម្បីកុំអោយយើងធ្ងន់ឈឺស្មាដោយសារទម្ងន់ទឹកនោះផង និងដើម្បីដើរទៅមុខអោយបានលឿនផង ។ កិរិយាដែលយោលចុះយោលឡើង ដើម្បីរក្សាលំនឹងខ្លួនពេលកំពុងរែកទឹក និងដើម្បីរក្សាកុំអោយទឹកក្រឡុកផងនោះ ជាលទ្ធផលនៃតុលាវិញ្ញាណដែលដណ្តប់អារម្មណ៍មនុស្សអោយស្គាល់លំនឹងរបស់ខ្លួនជានិច្ច មិនថាពេលណា ។

ម្យ៉ាងវិញទៀត សូម្បីតែពេលមនុស្សជិះរថយន្ត ជិះទូក ជិះយន្តហោះ តុលាវិញ្ញាណក៏នាំស្មារតីមនុស្សអោយដឹងថា ខ្លួនកំពុងស្ថិតនៅទីមួយទៀត ដែលមានចលនា មានល្បឿន ទៅមុខ ទៅក្រោយ ឡើងលើចុះក្រោម ឬវិលចុះវិលឡើង ។ល ។ អ្នកដែលមិនសូវបានហ្វឹកហ្វឺនប្រើតុលាវិញ្ញាណនេះ ច្រើនប្រទះបញ្ហានៅពេលខ្លួនរបស់គេត្រូវជួបនឹងចលនាល្បឿន ឡើងចុះ ទៅមុខទៅក្រោយដូចជា ពុលក្អួត វិលមុខ ចង្អោរ ជាដើម នោះមកពីរូបគេ ប្រឹងទប់ខ្លាំងពេក មិនសម្រួលបណ្តោយខ្លួនតាមចលនាល្បឿននោះ ។

នៅទីនេះ អ្នកនិពន្ធអាចប្រើតុលាវិញ្ញាណរៀបរាប់នូវអារម្មណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងលំនឹង និងទំនាញរបស់ផែនដី ។ បើសិនជា អ្នកនិពន្ធបានសិក្សាអំពីធរណីវិទ្យា រូបវិទ្យាទៀតផង នោះ ការសរសេរសំណេរផ្សេងៗ នឹងមានប្រសិទ្ធិភាពកាន់តែខ្លាំងឡើង ថែមទៀតមិនខាន ។

## ៣. វិញ្ញាណទី៨ ឬ ចិត្តវិញ្ញាណ ៖

នេះជាវិញ្ញាណដ៏សំខាន់មួយ ដែលនាំអោយយើងបានស្គាល់នូវមនោរម្មណ៍ និងចេតនាម្មណ៍ផ្ទាល់ខ្លួនច្រើនបែបច្រើនយ៉ាង ដូចជា សេចក្តីស្រឡាញ់ សេចក្តីនឹករលឹក ការសោកស្តាយ ខឹង ស្អប់ មួម៉ៅ សប្បាយ គុំគួន រំភើប ត្រេកត្រអាល ស្រើបស្រាល ខ្ពើម ឈឺចាប់ រន្ធត់ ភ័យខ្លាច តក់ស្លុត ត្រេកអរសោមនស្ស ធុញថប់ ចង្អៀតចង្អល់អារម្មណ៍ ខក ចិត្ត ច្រណែន ប្រចណ្ឌ ប្រទុស្ត ឆ្ងល់ ពិភាល់ សង្ស័យ ស្ងប់ស្ងៀម ក្រេមក្សាន្ត ស្រងេះស្រងោច ស្រងូតស្រងាត់ ស្រណោះអាល័យ ក្រៀមក្រំ សោកសៅសង្រែង ក្តៅក្រហាយ ក្តុកក្តួល ចំណង់ចំណូលចិត្ត ការប៉ុនប៉ងប្រាថ្នា សេចក្តីលោភលន់ ចំណង់មហិច្ឆតា ខ្ជិល អំនួត ជោរ ព្រើល ប្រមាថ ជាដើម ។ល ។

ចិត្តវិញ្ញាណចែកចេញជាពីរបែប មួយជាមនោរម្មណ៍ ដែលជាអារម្មណ៍ដែលទទួលបាន ដោយអនុភាពនិងបុព្វហេតុនៃបរិយាកាសជុំវិញខ្លួន ដូចជាអារម្មណ៍សប្បាយ នឹក ខឹង ស្អប់ ខ្ពើម ជាដើម ។ ឯមួយបែបទៀតគឺជាចេតនារម្មណ៍ ជាចិត្តដែលគិតប៉ងប្រាថ្នា ដើម្បីទាញផលប្រយោជន៍មកពីបរិយាកាសជុំវិញខ្លួន ដូចជា ចង់ត្រូវឆ្នោតរង្វាន់ធំ ចង់បានផ្ទះថ្មី ចង់ធ្វើយាន ចង់ប្តូន់ ប៉ងដណ្តើងកូនគេ ប៉ងរៀនអោយបានជាបណ្ឌិត ចង់សងសឹក ចង់ប្រដៅ ។ល ។

_ឧទាហរណ៍_ ៖

ចៅសុខដើរសំដៅទៅវត្តឯជាយភូមិ ទាំងដួងចិត្តសែនស្រពាប់ស្រពោន ដោយក្តីនឹករលឹកទៅដល់ម្តាយឪពុករបស់ខ្លួន ដែលបានចែកស្ថានទៅ ដោយប្រការឃាដកម្មអំពីពួកចោរប្ញស្យាឡើងប្លន់យកប្រាក់ដែលបានមកពីការលក់ក្របីមួយនឹមកាលពី៩ឆ្នាំមុននេះ ។ ថ្វីបើកាលនោះ ចៅសុខមានវ័យប្រហែល៥ឆ្នាំ ប៉ុន្តែហេតុការណ៍ឃាដកម្មដ៏រន្ធត់ដែលកើតឡើងចំពោះឪពុកម្តាយរបស់នាយបានផ្តិតភ្ជាប់រូបភាពជាប់នៅក្នុងបេះដូងរបស់កុមារ ធ្វើអោយកុមាររងការឈឺចាប់ក្តៅផ្សាក្តុកក្តួលក្នុងចិត្តចំពោះអំពើយង់ឃ្នងនោះផង ហើយក៏មានចិត្តក្តៅក្រហាយចងគំនុំនឹងបុគ្គល ដែលសម្លាប់ឪពុកម្តាយរបស់ខ្លួននោះផង ។ មិនតែប៉ុណ្ណោះ ការឈឺចាប់នោះបានបង្កក្លាយទៅជាហឹង្សានិងសេចក្តីស្អប់យ៉ាងមហិមានៅក្នុងចិត្តរបស់គេ ចំពោះជនពាលទាំងប៉ុន្មាននាក់ដែលរត់គេចខ្លួនបាត់ស្រមោល ។ គេលួចគិតក្នុងចិត្តតែម្នាក់ឯង ថា បើសិនណាគេមានលទ្ធភាពអាចវែកមុខពួកចោរទាំងនោះបាន គេប្រាកដជាមិនអោយពួកចោរនោះរួចខ្លួនបានស្រួលម្នាក់ណាឡើយ ។ គេសច្ចាថានឹងប្រដៅជនពាលនោះឲ្យសក្តិសមនឹងអំពើដែលពួកវា បានប្រព្រឹត្តទៅលើឪពុកម្តាយរបស់នាយ ។

*នៅក្នុងឧទាហរណ៍ខាងលើនេះ អ្នកនិពន្ធសរសេរអំពីអារម្មណ៍របស់តួអង្គដែលប្រកបដោយវិបត្តិក្នុងចិត្ត ដោយសារអំពើឃាដកម្មរបស់ពួកចោរទៅលើឪពុកម្តាយរបស់គេ ដូចជាសេចក្តីនឹករលឹក ភាពស្រពាប់ស្រពោនក្នុងចិត្ត ការឈឺចាប់ រន្ធត់ក្តុកក្តួល កំហឹង ភាពស្អប់ខ្ពើម ព្រមទាំងចេតនារម្មណ៍របស់គេក្នុងការគុំគួនសងសឹកជនពាលទាំងឡាយនោះ ។ នៅទីនេះ ចិត្តវិញ្ញាណបាននាំអោយតួអង្គយល់ នឹង ស្គាល់នូវអារម្មណ៍របស់គេ ផ្ទាល់ យ៉ាងជាក់ច្បាស់*

ប៉ុន្តែ ចិត្តវិញ្ញាណមិនមានសតិជួយដាស់តឿនតួអង្គថា ការគិតរបស់គេទាំងអស់នោះ ល្អឬអាក្រក់ ខុសឬត្រូវទេ ។ ចិត្តវិញ្ញាណគ្រាន់តែជាមនោរម្មណ៍និងចេតនារម្មណ៍ ដែលមនុស្សម្នាក់ៗ មានប្រតិកម្មចំពោះអ្វីៗ ជុំវិញខ្លួន តែប៉ុណ្ណោះ ។

សូមសួរថា តើអ្វីទៅដែលជួយអោយមនុស្សស្គាល់ល្អឬអាក្រក់ ខុសឬត្រូវ ហើយអាចញែកអត្ថន័យទាំងពីរនេះ ដាច់ស្រឡះចេញពីគ្នាបាន ដើម្បីកុំអោយការគិត ឬ ការប្រព្រឹត្តរបស់មនុស្សម្នាក់ៗ ធ្លាក់ទៅក្នុងលក្ខណៈមិនប្រពៃ នៅក្នុងសង្គមជាតិ ?

ដូចជាចៅសុខនេះជាដើម ដែលបានចងកំហឹងគុំគួនទៅលើពពួកជនពាលដែលសម្លាប់ឪពុកម្តាយរបស់ខ្លួន តើការគុំគួនរបស់គេ ដែលបណ្តាលមកពីកំហឹងនិងការឈឺចាប់ទាំងឡាយនោះ នឹងក្លាយទៅជាអំពើឃាដកម្មថ្មីមួយទៀតចំពោះមនុស្ស ឬក៏យ៉ាងណាវិញ ? តើចៅសុខត្រូវធ្វើយ៉ាងណា ដើម្បីកុំអោយខ្លួនគេក្លាយជាឃាដករ ដោយសារអារម្មណ៍ទោសៈរបស់ខ្លួន ?

នៅពេលនេះឯងហើយ ដែលចៅសុខត្រូវងាកបែរមកពឹងផ្អែកទៅលើវិញ្ញាណថ្មីមួយទៀត ដើម្បីរក្សាជីវិតរបស់គេអោយស្ថិតនៅក្នុងគន្លងសីលធម៌ គុណធម៌យ៉ាងប្រពៃ ។ នោះគឺជាវិញ្ញាណទី៤ ដែលមានឈ្មោះហៅថា សតិវិញ្ញាណ ។

## <u>៤. វិញ្ញាណទី៤ ឬ សតិវិញ្ញាណ</u> ៖

នេះជាវិញ្ញាណ ដែលមានសារៈប្រយោជន៍បំផុត ចំពោះជីវិតមនុស្សក្នុងលោកទាំងមូល ត្បិតជាវិញ្ញាណដែលនាំអោយមនុស្សមានស្មារតី ចេះពិចារណាគិតរាក់ជ្រៅ វែកញែកសេចក្តីខុស សេចក្តីត្រូវ ភាពល្អ ភាពអាក្រក់ អំពើសុចរិត និងអំពើទុច្ចរិត

*ភាពប្រពៃ និងភាពពាលា ចេញចេញដោយដាច់ឡែកពីគ្នា យ៉ាង ជាក់ច្បាស់ព្រំដែនជាទីបំផុត ។*

*សតិវិញ្ញាណជាកត្តាសំខាន់សំរាប់ញែកមនុស្ស អោយបែកចេញ ពីសភាពជាសត្វតិរិច្ឆាន ដែលមានតែមនោរម្មណ៍និងចេតនារម្មណ៍ មានន័យថា កាលបើមនុស្សមានសតិគ្រប់គ្រាន់ មានស្មារតីគ្រប់ គ្រាន់ នោះមនុស្សមានសមត្ថភាពគ្រប់គ្រងជីវិត និងអំពើរបស់ខ្លួន បានយ៉ាងប្រពៃ ស្គាល់ខុស ស្គាល់ត្រូវ ស្គាល់ល្អ ស្គាល់អាក្រក់ មិនកម្លៅដូចសត្វដែលប្រព្រឹត្តអ្វីៗ តាមតែចំណង់ចិត្ត មិនចេះ ពិចារណាហេតុផល ខុសឬត្រូវ នោះឡើយ ។ សតិវិញ្ញាណជា ឫសគល់គ្រប់គ្រងដណ្តប់គំនិតនិងសកម្មភាពរបស់មនុស្ស អោយ ស្ថិតនៅក្នុងព្រំដែនមនសិការ សម្បជញ្ញៈ គុណធម៌ សីលធម៌ មនុស្សធម៌ កតញ្ញូធម៌ សប្បុរសធម៌ ភក្តីភាព សេចក្តីស្មោះត្រង់ សុចរិតភាព សន្តិភាព ចាកផុតនូវ ការប្រមាថធ្វេស ការបង្កកំហឹង គំនុំនិន្នាឈ្នានីសព្យាបាទ សងសឹក ឬក៏ការវង្វេងទៅក្នុងលោភៈ ទោសៈ មោហៈ ជាដើម ។*

*<u>ឧទាហរណ៍</u> :*

នៅតាមផ្លូវ ចៅសុខបានប្រទះឃើញដើមក្រូចជាច្រើនក្នុង ចំការ ទម្លាក់ផ្លែទុំរយោងពេញដើម ។ គេនឹកស្រៀវទឹកមាត់ចង់ បេះបរិភោគតែម្តង ។ ចៅសុខដើរបណ្តើរលួចជៀងភ្នែកមើលទៅ ផ្លែក្រូចទាំងឡាយនោះបណ្តើរ គិតថា នឹងចូលទៅលួចបេះយក មួយផ្លែពីរផ្លែម្តងៗទៅហើយ ប៉ុន្តែ យុវជនយើងបែរជាមិនដាច់ ចិត្តនឹងធ្វើដូច្នោះ ព្រោះដឹងថាក្រូចនោះមានម្ចាស់ មិនគួរណាខ្លួន ចូលលួចរបស់គេដូច្នេះទេ ។ បើសិននាយចង់បានពិតមែន គួរ ណាស់តែនាយចូលទៅសុំម្ចាស់គេសិន មុននឹងចូលបេះ ។ កាល បើយល់ថា ការលួចបេះដោយមិនបានសុំម្ចាស់មិនមែនជាការប្រពៃ

ចៅសុខក៏បោះជំហានដើរបន្តទៅទៀត ថែមទាំងសន្យាក្នុងចិត្តថា ខ្លួនមិនលួចគេជាច់ខាត ថ្វីត្បិតរូបគេជាកូនចៅអ្នកក្រីក្រអត្តខាត់ក៏ដោយ ។

នៅក្នុងឧទាហរណ៍នេះ សតិវិញ្ញាណបានដាស់ស្មារតីចៅសុខ អោយយល់នូវភាពមិនប្រពៃនៃការលួចរបស់ទ្រព្យអ្នកដទៃ ហើយ អោយដកថយគំនិតប៉ងចង់បេះក្រូច ដោយមិនបានសុំម្ចាស់ ។ សតិវិញ្ញាណនេះ អាចមានប្រសិទ្ធិភាពប្រសើរបាន ដោយសារចៅសុខរបស់យើង មិនបណ្តោយខ្លួនអោយចិត្តវិញ្ញាណលាតអនុភាពដណ្តប់រូបគេខ្ពស់ជាងសតិវិញ្ញាណ ។ តាមធម្មតា វិញ្ញាណទាំងពីរនេះតែងតែប្រទាញប្រទង់គ្នា ប្រជែងអនុភាព ដើម្បីគ្រប់គ្រងជីវិតមនុស្សអោយធ្វើតាមបញ្ជារបស់ខ្លួន ។ មនុស្សណាដែលបណ្តោយខ្លួនអោយចិត្តវិញ្ញាណគ្រប់ដណ្តប់អនុភាពលើរូបកាយរបស់ខ្លួន ខ្លាំងជាងសតិវិញ្ញាណហើយ មនុស្សនោះច្រើនឃ្លាតចាកនូវគន្លងធម៌ប្រពៃក្នុងជីវិត ហើយច្រើនប្រព្រឹត្តអំពើអ្វីៗតាមទំនើងចិត្ត មិនមានវិចារណ៍សំរាប់ភាពល្អនិងអាក្រក់ ខុសនិងត្រូវឡើយ ។ ឧទាហរណ៍ ដូចជាមនុស្សដែលមានចិត្តមានះ ចចេស មានកំហឹង មានគំនិតព្យាបាទប្រទុស្តរាយ មានចិត្តចង់ចាក់ដោតអុជអាលយាយីអ្នកដទៃ ជាដើម កាលបើគេមិនរក្សាសតិអោយស្គាល់អ្វីខុសអ្វីត្រូវហើយ នោះគេនឹងក្លាយទៅជាជន វង្វេងក្នុងភពទោសៈ និងមោហៈ បង្កគ្រោះថ្នាក់អំពាល់ដល់សង្គម ពិបាកនឹងសម្រួលកែកុនណាស់ ។

ផ្ទុយទៅវិញ បុគ្គលដែលប្រកបដោយសតិស្មារតី រមែងមិនបណ្តោយអោយចិត្តរបស់ខ្លួន វង្វេងងងិតងងល់ទៅតាមមនោរម្មណ៍ ឬចេតនារម្មណ៍ រហូតដល់ហួសព្រំដែននឹងត្រួតត្រានោះ បានឡើយ ព្រោះថា បើគេអាចយកសតិស្មារតីមកពិចារណាខុសត្រូវហើយ គេប្រាកដជាយល់ច្បាស់នូវផ្លូវល្អ ផ្លូវត្រូវ ឆ្ពោះទៅរកសេចក្តីសុខក្នុង

ជីវិត ដែលប្រកបដោយភាពស្ងប់ស្ងៀមទាំងសំដី ទាំងកិរិយា ប្រកបដោយសីលធម៌ គុណធម៌ សិរីសួស្តី និងភាពក្សេមក្សាន្ត ជានិច្ច ។ នោះគឺមកពីបុគ្គលនោះបានជ្រើសរើសអោយសតិវិញ្ញាណ មកបំរើសេចក្តីត្រូវការ នៅក្នុងជីវិតរបស់គេ យ៉ាងពេញអំណាច ដោយមិនបណ្តោយអោយចិត្តវិញ្ញាណ វាតទីដណ្តប់អនុភាពលើរូប គេ បានដោយសេរីឡើយ ។

ក្នុងនាមជាអ្នកនិពន្ធដែលប្រើចុងប៉ាកកាជាសិល្ប៍សាស្ត្រដណ្តប់ អារម្មណ៍ និងដណ្តប់គំនិតរបស់អ្នកអាន យើងគប្បីយល់ជាក់ច្បាស់ នូវអត្ថន័យនិងមុខងាររបស់ចិត្តវិញ្ញាណនិងសតិវិញ្ញាណ ថាតើយើង ជាអ្នកសរសេរនោះ បានរក្សាអនុភាពនៃវិញ្ញាណណាមួយ រវាងចិត្ត វិញ្ញាណនិងសតិវិញ្ញាណ ក្នុងការប្រើចុងប៉ាកការបស់យើងអោយ លាតអនុភាពយ៉ាងប្រពៃហើយសក្តិសិទ្ធិ ទៅលើចិត្តគំនិតរបស់អ្នក អានទាំងឡាយ ? តើយើងកំពុងប្រើចិត្តវិញ្ញាណអោយដណ្តប់ស្លាប ប៉ាកការបស់យើង ឬក៏យើងកំពុងប្រើសតិវិញ្ញាណ អោយណែនាំ ស្លាបប៉ាកការបស់យើងជាជាង ?

នៅត្រង់នេះ អ្នកនិពន្ធទាំងឡាយមានសិទ្ធិពេញទី នៅក្នុងការ ជ្រើសរើសយកវិញ្ញាណនិមួយៗ មកប្រើជាជំនួយក្នុងការនិពន្ធ ។ ប៉ុន្តែ ថ្វីបើយ៉ាងនេះក៏ដោយ យើងជាអ្នកនិពន្ធគប្បីចងចាំថា អ្នក អានទាំងឡាយក៏ជាចៅក្រមកាត់ក្តីសំណេរយើងគ្រប់គ្នាទាំងអស់ដែរ ត្បិតបុគ្គលទាំងឡាយនោះអាចប្រើសតិវិញ្ញាណ ក្នុងការវាយតម្លៃ គំនិត និង ចេតនារម្មណ៍របស់អ្នកនិពន្ធបានគ្រប់ៗគ្នា ។ ដូច្នេះ ក្នុងនាមជាអ្នកនិពន្ធ ដែលធ្លាប់មានដំណើរឈានមុខ មុនអ្នកអាន យើងមិនគួរបណ្តោយអោយសំណេររបស់យើង បែរជំហានចាក ឆ្ងាយ ពីសតិប្រាជ្ញ មនសិការ និងភាពក្សេមក្សាន្តក្នុងអារម្មណ៍ បានជាដាច់ខាត ។

ប៉ុន្តែ ដើម្បីនឹងដើរឈានដល់ទីនោះ អោយបានប្រសើរ ហើយសក្តិសិទ្ធិ ក្នុងការបញ្ចេញសិល្បិ៍មន្តផ្នែកស្លាបប៉ាកកា នាំមុខអ្នកអានអោយត្រេកត្រអាលនឹងទទួលអនុភាពនៃសំណេររបស់យើង អ្នកនិពន្ធទាំងឡាយនឹងត្រូវការប្រើសតិនិងប្រាជ្ញយ៉ាងប៉ិនប្រសព្វ ក្នុងការចងខ្ចូចរឿងនិងការស្រាយខ្ចូចរឿងទាំងឡាយ ដែលខ្លួនគេបានប្រឌិតឡើង ពោលគឺ អ្នកនិពន្ធត្រូវបញ្ចេញទេពកោសល្យ ក្នុងការបង្កើតប្រធានបទ បង្កការសង្ស័យ បង្កើនចម្ងល់ អោយអ្នកអានមានចិត្តចង់តាមដានសាច់រឿង ដោយខានមិនបាន ព្រមទាំងចេះច្នៃប្រឌិតរចនា នូវការដោះស្រាយពន្យល់ ពន្លាត ស្ថានការណ៍ ក្នុងសំណេរអោយបានសមហេតុផល ក្បោះក្បាយ ហើយមានអត្ថរសគួរអោយអ្នកអានត្រេកត្រអាលនឹងតាមដានផង ហើយបានស្គាល់នូវខ្លឹមប្រយោជន៍នៃការនិពន្ធរបស់យើងផង ។

គ្រានោះហើយ ដែលអ្នកនិពន្ធទាំងឡាយ ចាប់យកប្រាជ្ញា វិញ្ញាណមកប្រើយ៉ាងហ្មត់ចត់ក្រៃលែង បន្ថែមពីលើសតិវិញ្ញាណដើម្បីបង្កបង្កើនសិល្បសាស្ត្រ និពន្ធអោយកាន់តែមានប្រសិទ្ធិភាពឧត្តុង្គឧត្តមជាអតិបរមា ។

## ៥. វិញ្ញាណទី១០ ឬ ប្រាជ្ញវិញ្ញាណ ៖

នេះគឺជាវិញ្ញាណដែលធ្វើអោយមនុស្សចេះស្រាវជ្រាវ ចេះគិតហើយស្វែងរកឃើញនូវមធ្យោបាយប្លែកៗ មកដោះស្រាយបញ្ហាផ្សេងៗ ដែលគេពើបប្រទះក្នុងជីវិត ។ ប្រាជ្ញាវិញ្ញាណមានអនុភាពអាចជួយអោយយើងហ្វឹកហ្វឺនគំនិតនិងស្មារតី ស្រូបយកការចេះដឹងនានាមក បន្ថែមអោយខ្លួនយើងរាល់ថ្ងៃ មានទាំងការរៀនសូត្រខាងអក្សរសាស្ត្រ វិទ្យាសាស្ត្រ និងវិជ្ជាជំនាញអ្វីៗទៀតទាំងឡាយ ។ ប្រាជ្ញាវិញ្ញាណជួយបណ្តុះបណ្តាលទេពកោសល្យរបស់យើង យ៉ាង

*ប្លែកៗសព្វបែបយ៉ាងទាំងអស់តាមលទ្ធភាពរបស់យើង ។ នៅពេលនោះ យើងអាចបង្កបង្កើនការចេះដឹងសំរាប់ជួយខ្លួនឯងផង ហើយក៏អាចជួយបង្កើនទេពកោសល្យ និងភាពប៉ិនប្រសប់ខាងច្នៃប្រឌិតអ្វីៗទៀត ដល់ប្រជាពលរដ្ឋខ្មែរដទៃទៀត អោយគេបានរៀនសូត្ររីកចំរើនដុះដាលក្នុងសង្គមវិញផង ។*

*<u>ឧទាហរណ៍ទីមួយ</u>៖*

បន្ទាប់ពីបានទៅសុំម្ចាស់គេហើយ ចៅសុខក៏ត្រឡប់មកចំការ វិញដើម្បីបេះក្រូចយកមកបរិភោគ ។ ប៉ែដន្យ ផ្លែក្រូចដែលចៅសុខចង់បាននោះ ជាផ្លែធំទំនៅចុងមែកខ្ពស់ ឈោងចាប់បេះមិនដល់ ។ ឯដើមក្រូចទៀតសោត ក៏សំបូរទៅដោយបន្លានិងសត្វអង្រ្កងពិបាកនិងឡើងបេះ ។ ចៅសុខគិតមួយស្របក់ ក៏បែរងាកជុំវិញខ្លួន ឃើញទំពក់ឫស្សីមួយ ដែលម្ចាស់ចំការដាក់ផ្អែកចោលម្តុំៗនោះ ។ យុវជនយើងក៏ស្ទុះទៅចាប់ទំពក់ឡើង ថ្កក់យកផ្លែក្រូចដែលគេចង់បាននោះភ្លាម ។ ប៉ែដន្យ ចៅសុខបេះបានក្រូចដល់ទៅប្រាំពីរផ្លែ ពិបាកនឹងដើរកាន់ណាស់ ។ គេក៏ដោះឈ្នួតពីក្បាលលាត ចងជាបង្វិច ដើម្បីដាក់ផ្លែក្រូចទាំងនោះ ។

*នៅក្នុងឧទាហរណ៍ងាយមួយនេះ ចៅសុខប្រើប្រាជ្ញាគិតរកមធ្យោបាយបេះក្រូច ហើយវេចក្រូចយកទៅតាមខ្លួនដើម្បីបរិភោគតាមផ្លូវ ។ នៅកន្លែងនេះ ចៅសុខប្រើប្រាជ្ញាវិញ្ញាណ ដើម្បីដោះស្រាយ ថ្វីបើជាការដោះស្រាយងាយៗក៏ដោយ ។*

*<u>ឧទាហរណ៍ទីពីរ</u> ៖*

*នៅក្នុងរឿងព្រេងសម័យបុរាណ មនុស្សអាចហោះហើរលើភ្នំឆ្លងអាកាស ឬដើរឆ្លងសមុទ្របានយ៉ាងងាយស្រួលបំផុត ។ បែរមកសម័យបច្ចុប្បន្នវិញ មនុស្សក៏នៅអាចតែអាចហោះហើរ ដើរលើ*

អាកាស ឬដើរឆ្លងសមុទ្របាន ដូចកាលសម័យបុរាណមិនខុសគ្នាទេ ប៉ុន្តែ តើមនុស្សមានសិល្បៈអ្វីទៅ ដែលជួយអោយរូបគេក្លាយទៅជាមនុស្សមានអនុភាពខ្លាំងក្លាបែបនោះបាន ? នោះគឺប្រាជ្ញវិញ្ញាណតែម្យ៉ាងគត់ ដែលជាគោលចំបង អាចនាំអោយមនុស្សក្លាយទៅជាទេវតាមានសិល្បៈមានអនុភាពខ្លាំងក្លា មិនចាញ់ពីសម័យកាលពីបុរាណនៅក្នុងរឿងព្រេងនានាឡើយ ។ មានន័យថា នៅនាបច្ចុប្បន្ននេះ មនុស្សបានសិក្សាអំពីគណិតវិទ្យា ធរណីវិទ្យា វិស្វកម្មអគ្គីសនី សំណង់ គីមីវិទ្យា រូបវិទ្យា និងវិទ្យាសាស្ត្រដទៃទៀតជាច្រើន រហូតអាចផលិតដែកអោយហោះបាន ជាយន្តហោះ ហោះដឹកមនុស្សរាប់រយនាក់ ដឹកអីវ៉ាន់រាប់តោនកាត់វេហាស៍ឆ្លងទ្វីបឆ្ងាយរាប់ម៉ឺនយោជន៍...មនុស្សអាចផលិតដែកអោយអណ្តែតលើទឹក ជាកប៉ាល់ដឹកមនុស្ស ដឹកអីវ៉ាន់ឆ្លងមហាសាគរ ឆ្លងទ្វីបអាចផលិតអោយប្រអប់ដែក អោយក្លាយជាទូរទស្សន៍ ជាកំព្យូទ័រជាយានអវកាស ជាទូរស័ព្ទ ជាអាយផង ជាអាយហ្វូន ប្រព័ន្ធឥន្ធនិត ប្រព័ន្ធទូរសព្ទ័ឆ្លងទ្វីប ប្រព័ន្ធទូរទស្សន៍ឆ្លងទ្វីប (ខ្សែកាប) ។ល ។ និង ។ល ។

បន្ថែមពីលើនោះទៀត មនុស្សក៏មានប្រាជ្ញា ដោះស្រាយបញ្ហាជីវិតផ្សេងៗ ទៀតជាច្រើន រាប់មិនអស់ ដើម្បីអោយមនុស្សដទៃទៀតក្នុងសង្គម អាចរស់នៅយ៉ាងសែនសប្បាយបំផុត ដូចជាការបង្កើតប្រព័ន្ធនៃការរស់នៅ អោយមានអធិបតេយ្យភាពរៀបរយមានសន្តិសុខ មានយុត្តិធម៌ មានសីលធម៌ មានច្បាប់រដ្ឋ មានវិន័យ មានការអប់រំថ្លៃថ្នូរ មានជីវិតរស់នៅមនោរម្យ ដោយការសាងសង់សំណង់អាគារល្អៗ មានម៉ាស៊ីនត្រជាក់ មានអាងសប់ទឹកពពុះ មានពូកខ្យល់ ពូកទឹក មានម៉ូតូទឹក ម៉ូតូគោក នាឡិកា ឌីវីឌី

ស៊ីឌី អិមភីទ្រី ប្រព័ន្ធផែនទីកាត់ត្រាដោយយានអវកាស ម៉ាស៊ីនបោកគក់ ម៉ាស៊ីន ហាលខោអាវ ម៉ាស៊ីនធ្វើសរសៃ ជាដើម ។ល ។
ប្រាជ្ញវិញ្ញាណមានឫទ្ធិអាចជួយអោយមនុស្សផលិតអ្វីៗ ដើម្បីជួយមនុស្សដទៃទាំងឡាយអោយក្លាយទៅមានភ្នែកទិព្វ អាចមើលឃើញគ្នាឆ្លងទ្វីប តាមរយៈប្រព័ន្ធឥន្ទ្រីណិត អាចស្តាប់គ្នាឮ តាមទូរស័ព្ទឆ្លងទ្វីប អាចដឹងដំណឹងបន្តផ្ទាល់ពីប្រទេសផ្សេងៗ តាមប្រព័ន្ធទូរទស្សន៍ខ្សែកាប អាចហោះឆ្លងទ្វីបទៅមក យ៉ាងស្រណុកសុខសប្បាយ អាចរស់នៅក្នុងបរិកាសត្រជាក់មនោរម្យក្នុងលំនៅស្ថានរបស់ខ្លួនពេលអាកាសខាងក្រៅក្តៅស្ទើរខ្លោចស្បែក អាចធ្វើអោយម៉ាស៊ីនចំអិនអាហារអោយបរិភោគ ដោយមិនបាច់បង្កាត់ភ្លើង អាចធ្វើអោយម៉ាស៊ីនពិនិត្យគ្រោះថ្នាក់ មុនមនុស្សដើរទៅដល់ ដូចជា គ្រឿងម៉ាស៊ីនស្ទង់មីនខ្យល់ជាដើម ។
រួមសេចក្តីមក ប្រាជ្ញវិញ្ញាណ ជាវិញ្ញាណដែលមានសារសំខាន់បំផុត ក្នុងការជួយអោយមនុស្សឆ្លៀវឆ្លាត មិនទាល់ច្រក មិនទាល់គំនិត មិនទាល់មធ្យោបាយ ក្នុងការដោះស្រាយជីវិត និងជីវភាពរបស់ខ្លួន អោយប្រសើរថ្កុំថ្កើងជាងមុន ។ ថ្វីបើមនុស្សទាំងឡាយកើតមក មិនបានទទួលកម្រិតសុខភាពផ្នែកប្រាជ្ញាស្មើៗគ្នាក៏ដោយក៏មនុស្សទាំងឡាយអាចទាញឱកាស ខិតខំហាត់រៀន ហ្វឹកហ្វឺនបណ្តុះបាជ្ញ អោយបានញឹកញាប់ តាមដែលចិត្តគេប៉ងប្រាថ្នា ដោយការស្រូបយកចំណេះចេះដឹងនានា ជុំវិញខ្លួន ទាំងនៅក្នុងសាលាទាំងនៅក្រៅសាលា ។ មិនយូរមិនឆាប់ បុគ្គលទាំងនោះនឹងក្លាយជាមនុស្ស ដែលបរិបូណ៌ដោយទេពកោសល្យដោះស្រាយជីវិត យ៉ាងប្រសើររុងរឿង ។ ប្រាជ្ញមនុស្សមានប្រសិទ្ធភាព មិនខុសអ្វីអំពីកាំបិតដែក ដែលប្រើណាស់កាន់តែភ្លឺរលោងណាស់ មិនមានច្រេះចាប់ឡើយ ។ ប្រាជ្ញាមនុស្សអាចបណ្តុះអោយកើនបាន នៅគ្រប់

វេលាណាទាំងអស់ មិនថាមនុស្សនៅក្នុងវ័យណាទេ ថ្វីបើជំរឿននៃការកើនប្រាជ្ញាអាចមានកម្រិតខុសៗគ្នា ទៅតាមបុគ្គលនិមួយៗក៏ដោយ ។

ប្រាជ្ញាអាចមានកំណើនមកពីការហ្វឹកហ្វឺនច្រើន ទីមួយ គឺមកពីការទម្លាប់សង្កេត ដោយការស្តាប់ ឬការអាន ទីពីរមកពីការទន្លាប់គិតវិភាគ ទីបីមកពីការអនុវត្តន៍ ស្រាវជ្រាវ ហ្វឹកហ្វឺនជាប្រចាំមិននៅទំនេរ ។ កាលបើយើងទម្លាប់គិត ល្អិតល្អន់ ទម្លាប់សង្កេតល្អិតល្អន់ ទាំងខាងស្តាប់ ទាំងខាងអាន ហើយទម្លាប់អនុវត្តន៍ការងារ ឬលំហាត់ច្រើនៗ នោះយើងនឹងកើនប្រាជ្ញច្រើនឡើងៗឯងៗដោយស្វ័យប្រវត្តិ ។ ដូច្នេះ បើសិនមនុស្សមានការហ្វឹកហ្វឺនកាន់តែច្រើន គេក៏កាន់តែកើននូវទេពកោសល្យច្នៃប្រឌិតនិងភាពប៉ិនប្រសប់ ទៅតាមកម្រិតនោះដែរ ។

មានពាក្យស្លោកមួយដែលនិពន្ធដោយព្រះគ្រូសង្ឃរាជជួនណាតមានសេចក្តីថា "ប្រាំបួនទាល់ ដប់ទាល់ សូមកុំអោយតែទាល់គំនិតប្រាជ្ញា " នោះគឺ ជាការសម្តែងអោយឃើញថា ព្រះអង្គកំពុងពន្យល់នរជនទាំងឡាយអោយរៀនគិត រៀនបណ្តុះបណ្តាលប្រាជ្ញនិងសតិរបស់ខ្លួន មិនអោយទាល់ច្រក មិនថា រូបគេស្ថិតនៅក្នុងករណីណា ស្ថានការណ៍ណាមួយឡើយ ។ មានន័យថា ព្រះអង្គកំពុងជំរុញបុគ្គលទាំងឡាយអោយដើរចាកភាពងងឹតងងល់ ភាពកម្លៅភាពទាល់ច្រក ដោយការប្រឹងព្យាយាមរៀនត្រិះរិះ រៀនពិចារណារៀនអនុវត្តន៍ គឺមិននៅអង្គុយត្រឹមតែសូត្រទ្រឹស្តី អោយគេស្តាប់តែប៉ុណ្ណោះទេ ប៉ុន្តែត្រូវអនុវត្តន៍អោយឃើញលទ្ធផល ជាប្រយោជន៍ដល់ខ្លួននិងដល់សង្គមមនុស្សទូទៅយ៉ាងប្រសិទ្ធ ថែមទៀតផង ។

ថែដន្យ ការមានកំណើនផ្នែកប្រាជ្ញតែម្យ៉ាង មិនអាចជួយឲ្យបុគ្គលនិមួយៗក្លាយជាមនុស្សល្អ ឬមនុស្សគម្រូបានឡើយ ព្រោះថា

បើមនុស្សម្នាក់មានកំណើនប្រាជ្ញខាងឆក់ប្លន់ ខាងរកមធ្យោបាយបង្កើតអាវុធប្រល័យជីវិតមនុស្ស ខាងផលិតថ្នាំញៀន ។ល ។ នោះក៏អាចបណ្តាលអោយទៅជាគ្រោះថ្នាក់មួយយ៉ាងធំ ដល់ជីវិតមនុស្សក្នុងសង្គមទាំងមូលដែរ ។ ដោយហេតុនេះ តើអ្វីទៅដែលមានអនុភាព អាចជួយរក្សាមនុស្សដែលមានប្រាជ្ញ អោយមានការអនុវត្តន៍ល្អប្រពៃ ដើម្បីនាំនូវប្រយោជន៍ដល់ខ្លួន ដល់ក្រុមគ្រួសារនិងដល់សង្គមជាតិ ?

ចម្លើយគឺ សតិវិញ្ញាណ មានន័យថា បុគ្គលណាដែលប្រកបដោយប្រាជ្ញខ្ពង់ខ្ពស់ហើយ ហើយមានសតិស្មារតីមុតមាំស្គាល់ខុសត្រូវ ស្គាល់ល្អអាក្រក់ ប្រពៃនិងពាលា ហើយរក្សាគំនិត រក្សាការប្រព្រឹត្តរបស់ខ្លួនអោយ ស្ថិតនៅក្នុងព្រំដែនមនសិការ សម្បជ្ជញ្ញៈ គុណធម៌ សីលធម៌ មនុស្សធម៌ កតញ្ញូធម៌ ភក្តីភាព សុចរិតភាព សន្តិភាព សេចក្តីស្មោះត្រង់ ចាកផុតនូវការប្រមាថឆ្វេស ការបង្កកំហឹងគំនុំនិន្នាឃ្នានីស ព្យាបាទសងសឹក ឬក៏ការវង្វេងទៅក្នុងលោភៈទោសៈមោសៈជាដើម បុគ្គលនោះរមែងនឹងប្រព្រឹត្ត និងបង្កបង្កើនតែអ្វីៗទាំងឡាយ ដែលនាំមកនូវប្រយោជន៍ និងសេចក្តីចម្រើនដល់សង្គមមនុស្សតែម្យ៉ាងប៉ុណ្ណោះ ។

រីជនណាដែលមានប្រាជ្ញ តែខ្វះសតិ ក៏មិនទាន់អាចសន្មតបាន ថាជាបុគ្គលដែលបង្កបង្កើនប្រយោជន៍ដល់សង្គមនោះបានដែរ ។

ហើយ ចំពោះជនដែលមានសតិ តែខ្វះប្រាជ្ញាដោះស្រាយនូវបញ្ហាផ្សេងៗក្នុងជីវិតក៏មិនទាន់អាចសន្មតថា ខ្លួនគេនោះអាចបង្កបង្កើនប្រយោជន៍ដល់ខ្លួននិងដល់សង្គមជាតិពេញលក្ខណៈដែរ គ្រាន់តែថារូបគេអាចរក្សាខ្លួនក្នុងភាពប្រពៃ បានតែម្យ៉ាងប៉ុណ្ណោះ ។

ដូច្នេះ បុគ្គលណាអាចពូតច្របាច់វិញ្ញាណទាំងពីរចុងក្រោយគឺសតិវិញ្ញាណ និងប្រាជ្ញវិញ្ញាណ អោយមកបម្រើខ្លួនដោយហ្មត់ចត់

ពេញអំណាចបំផុតនោះ បុគ្គលនោះប្រាកដជានឹងអាចឈានដល់លក្ខណៈជាអ្នកប្រាជ្ញបណ្ឌិត ដែលគួរអោយគោរពបំផុតក្នុងសង្គម ។ សរុបមក មនុស្សទាំងឡាយណាដែលគ្រប់គ្រងដោយសតិវិញ្ញាណ និងប្រាជ្ញវិញ្ញាណពេញលក្ខណៈ ច្រើនជាមនុស្សដែលមានសុទិដ្ឋិនិយម បរិបូណ៌ទៅដោយក្តីសង្ឃឹម សម្លឹងឃើញអ្វីៗតែក្នុងផ្លូវល្អផ្លូវប្រសើរ មានជំនឿជឿជាក់លើការចេះនឹងរបស់ខ្លួនពិតប្រាកដហើយរមែងចៀសវៀង មិនធ្វើខ្លួនជាមនុស្សទាល់ច្រកអស់សង្ឃឹមឡើយ ។ ម្យ៉ាងទៀត គេក៏មានសមត្ថភាព មានប្រាជ្ញ ជួយបំភ្លឺនូវមធ្យោបាយនានាដើម្បីដោះស្រាយផ្លូវជីវិតផ្សេងៗ ដល់មនុស្សទាំងឡាយអោយរស់នៅសុខសប្បាយ ហើយសំបូរបែប ក្នុងមូលដ្ឋានសង្គមធម៌ សីលធម៌ គុណធម៌ និង សប្បុរសធម៌យ៉ាងប្រពៃ មិនរំលងទៀតផង ។

================================

# សតិ នាំ សន្តិភាព

# ប្រាជ្ញា នាំ វឌ្ឍនភាព

អ្នកស្រីកែវច័ន្ទបូរណ៍

================================

==================================

# ជំពូកទី៩

# ប្រភេទអ្នកនិពន្ធ

==================================

ដើម្បីនឹងក្លាយជាអ្នកនិពន្ធម្នាក់បាននោះ យើងមិនចាំបាច់មានបរិញ្ញាបត្រខ្ពង់ខ្ពស់អ្វីនោះទេ ឲ្យតែយើង មានការព្យាយាមអានច្រើន ស្តាប់យោបល់អ្នកដទៃច្រើន ធ្វើការសង្កេតអ្វីៗជុំវិញខ្លួនអោយបានច្រើន រួចទម្លាប់សរសេរអោយបានហោចណាស់ពីកន្លះទំព័រទៅមួយទំព័រ ក្នុងមួយថ្ងៃ នោះយើងក៏អាចក្លាយជាអ្នកនិពន្ធបានយ៉ាងពិតប្រាកដ នៅថ្ងៃណាមួយ ។ អ្នកនិពន្ធណាដែលចូលចិត្តអាន ចូលចិត្តសង្កេត និងចូលចិត្តស្តាប់មតិយោបល់ច្រើន អ្នកនិពន្ធរូបនោះច្រើនតែបែកគំនិតថ្មីៗ ប្លែកៗ ជាច្រើន មកសរសេរជានិច្ច ពោលគឺអាចបញ្ចេញថ្មីដែដោយសមត្ថភាពផ្ទាល់ មិនចម្លងសាច់រឿងនិពន្ធយកមកពីប្រភពផ្សេងទៀតឡើយ ។

ស្នេរទាំងឡាយមានបែកចែកជាពីរលក្ខណៈ គឺ ៖

## <u>១. អ្នកចងក្រង</u> ៖

អ្នកចងក្រងគឺជាស្នេរដែលស្រាវជ្រាវនូវសំណៅផ្សេងៗហើយត្រងយកពត៌មានទាំងនោះ យកមកចងក្រងទុកជាឯកសារសំរាប់រៀន ឬសំរាប់កំសាន្ត ។ ស្នេរទាំងនេះមិនមានប្រឌិតពាក្យពេចន៍បញ្ចេញបញ្ចូលគំនិតបន្ថែមពីលើអត្ថបទរបស់អ្នកនិពន្ធដទៃ ដែលសរសេររួចមកហើយនោះឡើយ គឺគេមានបំណងគ្រាន់តែប្រមូលផ្តុំគំនិតយោបល់ ទ្រឹស្តី ឬពត៌មានដែលមានប្រយោជន៍ផ្សេងសំរាប់

សិក្ខាជនអានសិក្សាបន្តៗទៀតតែប៉ុណ្ណោះ ។ ដូច្នេះ ស្មេរជំពូកនេះ មិនអាចសន្មតចូល ក្នុងចំណោមអ្នកនិពន្ធបានទេ ត្បិតបុគ្គលទាំងនោះ មិនបានបញ្ចេញស្នាដៃនិពន្ធដោយខ្លួនឯង មិនបានបញ្ចេញគំនិត បង្ហាញស្មារតី បង្ហាញនូវអត្តគតិ ឬឆន្ទៈរបស់អ្នកនិពន្ធផ្ទាល់ មកជាសំណេរផ្សេងៗ មិនថាជាពាក្យពេចន៍អត្ថបទ ខ្លីឬវែង ក៏ដោយ ។

## ២. អ្នកនិពន្ធ ៖

អ្នកនិពន្ធគឺជាស្មេរដែលប្រើសមត្ថភាពរបស់ខ្លួនផ្ទាល់ មកនិពន្ធអត្ថបទ ដោយមិនចម្លងគំនិតរបស់នរណា ឬចម្លងសំណេរមកពីខាងណាទៀត ។ អ្នកនិពន្ធគឺជាស្មេរ ដែលមានគំនិតពូកែខាងច្នៃប្រឌិត ប៉ិនប្រសប់ក្នុងការជ្រើសរើសពាក្យពេចន៍ យកមកនិពន្ធអោយចេញជាសំណេរប្លែកៗ ផ្សេងៗ ពីគ្នា នៅគ្រប់សំណៅទាំងឡាយ ។ អ្នកនិពន្ធក៏ជាអ្នកស្រាវជ្រាវ ដូចគ្នានឹងប្រភេទអ្នកចងក្រងដែរ ខុសត្រង់ថា គេមិនចម្លងគំនិតទាំងដុល ចម្លងទ្រឹស្តីទាំងដុល អត្ថបទទាំងដុល មកដាក់នៅក្នុងសំណៅដែលគេកំពុងចងក្រងនោះទេ ។ គេគ្រាន់តែស្រាវជ្រាវនូវគំនិតប្លែកៗ របៀបសរសេរប្លែកៗ សិល្បសាស្ត្រប្លែកៗ ដើម្បីបំបែកគំនិតរបស់ខ្លួនឯង អោយសំណេរនិពន្ធន៍របស់ខ្លួន ក្លាយជាអត្ថបទថ្មី ដែលមិនដូចស្នាដៃរបស់ស្មេរដទៃទៀតណាទាំងអស់ ពោលគឺ អ្នកនិពន្ធជាម្ចាស់ដើមកំណើត ដែលច្នៃខ្លឹមអត្ថរសរបស់សំណេរនិមួយៗ របស់ខ្លួនអោយចេញជារូបរាងឡើង ប្លែកៗពីអត្ថបទរបស់អ្នកដទៃទៀតណាទាំងអស់ ។

អ្នកនិពន្ធទាំងឡាយតែងមានគោលបំណងខុសៗគ្នាជានិច្ច នៅក្នុងការប្រឌិតនិពន្ធអត្ថបទឬសំណៅនានា ។ ខ្លះសរសេរដើម្បីគ្រាន់

តែជាការកំសាន្ត ខ្លះសរសេរដើម្បីក្រពះ ខ្លះសរសេរដើម្បីផ្តល់នូវគំនិតនិងការអប់រំដល់នរជននានាក្នុងសង្គម ។ ដោយមូលហេតុនេះយើងអាចបែងចែកសង្គមអ្នកនិពន្ធជាបួនក្រុមផ្សេងៗគ្នាដូចជា ៖

២ក. អ្នកនិពន្ធអាជីព

២ខ. អ្នកនិពន្ធកំសាន្ត

២គ. អ្នកនិពន្ធអភិវឌ្ឍន៍

២ឃ. គន្ថការី

## ២ក. អ្នកនិពន្ធអាជីព ៖

នេះជាប្រភេទអ្នកនិពន្ធមួយប្រភេទ ដែលសរសេរអត្ថបទ ឬសៀវភៅ ដោយមានទទួលប្រាក់កម្រៃជាបៀវត្សរ៍ ជាទុនបំរុង ឬជាប្រាក់ចំណូលពីការលក់សៀវភៅ ។ ក្នុងករណីនេះ អ្នកនិពន្ធតែងសរសេរចងក្រងអ្វីៗ សម្រេចទៅតាមការតម្រូវពីម្ចាស់ទុន ។ ឧទាហរណ៍ បើគេជាគ្រូ គេត្រូវបង្កើតសំណេររបស់គេអោយសមស្របទៅតាមការតម្រូវរបស់ក្រសួងសិក្សាធិការអប់រំ តាមកម្រិតប្រាក់កម្រៃ និងតាមមុខនាទីដែលគេបានទទួល ។ បើគេជាអ្នកសរសេររឿងអោយក្រុមហ៊ុន ឬអោយបុគ្គលណាមួយវិញ គេនឹងត្រូវសរសេរតាមដែលម្ចាស់ទុនទាមទារចង់បាន ។ បើគេសរសេរសំរាប់ការលក់ដូរនៅទីផ្សារ គឺគេសរសេរតាមការទាមទាររបស់អ្នកអាន ដើម្បីឲ្យឆាប់លក់ដាច់ ហើយអាលប្រមូលកម្រៃបានឆាប់រហ័សវិញផង ។ នៅទីនេះ ម្ចាស់សំណេរមិនសូវមានឱកាសនឹងបានបញ្ចេញឆន្ទៈ មនសិការ ឬកិរិតសីលធម៌វប្បធម៌របស់ខ្លួនអោយបានពេញលេញឡើយ ព្រោះសំណៅដែលគេនិពន្ធគឺគ្រាន់តែតម្រូវទៅតាមការបង្គាប់បញ្ជារបស់ម្ចាស់ទុនដែលផ្តល់កម្រៃ អោយជាប្រាក់ខែសម្រាប់លៀងជីវិត តែប៉ុណ្ណោះ ។

អ្នកនិពន្ធប្រភេទនេះច្រើនផ្តោតភ្ជាប់ស្នាដៃរបស់ខ្លួន ថ្លឹងថ្លែងទៅតាមប្រាក់កម្រៃ ដែលគេត្រូវបានទទួលត្រឡប់មកវិញ ភ្លាមៗនៅពេលបច្ចុប្បន្ន ហើយពុំសូវគិតដល់តម្លៃអមតៈរបស់សំណេរខ្លួនគេនៅពេលអនាគត ឆ្ងាយទៅខាងមុខទៀតនោះឡើយ គឺគេគ្រាន់តែធ្វើយ៉ាងណាអោយតែអាច "ស្រង់ដើម " រួចតម្លៃពេលវេលាដែលគេចំណាយទៅ ដើម្បីសរសេរសំណៅទាំងនោះ តាមសេចក្តីតម្រូវមកពីម្ចាស់ទុនដែលទំនុកបំរុងថវិកា ឬអាហារូបករណ៍ដល់រូបគេ ។

នេះជាការខាតបង់មួយយ៉ាងធំរបស់អ្នកនិពន្ធ ដែលមានទេពកោសល្យក្នុងការសរសេរយ៉ាងឆ្នើម ព្រោះថា កាលបើអ្នកនិពន្ធផ្តោតតម្លៃគំនិតនិងទេពកោសល្យរបស់ខ្លួន អោយស្មើត្រឹមកម្រិតប្រាក់កម្រៃ ឬក៏បៀវត្សខ្លាំងពេក គេនឹងបាត់បង់នូវតម្លៃឆន្ទៈ និងខ្លឹមសាររបស់អត្ថបទអក្សរសិល្ប៍របស់គេ ដែលគេគួរណាស់តែបញ្ចេញទឹកដៃសរសេរឲ្យបានល្អប្រសើរបំផុត មានសារប្រយោជន៍បំផុត មានតម្លៃបំផុត លើសអំពីប្រាក់កម្រៃដែលគេបានទទួលនោះមិននឹងប៉ុន្មានលាន ប៉ុន្មានសែនដង ជាពិសេសនៅនាអនាគត ។

ដូច្នេះ ក្នុងនាមជាអ្នកនិពន្ធ យើងមិនគួរផ្តោតភ្ជាប់ទឹកដៃសរសេររបស់យើង ត្រឹមតែចំនួនប្រាក់កម្រៃដែលយើងអាចប្តូរបានភ្លាមៗនៅពេលបច្ចុប្បន្នតែប៉ុណ្ណោះនោះទេ ។ យើងគួរផ្តោតភ្ជាប់ថ្វីដៃរបស់យើងទៅលើតម្លៃអក្សរសិល្ប៍ ដែលនឹងមានអាយុស្ថិតស្ថេរនៅក្នុងសង្គមរបស់យើង ជាយូរអង្វែងតទៅមុខទៀតនាអនាគតជាជាង ព្រោះថា ថ្ងៃណាមួយ យើងនឹងដឹងថា អ្វីដែលយើងបានសរសេរថ្ងៃនេះ ផ្តល់សារប្រយោជន៍ប៉ុនណា មានតម្លៃប៉ុនណា ចំពោះអ្នកអានគ្រប់រូប និងចំពោះសង្គមជាតិរបស់យើង

ទាំងមូល ។ នៅពេលនោះហើយដែលយើងមិនមានការដកដង្ហើមធំហើយហើយពោលពាក្យថា "ស្តាយក្រោយណាស់!" ។

## ២៦. អ្នកនិពន្ធកំសាន្ត ៖

នៅក្នុងជំពូកនេះ អ្នកនិពន្ធច្រើនទាញឱកាសសរសេរបញ្ចេញនូវអារម្មណ៍ គំនិត និង ឆន្ទៈទៅតាមគំនិតរបស់ខ្លួនផ្ទាល់ទៅក្នុងសំណេរនានាទាំងឡាយ ដោយមិនសូវគិតអំពីអារម្មណ៍របស់អ្នកអានប៉ុន្មានឡើយ ។ អ្នកនិពន្ធខ្លះជ្រើសរើសសរសេរអំពី ជីវប្រវត្តិខ្លួនឯង អំពីសាច់រឿងជីវិតពិសេសអ្វីមួយដែលគេបានដើរឆ្លងកាត់មក អំពីការឈឺចាប់ព្រោះស្នេហា ឬ អំពីចំណោទជីវិត ដែលកៀបសង្កត់រូបគេ អោយទ្រាំនៅបៀមទុក្ខក្នុងចិត្ត តែម្នាក់ឯងទៀត មិនបាន ។ អ្នកខ្លះទៀតសរសេររិះគន់អំពីសង្គម នយោបាយ សីលធម៌ សង្គមធម៌ ប្រពៃណី រឿងប្លែកៗផ្សេងៗ ។ល ។ អ្នកនិពន្ធទាំងនេះ ច្រើនប្រើទុនចេញពីហោប៉ៅខ្លួន សំរាប់យកទៅបោះពុម្ពផ្សាយស្នាដៃរបស់ខ្លួន ដោយមិនមានចិត្តនឹកគិតចង់បាននូវកម្រៃចំណូលត្រឡប់មកវិញតាមការលក់សៀវភៅទាំងនោះឡើយ ។ បើសិនណាជាគេបែរជាបានទទួលថវិកាឧបត្ថម្ភខ្លះៗ ពីសំណាក់ញាតិមិត្តដែលជួយលើកទឹកចិត្តអ្នកសរសេរ ក៏អ្នកនិពន្ធបែបនេះមិនសូវជាត្រេកត្រអាលនឹងប្រាក់កម្រៃទាំងនោះប៉ុន្មានដែរ ។ ភាគច្រើន គេនឹងយកថវិកាទាំងនោះត្រឡប់ទៅប្រើវិញ ដើម្បីបោះពុម្ពផ្សាយស្នាដៃរបស់គេ អោយកាន់តែច្រើនថែមទៀតមិនខានឡើយ ។

អ្នកនិពន្ធបែបខាងលើនេះ មានសេរីភាពពេញលេញក្នុងការបញ្ចេញគំនិតនិងអារម្មណ៍របស់គេមកតាមស្ទាបប៉ាកកា ដោយមិនសូវគិតអំពីអារម្មណ៍និងប្រតិកម្មរបស់អ្នកអាន ចំពោះអត្ថបទរបស់គេប៉ុន្មានឡើយ គឺគ្រាន់តែធ្វើយ៉ាងណាអោយខ្លួនគេ អាចបញ្ចេញ

មតិ បញ្ចេញយោបល់ ឬអ្វីៗជាច្រើន ដែលនៅកប់ជាប់ក្នុងបេះដូង អោយអស់កម្រិតដែលគេចង់ទំលាយតែប៉ុណ្ណោះ ។

ដោយមូលហេតុនេះ ស្នាដៃរបស់អ្នកនិពន្ធយើងមានតម្លៃជាទីបំផុតសម្រាប់ខ្លួនអ្នកសរសេរនោះតែម្តង មានន័យថា អត្ថបទដែលគេសរសេរបានទាំងអំបាលម៉ាន សុទ្ធតែជាការសម្រាលទុក្ខដោយការរំលែកយកសោកវិយោគពីក្នុងបេះដូង មកដាក់អោយសៀវភៅកាន់ទុកជំនួសដើមទ្រូងរបស់ខ្លួន ។ ល្អីកណាគេសរសេរចេញមកបានកាន់តែច្រើន ទ្រូងរបស់គេក៏នឹងបានធូរស្រាលទុក្ខសោកមួយកម្រិតទៅតាមនោះដែរ ។ ប៉ុន្តែ បើនិយាយអំពីសារប្រយោជន៍ចំពោះអ្នកអានវិញ ប្រហែលអ្នកអានខ្លះដែលបានឆ្លងកាត់ជីវិតប្រហាក់ប្រហែលគ្នា មានចិត្ត មានអារម្មណ៍ប្រហាក់ប្រហែលគ្នានោះ អាចស្រាលទុក្ខសោកពីការអានសំណេរនោះដែរ ព្រោះគេនឹងគិតថា ហោចណាស់ក្នុងលោកនេះ មិនមែនតែរូបគេម្នាក់ទេដែលពាំបៀមទុក្ខសោកកំហឹងធំធេងយ៉ាងនោះ សូម្បីតែអ្នកនិពន្ធម្នាក់នោះក៏មានទុក្ខសោកគួរសង្វេគ ដូចគ្នាដែរ ។

ចំែដន្យ ការសរសេររបៀបនោះមិនសូវមានអនុភាពខ្លឹមសារទៅលើសង្គមជាតិប៉ុន្មានទេ ត្បិតមនុស្សទាំងឡាយច្រើនមានការឆ្លងកាត់ជីវិតខុសៗគ្នា មានអារម្មណ៍ មានចិត្ត មានឆន្ទៈមិនដូចគ្នា បើអោយគេមកអានតំអូញទំនួញឈឺចាប់ អោយយូរអង្វែងនោះ ពិតជាមិនអាចទៅរួចបានប៉ុន្មានឡើយ ត្បិតការអានសៀវភៅបែបនោះយូរៗទៅ អ្នកអានខ្លះនឹងកើតទុក្ខតាមអ្នកនិពន្ធ ខ្លះបែរជាធុញទ្រាន់ ខ្លះអាចគិតថា អ្នកនិពន្ធរូបនោះគឺជាមនុស្សដែលគិតតែអំពីអារម្មណ៍ស្ងួនតួតែម្យ៉ាង ហើយមិនព្រមអនុញ្ញាត្តិអោយអ្នកអានអាចរំលែកអ្វីល្អៗចេញមកពីសំណេរទាំងនោះ ក្រៅពីអារម្មណ៍ដ៏សែនជូរចត់របស់អ្នកនិពន្ធ តែម្យ៉ាងនោះ ។

មួយវិញទៀត បើអ្នកអានណោះជាគូបដិបក្ខផ្នែកជីវិត ផ្នែក សង្គម ផ្នែកនយោបាយ ផ្នែកឆន្ទៈ គេនឹងយល់ថា ការសរសេរ នោះជាការនិន្ទាដៀមដាម ជាសំណោរឫស្យាបណ្តុះទោសៈ បណ្តុះ សេចក្តីស្អប់ បណ្តុះគំនុំគុំគួនមិនរសាយ ហើយគេនឹងគិតថាអត្ថបទ នោះគ្មានតម្លៃសូម្បីបន្តិចសោះឡើយ ។ ដូច្នេះ អ្នកនិពន្ធយើងនឹង បាត់បង់អ្នកអានមួយចំនួនទៀត ដោយខានមិនបាន ថែមទាំងបាត់ បង់តម្លៃអក្សរសិល្ប៍ និងតម្លៃនៃការខិតខំសរសេរយ៉ាងសស្រាក់ សស្រាំរបស់អ្នកនិពន្ធនោះទៀតផង ។

## ២គ. អ្នកនិពន្ធអភិវឌ្ឍន៍ ៖

អ្នកនិពន្ធអភិវឌ្ឍន៍ចូលចិត្តផ្តោតថ្វីដៃទៅលើអ្វីៗ ដែលអាចបង្ក ប្រយោជន៍ចំពោះអ្នកអាន មិនថាជាសំណោរអប់រំ អត្ថបទសាសនា ចំណេះទូទៅ ឬជាសាច់រឿងនិទាន ដោយមិនគិតចង់ស្វែងរកប្រាក់ ចំណូលពីការនិពន្ធសៀវភៅរបស់គេឡើយ ។ អ្នកនិពន្ធខ្លះចូល ចិត្តស្រាវជ្រាវសរសេរពីអ្វីប្លែកៗ ដែលអាចជួយបណ្តុះគំនិតល្អៗ ដល់អ្នកអាន ជួយបង្កើនការចេះដឹងដល់សង្គមមនុស្ស ថែមទាំង ខិតខំប្រឹងប្រែងដើររកប្រាក់ទុន សំរាប់បោះពុម្ពផ្សាយសំណោរទាំង នោះ អោយក្លាយជាប្រយោជន៍សាធារណៈទៀតផង ។ ចំពោះ សំណៅដែលបោះពុម្ពបានហើយ គេច្រើនយកទៅចែកចាយដល់ អ្នកអានដែលគ្មានសមត្ថភាពទិញសៀវភៅយកមកអាន ។ នៅក្នុង ប្រភេទទី៣នេះ អ្នកនិពន្ធក៏មិនអាចបញ្ចេញនូវអារម្មណ៍ ឆន្ទៈ ឬឧត្តមគតិផ្ទាល់ខ្លួនយ៉ាងសេរី ដូចជាអ្នកនិពន្ធជំពូកទីពីរបានដែរ ព្រោះ គេត្រូវផ្តោតគំនិតទៅលើការសេរសេរ ដែលនាំប្រយោជន៍ វិជ្ជមានដល់មនុស្សតែម្យ៉ាងប៉ុណ្ណោះ មិនអាចសរសេរតាមអារម្មណ៍ របស់ខ្លួនផ្ទាល់បានឡើយ ។ គេត្រូវគិតពីអារម្មណ៍ផ្ទាល់របស់អ្នក

អាន ច្រើនជាជាង ដូចជាការសរសេរសៀវភៅ អំពីវប្បធម៌ សីលធម៌ អប់រំកូនចៅ សៀវភៅរក្សាសុខភាព សៀវភៅធម៌ សៀវភៅ ប្រវត្តិសាស្ត្រ សំណេរសិក្សា សំណេរស្រាវជ្រាវ ។ល ។ ប៉ុន្តែ អ្វីដែលគេអាចបញ្ចេញបាន យ៉ាងសេរីបំផុតនោះ គឺករិត សីលធម៌និងវប្បធម៌របស់គេ ក្នុងការសរសេរផ្តល់គំនិត ផ្តល់មធ្យោបាយ នាំអ្នកអានដើរទៅរកភាពភ្លឺថ្លាប្រពៃក្នុងជីវិត ។ អ្នកនិពន្ធប្រភេទទីបីខាងលើនេះ ច្រើនជាមនុស្សដែលគិតអំពីតម្លៃអក្សរសិល្ប៍ និងសារប្រយោជន៍ដ៏ស្ថិតស្ថេរ របស់សំណេរនិមួយៗ ចំពោះអ្នកអាននិងសង្គមជាតិ មុននឹងគេចាប់និពន្ធ ។ គេចូលចិត្តស្រាវជ្រាវ ចូលចិត្តប្រមូលគំនិត ប្រមូលឯកសារ ប្រមូលមតិប្លែកៗ មកធ្វើជាចន្ទល់ សម្រាប់ជួយទ្រទ្រង់គំនិតក្នុងអត្ថបទ អោយមានខ្លឹមសារចំពោះអ្នកអានគ្រប់វ័យ សំរាប់ជាប្រយោជន៍បច្ចុប្បន្នផង និងជាប្រយោជន៍ទៅអនាគតផង ។ អ្នកនិពន្ធបែបនេះ មិនសូវជាមនុស្សដែលស្វែងរកកម្រៃឬប្រយោជន៍អ្វីតបស្នងត្រឡប់មកពីការសរសេររបស់គេឡើយ ។ អ្វីដែលគេចង់បានបំផុត គឺការដែលគេអាចនាំអ្នកអានអោយបានប្រទះនូវគំនិតស្មារតីភ្លឺស្វាង បានទទួលការចេះដឹងជាងមុន បានទទួលអារម្មណ៍ល្អជាងមុន បានទទួលប្រយោជន៍ពីតម្លៃអត្ថបទដែលគេបានអានរួចហើយនោះ ។ ជាពិសេសទៅទៀត អ្នកនិពន្ធទាំងនោះនឹងមានការរំភើបចិត្តជាទីបំផុត កាលបើគេបានឃើញអ្នកអានអាចទទួលយកខ្លឹមសាររបស់សំណេរ ទៅអនុវត្តន៍ក្នុងជីវិត ស្វែងរកផ្លូវគាប់ប្រសើរ សំរាប់ផ្លាស់ប្តូរកម្រិតជីវភាពរបស់ខ្លួននិងក្រុមគ្រួសារ ផ្លាស់ប្តូរគំនិតមារយាទ ផ្លាស់ប្តូរសតិស្មារតីនិងមនសិការ ផ្លាស់ប្តូរស្ថានភាពនៃការរស់នៅ ពីរណ្តៅកម្ម ឡើងឆ្ពោះទៅរកភាពថ្កុំថ្កើងរុងរឿងក្នុងសង្គមដូចគេដូចឯង ជាដើម ។

អ្នកនិពន្ធប្រភេទនេះ មិនសូវទទួលការប្រឆាំង ឬប្រជែងអំពីសំណាក់អ្នកនិពន្ធដូចគ្នា ឬអំពីសង្គមអ្នកអានឡើយ ត្បិតគេមិនមែនជាអ្នកនិពន្ធដែលសរសេរ ដើម្បីស្វែងរកប្រយោជន៍ខ្លួនឯង ។ ពួកគេច្រើនជាមនុស្សបរិបូណ៌ទៅដោយញាតិមិត្ត គ្រប់ទីកន្លែងដែលគេបានទៅដល់ ហើយស្នាដៃរបស់គេសុទ្ធសឹងមានតម្លៃគង់នៅយូរអង្វែងក្នុងប្រវត្តិអក្សរសិល្ប៍ផងដែរ ។

## ២ឃ. អំពី គន្ថការី ៖

នៅក្នុងច្បាប់ព្រះពុទ្ធសាសនា គន្ថការី គឺជាអ្នកសរសេរគម្ពីរសាសនា ដោយចម្លងយកទ្រឹស្តីព្រះពុទ្ធមកសរសេរសម្រាយជាពាក្យងាយៗសំរាប់បង្រៀនពុទ្ធសាសនិកជននានា អោយឆាប់យល់ឆាប់ចេះចាំ ដើម្បីអនុវត្តន៍ធម៌វិន័យអោយបានប្រពៃ ។

នៅក្នុងប្រភពអក្សរសិល្ប៍ គន្ថការី គឺជាអ្នកចងក្រងសំណេរ ផងជាអ្នកនិពន្ធផង ពោលគឺ គន្ថការី ជាបណ្ឌិតវិទូ ឬ និស្សិតឧត្តមសិក្សា ដែលសរសេរនិពន្ធអត្ថបទស្រាវជ្រាវ សម្រាប់ការសិក្សានានា មិនថាជាអត្ថបទសំរាប់សាលា ឬជាអត្ថបទសម្រាប់សង្គមអ្នកអានទូទៅនោះទេ ។ នៅទីនេះ គន្ថការីជាស្មេរដែលសរសេរតែអ្វីដែលបង្កបង្កើនប្រយោជន៍ ចំពោះអ្នកអានសុទ្ធសាធតែម្យ៉ាងប៉ុណ្ណោះ ថ្វីបើគំនិតនិពន្ធជាគំនិតផ្ទាល់របស់ស្មេរក៏ដោយ ។ ឯការនិពន្ធនោះទៀតសោត ក៏ជាការនិពន្ធដែលបរិបូណ៌ទៅដោយដំណោះស្រាយបញ្ហាប្លែកៗ យោបល់ប្លែកៗ អំពីចំណុចបំភ្លឺប្លែកៗទៅតាមប្រធានបទនានា ដែលគន្ថការីបានខិតខំជ្រើសរើសយកមកសរសេរ ។

សូមបញ្ជាក់ថា អ្នកចងក្រងសំណៅមិនមែនជាគន្ថការីទេ ។ គេគ្រាន់តែជាអ្នកចម្លងគំនិតទ្រឹស្តីរបស់អ្នកនិពន្ធដទៃ ទុកជាឯកសារ

ជាដុំៗ តាមផ្នែក តាមកម្រិត តែម្យ៉ាង មិនមានសរសេរបន្ថែមនូវគំនិតយោបល់របស់ខ្លួន ឬទ្រឹស្តីថ្មី ដែលខ្លួននិពន្ធបានដោយខ្លួនឯងទៅក្នុងសំណៅចងក្រងនោះអ្វីបន្តិចឡើយ ។ ជួនកាលអ្នកចងក្រងមានការងារកាន់មុខនាទីជាបណ្ណារក្ស ជួនជានិស្សិត ឬជាបុគ្គលិកធ្វើការឲ្យសាលា ។ រីឯគន្ថការីវិញ គឺជាបណ្ឌិតវិទូ ឬ និស្សិតឧត្តមសិក្សា ដែលសរសេរសារណា សរសេរអត្ថបទស្រាវជ្រាវ និពន្ធសៀវភៅផ្សេងៗ សំរាប់កម្មវិធីសិក្សាជាតិ ប្រចាំឆ្នាំ ដោយគំនិតនិងចំណេះវិជ្ជារបស់ខ្លួនផ្ទាល់តែម្តង ។ ក្នុងន័យប្រៀបធៀប អ្នកចងក្រង គឺជាអ្នកដើរប្រមូលនំមករៀបទុកដាក់ យ៉ាងមានរបៀបដើម្បីអោយមនុស្សស្រួលជ្រើសរើសផឹ ប៉ុន្តែគន្ថការីគឺជាអ្នកធ្វើនំដោយសមត្ថភាពរបស់ខ្លួនផ្ទាល់ ថ្វីបើគន្ថការីខ្លួនត្រូវលួចក្បួន លួចគំនិតធ្វើនំមកពីអ្នកដទៃបន្ថែមខ្លះទៀត ដើម្បីរចនាការដុតនំរបស់ខ្លួន អោយឆ្ងាញ់ជាងមុន នោះក៏ដោយ ។

គន្ថការី ច្រើនតែជាអ្នកប្រាជ្ញដែលមានការសិក្សាខ្ពង់ខ្ពស់ មានការពិសោធន៍ច្រើន ក្នុងការបង្រៀន ក្នុងការស្រាវជ្រាវ ក្នុងការណែនាំខ្លួនរបស់គេ អោយព្យាយាមសិក្សាទៀងទាត់បន្ថែមទៀតជានិច្ច រៀងរាល់ឆ្នាំ ដើម្បីដើរអោយទាន់ជំរឿននៃឧត្តមវិជ្ជានៅក្នុងក្នុងសកលលោកនាបច្ចុប្បន្ន មានន័យថា គន្ថការីគឺជាអ្នកនិពន្ធដែលមានកម្រិតវិជ្ជា ទេពកោសល្យ និងការចេះដឹងខ្ពស់ជាងគេបង្អស់ នៅក្នុងចំណោមអ្នកនិពន្ធទាំងបួនប្រភេទ ខាងលើ ។

សូមកត់ចំណាំផងដែរថា គន្ថការីជួនកាលអាចជាបុគ្គលិកក្រសួងដែលទទួលបៀវត្ស ជួនកាលជាបុគ្គលិកដែលធ្វើការដោយស្ម័គ្រចិត្ត ដោយឥតកម្រៃ ជួនកាលក៏ជានិស្សិតឧត្តមសិក្សា ដែលធ្វើការស្រាវជ្រាវនិពន្ធ ដើម្បីបំពេញការសិក្សា ឬជួនកាលគ្រាន់តែជាអ្នកនិពន្ធដែលសរសេរអ្វីៗទាំងឡាយ ក្នុងគោលបំណងផ្តល់ជំរៅ

នៃការចេះនឹងដល់សង្គម អោយកាន់តែមានអភិវឌ្ឍន៍ទៅមុខថែមទៀតតែប៉ុណ្ណោះ ។

រួមសេចក្តីមក អ្នកនិពន្ធទាំងឡាយមានសិទ្ធិពេញទីក្នុងការជ្រើសរើសផ្លូវដើរជាអ្នកនិពន្ធ តើផ្លូវណាមួយជាផ្លូវប្រសើរសំរាប់អោយខ្លួនគេមានលទ្ធភាពបញ្ចេញស្នាដៃនិងទេពកោសល្យ យ៉ាងអស់ពីសមត្ថភាព ។ ម្យ៉ាងទៀត អ្នកនិពន្ធក៏មានសេរីភាពពេញទីក្នុងការជ្រើសប្រធានបទ និង ការវិភាគវែកញែកខ្លឹមអត្ថរសរបស់សំណេរដែលខ្លួននិពន្ធនោះផងដែរ ។ ដូច្នេះ តើអ្នកនិពន្ធត្រូវធ្វើយ៉ាងណា ដើម្បីអោយអត្ថបទរបស់ខ្លួន មានប្រជាប្រិយភាពផង មានសារប្រយោជន៍ដល់ខ្លួនជាអ្នកនិពន្ធ ដល់សង្គមជាតិផង ហើយតម្លៃចេរកាលផង នៅក្នុងប្រវត្តិអក្សរសិល្ប៍ខ្មែរ ?

================================

# សំដី ស តម្រា

# ភាសា ស តម្រេះ

អ្នកស្រីកែវច័ន្ទបូរណ៍

========================================

==============================

# ជំពូកទី១០
# អត្ថប្រយោជន៏នៃការប្រើវិញ្ញាណ១០

==============================

## ១. អំពីការប៉ិនប្រសប់របស់អ្នកនិពន្ធ ៖

ពាក្យស្លោកបុរាណមួយបានចែងថា "ទាល់អ្វីទាល់ចុះ សូមតែកុំអោយទាល់គំនិត " មិនខុសអ្វីនឹងសុភាសិតមួយរបស់ព្រះគ្រូសង្ឃរាជជួនណាតដែលមានសេចក្តីស្រដៀងគ្នានោះដែរថា "ទាល់ប្រាំបួន ទាល់ដប់ សុំកុំអោយតែទាល់សតិប្រាជ្ញ " នោះបាន សបង្ហាញអោយឃើញថា បុព្វាចារ្យរបស់យើងមានទឹកចិត្តចង់ណែនាំអោយយើងខំសង្វាត រៀនគិត រៀនប្រើសតិនិងប្រាជ្ញ ដោយឱហាតឧស្សាហ៍ព្យាយាមមិនរួញរា មិនប្រមាថធ្វេសប្រហែស មិនត្អូញត្អែ មើលបំណាំ ។ ឯការដែលយើងចេះសង្កេតច្រើន ចេះគិតពិចារណាច្រើន ចេះអនុវត្តន៏ច្រើននោះហើយ ដែលធ្វើអោយយើងយល់ដឹងកាន់តែច្រើន ហើយការចេះដឹងច្រើននោះហើយដែលបង្ហាញអោយដឹងថា យើងជាមនុស្សមិនមានគំនិតទាល់ច្រកសុញគុញគុះ គិតមិនចេញ ធ្វើមិនចេញ ដោយប្រការណាមួយសោះឡើយ ។

ការបង្ហាញនូវគំនិតទូលាយមិនទាល់ច្រក គឺជាកត្តាប៉ិនប្រសប់របស់អ្នកនិពន្ធដែលមានល្បិចខ្ពស់ក្នុងការប្រើសន្ទេហវិធី បណ្តុះគំនិត និងចម្ងល់ផ្សេងៗអោយអ្នកអានចង់ស្វែងតាមដាន ហើយក៏

អាចរកមធ្យោបាយដោះស្រាយនូវប្រស្នា ឬខ្ទង់ចរឿង ដែលគេប្រឌិត មកនោះ បានយ៉ាងល្អៗ ប្លែកៗ ដែលអ្នកអានអាចត្រេកត្រអាល ដោយសោមនស្សរីករាយជាទីបំផុត ។
ប៉ុន្តែ យើងបានឃើញច្រើនរួចមកហើយ ដែលអ្នកនិពន្ធយើង ខ្លះនៅមានការរារែកក្នុងការនិពន្ធសំណេររបស់ខ្លួន ភាគច្រើនមិន សូវហ៊ានសរសេរបញ្ចប់សេចក្តី ស្រាយរឿងផ្តល់យោបល់ ផ្តល់ អត្តមតិ ផ្តល់គំនិតបំភ្លឺឡើយ ត្បិតអ្នកនិពន្ធទាំងនោះច្រើនមានផ្នត់ គំនិតគិតថា បើសិនគេសរសេរផ្តល់នូវការរារែក មិនបញ្ចប់គំនិត ចំពោះសាច់រឿងដែលគេនិពន្ធនោះ គឺមានន័យថាជាការចងខ្ទង់ គំនិតដ៏ស៊ីជម្រៅរបស់អ្នកនិពន្ធ ។
ឧទាហរណ៍ បើអ្នកមានអានសួរថា តើគំនិតស៊ីជម្រៅរបស់អ្នក និពន្ធ មានអ្វីខ្លះ នៅក្នុងអត្ថបទ ដែលគេបានសរសេររួចមក ហើយ ? តើដំណោះស្រាយរបស់អ្នកនិពន្ធ មានអ្វីខ្លះដែរ ដែល គួរផ្តល់ទៅអ្នកអាន ដើម្បីត្រងទទួលសិក្សា អំពីអត្ថរសនិងអត្ថន័យ របស់គំនិតនិពន្ធ ? នៅពេលនោះ តើអោយអ្នកអានតាមទៅរក អ្នកនិពន្ធនៅឯណា ឲ្យមកបកស្រាយសំនួរទាំងនេះ បើអ្នកនិពន្ធ ខ្លួនឯងមិនសរសេរចម្លើយ ដោះស្រាយរួចអោយហើយ នៅក្នុង សំណៅងដែលនោះ ? នោះមិនខុសឡើយពីការនិពន្ធសំណៅពាក្យ បណ្តៅខ្មែរដែលមានតែសំនួរ តែគ្មានផ្តល់ចម្លើយ ឬក៏ការនិពន្ធ សៀវភៅគណិតវិទ្យា ដែលមានតែចំណោទ មានតែប្រស្នា ប៉ុន្តែ គ្មានរបៀបស្រាយបំភ្លឺ ថាចម្លើយយ៉ាងណានោះឡើយ ។ សូម សួរថា តើសៀវភៅទាំងនោះមានខ្លឹមសារ មានតម្លៃ សម្រាប់ អ្នកអានយកមករៀនសូត្រដែរឬទេ ? ដូច្នេះ បើសិនប្រស្នាទាំង ឡាយគ្មានការស្រាយបំភ្លឺទេ គេអាចចាត់ទុកថាជាប្រស្នាមោឃៈ ។

ឧទាហរណ៍មួយវិញទៀត បើអ្នកនិពន្ធន៍សរសេរអំពីជំងឺនានា ដែលទន្ទ្រានសុខភាពពលរដ្ឋ តែមិនបង្ហាញនូវវិធីថែរក្សាព្យាបាល ឬ វិធីដោះស្រាយការពារជំងឺអ្វីសោះ តើសៀវភៅនិពន្ធនោះ មានតម្លៃសម្រាប់អ្នកអានក្រេបយកប្រយោជន៍បានប៉ុនណាដែរ ? ហើយបើយើងជាអ្នកអានសំណៅ ដែលប្រកបដោយខ្លួចប្រស្នាគ្មានមុខស្រាយ តើយើងមានអារម្មណ៍ មានគំនិត មានចេតនា ចង់អោយអ្នកនិពន្ធធ្វើយ៉ាងណាវិញ នៅវគ្គចុងក្រោយនៃសាច់រឿង ?
ពាក្យចាស់លោកថា " ចេះដប់មិនស្មើប្រសប់មួយ " នោះក៏សបញ្ជាក់អោយយើងដឹងដែរដែរថាអ្នកនិពន្ធ ដែលចេះប្រឌិតកែច្នៃរចនាចងក្រងនិពន្ធសំណេរអោយបានល្អៗមកនោះ មិនមែនត្រឹមតែចេះប្រើអក្សរសាស្ត្រជ្រៅជ្រះ ដើម្បីសរសេរអោយត្រឹមត្រូវតាមក្បួនខ្នាតតែប៉ុណ្ណោះទេ តែគេត្រូវចេះបន្ថែមអត្ថរសចុងប៉ាកកានូវគំនិតជ្រៅជ្រះ នូវប្រាជ្ញស្មារតី នូវមធ្យោបាយល្អប្រសើរនានានាំមុខអ្នកអានអោយឆ្ពោះទៅរកភាពភ្លឺស្វាង បន្ទាប់ពីអ្នកអានបានអានសំណៅរបស់អ្នកនិពន្ធនោះរួចហើយ ។ ដូច្នេះអ្នកនិពន្ធដែលមានកម្រិតទឹកដៃប៉ិនប្រសប់ គឺមិនត្រឹមតែនាំអ្នកអាន អោយរំជើបរំជួលផ្អេកផ្អួលរម្ជួលអារម្មណ៍ ទៅតាមប្រសិទ្ធិភាពនៃទឹកខ្មៅតែប៉ុណ្ណោះទេ គឺថែមទាំងមានអនុភាពយ៉ាងប្រសិទ្ធិ ក្នុងការនាំមនុស្សអោយមានសតិប្រាជ្ញភ្លឺស្វាង ដោយការចេះដឹងល្អជាងមុន ខ្ពស់ជាងមុន ប្រពៃជាងមុន ឧត្តង្គឧត្តមជាងមុន នៅពេលដែលគេបានអានសំណេរនិពន្ធរួចហើយ ។ ពេលនោះ ទើបយើងអាចសន្មតបានថា ស្នាដៃរបស់គេជាស្នាដៃមាស ស្នាដៃពេជ្រពណ្ណរាយ ពិតប្រាកដមែន ត្បិតព្រោះជាស្នាដៃដែលមាននាំមក នូវបញ្ញា នូវគតិនិងមធោបាយភ្លឺស្វាង ដែលមនុស្សទាំងឡាយអាចត្រងយកមករៀនអនុវត្តន៍កើតបានជាប្រយោជន៍ល្អៗ សំរាប់ខ្លួននិងសង្គម ។

ដើម្បីជំរុញអោយការសរសេរកាន់តែមានទឹកដម មានអត្ថរស មានប្រសិទ្ធិភាព មានខ្លឹមសារគាប់ប្រសើរសំរាប់សង្គមអ្នកអាន អ្នកនិពន្ធត្រូវមានចំណេះចេះដឹង ផ្នែកអក្សរសាស្ត្រ អក្សរសិល្ប៍ ចិត្តវិទ្យា វប្បធម៌ សង្គមធម៌ និង ការពិសោធន៍ផ្សេងៗ នៅក្នុងឆាកជីវិតអោយបានច្រើនបំផុត ។ អ្នកនិពន្ធដែលមានការសិក្សាខ្ពស់បន្តិច អាចសរសេរបានប្រសើរបន្តិច ។ បើសិនជាគេមានការពិសោធន៍ថែមបន្តិច សំណេររបស់គេក៏កាន់តែមានអត្ថន័យ ល្អថែមទៀតបន្តិចដែរ ។ នេះមិនមែនមានន័យថា អ្នកដែលមានវិជ្ជាស្តួចស្តើង ឬ មានការពិសោធន៍ស្តួចស្តើង មិនអាចក្លាយជាអ្នកនិពន្ធប្រសើរនោះបានទេ ។ តាមការពិតទៅ អ្នកដែលអាចក្លាយជាអ្នកនិពន្ធប្រសើរបាន គឺជាមនុស្សដែលឧស្សាហ៍ ព្យាយាមសរសេរ មិនថា បុគ្គលនោះមានវ័យប៉ុនណា មានចំណេះប៉ុនណាទេ អោយតែគេឧស្សាហ៍សរសេររាល់ថ្ងៃ ឧស្សាហ៍សង្កេត ឧស្សាហ៍គិត វិភាគ ហើយឧស្សាហ៍ស្តាប់យោបល់ (ទោះបីយោបល់ខ្លះ ហាក់ដូចជាមានភាពអវិជ្ជមានចំពោះរូបគេបន្តិចក៏ដោយ) ហើយឧស្សាហ៍អនុវត្តន៍ គឺសរសេរផង ស្រាវជ្រាវផង ស្រង់មតិផង នោះគេនឹងក្លាយជាអ្នកនិពន្ធមួយយ៉ាងល្បី នៅនាអនាគតជាមិនខាន ។ ឯការហ្វឹកហ្វឺនសរសេររាល់ថ្ងៃ គិតរាល់ថ្ងៃ វិភាគរាល់ថ្ងៃ នឹងជួយអោយគេកាន់តែបែកប្រាជ្ញ បែកគំនិត បែកទេពកោសល្យ ទាំងភាសា ទាំងការចេះដឹង ទាំងការវិភាគអត្ថបទ និងការបណ្តុះមធ្យោបាយដោះស្រាយសំរាប់សំណេររបស់គេ កាន់តែច្រើនឡើងៗ មិនចមចយមួយវេលាណាឡើយ ។ ហើយការដែលគេប្រឹងសរសេរ ដើម្បីបញ្ចេញគំនិតរបស់ខ្លួនមកលើក្រដាស ដោយមិនខ្លាចនរណាសើចយំនោះហើយ ដែលជាកត្តាបង្ហាញនូវជំនឿចិត្ត និងការប្តេជ្ញាចិត្តដ៏មុតមាំរបស់អ្នកនិពន្ធនោះតែម្តង ។

<u>២. ប្រយោជន៍នៃការនិពន្ធដោយប្រើវិញ្ញាណទាំង១០</u> ៖

នៅទីនេះ តើអ្នកនិពន្ធត្រូវការវិញ្ញាណទាំង១០អោយមកជួយទ្រទ្រង់សមត្ថភាពនិងទេពកោសល្យរបស់គេបានដូចម្តេចខ្លះ ក្នុងការសាងស្នាដៃឆ្ពោះទៅរកភាពពណ្ណរាយរុងរឿង ? តើវិញ្ញាណទាំងដប់មានប្រសិទ្ធិភាពប៉ុនណា ចំពោះស្លាបប៉ាកកាអ្នកនិពន្ធ ?

នៅពេលកន្លងមក យើងបានឃើញអ្នកនិពន្ធខ្មែរទាំងឡាយប្រើរូបវិញ្ញាណសរសេរសារស័ព្ទអត្ថបទរបស់គេបានយ៉ាងល្អប្រសើរស្ទើរតែគ្រប់ៗគ្នា ប៉ុន្តែ ស្នាដៃអ្នកនិពន្ធដែលប្រើអរូបវិញ្ញាណទាំងប្រាំនោះ នៅមានកម្រិតស្តួចស្តើងនៅឡើយ ជាពិសេសការសរសេរនិពន្ធ ដោយប្រើវិញ្ញាណទី៩ និងទី១០ ។

<u>២ក. ការប្រើព្រលឹងវិញ្ញាណ</u> ៖

នៅក្នុងប្រភេទនៃការប្រើវិញ្ញាណទី៦ អ្នកនិពន្ធរបស់យើងចូលចិត្តប្រឡូងស្លាបប៉ាកការបស់ខ្លួនជាមួយរឿង ដែលទាក់ទងទៅនឹងព្រលឹងវិញ្ញាណ ដូចជា ការសរសេររឿងខ្មោច រឿងបិសាច រឿងព្រលឹងចាំជាតិ រឿងអាត្ម័ននិងរូបកាយ រឿងប្រលឹងឆ្លងភព រឿងព្រេងប្រឌិត អំពីជំនឿអាគមអូមអាម រឿងអ្នកតា ឬ សរសេរអំពីជំនឿអាបធ្មប់ ធ្វើអំពើ ធ្វើមន្តស្នេហ៍ហូតព្រលឹង ដកវិញ្ញាណប្រផ្នូល ទំនាយយល់សប្តិ ទំនាយគូព្រេង ទំនាយញាក់ភ្នែកកម្រើកសរសៃ ជំនឿស្តោះផ្លុំ ជំនឿរំដោះគ្រោះ ជំនឿរាសីជំនឿពៃរ ជំនាងផ្ទះ ព្រះភូមិ ខ្សែកាថា យ័ន្តការពារ សាក់យ័ន្តដើម្បីអោយស្បែក គង់ ជំនឿកូនក្រក ជំនឿបញ្ចូលរូប បញ្ជាន់អារក្ស និងជំនឿរូបឧបកិច្ចបណ្តេញព្រលឹងឧបទ្រពផ្សេងៗ ។

នៅប៉ុន្មានឆ្នាំកន្លងទៅនេះ ប្រទេសកម្ពុជាយើងសំបូរទៅដោយអ្នកនិពន្ធដែលសរសេររឿងខ្មោចព្រាយអាបខាបព្រលឹងឃាយើជីវិតហើយចតជាខ្សែភាពយន្តបញ្ចាំងពាសពេញប្រទេស តាមរោងភាព

យន្តនានាផង ជាវិដេអូបញ្ចាំងតាមផ្ទះផង តាមទូរទស្សន៍ផង ស្ទើរតែមិនលោះរឿងមួយណាឡើយ ។ ការនិពន្ធបែបនោះជាលំនាំដែលពឹងផ្អែកទៅលើព្រលឹងវិញ្ញាណទាំងស្រុង ដើម្បីបង្កើតស្ថានការណ៍នៅក្នុងសាច់រឿងអោយតក់ស្លុតរន្ធត់ ដោយសារព្រលឹងវិញ្ញាណដែលនៅវិលវល់តាមយាយីជីវិតមនុស្សក្នុងលោក មិនព្រមទៅចាប់ជាតិ ចាប់កំណើត ។

បន្ថែមពីលើនោះ អ្នកនិពន្ធខ្លះទៀត ក៏បានសរសេរសៀវភៅរឿងប្រឌិតអំពីព្រលឹងចាំជាតិ អំពីគ្រូចាប់ខ្មោច អំពីវិធីតម្លើងរាសីអំពីជំនឿអរូបីផ្សេងៗដែលទាក់ទងទៅ នឹងព្រលឹងអាត្មន៍ ។ នោះមិនជាការទាស់ខុសអ្វីទេ ដែលគេចូលចិត្តនិពន្ធសំណេរបែបនោះ ។ ជួនគេគ្រាន់តែសរសេរដើម្បីជូនអ្នកអាន អានកំសាន្ត ។ អ្នកនិពន្ធខ្លះទៀតគ្រាន់តែសរសេរ យោងទៅតាមជំនឿនៅក្នុងស្រុកភូមិ ។ ខ្លះទៀតគ្រាន់តែចង់ចងក្រងសំណៅនៃជំនឿក្នុងសង្គម ដើម្បីទុកជាឯកសារសំរាប់សិក្សា ផ្នែកសង្គមធម៌ វប្បធម៌ និង ប្រពៃណីតែប៉ុណ្ណោះ ។ ប៉ុន្តែទោះជាយ៉ាងណា អ្នកនិពន្ធទាំងឡាយនោះគប្បីសិក្សា អំពីការប្រើសតិនិងប្រាជ្ញាវិញ្ញាណ ដើម្បីញ៉ាំងអោយស្នាដៃនិពន្ធអំពីព្រលឹងចងពៀរ ថមថយនូវភាពយង់ឃ្នងសម្លុតស្មារតីអ្នកអានដោយខ្វះសតិ ហើយអាចជួយអោយស្នាដៃនិពន្ធនោះ នាំអ្នកអានវិលមករកសតិភ្លឺស្វាង មិនវង្វេងទៅក្នុងជំនឿអរូបី ដោយងងឹតងងល់តទៅទៀត ។ ម្យ៉ាងទៀត ការសរសេររឿងអរូបីជំនឿរបស់ខ្មែរយើងកន្លងមក មិនសូវមានគតិអប់រំអ្នកអានប៉ុន្មានឡើយក្រៅពីការនិពន្ធដើម្បីបន្លាចសម្លុតអារម្មណ៍របស់អ្នកអានប៉ុណ្ណោះ ។ ដូច្នេះ នៅសម័យកាលថ្មីនេះ យើងគប្បីមានការបំបែកគំនិតនិងចំណុចសំណេរខ្លះៗអោយប្លែកៗប្រកបដោយការអប់រំ ដើម្បីនាំអ្នកអានបានភ្លឺសតិ ចាកផុតពីការជឿជំនឿអប្រិយដែលនាំអោយអ្នក

ស្រុករស់នៅដោយភ័យខ្លាចមិនស្រាកស្រាន្ត ថែមទាំងត្រូវបង់ទ្រព្យសម្បត្តិ បង់ជីវិត ដោយព្រោះតែជឿលើវិធីរំដោះគ្រោះ មិនប្រពៃទាំងឡាយ ។

<u>២ខ. ការប្រើតុលាវិញ្ញាណ</u> ៖

នៅទីនេះ អ្នកនិពន្ធចូលចិត្តប្រឡែងស្លាបប៉ាកកា ជាមួយការនិពន្ធអ្វីៗដែលទាក់ទងទៅនឹងចលនា សកម្មភាព ល្បឿន ដូចជានិពន្ធរឿងសិល្ប៍ហោះហើរដើរលើអាកាស និពន្ធអំពីឡានប្រណាំង អំពីកប៉ាល់ជ្រមុជទឹក អំពីយានយន្តផ្ទុកមនុស្សសំរាប់ប្រើក្នុងស្នូនកំសាន្ត អំពីរបៀបធ្វើខ្លែងយន្ត អំពីយន្តហោះ យានអវកាស អំពីដំណើរលើស្ថានព្រះច័ន្ទ និង ទំនាញផែនដីជាដើម ។ល ។ អ្នកនិពន្ធដែលចូលចិត្តសរសេរអំពីអ្វី ដែលទាក់ទងទៅនឹងតុលាវិញ្ញាណ ច្រើនជាមនុស្សដែលបរិបូណ៌ ដោយប្រាជ្ញា និងការចេះដឹង ខាងរូបវិទ្យា ខាងបច្ចេកវិជ្ជា និង ខាងគណិតវិទ្យា ។ ដូច្នេះ ដើម្បីនិងអាចក្លាយជា អ្នកនិពន្ធ ឬ ជាអ្នកផលិតបង្កើតគ្រឿងទាំងនេះយ៉ាងប្រសើរបាន លុះណាតែបុគ្គលរូបនោះ អាចពូតតុលាវិញ្ញាណ និង ប្រាជ្ញវិញ្ញាណទាំងពីរ យ៉ាងមានប្រសិទ្ធភាព ដើម្បីធ្វើជាជំនួយ ក្នុងការបណ្តុះបណ្តាលនូវការយល់ដឹងរបស់គេអោយបានបរិបូណ៌ជាទីបំផុត ។ បើសិនជាគេមានត្រឹមតុលាវិញ្ញាណ តែខ្វះប្រាជ្ញាវិញ្ញាណ បុគ្គលនោះមានសមត្ថភាពត្រឹមតែទទួលនឹងនូវអារម្មណ៍ ថាមានលំនឹងនិងមានទំនាញផែនដីតែម្យ៉ាង ប៉ុណ្ណោះមិនអាចឈានទៅមុខបានឆ្ងាយបានប្រសើរ ដូចការដែលគេពូតច្របាច់ការប្រើតុលាវិញ្ញាណនិងប្រាជ្ញវិញ្ញាណ ចូលគ្នានោះឡើយ ។

## <u>២គ. ការប្រើចិត្តវិញ្ញាណ</u> ៖

អ្នកនិពន្ធដែលចូលចិត្តប្រើមនោសញ្ចេតនា តំអូញ សោកសៅ រអ៊ូរទាំ ធុញ ខឹងទោសៈ ស្រឡាញ់ ស្អប់ មួម៉ៅ កណ្តោចកណ្តែង រំភើបស្រើបស្រាល ក្តុកក្តួល ភ័យរន្ធត់ លោភលន់ មានមហិច្ឆតា លោភលន់ ចង់បាន មិនចេះអស់មិនចេះហើយ មានការចចេស មានះ មានភាពឆ្មើងកន្ទ្រើង មានភាពនិន្ទាប្រទុស្តឬស្យាក្នុងចិត្ត មានការច្រណែន ប្រច័ណ្ឌ មើលបំណាំ ចងគំនុំ មានកលល្បិច មានការសងសឹក មានការប្រកួតប្រជែងយកឈ្នះយកចាញ់ មានការត្រេកត្រអាល ការដៀមដាមចាក់ដោតអុជអាល មានការបញ្ឆោះបន្សែក ឬការបញ្ឈឺ មានការចូលចិត្ត មានការនឹករលឹក ទិប្បដិសារី សោកស្តាយ មានក្តីអាលោះអាល័យ មានអំនួតជោរពោរពេញខ្លួន មានភាពក្អេងក្អងពើងទ្រូង... ទាំងនេះ សុទ្ធសឹងតែជាអ្នកនិពន្ធដែលមានចំណងចងភ្ជាប់អារម្មណ៍របស់ខ្លួនយ៉ាងមុតមាំ ជាមួយការប្រើចិត្តវិញ្ញាណ ក្នុងការសរសេរអត្ថបទ ឬសំណេរផ្សេងៗ ។ អ្នកនិពន្ធបែបនោះ ចូលចិត្តប្រឹងផ្តោតអារម្មណ៍របស់ខ្លួនយ៉ាងជ្រៅ ទៅក្នុងអនុភាពនៃចិត្តវិញ្ញាណ ហើយច្រើនតែភ្លេចសតិ ភ្លេចស្មារតី ទៅតាមសាច់រឿងដែលខ្លួននិពន្ធនោះរួចក៏ចេះតែបណ្តែតបណ្តោយអោយអារម្មណ៍នោះ ដឹកស្លាបប៉ាកកាទៅកាន់ទីស្ថាន ដែលខ្វះសតិ កាន់តែឆ្ងាយទៅៗ រកទីបញ្ចប់គ្មាន ។ ពេលនោះហើយ ដែលអ្នកនិពន្ធបែរមកជួបប្រទះនឹងការស្រកស្រុតទឹកដមស្នាដៃ ដោយការភ្លេចប្រើសតិប្រាជ្ញ សំរាប់គ្រប់គ្រងអារម្មណ៍ នៅក្នុងសាច់រឿងសំណេរ អោយវិលត្រឡប់បែរមករកភាពភ្លឺស្វាងវិញ ។

អ្នកនិពន្ធដែលចូលចិត្តបណ្តោយខ្លួន ទៅតាមមន្តអំណាចនៃចិត្តវិញ្ញាណ ច្រើនជាអ្នកនិពន្ធអត្ថបទមនោសញ្ចេតនា អត្ថបទដែលមានវិបត្តិជីវិតធ្ងន់ធ្ងរ ដូចជាការសរសេរអំពីសឹកង្រ្គាម ឃាដកម្ម ទារុណកម្ម ការកៀបសង្កត់ដោយសារវណ្ណៈយសសក្តិ ការកៀប

សង្កត់ផ្លូវចិត្តដោយសារប្រពៃណី ដោយការបំពារបំពានរំលោភសិទ្ធិគ្នា ដោយការរំលោភលើរូបកាយ ហើយដែលមានតួអង្គប្រកួតប្រជែងគ្នា ដោយល្បិចកលរាប់មិនអស់ ដើម្បីសងសឹកយកចាញ់យកឈ្នះ យកស្លាប់យករស់ យ៉ាងទារុណខ្លោចផ្សា រៀងៗខ្លួនរហូតដល់ទីបញ្ចប់ ដោយមិនគិតពីមនុស្សធម៌ សីលធម៌ ឬបាបបុណ្យអ្វីឡើយ ។

ម្យ៉ាងវិញទៀត អ្នកនិពន្ធដែលដណ្តប់ដោយចិត្តវិញ្ញាណ ច្រើនចូលចិត្តសរសេរអត្ថបទដៀមដាម បញ្ឆេះបន្សោក បញ្ឆឺ ពន្យុះ អុជអាល ឬបង្កទំនោរចិត្ត យ៉ាងពុះកញ្ជ្រោល អោយក្រុមមួយស្អប់ក្រុមមួយទៀត អោយក្រុមមួយស្រឡាញ់ក្រុមមួយទៀត តាមតែទំនោរចិត្តរបស់អ្នកនិពន្ធ ។ បើអ្នកនិពន្ធនោះមានទំនោរអារម្មណ៍ទេរទៅខាងណា គេនឹងនាំចុងស្លាបប៉ាកការបស់គេអោយបែរទៅរកទិសនោះដែរ ។ បន្ថែមពីលើ សង្គមខ្មែរយើងមានទម្លាប់មួយបាក់ផ្ចត់តាំងពីបុរាណមក គឺការសម្តែងគំនិតចង់ប្រដៅគេ ដោយពាក្យសំដីដៀមដាមបញ្ឆិតបញ្ឆៀង ព្រោះគិតថា ការនិយាយត្រង់ៗជួនកាលអាចនាំអោយគេទទួលគ្រោះថ្នាក់ដល់ខ្លួនវិញ ជាពិសេសបើសិនអ្នកដែលគេចង់ប្រដៅនោះ ជាមនុស្សដែលមានអំណាចធំជាងខ្លួន ម្ល៉ោះហើយក៏សរសេរបញ្ឆិតបញ្ឆៀងឌីដង ជាជំនួសវិញ ដើម្បីរំសាយកំហឹងពុះពោរកញ្ជ្រោល ដែលមាននៅក្នុងចិត្ត ។ មួយវិញទៀត សីលធម៌ខ្មែរក្រោយៗមក ច្រើនតែយកកម្លាំងបាយ ជាដំណោះស្រាយកំហឹងក្នុងចិត្ត ជាជាងការដោះស្រាយដោយស្មារតីសតិបញ្ញា ត្បិតគិតថាកម្លាំងបាយអាចដោះស្រាយអោយឃើញផលទាន់ចិត្ត ដោយមិនបាច់រង់ចាំយូរ ។ ចៃដន្យ អ្នកនិពន្ធដែលចូលចិត្តដោះស្រាយរបៀបនេះ មិនបាននាំផលប្រយោជន៍ធុំថ្កើងអ្វី ដល់សង្គមជាតិវិញឡើយ រួមទាំងអ្នកនិពន្ធផង ព្រោះអ្នកនិពន្ធប្រភេទ

នោះច្រើនរស់រងអារម្មណ៍វេទនា ដោយកំហឹងពុះពោរ ដោយការខកចិត្ត ដោយក្តីចំបែង ដោយក្តីសោកសៅវិបរិត សោកស្តាយ ឈឺចិត្ត ធុញថប់ តឹងដើមទ្រូង រកសេចក្តីសុខស្ងប់ក្សេមក្សាន្ត សន្តិនៅក្នុងចិត្ត មិនឃើញឡើយ ។

ដូច្នេះ តើអ្នកនិពន្ធត្រូវធ្វើដូចម្តេចដើម្បីអោយសំណេររបស់ខ្លួន មានតម្លៃជាតុល្យភាព មិនលង់ មិនវង្វេង ទៅក្នុងអនុភាពរបស់ចិត្តវិញ្ញាណ ជ្រុលហួសហេតុពេក ? គឺនៅពេលនោះហើយដែលអ្នកនិពន្ធត្រូវការវិញ្ញាណពីរទៀតដែលសំខាន់ជាងគេបំផុត ដើម្បីមកជួយទ្រទ្រង់សមត្ថភាពនិងទេពកោសល្យរបស់អ្នកនិពន្ធ អោយកាន់តែមានដំណើរជាកណ្តាលហើយមានប្រសិទ្ធិភាព មានតម្លៃខ្ពង់ខ្ពស់មកវិញ ។

## ២ឃ. ការប្រើសតិវិញ្ញាណ និង ប្រាជ្ញាវិញ្ញាណ ៖

នៅផ្នែកនេះ អ្នកនិពន្ធជាបុគ្គលពូកែមុតមាំក្នុងការប្រើសតិ វិញ្ញាណ ដើម្បីវិភាគពិចារណា រកហេតុផល ល្អអាក្រក់ វែកញែក មិនមែនដើម្បីរកផ្លូវឈ្នះទេ តែរកផ្លូវល្អ មិនមែនរកផ្លូវផ្ទាញ់ផ្ទាល ពេលឃើញគេប្រព្រឹត្តខុសនោះទេ តែរកវិធីអប់រំដោយសន្តិវិធី ដើម្បីអោយមនុស្ស មានកម្លាំងចិត្ត ចង់កែប្រែខ្លួន មកល្អវិញ ។ អ្នកនិពន្ធ ដែលអាចរក្សាការសរសេរដែលពោរពេញទៅដោយសតិស្មារតីខ្ពស់នឹងន ច្រើនជាមនុស្សដែលមានទឹកចិត្តស្ងប់ មិនពុះកញ្ជ្រោល មិនលង់វង្វេងផ្តេកផ្តួលរមួលអារម្មណ៍ ដូចបុគ្គលដែលដណ្តប់ដោយអនុភាពនៃចិត្តវិញ្ញាណ យ៉ាងពេញទីនោះឡើយ ។

ឯការនិពន្ធដែលល្អ ដែលមានទឹកដម ដែលមានខ្លឹមសារ គឺមិនមែនត្រឹមតែជាសំណេរ ដែលបង្កប់នូវអារម្មណ៍ពុះកញ្ជ្រោល របស់អ្នកនិពន្ធតែម្យ៉ាងនោះទេ តែគឺជាសំណេរដែលពោរពេញទៅដោយ

សិល្បវិធីសក្តិសិទ្ធិក្នុងការបង្ក្រាបភាពពុះកញ្ជ្រោលនោះ កុំអោយរាលដាលអនុភាព រហូតលែងនឹងខុសត្រូវល្អអាក្រក់ តទៅទៀត ។ ដូច្នេះ អ្នកនិពន្ធដែលប្រកបដោយសតិស្មារតីឧត្តុង្គឧត្តម គឺជាអ្នកនិពន្ធដែលសរសេរសំណេរទាំងឡាយ ដែលបណ្តុះនូវសតិស្មារតីភ្ញាក់រលឹក មានសម្បជញ្ញៈ មនសិការ មានពិចារណា មានការអប់រំវិន័យខ្ជាប់ខ្ជួន មានការរក្សាចិត្តមារយាទសម្តីក្នុងតម្រា មិនខ្ជីខ្ជា មិនប្រមាថឡេះឡោះ មិនរាយមាយ មិនឆ្មើងកន្ទ្រើង មិនដើរក្នុងផ្លូវអពមុខ មិនកំណាញ់ មិនព្យាបាទ មិនយាយី មិនបង្កអសន្តិសុខ និងភាពសៅហ្មងដល់បុគ្គលណាសង្គមណា មិនអុជអាលបង្កទោសៈ មោហៈ និងកំហឹងគុំគួនប្រទុស្តរាយឡើយ ។ អ្នកនិពន្ធទាំងឡាយនោះ ច្រើនជាអ្នកដែលមានសិល្បវិធីប្លែកៗសំខាន់ៗ ដើម្បីរំងាប់ឬបង្ក្រាបទោសៈ មោហៈទាំងឡាយនោះ អោយសាបសូន្យទៅវិញ ដោយមូលហេតុនៃសីលធម៌ គុណធម៌ សប្បុរសធម៌ ការមានចិត្តមេត្តាករុណា មានសេចក្តីអត់អោនអធ្យាស្រ័យ ចូលចិត្តអភ័យទោស ហើយផ្តល់ឱកាសដល់ញាតិទាំងឡាយ ដែលធ្លាប់បង្កទោសកំហុស ដើម្បីប្រឹងខិតខំរៀនសូត្រ កែខ្លួន បែរមករកផ្លូវប្រពៃវិញ ។

ថែងន្យការសរសេរនិពន្ធដែលប្រើតែសតិស្មារតីតែម្យ៉ាង មិនគ្រប់គ្រាន់ទេ ។ ដូច្នេះ យើងត្រូវការកម្លាំងប្រាជ្ញាមកជួយបន្ថែមក្នុងការស្វែងរកឱបាយល្អៗផ្សេង សំរាប់ណែនាំមនុស្សអោយវិលមកកាន់សភាពដែលមានសតិស្មារតីរុងរឿង ហើយបរិបូណ៌ទៅដោយវិជ្ជា បញ្ញា និងទេពកោសល្យថែមទៀតផង ។ អ្នកនិពន្ធម្នាក់ៗត្រូវការការប៉ិនប្រសប់ទាំងពីរយ៉ាង គឺខាងសតិផង ខាងប្រាជ្ញផង មិនអាចមានមួយណា បាត់មួយណាបានឡើយ ។ ប្រាជ្ញា និងសតិស្មារតីត្រូវតែដើរទន្ទឹមគ្នាជាគូជានិច្ច ឧទាហរណ៍ ដូច ជា បើសិនមានអ្នកឆ្លាតមួយរូបដែលមានប្រាជ្ញា អាចផលិតគ្រឿងផ្ទុះ

ដោយខ្លួនឯងបាន ប៉ុន្តែ បើគេជាមនុស្សដែលមិនមានសតិ ចេះគិតខុសត្រូវល្អអាក្រក់ គេអាចយកគ្រឿងផ្ទុះនោះ ទៅបង្កចលាចលបង្កគ្រោះថ្នាក់ដល់សង្គមបាន ។ ប៉ុន្តែ បើជននោះមានប្រាជ្ញាដូច្នោះហើយ ហើយក៏មានសតិបរិបូណ៌ នោះគេច្បាស់ជាមិនយកគ្រឿងផ្ទុះទាំងឡាយនោះ ទៅបង្កសេចក្តីភ័យខ្លាច ដល់សង្គមឡើយ ។ ផ្ទុយទៅវិញ គេនឹងយកគ្រឿងផ្ទុះនោះ ទៅប្រើជាប្រយោជន៍ដល់សង្គមវិញ ដូចជាការដាក់គ្រឿងផ្ទុះ ដើម្បីបំបែកថ្មភ្នំ ធ្វើផ្លូវថ្នល់សំរាប់ការប្រើប្រាស់ក្នុងសង្គមជាដើម ឬ បង្កើតគ្រឿងផ្ទុះសំរាប់រំលំផ្តួលសំណង់អាគារចាស់ៗប្រើលែងបាន រួចរំលាយយកស៊ីម៉ង់ចាស់មកលាយជាមួយជាតិគីមីថ្មី ដើម្បីប្រើក្នុងការសាងសង់អាគារថ្មីមួយទៀត ដែលល្អស្អាតជាងមុន ជាដើម ។ល ។

ដូច្នេះ ការប្រើសតិវិញ្ញាណនិងប្រាជ្ញវិញ្ញាណពូតច្របាច់ចូលគ្នាយ៉ាងពេញអនុភាព អាចជួយអោយអ្នកនិពន្ធមានសតិនឹងន មានប្រាជ្ញភ្លឺស្វាងហើយឆ្លៀវឆ្លាត ក្នុងការស្វែងរកដំណោះស្រាយនានាចំពោះបញ្ហាទាំងឡាយ ដែលអ្នកនិពន្ធបានគួចចង នៅក្នុងសាច់រឿង ។ បើសិនជាតួអង្គជាមនុស្សខ្វះមារយាទ ខ្វះសីលធម៌ ខ្វះវិន័យ ខ្វះទេពកោសល្យ តើអ្នកនិពន្ធត្រូវប្រើសតិប្រាជ្ញដោះស្រាយយ៉ាងណា ដើម្បីផ្លាស់ប្តូរតួអង្គយើងអោយមានវិន័យ មានមារយាទមានសីលធម៌ ស្គាល់ផ្លូវល្អ និងការរីកចំរើនសុខសប្បាយមកវិញ ? ពេលនេះ អ្នកនិពន្ធត្រូវប្រើប្រាជ្ញ បណ្តុះគំនិត ស្មារតី ច្បាប់វិន័យសីលធម៌ មនុស្សធម៌ គុណធម៌ ក្នុងការជួយរកមធ្យោបាយដោះស្រាយវិបត្តិជីវិតជូនតួអង្គក្នុងរឿង ដោយប្រកាន់យកភាពយុត្តិធម៌និងសិល្បវិធីអប់រំអហឹង្សា ប្លែកៗ ជាគោលឱបាយ ។ កាលបើអ្នកអានបានទទួលនូវចំណោះល្អៗ គំនិតល្អៗ វិធីល្អៗ ប្រកបដោយសតិប្រាជ្ញា គេទាំងអស់ក៏នឹងក្លាយជាមនុស្សភ្លឺស្វាងមានសមត្ថភាព

មានតម្រេះប្រពៃដែលអាចបំរើសេចក្តីត្រូវការរបស់ខ្លួន ឬ សេចក្តីត្រូវការរបស់សង្គមជាតិ ដើម្បីធ្វើដំណើរ ឆ្ពោះទៅរកភាពរីកចំរើនមានសណ្តាប់ធ្នាប់ មានវឌ្ឍនភាព សន្តិភាព និង អធិតេយ្យភាពយ៉ាងប្រសើរខ្ពង់ខ្ពស់ ដោយស្វ័យប្រវត្តិដែរ ។

========================================

**ចន្ទប៉ាកកាមានសិល្បៈអច្ឆរិយៈ អាចជួយ**

**ជប់មនុស្សអោយក្លាយជាពលរដ្ឋយ៉ាងប្រសើរ**

**បើសិនអ្នកកាន់ប៉ាកកាជាមនុស្សមានសតិប្រាជ្ញា**

អ្នកស្រីកែវច័ន្ទបូរណ៍

========================================

=====================================

# ជំពូកទី១១
# អក្សរសិល្ប៍ និង
# មោទនភាពរបស់អ្នកនិពន្ធ

=====================================

១. អ្វីទៅដែលហៅថាអក្សរសិល្ប៍ ? ៖

និយមន័យ ៖

អក្សរ + សិល្ប៍

អក្សរ = សំណេរអត្ថបទ

សិល្ប៍ = សិល្ប: វិធីសាស្ត្រ រចនាបថ

អក្សរសិល្ប៍មានន័យថា ជាសំណេរអត្ថបទ ដែលប្រកបដោយសិល្បវិធីប្លែកៗនានា ដែលមានអនុភាពដណ្តប់អារម្មណ៍ ដណ្តប់គំនិត ដណ្តប់ស្មារតី ដណ្តប់ជីវិតរបស់អ្នកអាន អោយមានដំណើរលង់វិញ្ញាណ ទៅតាមស្នាដៃរបស់អ្នកនិពន្ធ ដោយខានមិនបានឡើយ ។

សូមបញ្ជាក់ថា អក្សរសិល្ប៍មិនមែនជាអក្សរសាស្ត្រទេ ថ្វីបើអក្សរសិល្ប៍ត្រូវការប្រើភាសាអក្សរសាស្ត្រ អោយជួយពន្យល់នូវអត្ថន័យអត្ថរសរបស់សំណេរនិមួយៗក៏ដោយ ។ អក្សរសាស្ត្រគឺជាការសិក្សាអំពីដើមកំណើតនៃភាសា ការសិក្សាអំពីអក្ខរាវិរុទ្ធ អំពីវេយ្យាករណ៍ អំពីសិល្ប៍សាស្ត្រនៃការសរសេរអោយត្រឹមត្រូវតាមតម្រាក្បួនខ្នាតអក្សរសាស្ត្រ ។ ប៉ុន្តែ អក្សរសិល្ប៍គឺជាសិល្ប:នៃការសរសេរ បង្ហាញនូវគំនិតប្រាជ្ញស្មារតី និងទេពកោសល្យប្លែកៗរបស់អ្នកនិពន្ធនិមួយៗ ក្នុងការដឹកនាំមនុស្សអោយទៅកាន់ភពមួយទៀតដែលមានអារម្មណ៍ មានវិញ្ញាណ មានសតិប្រាជ្ញា មានការ

គិតជ្រាលជ្រៅភ្ជាប់ទៅនឹងជីវិតរស់នៅ ឬក្តីស្រមៃរបស់មនុស្ស ។ ក្នុងន័យប្រៀបធៀប អក្សរសាស្ត្រគឺជាដើមឫស្សី តែអក្សរសិល្ប៍គឺជាការរចនាដើមឫស្សីអោយក្លាយប្រយោជន៍សម្រាប់មនុស្ស ដូចជាការយកឫស្សីមកធ្វើបំពង់ទឹកត្នោត មកដុតក្រឡាន មកធ្វើចង្កើស ធ្វើវែក ធ្វើគ្រែគេង ធ្វើផ្ទះនៅ ធ្វើរបង និងអ្វីទៀតជាច្រើន សំរាប់បម្រើសេចក្តីត្រូវការរបស់មនុស្ស ។ ដូចគ្នានេះដែរ អក្សរសិល្ប៍គឺជាការប្រើអក្សរសាស្ត្រ ដើម្បីរចនាគំនិត ស្មារតី ប្រាជ្ញា របស់មនុស្សអោយបង្កបង្កើតជាប្រយោជន៍ផ្សេងៗសំរាប់សង្គមជាតិ ដូចជាការយកអក្សរសាស្ត្រ មកនិពន្ធសៀវភៅកំណាព្យ រឿងព្រេង ប្រលោមលោក ទស្សនាវត្តី វិធីព្យាបាលជម្ងឺ វិធីអប់រំគ្រួសារ វិធីរំលត់ហឹង្សា ពាក្យបណ្តៅ អំពីប្រពៃណីនិងវប្បធម៌ជាតិ ។ល ។

អក្សរសិល្ប៍ដែលមានប្រសិទ្ធិភាព ហើយមានតម្លៃជាអតិបរមា នោះគឺការនិពន្ធដែលធ្វើអោយអ្នកអានពេញចិត្ត អានហើយអាន ទៀត មិនត្រឹមតែប៉ុណ្ណោះអ្នកអានក៏មានអំណរសោមនស្ស មាន មោទនភាព មានចំណាប់អារម្មណ៍ មានចំណង់ចំណូលចិត្ត ទប់មិនបាន រហូតដល់ទៅបបួលមិត្តភក្តិញាតិសន្តានដទៃៗទៀត អោយមកអានជាបន្តៗដូចខ្លួនដែរ ព្រោះគេយល់ថាអត្ថបទនោះអាចជួយជួយបង្កសតិប្រាជ្ញា បណ្តុះការចេះដឹង បណ្តុះក្តីសង្ឃឹម ក្តីស្រមៃល្អៗ និងវិធីសាស្ត្រផ្សេងៗ ដែលអាចជួយប្រែ ជីវភាពមនុស្ស អារម្មណ៍មនុស្ស ចិត្តមនុស្ស សតិមនុស្ស និងការចេះដឹងរបស់មនុស្ស អោយបានភ្លឺស្វាង មានសេចក្តីសុខបរិបូណ៌ មានភាពក្សេមក្សាន្ត ជាងពេលណាទាំងអស់ ។ ពោលគឺ បន្ទាប់ពីគេបានអានសៀវភៅអក្សរសិល្ប៍មួយក្បាលចប់ អ្នកអាននឹងបានទទួលនូវការចេះដឹងជាងមុន ឆ្លាតវៀងវៃជាងមុន មានដួងចិត្តត្រជាក់រមនាជាងមុន សតិប្រាជ្ញាជាងមុន មិនកម្លៅ មិនកំរោល

មិនចចេស មានះ មិនហឹង្សា តទៅទៀតឡើយ ។ បន្ថែមពីលើនោះទៅទៀត អ្នកអានក៏បែរជាក្លាយជាមនុស្សដែលមានស្មារតីខ្ពស់ចេះស្គាល់ទុក្ខធុរៈ មានអធ្យាស្រ័យ ប្រាសចាកនូវភាពគុំគួនប្រទុស្ត និងចាកភាពកំណាញ់ទ្រឹស្នូរ មើលបំណាំ ចំពោះញាតិមិត្តផងទាំងពួង ថែមទៀតផង ។

ដូច្នេះ អក្សរសិល្ប៍ដ៏ល្អៗ តែងតែនាំអ្នកអាន បណ្តុះប្រាជ្ញ និងគំនិតកាន់តែភ្លឺស្វាង ក្នុងការដោះស្រាយជីវភាពរបស់គេ ទៅតាមគន្លងផ្លូវសុចរិត ផ្លូវសីលធម៌ ផ្លូវសន្តិភាព ថ្លៃថ្នូរ ហើយមានការចេះដឹងច្រើនបែបច្រើនបទផ្សេងៗទៀត ដែលអាចជួយអ្នកអានបណ្តុះបណ្តាលខ្លួនជាមនុស្ស ដែលនាំសារប្រយោជន៍ល្អៗ ដល់ក្រុមគ្រួសារ ដល់ញាតិមិត្ត និងដល់សង្គមជាតិទាំងមូល ។

ដូច្នេះ មិនថាជាការនិពន្ធកំណាព្យ មិនថាជាការនិពន្ធប្រលោមលោក ឬជាការនិពន្ធអត្ថបទសិក្សាអ្វីនោះទេ អោយតែអ្នកនិពន្ធអាចប្រកាន់ខ្ជាប់នូវសតិប្រាជ្ញថ្លៃថ្នូរឧត្តមបានជានិច្ចនោះ អនុភាពនៃស្លាបប៉ាកការបស់យើង នឹងក្លាយទៅជាទេពមន្តយ៉ាងប្រសិទ្ធដណ្តប់ជីវិតមនុស្ស អោយរស់នៅក្នុងលោក ដោយប្រពៃថ្កុំថ្កើងរុងរឿង បរិបូណ៌ទៅដោយសន្តិភាព និងសុភមង្គលពិតប្រាកដ ។

<u>២. មោទនភាពរបស់អ្នកនិពន្ធ</u> ៖

ក្នុងនាមជាអ្នកនិពន្ធដែលត្រួតត្រាចុងស្លាបប៉ាកការបស់ខ្លួនឯង យើងមានអំណាច មានសិទ្ធិពេញទី ក្នុងការជ្រើសរើសពាក្យពេចន៍នានា មកសរសេរបង្ហាញគំនិត អារម្មណ៍ និងឆន្ទៈរបស់អ្នកនិពន្ធ មិនថា ការបញ្ចេញថ្វីដៃនោះជាការសរសេរត្រឹមវិញ្ញាណប្រាំ ឬកវិតវិញ្ញាណ លើសពីនោះទៀតក៏ដោយ ។ ប៉ុន្តែ អ្វីដែលអ្នកនិពន្ធគប្បីចងចាំហើយត្រូវគិតអោយច្បាស់លាស់នោះ គឺការរក្សាមោទនភាពរបស់ខ្លួនជាអ្នកសរសេរ ថាតើ យើងចង់រក្សាមោទនភាពរបស់

យើងអោយនៅកម្រិតណាមួយ ក្នុងសង្គម ។ មានន័យថាយើងត្រូវតែគិតទុកក្នុងចិត្តជានិច្ច ថាការសរសេរនិពន្ធរបស់យើងនោះគួរនាំមោទនភាពអ្វីខ្លះ ចំពោះយើងជាអ្នកនិពន្ធវិញ បន្ទាប់ពីសំណេរនោះ បានបោះពុម្ពចេញផ្សាយរួចហើយ ។ តើតម្លៃទឹកខ្មៅចុងប៉ាកការបស់យើង នាំមោទនភាពមកដល់យើងវិញ ត្រឹមតែប្រាក់កម្រៃប្រចាំខែ ដើម្បីក្រពះតែប៉ុណ្ណោះទេ ឬក៏សំណេរនិពន្ធនោះគួរនាំមោទនភាព ខ្ពស់ជាងនោះ រាប់រយដង ? ហើយបើសិនយើងគិតថា យើងចង់អោយសំណេររបស់យើងមានតម្លៃខ្ពស់ចេរកាលក្នុងសង្គមខ្មែររៀងរហូតទៅវិញ តើយើងជាអ្នកនិពន្ធគប្បីប្រើទេពកោសល្យ សិល្បវិធីអ្វីខ្លះ ដែលញ៉ាំងអោយអ្នកអាន ស្រឡាញ់គោរពហើយរក្សាស្នាដៃនោះអោយមានអាយុស្ថិតស្ថេរយូរអង្វែង ? នៅក្នុងសង្គមខ្មែរកន្លងមក យើងឃើញមានអ្នកនិពន្ធជាច្រើនខំព្យាយាមចាយពេលសរសេរ ចាយថវិកាបោះពុម្ព ចាយការប្រឹងប្រែង ដើម្បីផ្សព្វផ្សាយស្នាដៃរបស់ខ្លួន អោយបានសុះសាយគ្រប់ទីកន្លែង ។ ចៃដន្យ អ្នកនិពន្ធភាគច្រើនមិនសូវបានគិតដល់ព្រលឹងអមតៈនៃសំណេររបស់ខ្លួនឡើយ ។ ភាគច្រើន អ្នកនិពន្ធទាំងឡាយនោះច្រើនវាស់តម្លៃសំណេររបស់គេ ទៅនឹងទឹកប្រាក់ចំណូលដែលគេត្រូវរកបានភ្លាមៗ ដើម្បីជាថ្នូរត្រឡប់មកវិញ មិនថាគេត្រូវសរសេរ អសីលធម៌បន្តិច យង់ឃ្នងបន្តិច សាហាវបន្តិច ឬអយុត្តិធម៌បន្តិច ក៏ដោយ ។ ដោយមូលហេតុនោះហើយ ទើបយើងឃើញសំណេរទាំងឡាយរបស់អ្នកនិពន្ធបែបនោះ មិនសូវមានគេលើកតម្កើងនៅក្នុងវិស័យអក្សរសិល្ប៍ឡើយ ហើយសំណេរនិពន្ធបែបនោះក៏មិនសូវមានអាយុយូរអង្វែង នៅក្នុងសង្គមយូរលង់ដែរពោលគឺ សំណេរនឹងសាបរលាបទៅវិញយ៉ាងឆាប់ៗ តាមកាលវេលាត្បិតថា បើស្លាបប៉ាកការបស់យើង ឃ្លាតចាកសតិប្រាជ្ញ សីលធម៌

និង ភាពថ្លៃថ្នូរ ប្រាសចាកប្រយោជន៍សង្គមធម៌ហើយ ស្នាដៃរបស់យើង នឹងក្លាយជាមានតម្លៃសូន្យអាសារចំពោះសង្គមជាតិ ព្រោះស្នាដៃនោះ មិនត្រឹមតែឆ្លុះបញ្ចាំងនូវកិរិតវប្បធម៌ សីលធម៌ដ៏ទាបរបស់អ្នកនិពន្ធតែម្យ៉ាងប៉ុណ្ណោះទេ ប៉ុន្តែសំណៅទាំងនោះក៏អាចបង្វែរនាំជីវិតរបស់អ្នកអាន អោយឃ្លាតចាកភាពត្រឹមត្រូវប្រពៃក្នុងជីវិតរបស់គេទៅវិញថែមទៀតផង ។ នោះជាការបាត់បង់នូវមោទនភាពដ៏ធំមួយរបស់អ្នកនិពន្ធតែម្តង ។

អាស្រ័យដោយហេតុនេះហើយ អ្នកនិពន្ធមិនត្រឹមតែត្រូវរក្សាមោទនភាពរបស់ខ្លួន ជាអ្នកនិពន្ធយ៉ាងល្បីល្បាញ នៅក្នុងពេលបច្ចុប្បន្នតែម្យ៉ាង ប៉ុននោះទេ គឺយើងគប្បីសរសេរនូវអ្វីៗដែលអាចរក្សាមោទនភាពនិងកិត្តិយសរបស់ខ្លួនយើង ដែលជាអ្នកនិពន្ធដ៏ប្រសិទ្ធិម្នាក់ សំរាប់ពេលដែលយើងចូលនិវិត្តន៍ទៅវិញនោះផងព្រោះថា ក្រោយពេលដែលយើងបានចូលនិវត្តន៍ទៅ យើងនឹងមានឱកាសបែរក្រោយសម្លឹងស្នាដៃរបស់យើងទាំងឡាយ កន្លងមក សាជាថ្មីម្តងទៀត ហើយយើងក៏មានចិត្តរំភើប សោមនស្ស ត្រេកអរមានមោទនភាពខ្ពស់ចំពោះខ្លួនឯងជាលើកទីពីរ ដែលបានកសាងសន្សំស្នាដៃនិពន្ធ ទុកចែកសង្គមជាតិជាប្រយោជន៍សាធារណ៍យ៉ាងឧត្តុង្គឧត្តម ។ ព្រមជាមួយគ្នានោះដែរ ចិត្តយើងក៏បានទទួលនូវសេចក្តីស្ងប់ សុខមង្គល យ៉ាងភ្លឺថ្លា ជ្រះស្រលះអំពីវិប្បដិសារីទាំងឡាយ ជាពិសេសគឺបានចៀសផុតនូវការទទួលពាក្យរិះគន់ពីសង្គមជាតិមកវិញថា ស្នាដៃដែលយើងបានខិតខំសរសេរ តាំងពីយូរមកហើយនោះ មិនមែនជាធូលីដ៏សែនមន្ទិល ដែលផ្តល់នូវភាពល្អក់កករដល់ជីវិតអ្នកអាននិងសង្គមជាតិ នោះឡើយ ។

ចំពោះគោលគំនិតខាងលើ បុគ្គលដែលមានមោទនភាពបំផុត នោះគឺអ្នកដែលបានសរសេរអត្ថបទនិពន្ធដែលប្រកបដោយសតិ និងប្រាជ្ញ

ប្រកបដោយសិល្បវិធីណែនាំអ្នកអានអោយក្នុងផ្លូវប្រពៃ ក្នុងអារម្មណ៍ដែលស្ងប់ ក្នុងសតិនឹងន ហើយពោរពេញទៅដោយមនសិការនិងសម្បជញ្ញៈ ព្រមទាំងមានប្រាជ្ញភ្លឺស្វាងក្នុងការណែនាំខ្លួនអោយដើរឆ្ពោះទៅរកភាពរុងរឿងកេរ្យមក្សាន្តត្រកាលត្រកុំរមនាក្នុងជីវិត ។

========================================

# សតិជាតម្រា

# ប្រាជ្ញាជាមាគ៌ា

អ្នកស្រី កែវ ចន្ទ័បូរណ៍

========================================

==========================================

# ជំពូកទី១២
# ការផ្សព្វផ្សាយស្នាដៃ
# របស់អ្នកនិពន្ធ

==========================================

កាលបើយើងមានទេពកោសល្យប្រសើរ ក្នុងការសរសេរនិពន្ធរួចហើយ តើយើងត្រូវការពឹងផ្អែកអ្វីខ្លះទៀតជាជំហរ ក្នុងការជួយផ្សព្វផ្សាយស្នាដៃរបស់យើងទៅក្នុងសង្គមជាតិ ដើម្បីពង្រីកការទទួលស្គាល់ពីរង្វង់អ្នកអានចំពោះអត្ថបទអក្សរសិល្ប៍របស់យើង ? នៅចំណុចនេះ អ្នកនិពន្ធត្រូវការជំនួយបន្ថែមជាច្រើនយ៉ាងដើម្បីជាសសរបង្អែកនិងជាផ្លូវនាំសំណេររបស់អ្នកនិពន្ធឆ្ពោះទៅរកប្រជាប្រិយភាព និងការទទួលស្គាល់ពីសង្គមអ្នកអានយ៉ាងធំធេង ដូចជា ការស្រង់មតិយោបល់របស់អ្នកអាន ជំនួយកម្លាំងចិត្តរបស់អ្នកនិពន្ធ ការគាំទ្រអំពីសំណាក់សមាគមអ្នកនិពន្ធនានាក្នុងសង្គម ការប្រមូលផ្តុំគណកម្មការពិនិត្យ ជំនួយថវិកាសំរាប់ឧបត្ថម្ភនិងទ្រទ្រង់ការបោះពុម្ពផ្សព្វផ្សាយ និងឱកាសសំរាប់ផ្សព្វផ្សាយ ជាដើម ។

១. <u>បង្អែកកម្លាំងចិត្តរបស់អ្នកនិពន្ធ</u> ៖

តាមធម្មតា នៅក្នុងពេលអនុវត្តន៍កិច្ចការអ្វីមួយ បុគ្គលទូទៅតែងតែប្រាថ្នាការលើកកម្លាំងចិត្តពីសំណាក់មនុស្សជុំវិញខ្លួន គ្រប់ៗគ្នា ដូចជាការលើកកម្លាំងចិត្តអំពីសមាជិកក្រុមគ្រួសារ អំពីមិត្តភក្តិ អំពីគ្រូអាចារ្យ អំពីចាស់ទុំដែលគេគោរពរាប់អាន អំពីព្រះសង្ឃជាដើម ។ល ។ កម្លាំងចិត្តជាកត្តាចំបង ដែលជួយជំរុញអោយអ្នកនិពន្ធកាន់តែមានទឹកចិត្តឱហាត ធ្វើការជាងមុន ស្វះស្វែងព្យាយាមជាងមុន

ហើយខំប្រឹងប្រែងដោយមិនខ្លាចហត់នឿយសោះឡើយ ។ អ្នកនិពន្ធខ្លះត្រូវការជំនួយផ្នែកកម្លាំងចិត្ត ច្រើនជាងអ្នកនិពន្ធដទៃខ្លះទៀត មុននឹងគេអាចបោះជំហានចាប់ផ្តើមធ្វើកិច្ចការរបស់គេ ។ ប៉ុន្តែចំពោះអ្នកនិពន្ធដែលមានការប្តេជ្ញារឹងមាំ និងមានជំនឿទៅលើសមត្ថភាពរបស់ខ្លួនយ៉ាងជាក់លាក់ប្រាកដ គេអាចបំពេញការងាររបស់គេជាអ្នកនិពន្ធបានយ៉ាងឯករាជ្យ ដោយមិនទាមទារការលើកកម្លាំងចិត្ត ពីសំណាក់សាច់ញាតិ មិត្តភក្តិ ឬគ្រូបាអាចារ្យប៉ុន្មានទេ គឺគេអាចចាប់ផ្តើមធ្វើការយ៉ាងហ្មត់ចត់ ហើយមុតមាំបំផុតតែម្នាក់ឯង រហូតដល់កិច្ចការរួចរាល់ ។ ថ្វីបើយ៉ាងនោះក្តី ក៏អ្នកនិពន្ធទាំងឡាយនោះនៅរំពឹងរង់ចាំជានិច្ច នូវការលើកកម្លាំងចិត្តពីសង្គមអ្នកអានទូទៅ នៅពេលសៀវភៅគេបានបោះពុម្ពចេញផ្សាយ ទៅគ្រប់មជ្ឈដ្ឋាន ។ ដូច្នេះ មិនថាអ្នកនិពន្ធជានរណាទេ ការលើកកម្លាំងចិត្តពីសំណាក់ញាតិមិត្ត គ្រូអាចារ្យ និងមិត្តអ្នកអាន ជាគ្រឹះមាំបំផុតក្នុងការជួយអោយអ្នកនិពន្ធមានទឹកចិត្ត បន្តការឧស្សាហ៍ និងបង្កើនស្នាដៃរបស់ខ្លួនអោយកាន់តែប្រសើរហើយអោយកាន់តែច្រើន តាមដែលគេអាចធ្វើបាន ។ បើមិនដូច្នោះទេ ទោះបីស្នេរជាបុគ្គលដែលមានទឹកដៃសរសេរល្អបែបណា ក៏ល្បឿននៃការនិពន្ធ ចំនួននៃអត្ថបទនិពន្ធ និងទឹកដមនៃការនិពន្ធ អាចស្រកស្រុតយ៉ាងងាយទៅវិញ កាលបើគ្មានកំស្ទួលកម្លាំងចិត្តមុតមាំទ្រទ្រង់ទេនោះ ។ កត្តាខាងលើនោះបានបង្ហាញអោយយើងឃើញថា អ្នកនិពន្ធទាំងឡាយយល់ ហើយស្គាល់នូវអារម្មណ៍ទាំងនោះ គ្រប់ៗគ្នា ដូច្នេះក្នុងនាមជាអ្នកនិពន្ធដូចគ្នា យើងគប្បីជួយលើកកម្លាំងចិត្តគ្នាទៅវិញទៅមក ដើម្បីជួយគ្នាបណ្តុះបណ្តាលស្នាដៃនិមួយៗ អោយកាន់តែប្រសើរឡើងៗ ។ យើងមិនគួរប្រកាន់ទដ្ឋិ ជាអ្នកប្រជែងជាមួយអ្នកនិពន្ធដូចគ្នាឡើយ ព្រោះថា បើសិនយើងជាអ្នកនិពន្ធដែល

បរិបូណ៌ទៅដោយទេពកោសល្យនិងការប៉ិនប្រសប់ ក្នុងការសរសេរ អត្ថបទប្លែកៗរួចទៅហើយ រឿងអីដែលយើងទៅខ្លាចនឹងបង្ហាញ ជំនឿមុតមាំទៅលើស្នាដៃរបស់យើង ? រីឯការដែលយើងអាច សរសេរបានប្លែក បានល្អ រួចមកហើយ ហេតុអ្វីយើងបែរទៅជា នឹកចង់ប្រជែងនឹងអ្នកនិពន្ធដទៃទៀត ឲ្យស្រកស្រុតតម្លៃមិត្តភាព ល្អៗរបស់យើងនោះធ្វើអ្វី ? ម្យ៉ាងទៀត កាលបើយើងនៅប្រកាន់ ថា រូបយើងជាបេក្ខជនប្រណាំងប្រជែងនៅឡើយ នោះសបញ្ជាក់ អោយឃើញថា រូបយើងនៅខ្វះជំនឿមុតមាំទៅលើស្នាដៃរបស់ខ្លួន ឯងថាជាសំណេរប្រសើរ នោះតែម្តង ។

(សូមបញ្ជាក់ថា ការប្រណាំងប្រជែងនេះ មិនមែនជាការ ប្រជែងយកពានរង្វាន់មេដាយមាសនោះទេ តែជាការប្រជែងបញ្ឈឺ បញ្ឆោះបនៀក ដោយសំដី ឬ ឥរិយាបថ ចំពោះអ្នកនិពន្ធដូចគ្នា ដើម្បីបង្អាក់ទឹកចិត្តគូប្រជែង)

រួមសេចក្តីមក អ្នកនិពន្ធនិមួយៗភាគច្រើន តែងតែផ្តល់កម្លាំង ចិត្តចំពោះគ្នា ទៅវិញទៅមកយ៉ាងបរិបូណ៌ ដូចជាមានការបង្កើត សមាគមអ្នកនិពន្ធផ្សេងៗ ដើម្បីឆក់ឱកាសជួបជុំគ្នា សំរាប់ពិគ្រោះ ពិភាក្សា និងជួយរកមធ្យោបាយបណ្តុះបណ្តាលសមត្ថភាពនិងទេព កោសល្យរបស់អ្នកនិពន្ធនិមួយៗ អោយឈានទៅរកភាពត្រសាយ ត្រសុំថ្កុំថ្កើងក្នុងសង្គមអក្សរសិល្ប៍ខ្មែរ ។

<u>២. គណៈកម្មការពិនិត្យ</u> ៖

អ្នកនិពន្ធរូបណាក៏ដូចរូបណាដែរ តែងតែត្រូវការជំនួយដើម្បី មកជួយពិនិត្យអត្ថបទដែលខ្លួននិពន្ធរួចមកហើយ ដូចជាការជួយ ពិនិត្យកែសម្រួលផ្នែកអក្ខរាវិរុទ្ធ វេយ្យាករណ៍ ជួយពិនិត្យការ សរសេររៀបឃ្លោងឃ្លាមិនអោយស្មុគស្មាញអត្ថន័យ មិនអោយវង្វេង សាច់រឿង ពិនិត្យពិភាក្សាអំពីគំនិតស្មារតី និងគតិណែនាំរបស់

សំណេរជាដើម នៅមុនពេលអ្នកនិពន្ធយកសំណៅមួយនោះ ទៅបោះពុម្ពផ្សាយ ជាសាធារណៈ ។

នៅក្នុងប្រទេសខ្មែរ អ្នកនិពន្ធដែលជាសមាជិករបស់សមាគមអ្នកនិពន្ធមួយ អាចមានលទ្ធភាពពឹងពាក់ក្រុមអ្នកនិពន្ធនោះ អោយជួយពិនិត្យកែកុននិងអោយយោបល់ ចំពោះសំណេររបស់ខ្លួនដែលទើបសរសេរបានហើយ ។ ជួនកាលទៀត គេអាចប្រមូលមិត្តភក្តិជាទីទុកចិត្តអោយមកជួបជុំដើម្បីជួយត្រួតពិនិត្យនិងជួយសម្រួល ។ អ្នកនិពន្ធខ្លះទៀត ក៏ព្រងើយកន្តើយមិនរវល់នឹងស្វែងរកជំនួយមកជួយកែកុនថ្វីដៃរបស់ខ្លួនឡើយ ។ ប៉ុន្តែទោះបីជាអ្នកនិពន្ធទាំងនោះមានជំនឿមុតមាំទៅលើចំណេះចេះដឹងនិងថ្វីដៃរបស់ខ្លួនយ៉ាងណាក្តី ក៏គេមិនគួរចៀសវាងក្រុមពិនិត្យដែរ ព្រោះថា ការពិនិត្យនោះមានសារប្រយោជន៍សំខាន់ណាស់ ក្នុងការជួយអោយយើងមានលទ្ធភាពបានកែកុនឃ្លោងឃ្លានិងអក្ខរាវិរុទ្ធ ហើយសម្រួលសាច់រឿងនិពន្ធរបស់យើងអោយបានប្រសើរជាងមុន មុននឹងយើងយកសំណៅនោះចេញទៅបោះពុម្ព ។

ចំណែកឯ ចំពោះអ្នកនិពន្ធដែលរស់នៅប្រទេសក្រៅ ដូចជានាងខ្ញុំដែលជាអ្នកនិពន្ធសៀវភៅមួយនេះជាដើម មានការលំបាកក្នុងការស្វែងរកគ្នីគ្នា មកជួយពិនិត្យសម្រួលអត្ថបទនិពន្ធណាស់ ដោយប្រការទីកន្លែងរស់នៅ ឆ្ងាយៗពីគ្នារាប់រយរាប់ពាន់គីឡូម៉ែត្រ មិនអាចធ្វើដំណើរទៅជួបគ្នាបាន ដូចដែលយើងត្រូវការនោះឡើយ ។ ថ្វីបើកិច្ចការខ្លះអាចជួយបានតាមអ៊ីមែលក៏ដោយ ក៏យើងនៅមានការពិបាកក្នុងការជួយកែសម្រួល ព្រោះគណកម្មការខ្លះមិនចេះប្រើកំព្យូទ័រ ម្ល៉ោះហើយ ស្នាដៃនិពន្ធកន្លងមកទាំងឡាយរមែងមានលាយឡំនូវកំហុសអក្ខរាវិរុទ្ធខ្លះៗ ចៀសវាងមិនបាន ។ ប៉ុន្តែថ្វីបើយើងប្រទះនូវការខ្វះខាតយ៉ាងនេះក៏ដោយ ក៏យើងមិនគួរ

លះបង់ការសរសេររបស់យើងចោលដែរ ។ អ្នកនិពន្ធនៅបរទេសជាច្រើន នៅបន្តការសរសេរនិពន្ធរបស់ខ្លួន ដោយមិនព្រងើយកន្តើយ ព្រោះមានចិត្តសង្ឃឹមថា មិត្តអ្នកអានទាំងឡាយនឹងបានក្រេបជញ្ជក់នូវអត្ថរសនិងខ្លឹមសាររបស់ស្នាដៃប្លែកៗ នៃអ្នកនិពន្ធនិមួយៗ ដោយទឹកចិត្តសោមនស្សរីករាយដែល មិនស្រេកស្រុតឡើយ ។

<u>៣. សម្រង់មតិ</u> ៖

<u>៣ក. សម្រង់មតិមុនពេលចាប់សរសេរ</u> ៖

ជាទូទៅ មុននឹងអ្នកនិពន្ធចាប់ផ្តើមសរសេរអំពីអត្ថបទអ្វីមួយ គេច្រើនធ្វើការស្រង់មតិដោយសួរយោបល់អំពីអ្នកអាននានា ថាតើសង្គមអ្នកអាន ចូលចិត្តអានអ្វីជាងគេ ? តើសង្គមអ្នកអាន នៅខ្វះសៀវភៅបែបណាទៀតសំរាប់អាន ? តើអត្ថបទអ្វីទៅ ដែលមានសារប្រយោជន៍ដល់អ្នកអាន ? តើការសរសេរសំណេរប្រឌិត និងសរសេរមិនប្រឌិត អាចផ្តល់ផលអ្វីខ្លះដែលអ្នកអានអាចក្រេបជញ្ជក់យកបានពីសំណេរនោះ...ជាដើម ។ល ។ នៅពេលនោះ អ្នកនិពន្ធបែរមកមើលទេពកោសល្យរបស់ខ្លួនវិញម្តង ថាតើខ្លួនមានជំនាញសរសេរខាងផ្នែកណាមួយដែរ ? តើគេមានសមត្ថភាពគ្រប់គ្រាន់នឹងចាប់ផ្តើមកិច្ចការនោះបានហើយឬនៅ ? បើសិនជានៅទេ តើអ្នកនិពន្ធយើងត្រូវដុសខាត់សំលៀងទេពកោសល្យរបស់ខ្លួន បែបណាទៀត ដើម្បីនឹងអាចផលិតសៀវភៅមួយបាន យ៉ាងពេញលក្ខណៈ ? នៅពេលនោះឯងហើយ ដែលអ្នកនិពន្ធត្រូវបន្តការស្រាវជ្រាវសិក្សាហ្វឹកហ្វឺនបន្ថែមទៀត ដើម្បីផ្តោតទឹកខ្មៅចុងស្លាបប៉ាកកាអោយកាន់តែមានន័យមានខ្លឹមសារថែមទៀត ។

នៅក្នុងប្រទេសខ្មែរ គេអាចធ្វើការស្រង់មតិដោយការសាកសួរសង្គមអ្នកអានទូទៅ ឬដោយការសង្កេតផ្ទាល់របស់អ្នកនិពន្ធអស់រយៈពេលជាយូរកន្លងមកហើយ ។ នៅបរទេស ដូចជានៅសហរដ្ឋ

អាមេរិកជាដើម គេច្រើនធ្វើការស្រង់មតិ តាមប្រព័ន្ធឥន្ទ្រីណិត ឬតាមសំបុត្រប្រៃសណីយ៍ ។ ជួនកាលទៀត គេធ្វើការស្រង់មតិនៅតាមបណ្ណាគារឯកជននានា តាមបណ្ណាល័យជាតិ ឬតាមបណ្ណាល័យរបស់សាលាដោយការសាកសួរសិស្សផ្ទាល់ៗតែម្តង ។

ប៉ុន្តែ មិនថា គេប្រើមធ្យោបាយណាទេ សម្រាប់ស្រង់មតិ អ្នកនិពន្ធនិមួយៗ គប្បីរៀនសង្កេតនូវចំណុចខ្វះខាតក្នុងសង្គម ហើយនាំគ្នាសរសេរបំពេញសេចក្តីត្រូវការនោះវិញ នោះទើបសំណេរទាំងនោះមានប្រជាប្រិយភាព ត្បិតអ្វីដែលខ្វះ តែងនាំអោយមនុស្សស្រេកឃ្លានប្រាថ្នាចង់បាន ដូច្នោះហើយ បើសិនជាយើងអាចផលិតនូវអ្វីដែលគេចង់បាននោះអោយបានឆាប់រហ័សទាន់ចិត្ត ហើយមានអត្ថរសប្រសើរ នោះស្នាដៃរបស់យើង នឹងបានទៅដល់គោលដៅជោគជ័យ យ៉ាងឆាប់ៗដូចគ្នាដែរ ។

<u>៣ខ. សម្រង់មតិបន្ទាប់ពីសៀវភៅបោះពុម្ពផ្សាយ</u> ៖

ការស្រង់គំនិតនិងមតិមានប្រយោជន៍សំខាន់ណាស់ សំរាប់អ្នកនិពន្ធគ្រប់រូប ដើម្បីជួយកែលំអស្នាដៃថ្មីៗទៀត ឲ្យកាន់តែប្រសើរឡើង ។ អ្នកនិពន្ធដែលពូកែស្តាប់មតិយោបល់ ស្តាប់គំនិតប្លែកៗរបស់អ្នកដទៃ ស្តាប់ការពន្យល់នូវវិធីកែឆ្នៃអោយសំណេរមានទឹកដមនិងប្រសិទ្ធិភាព ស្តាប់នូវមធ្យោបាយផ្សេងៗទៀតដែលអ្នកអានមានសំណូមពរ អ្នកនិពន្ធនោះតែងតែកើនប្រាជ្ញាបណ្តុះគំនិតបន្ថែមទៀតទៅលើសំណេរថ្មីៗរបស់ខ្លួន យោងទៅតាមគំនិតយោបល់ទាំងឡាយនោះ ។ កន្លងមក យើងសង្កេតឃើញអ្នកនិពន្ធខ្លះមានការអត់ធ្មត់នឹងស្តាប់ការសរសើរលើកទឹកចិត្ត មតិរិះគន់ និងសំណូមពរ ពីអ្នកអាន ។ ប៉ុន្តែ ខ្លះទៀតមិនសូវរវីរវល់នឹងស្តាប់យោបល់អ្នកអានទេ ហើយក៏ច្រើនឆ្លើយតបតទៅអ្នកអានវិញ ដោយកិរិយាឬកពារើសអើងឆ្មើងឆ្មៃ ។ នោះជាទង្វើមួយដែលអាចធ្វើអោយអ្នក

និពន្ធស្រេកស្រុតប្រិយភាពនៅក្នុងសង្គមអ្នកអាន ស្រេកស្រុតគំនិត និងវិធីប្លែកៗជាច្រើន ដែលគេអាចទទួលបានពីប្រភពក្រៅៗ ។ អ្នកនិពន្ធរបៀបនេះមិនសូវមានការរីកចំរើនខាងគំនិត សតិស្មារតី និងប្រាជ្ញា ដូចជាបុគ្គលខ្លះដែលពូកែស្តាប់មតិអ្នកអាននោះឡើយ ។ ដូច្នេះ អ្នកនិពន្ធគ្រប់គ្នាគប្បីបើកចិត្ត បើកគំនិតអោយទូលាយ រួចហើយរៀនស្តាប់យោបល់ ស្តាប់ការរិះគន់ និងសំណូមពរដើម្បីការរីកចំរើន ។ នៅពេលដែលអ្នកនិពន្ធឈានដល់ដំណាក់ដែលខ្លួនអាចស្តាប់មតិយោបល់ទាំងវិជ្ជមាន និងអវិជ្ជមាន ដោយមិនមានកើតក្តីទើសទាល់ក្នុងចិត្តបានហើយ ពេលនោះអ្នកនិពន្ធបានក្លាយជាបុគ្គលដែលដណ្តប់ទៅដោយសតិវិញ្ញាណពិតប្រាកដ ។ កាលបើមានសតិល្អគ្រប់គ្រងហើយ ប្រាជ្ញាវិញ្ញាណក៏ឈានចូលមកគ្រប់គ្រងអោយអ្នកនិពន្ធបណ្តុះបណ្តាលគំនិតថ្មី សិល្បវិធីថ្មី និង ទេពកោសល្យថ្មីឲ្យកាន់តែរីកចំរើនប្រសើរឡើងថែមទៀត ដោយស្វ័យប្រវត្តិ ។

<u>៨. ថវិកាសំរាប់ឧបត្ថម្ភការបោះពុម្ពផ្សាយ</u> ៖

កាលបើយើងបានផ្សំផ្គុំពូតសំណេរ បានចប់ជាស្ថាពរហើយនោះ យើងតែងតែត្រូវការថវិកាសំរាប់បោះពុម្ព ដើម្បីផ្សាយបញ្ចេញទៅសាធារណៈ ។ ចំពោះអ្នកនិពន្ធខ្លះដែលមានសមត្ថភាពផ្គត់ផ្គង់ការបោះពុម្ពនោះបានដោយខ្លួនឯង នោះសំណេរនឹងបានផ្សព្វផ្សាយយ៉ាងឆាប់រហ័សទាន់ចិត្តរបស់អ្នកនិពន្ធ ។ ចំពោះអ្នកនិពន្ធខ្លះទៀត ជាពិសេស អ្នកនិពន្ធពន្លកថ្មីដែលទើបចុះប្រឡូកក្នុងការសាងស្នាដៃក្នុងទីផ្សារជាលើកដំបូង រមែងមានការខ្វះខាតទុនបំរុងជានិច្ច ។ ជួនកាលអ្នកនិពន្ធទាំងនោះ រំពឹងផ្អែកទៅលើការប្រកួតប្រជែងយករង្វាន់ជាប្រាក់ សំរាប់យកមកជួយឧបត្ថម្ភការបោះពុម្ពសៀវភៅរបស់ខ្លួន ។ ខ្លះទៀតព្យាយាមទាក់ទងស្វែងរកសប្បុរសជនទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ដើម្បីបង្ហាញនូវស្នាដៃរបស់ខ្លួន

ហើយអំពាវនាវរកអំណោយទុន មកផ្គត់ផ្គង់ការផ្សព្វផ្សាយសំណេរទាំងនោះ ។

សំណាងល្អ សមាគមសម្ព័ន្ធអក្សរសិល្ប៍នួហាច ដែលមានទីតាំងការិយាល័យនៅទីក្រុងភ្នំពេញ បានផ្តល់នូវឱកាសប្រសើរនេះទៅដល់ស្មេរគ្រប់រូប អោយមកប្រកួតប្រជែង បង្ហាញស្នាដៃនិពន្ធន៍របស់ខ្លួន មួយឆ្នាំម្តងៗ ដើម្បីឲ្យគណកម្មការជ្រើសរើសសំណៅបីដែលល្អជាងគេ យកទៅបោះពុម្ពផ្សព្វផ្សាយជាសាធារណ៍ទូទាំងប្រទេស ។ បើសិនអ្នកនិពន្ធទាំងឡាយត្រូវការពត៌មានច្បាស់លាស់ សូមទាក់ទងទៅលោក ខូ តារាឫទ្ធិ តាមរយៈអាសយដ្ឋាន ៖

==============================

ការិយាល័យពុទ្ធសាសនបណ្ឌិត្យ

១២៣០១ វិថីសម្តេចសុធារស ក្រុងភ្នំពេញ

ទូរស័ព្ទ ០២៣-៣៥៥-៤៨៤

០៩៩-២៦៣-៧៦៣

០១១-៩៥៥-៥៩៩

ចំពោះអ្នកនិពន្ធដែលចេះប្រើអ៊ីមែល អាចមានឱកាសបោះពុម្ពផ្សាយស្នាដៃរបស់ខ្លួនតាមឥន្ទ្រីណិត តាមរយៈវិបសៃពីរខាងក្រោមនេះ បើសិនជាសំណេរនោះជាអត្ថបទជាតិនិយម ពោរពេញដោយគំនិតប្រាជ្ញ ផ្តល់សារប្រយោជន៍ដល់អ្នកអានទាំងឡាយ ៖

============================

http://www.chanbokeo.com

សូមទាក់ទង អ្នកស្រីកែវច័ន្ទបូរណ៍

chanbo@camboda.com

==============================

http://www.smaradeykhmer.org

សូមទាក់ទង លោក ឆភ ហង្សផលា

contact: nphalla@hotmail.com

============================

## ៥. សរុបសេចក្តី ៖

រួមសេចក្តីមក អ្នកនិពន្ធមិនមែនត្រឹមជាអ្នកសរសេរអត្ថបទ បោះពុម្ពអោយគេអានកំសាន្តអារម្មណ៍តែម្យ៉ាងទេ ។ តាមការពិត អ្នកនិពន្ធគឺជាអ្នកកាន់ចង្កូតឡាន បរនាំផ្លូវអ្នកអានឆ្ពោះទៅរកទីដៅមួយអោយបានជោគជ័យ ។ បើសិនអ្នកកាន់ចង្កូតមានសតិភ្លឺស្វាងមើលឃើញផ្លូវច្បាស់ ស្គាល់ផ្លូវដែលត្រូវធ្វើដំណើរច្បាស់ គេក៏អាននាំអ្នកជិះអោយបានទៅដល់គោលដៅដោយរីករាយ ហើយមានសុវត្ថិភាពទៀតផង ។ ប៉ុន្តែបើអ្នកកាន់ចង្កូតមានសតិប្រាជ្ញាស្មារតីយ៉ាងងងិតអ្សួរអាប់នោះ គេអាចបើកបរចរនាំអ្នកអាន ទាំងងងិតឈឹង មិនស្គាល់ផ្លូវ ឬមើលផ្លូវមិនឃើញ ធ្វើអោយរថយន្តរេចង្កូតខុសផ្លូវ ធ្លាក់ទឹកធ្លាក់ភក់ តាមដំណើរកាច់ចង្កូតរបស់គេ ។ រីឯអ្នកជិះវិញក៏បានទទួលនូវអារម្មណ៍ល្អក់កករហ្មួហ្មង ដោយសារអ្នកបើកបរធ្វើដំណើរវង្វេង មិនព្រមស្វាងយ៉ាងនោះដែរ ។ ដូច្នេះហើយដើម្បីនឹងក្លាយខ្លួនជាអ្នកបើកបរដ៏ប្រពៃ តើអ្នកនិពន្ធគួរត្រៀមខ្លួនយ៉ាងណា ក្នុងការបណ្តុះជំនាញរបស់ខ្លួនឲ្យបានភ្លឺស្វាង ?

ចំណុចសំខាន់មួយទៀត ដែលអ្នកនិពន្ធគប្បីចងចាំគ្រប់គ្នានោះ គឺនៅក្នុងនាមជាស្មេរ យើងក៏មានស្មារតីដឹកនាំជាតិ មិនចាញ់អ្នកនយោបាយដឹកនាំជាតិទាំងឡាយនោះដែរ ។ គឺមានន័យថាយើងជាអ្នកដឹកនាំពលរដ្ឋខ្មែរអោយបណ្តុះគំនិតស្មារតី ប្រាជ្ញា និងការចេះដឹងដ៏ប្រពៃថ្លៃថ្នូរ តាមរយៈសំណេរដ៏ប្រសិទ្ធិរបស់យើងផ្ទាល់ ដើម្បីស្វែងរកជីវិតចំរើនរុងរឿង ។ កាលបើប្រជាពលរដ្ឋជួបក្តីរីកចំរើន ហើយ សង្គមជាតិក៏ចំរើនអភិវឌ្ឍន៍ សំបូរសប្បាយទៅតាមនោះដែរ ។ សូមជូនពរដល់អ្នកនិពន្ធគ្រប់រូបដែលបានអានសំណេរនេះ សូមលោកអ្នកប្រទះតែជោគជ័យរុងរឿងត្រចះ លើសពីសមត្ថភាព

*របស់រៀមច្បងរបស់ខ្មែរជំនាន់ណាៗទាំងអស់ សមនឹងពាក្យស្លោក ថ្មីដែលមានសេចក្តីថា ៖*

ទំពាំងស្នងឫស្សី ទំពាំងលាស់ថ្មីត្រូវលូតធំខ្ពស់ជាងឫស្សី ចាស់នោះទើបច្បាស់ថាពិតជាអាចវាតទី បន្សាយគុម្ពយ៉ាង វិសាលលើសទំហំគុម្ពឫស្សីរបស់ខ្មែរ កាលពីអតីតកាល !

នៅពេលនោះ *ប្រទេសខ្មែរនឹងបានបែរត្រឡប់មកជួបនឹង ភាពថ្កុំថ្កើងជឿនលឿនក្បែមក្សាន្តសម្បូរសប្បាយ សាជាថ្មីម្តងទៀត ដោយសារទេពកោសល្យ កម្លាំងប្រាជ្ញាស្មារតី និងមនសិការជាតិ នៃពលរដ្ឋឧត្តម គ្រប់ៗរូប ។*

========================================

**សតិប្រាជ្ញានិងការចេះដឹង**

**អាចបណ្តុះបាននៅគ្រប់វ័យទាំងអស់**

**មិនថានរជននោះមានអាយុប៉ុន្មានឡើយ**

**អោយតែគេមានការខិតខំព្យាយាម!**

========================================

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់

ចំពោះទឹកចិត្ត សមត្ថភាព

ទេពកោសល្យ សតិប្រាជ្ញ មនសិការជាតិ

របស់អ្នកនិពន្ធខ្មែរទាំងឡាយ ! ! !

*ពី*

*អ្នកស្រីកែវច័ន្ទបូរណ៍*

*រដ្ឋមិនីសូតា សហរដ្ឋអាមេរិក*

chanbo@camboda.com

SPONSORS

www.chanbokeo.com
www.camboda.com
www.english-khmer.com
www.khmermagazines.com
www.angkorwat.com
www.khmer-music.com
www.smaradeykhmer.org
www.nouhachjournal.net
www.khmermassage.com